សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការរៀបចំ និងការប្រព្រឹត្តទៅនៃ អន្តរជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ៖
និស្សិតឈ្មោះ **ក. ជាម សុខឡេន**
**ក. ជា ម៉ាន់នីតា**

សាស្ត្រាចារ្យណែនាំ
លោក **ម៉ម ចាន់ណែត**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២០

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

ការសិក្សាស្រាវជ្រាវនេះអាចត្រូវបានសម្រេចឡើងដោយមានការជួយជ្រោមជ្រែងពីសំណាក់បុគ្គលដែលពាក់ព័ន្ធសំខាន់ៗជាច្រើន។

ជាបឋមយើងខ្ញុំសូមលំអោនកាយគោរពនិងថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះលោកឪពុក និងអ្នកម្តាយ ដែលបានផ្តល់កំណើត និងពលីកម្មគ្រប់បែបយ៉ាងដើម្បីចិញ្ចឹមបីបាច់ថែរក្សា ផ្តល់នូវភាពកក់ក្តៅ សេចក្តីស្រលាញ់អនុគ្រោះ ព្រហ្មវិហារធម៌ និងអប់រំទូន្មានឱប្រព្រឹត្តខ្លួនទៅតាមគន្លងធម៌ដើម្បីរស់នៅក្នុងសង្គមព្រមទាំងទំនុកបម្រុងថវិកានិងសិក្ខូបករណ៍ចាប់តាំងពីកំរិតបឋមសិក្សា មធ្យមសិក្សារហូតដល់ឧត្តមសិក្សា។ កូនសូមក្រាបប្រតិបត្តិនិងសម្តែងនូវកត្តញ្ញូធម៌ យ៉ាងជ្រាលជ្រៅបំផុតចំពោះឧបក្ការៈគុណរបស់លោកទាំងទ្វេដែលចំពោះរូបកូន។

សូមគោរពថ្លែងអំណរគុណដល់ឯកឧត្តមសាកលវិទ្យាធិការ **លុយ ចណ្ណា** ព្រមទាំងព្រឹទ្ធបុរសរង និងសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសេដ្ឋកិច្ចទាំងអស់ ព្រមទាំងលោកគ្រូ អ្នកគ្រូទាំងអស់ដែលបានជួយបង្ហាត់បង្រៀនឲ្យយើងខ្ញុំទទួលបានចំណេះដឹង ដែលជាទីបំភ្លឺផ្លូវសំរាប់ជីវិតយើងខ្ញុំរហូតមានដល់ថ្ងៃនេះ។

សូមគោរពថ្លែងអំណរគុណលោកសាស្ត្រាចារ្យ **ម៉ម ចាន់ណែត** ដែលចំណាយពេលវេលាដ៏មានតម្លៃក្នុងការជួយជ្រោមជ្រែងណែនាំ កែតម្រូវ ផ្តល់មតិយោបល់ និងដំបូន្មានល្អៗសំរាប់យើងខ្ញុំ។ សូមថ្លែងអំណរគុណដល់គណៈកម្មការវាយតម្លៃ ដែលបានផ្តល់ដំបូន្មានល្អៗ និងកែតម្រូវសារណានេះ។

សូមសំដែងនូវការដឹងគុណចំពោះមិត្តរួមជំនាន់ និងមិត្តភ័ក្រ្តទាំងអស់ដែលបានផ្តល់ជាគំនិតយោបល់លើកទឹកចិត្តដល់យើងខ្ញុំក្នុងការសរសេរសារណានេះ ជាពិសេសសូមថ្លែងអំណរគុណចំពោះមិត្តភ័ក្រ្តទាំងអស់ដែលបានចំណាយទាំងកំលាងកាយ និងកំលាំងចិត្តក្នុងការជួយចុះប្រមូលទិន្នន័យ បញ្ចូលទិន្នន័យ ជួយពិនិត្យ និងកែសំរួលអក្ខរាវិរុទ្ធ ឃ្លា ប្រយោគ ដើម្បីអោយអត្ថបទស្រាវជ្រាវនេះមានភាពល្អប្រសើរឡើង។ ដោយសារតែការខិតខំប្រឹងប្រែងជួយជ្រោមជ្រែងទាំងអស់នេះហើយ ដែលអាចអោយអត្ថបទសារណាបញ្ចប់បរិញ្ញាបត្ររបស់យើងខ្ញុំត្រូវបានបញ្ចប់ប្រកបដោយភាពជោគជ័យ។

ជាទីបញ្ចប់ នាងខ្ញុំទាំងពីរនាក់សូមបួងសួងដល់វត្ថុស័ក្តសិទ្ធទាំងអស់ដែលមានក្នុងលោកនេះជួយតាមថែរក្សា លោកអ្នកមានគុណ ឯកឧត្តម សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ព្រមទាំងមិត្តភ័ក្រ្តទាំងអស់អោយជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀតឃ្លាតឡើយ។

# អារម្ភកថា

ប្រទេសកម្ពុជា ជាប្រទេសមួយដែលទើបរួចផុតពីសង្គ្រាមស៊ីវិល ជាពិសេសរបបកម្ពុជាប្រជាធិបតេយ្យ(ឆ្នាំ១៩៧៥-១៩៧៩) ដែលបានធ្វើឱ្យប្រទេសកម្ពុជាធ្លាក់ទៅក្នុងស្ថានភាពដុនដាប អ្វីៗត្រូវបានកម្ទេចស្ទើរទាំងស្រុង ដូចជាហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្សជាដើម។ ក្នុងរយៈពេលរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនត្រូវរស់នៅក្នុងសភាពភ័យខ្លាច តក់ស្លុត រន្ធត់ ក្រោមគោលនយោបាយដឹកនាំដ៏សាហាវឃោរឃៅរបស់បក្សកុម្មុយនីស្តកម្ពុជា។ ដោយសារតែការដឹកនាំដ៏សាហាវរបស់ពួកខ្មែរក្រហម ដែលធ្វើឱ្យប្រជាជនរាប់លាននាក់ត្រូវបានបាត់បង់ជីវិត និង ប្រជាជនភាគច្រើនត្រូវបាត់បង់សាច់ញាតិ ឪពុកម្តាយ បងប្អូន ព្រមទាំងបានបន្សល់ទុកនូវស្ត្រីមេម៉ាយ ក្មេងកំព្រាជាច្រើននាក់។

បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជា និង អង្គការសហប្រជាជាតិ បានសហប្រតិបត្តិការគ្នាក្នុងការបង្កើតនូវតុលាការមួយដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ដោយតុលាការនោះមានឈ្មោះថា "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា"។ ហេតុដូច្នេះ ទើបក្រុមយើងខ្ញុំទាំងអស់គ្នា សម្រេចជ្រើសរើសយកប្រធានបទស្តីពី "ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" មកធ្វើការស្រាវជ្រាវ និង ចងក្រងជាសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ។ ម្យ៉ាងវិញទៀត យើងខ្ញុំសង្ឃឹមថាសារណានេះអាចធ្វើជាឯកសារជំនួយក្នុងការស្វែងយល់ និង បំពេញតម្រូវការរបស់លោកអ្នកអានទាំងឡាយ ឱ្យបានយល់កាន់តែច្បាស់នូវអ្វីដែលទាក់ទងទៅនឹងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលបានប្រព្រឹត្តទៅក្នុងពេលកន្លងទៅនេះ។

មិនតែប៉ុណ្ណោះ សារណានេះអាចចាត់ទុកជាឯកសារជំនួយស្មារតីផ្នែកច្បាប់សម្រាប់និស្សិតជំនាន់ក្រោយធ្វើការសិក្សា ស្រាវជ្រាវអំពីករណីមួយចំនួនដែលទាក់ទងទៅនឹងការចោទប្រកាន់ចំពោះមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម។ ទោះបីសារណានេះត្រូវបានចងក្រងលេចចេញជារូបរាងហើយក៏ដោយ ក៏យើងខ្ញុំយល់ថាសារណានេះពុំទាន់មានលក្ខណៈ និង ខ្លឹមសារគ្រប់គ្រាន់នូវឡើយ ដោយសារតែឯកសារនៅមានការខ្វះខាត និងការប្រើពាក្យពេចន៍ ឃ្លោងឃ្លានៅមានការខ្វះចន្លោះ។ ហេតុដូច្នេះ សូមលោកអ្នកអានខន្តីអភ័យទោសនូវរាល់កំហុសខុសឆ្គងទាំងឡាយនេះ ហើយក្រុមយើងខ្ញុំនៅរង់ចាំទទួលនូវការផ្តល់មតិរិះគន់ ដើម្បីធ្វើការកែលម្អសារណានេះឱ្យកាន់តែមានលក្ខណៈល្អប្រសើរជាងនេះទៅទៀត។

# មាតិកា

ទំព័រ

**សេចក្ដីផ្ដើម** ........ ១

១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ២

៤. ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ ........ ៣

៥. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣

៦. សារប្រយោជន៍នៃការស្រាវជ្រាវ ........ ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤

**ជំពូកទី ១**

**ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

១. គោលបំណងនៃការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ........ ៥

២. កិច្ចព្រមព្រៀងស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ........ ៦

៣. លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា ........ ៦

៣.១. ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ........ ៦

៣.២. ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា ........ ៨

៣.៣. ព្រះរាជក្រឹត្យតែងតាំង ........ ៨

**ជំពូកទី ២**

**រចនាសម្ព័ន្ធនៃការគ្រប់គ្រងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

១. ផ្នែកតុលាការ និង ការិយាល័យច្បាប់ ........ ១០

១.១. អង្គបុរេជំនុំជម្រះ ........ ១០

១.២.អង្គជំនុំជម្រះសាលាដំបូង ........ ១០

១.៣. អង្គជំនុំជម្រះតុលាការកំពូល ........ ១០

១.៤. ការិយាល័យសហចៅក្រមស៊ើបអង្កេត ........ ១០

១.៥ ការិយាល័យសហព្រះរាជអាជ្ញា ........ ១២

២. ការិយាល័យរដ្ឋបាល ........................................ ១២
២.១ ផ្នែកគ្រប់គ្រងតុលាការ ........................................ ១៣
២.១.១. ផ្នែកបុគ្គលិក ........................................ ១៦
២.១.២. ផ្នែកហិរញ្ញវត្ថុ និងថវិកា ........................................ ១៧
២.២.៣. ផ្នែកសេវាកម្មទូទៅ ........................................ ១៩
២.២. ផ្នែកកិច្ចការសាធារណៈ ........................................ ១៩
២.២.១. ផ្នែកសន្តិសុខនិងសុវត្ថិភាព ........................................ ២២
២.២.២. ផ្នែកបច្ចេកវិទ្យានិងពត៌មាន ........................................ ២៣
២.៣. អង្គភាពគាំពារជនរងគ្រោះ ........................................ ២៤
២.៣.១. អង្គភាពគាំពារការការពារក្តី ........................................ ២៤
២.៣.២ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ........................................ ២៥

## ជំពូកទី៣

## សំណុំរឿងក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

១. សំណុំរឿង ០០១ ........................................ ២៦
១.១. ជនជាប់ចោទ ........................................ ២៦
១.២. នីតិវិធីនៃបណ្តឹង ........................................ ២៧
១.៣. សាលដីកាសម្រេច ........................................ ២៨
២. សំណុំរឿង ០០២ ........................................ ៣០
២.១. ជនជាប់ចោទ ........................................ ៣០
២.១.១. នួន ជា ........................................ ៣១
២.១.២. ខៀវ សំផន ........................................ ៣៣
២.១.៣. អៀង សារី ........................................ ៣៤
២.១.៤. អៀង ធីរិទ្ធ ........................................ ៣៥
២.២. សំណុំរឿង ០០២/០១ ........................................ ៣៦
២.២.១. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់បុគ្គល ........................................ ៣៧
២.២.១.១. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា ........................................ ៣៧

២.២.១.២. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន .................................... ៣៩
២.២.២. សាលក្រមសម្រេច .................................................................................... ៣៩
២.៣. សំណុំរឿង ០០២/០២ ..................................................................................... ៤០
២.៣.១. ការផ្តន្ទាទោស ........................................................................................ ៤០
២.៣.២. សេចក្តីសម្រេច ....................................................................................... ៤១
៣. សំណុំរឿង ០០៣ ................................................................................................ ៤១
៣.១. ជនជាប់ចោទ ................................................................................................. ៤១
៣.២. នីតិវិធីនៃបណ្តឹង និង ការតវ៉ារបស់ជនជាប់ចោទ .............................................. ៤១
៤. សំណុំរឿង ០០៤ ................................................................................................ ៤៣
៤.១. ជនជាប់ចោទ ................................................................................................. ៤២
៤.១.១. យឹម ទិត្យ ............................................................................................ ៤៣
៤.១.២. អោ អាន ............................................................................................. ៤៣
៤.១.៣. អ៊ឹម ចែម ............................................................................................ ៤៣
៤.២. ការបំបែកសំណុំរឿង ....................................................................................... ៤៤
៤.២.១. សំណុំរឿង ០០៤/០១ ............................................................................. ៤៥
៤.២.២. សំណុំរឿង ០០៤/០២ ............................................................................. ៤៦

## ជំពូកទី៤

## គុណសម្បត្តិ និងគុណវិបត្តិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

១. គុណសម្បត្តិ .................................................................................................... ៤៨
១.១. ស្វែងរកយុត្តិធម៌ជូនដល់ជនរងគ្រោះនៃរបបខ្មែរក្រហម .......................................... ៤៨
១.២. តម្លាភាពនៃតុលាការកម្ពុជា ............................................................................ ៤៨
១.៣. ផ្នែកចំណេះដឹងទូទៅ ...................................................................................... ៤៩
២. គុណវិបត្តិ ......................................................................................................... ៤៩
២.១. ផ្នែកហិរញ្ញវត្ថុ ............................................................................................. ៤៩
២.២. ការអូសបន្លាយពេលវេលា ............................................................................... ៥០
២.៣. ផ្នែកចិត្តសាស្ត្រ ............................................................................................ ៥០

**សេចក្តីសន្និដ្ឋាន** ........................................................................................................ ៥១
**ការផ្តល់អនុសាសន៍** ....................................................................................................... ៥៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ការសម្លាប់រង្គាលគឺជាព្រឹត្តការណ៍ដែលកើតមានឡើងនៅជុំវិញពិភពលោក មិនថាស្ថិតនៅប្រទេសក្នុងអឺរ៉ុប អាហ្វ្រិក ឬផ្ទែកអាស៊ីក្តី។ តុលាការ *ad hoc* ឬ គេហៅជាភាសាខ្មែរថាតុលាការកូនកាត់ មានមុខងារដោះស្រាយបញ្ហា និងផ្តន្ទាទោសឧក្រិដ្ឋជនដែលប្រព្រឹត្តបទល្មើសប្រល័យពូជសាសន៍ ប្រឆាំងមនុស្សជាតិ ក៏ដូចជាឧក្រិដ្ឋកម្មនានាដែលប៉ះពាល់ដល់សង្គមជាតិ និងសន្តិសុខសង្គម។ តុលាការកូនកាត់នេះផងដែរបានបង្កើតឡើងតាមបណ្តាប្រទេសមួយចំនួននៅលើពិភពលោក ដើម្បីដោះស្រាយនិងកាត់ទោសលើឧក្រិដ្ឋជនដែលប្រព្រឹត្តបទល្មើសទាំងនោះ។ តុលាការទាំងនោះមានដូចជា Special Panels and Serious Crimes Unit in East-Timor ដែលបង្កើតឡើងដោយ United Nations Transitional Administration in East Timor (UNTAET) ក្នុងឆ្នាំ ២០០០ ដើម្បីដោះស្រាយបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរ នៅក្នុងប្រទេសទីម័រ (East Timor)ខាងកើតក្នុងឆ្នាំ ១៩៩៩។ តុលាការកូនកាត់ផ្សេងៗមានដូចជា Special Court for Sierra Leone ដើម្បីដាក់ទោសឧក្រិដ្ឋជនដែលប្រព្រឹត្តបទល្មើសប្រឆាំងមនុស្សជាតិក្រោយថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦, Regulation 64 Panels in the Courts of Kosovo សម្រាប់កាត់ទោសលើឧក្រិដ្ឋជនលើបទល្មើសសង្គ្រាមឆ្នាំ ១៩៩៩ និង Extraordinary African Chambers លើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងទារុណកម្មធ្ងន់ធ្ងរ នៅក្នុងកំឡុងឆ្នាំ ១៩៨២ ដល់ ឆ្នាំ ១៩៩០[1]។ ការប្រព្រឹត្តទៅយ៉ាងរលូននេះ ទើបបណ្តាលអោយមានការបង្កើតតុលាការកូនកាត់នៅប្រទេសកម្ពុជានេះ។ គួរបញ្ជាក់ផងដែរថា របបកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហម បានចូលគ្រប់គ្រងប្រទេសកម្ពុជាចាប់ពីថ្ងៃទី១៧ ខែ មេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ក្នុងរយៈពេល ៣ឆ្នាំ ៨ខែ និង ២០ថ្ងៃ។ របបនេះបានធ្វើឱ្យប្រជាជនកម្ពុជាទាំងអស់ទទួលរងទុក្ខវេទនា អត់ឃ្លាន បែកបាក់គ្រួសារ រហូតឈានដល់ការបាត់បង់ជីវិតថែមទៀតផង ដែលប្រជាជនចំនួនប្រមាណជាង ១លាន ៧សែននាក់ ត្រូវបានបាត់បង់ជីវិតយ៉ាងអយុត្តិធម៌។ ម្យ៉ាងទៀត របបនេះក៏បានធ្វើកម្ពុជាធ្លាក់ចុះដុនដាបយ៉ាងខ្លាំង ព្រោះថារាល់ហេដ្ឋារចនាសម្ព័ន្ធនានានៅក្នុងប្រទេសត្រូវបានបំផ្លិចបំផ្លាញគ្មានសេសសល់បន្តិចសោះឡើយ។

ករណីនេះ បានបន្សល់ទុកនូវភាពឈឺចាប់ក្នុងសង្គមកម្ពុជាដែលមិនធ្លាប់មានពីមុនមក។ ក្រោយពីមានការបង្រួបបង្រួមជាតិឡើងវិញ និងមានប្រជាជនជាច្រើនបានទាមទារយុត្តិធម៌ ទើបសហនាយករដ្ឋមន្ត្រីរបស់កម្ពុជាបានស្នើសុំទៅអង្គការសហប្រជាជាតិ អោយបង្កើតសាលាក្តីមួយ ដើម្បីកាត់ទោសមេដឹកនាំខ្មែរ

[1] https://www.asser.nl/nexus/international-criminal-law/the-history-of-icl/hybrid-courts/

ក្រហម។ ជាលទ្ធផល អង្គការសហប្រជាជាតិក៏បានបញ្ជូនក្រុមអ្នកជំនាញមកកាន់កម្ពុជាដើម្បីសិក្សាអំពីលទ្ធភាពបង្កើតតុលាការលក្ខណៈអន្តរជាតិ និងបានផ្តល់អនុសាសន៍អោយមានការបង្កើត តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលស្រដៀងគ្នានឹងតុលាការដែលបានបង្កើតនៅអតីតយូហ្គោស្លាវី និងរ៉្វាន់ដា។ ប៉ុន្តែសំណើនេះមានលក្ខណៈចំរូងចម្រាស់ ហើយនាំអោយមានការចរចាអស់រយៈពេលជាច្រើនឆ្នាំ។

នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៦ យើងឃើញមាន អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលហៅកាត់ថា "អ.វ.ត.ក" ឬភាគច្រើនដែលគេស្គាល់ថា សាលាក្តីខ្មែរក្រហម ឬសាលាក្តីកូនកាត់នេះលេចរូបរាងឡើងនៅលើផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ។

តើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងតុលាការកម្ពុជា ដែលបានដំណើរការរួចមកហើយនេះបានធ្វើការចោទប្រកាន់មេដឹកនាំខ្មែរក្រហមនូវបទល្មើសអ្វីខ្លះ? មានសមាសភាពបុគ្គលិកដូចម្តេចខ្លះ? ហើយប្រើប្រាស់ច្បាប់អ្វីខ្លះដើម្បីកាត់ទោសចំពោះមេដឹកនាំទាំងនោះ?

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ចំពោះហេតុផលដ៏សំខាន់នៃការស្រាវជ្រាវនេះ បានផ្តោតទៅលើចំណោទបញ្ហាស្រាវជ្រាវសំខាន់ៗដូចខាងក្រោម៖

- តើមូលហេតុអ្វីបានជានាំអោយមានការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា?
- តើរចនាសម្ព័ន្ធនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានលក្ខណៈដូចម្តេចខ្លះ?
- តើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានជំនុំជម្រះ លើសំណុំរឿងចំនួនប៉ុន្មាន?សំណុំរឿងអ្វីខ្លះ?
- តើការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

របបប្រល័យពូជសាសន៍នាសម័យកម្ពុជាប្រជាធិបតេយ្យគឺជាប្រវត្តិសាស្ត្រមួយដែលមិនធ្លាប់មានពីមុនមកក្នុងប្រទេសកម្ពុជា និងនៅលើបណ្តាប្រទេសនានាលើពិភពលោក។ ការសម្លាប់នេះបានធ្វើអោយមានជាប់ស្នាមជិតដាម និងការឈឺចាប់ជាច្រើនដល់ប្រជាជនកម្ពុជា ដែលកត្តានេះហើយដែលទោះបីជារបបនេះបានកន្លងផុតអស់រយៈកាលប្រមាណជាបីទស្សវត្សហើយក្តី ក៏ការចោទទៅលើមេដឹកនាំទាំងនោះត្រូវបានបន្តនិងជាប្រធានបទទូទៅចំពោះប្រជាពលរដ្ឋទូទៅ។ កត្តាទាំងនេះហើយដែលបណ្តាលអោយយើងខ្ញុំសម្រេចធ្វើការសិក្សាស្រាវជ្រាវអំពី ការរៀបចំ និងការប្រព្រឹត្តទៅនៃ អ.វ.ត.ក។ ការស្រាវជ្រាវនេះ និងធ្វើអោយយើងខ្ញុំបានដឹងយ៉ាងស៊ីជម្រៅ និងរចនាសម្ព័ន្ធនានាដែលមិនអាចមើលឃើញត្រឹមតែសម្បកក្រៅនោះឡើយ ប៉ុន្តែអាចដឹងអំពីពេលវេលា ភស្តុតាងដែលបានប្រមូលពីសាក្សី និងជនជាប់ចោទដល់បានដាក់តម្កល់នៅ អ.វ.ត.ក។ ការស្រាវជ្រាវនេះក៏មានគោលបំណងដើម្បីឱ្យសិស្ស និស្សិតគ្រប់ជំនាន់ទាំងអស់ព្រមទាំងសាធារណៈជនគ្រប់រូប

បានយល់ដឹងឱ្យកាន់តែច្បាស់អំពីមូលហេតុនៃការបង្កើត និងការប្រព្រឹត្តទៅ ព្រមទាំងគុណសម្បត្តិនិងគុណវិបត្តិរបស់តុលាការកូនកាត់មួយនេះ។

ម្យ៉ាងវិញទៀត ការសិក្សាស្រាវជ្រាវអំពីប្រធានបទនេះគឺមានគោលបំណង ឆ្លុះបញ្ចាំងឱ្យកាន់តែច្បាស់ចំពោះអំពើច្បាប់ហាមឃាត់ ឬអំពើដែលធ្វើឱ្យសង្គមមានចលាចល ឬធ្វើឱ្យសង្គមល្អក់កករ ទទួលរងនូវការអន្តរាយដែលបង្កការប៉ះពាល់ដល់ជីវិតរបស់ប្រជាពលរដ្ឋផងដែរ។

## ៤. ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទនៃសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រស្តីអំពី ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានធ្វើឡើងទៅតាមយន្តការប្រមូលផ្តុំព័ត៌មាន និងការសិក្សាស្រាវជ្រាវពីប្រភពផ្សេងៗ និងមូលហេតុដែលបង្កអោយមានរបបប្រល័យពូជសាសន៍នេះកើតឡើង។ ជីវប្រវត្តិនៃមេដឹកនាំនីមួយៗនៅក្នុងសំណុំរឿងរបស់ អ.វ.ត.ក ក៏នឹងត្រូវបានដាក់បញ្ចូលក្នុងឯកសារស្រាវជ្រាវនេះផងដែរ។ យ៉ាងណាមិញ ការស្រាវជ្រាវនេះនឹងបកស្រាយបញ្ជាក់អំពីរចនាសម្ព័ន្ធនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលមានបញ្ជាក់ពីព្រមទាំងសំណុំរឿងនីមួយៗតាំងពីដើមរហូតដល់ចេញសាលដីកាបញ្ចប់នៃសំណុំរឿងទាំងឡាយ។ លើសពីនេះទៅទៀត សារណានេះក៏បានបង្ហាញពីគុណសម្បត្តិនិងគុណវិបត្តិ សម្រាប់ផ្តល់ជាព័ត៌មានជូនអ្នកអានអោយយល់ច្បាស់បន្ថែមពីរបបប្រល័យពូជសាសន៍នេះផងដែរ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវនៃប្រធានបទខាងលើនេះ ត្រូវបានធ្វើឡើងដោយមានការស្រាវជ្រាវយ៉ាងស៊ីជម្រៅដោយប្រមូលទិន្នន័យពីសៀវភៅជានានាច្រើនដែលបានចងក្រងដោយអ.វ.ត.ក។ សៀវភៅណែនាំទាំងនោះបានបង្ហាញពីការរៀបចំនឹងប្រព្រឹត្តទៅនានា និងសំណុំរឿងនីមួយៗដែលមានបញ្ជាក់ពីសាលក្រមទាំងឡាយតាំងពីដើមរហូតដល់ចប់ និងច្បាប់នានាដែលចៅក្រមយកមកប្រើប្រាស់ដើម្បីដាក់ទោសទៅតាមបទល្មើសដែលជនល្មើសបានប្រព្រឹត្តដោយសមីខ្លួន។ ក្រុមសារណាយើងខ្ញុំ បានប្រមូលព័ត៌មានដោយធ្វើការស្រាវជ្រាវជាច្រើនទៀតពីប្រព័ន្ធអ៊ីធឺណែត ដែលមាននៅក្នុងវេបសាយសារព័ត៌មាននិងវេបសាយសមាគមនានាដើម្បីបង្កើតជាកម្រងសារណាមួយនេះ។

## ៦. សារប្រយោជន៍នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះបានផ្តល់អត្ថប្រយោជន៍ជាច្រើនចំពោះសិស្ស និងនិស្សិតគ្រប់រូបឲ្យបានយល់ដឹងឲ្យកាន់តែស៊ីជម្រៅអំពីការបង្កើត អ.វ.ត.ក និងរចនាសម្ព័ន្ធនានាដែលមាននៅក្នុងតុលាការនេះ ព្រមទាំងការយល់ដឹងសង្ខេបអំពីសំណុំរឿងនីមួយៗដែលបានកាត់ក្តីនៅក្នុងតុលាការកូនកាត់នេះ។ ការស្រាវជ្រាវនេះមិនត្រឹមតែផ្តល់ជាព័ត៌មានតែប៉ុណ្ណោះទេថែមទាំងផ្តល់ជាដំបូន្មាននានាដើម្បីអោយកូនខ្មែរជំនាន់ក្រោយៗ បានយល់ច្បាស់ពីរបបប្រល័យពូជសាសន៍ដ៏សែនឃោរឃៅទៅលើប្រជាជនខ្មែរគ្រប់រូប។ លើសពីនេះទៅទៀត

ការសិក្សាស្រាវជ្រាវពីប្រធានបទនេះក៏បានធ្វើអោយក្រុមសារណាយើងខ្ញុំបានផ្លាស់ប្តូរយោបល់គ្នា និងបង្កើនចំណងមិត្តភាពរបស់យើងទាំងពីរអោយកាន់តែជិតស្និទ្ធបន្ថែមទៀត ដែលជាហេតុធ្វើអោយសារណានេះប្រព្រឹត្តទៅយ៉ាងរលូនបាន។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ប្រធានបទ ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានចែកចេញជា៖

- សេចក្តីផ្តើម
- ជំពូកទី១ ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
- ជំពូកទី២ រចនាសម្ព័ន្ធនៃការគ្រប់គ្រងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
- ជំពូកទី៣ សំណុំរឿងក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
- ជំពូកទី៤ គុណសម្បត្តិ និង គុណវិបត្តិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
- សេចក្តីសន្និដ្ឋាននិងអនុសាសន៍

# ជំពូកទី ១

# ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ
# ក្នុងតុលាការកម្ពុជា

# ជំពូកទី ១
# ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
## ១. គោលបំណងនៃការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានបង្កើតឡើងក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិនិងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ហើយបានប្រព្រឹត្តក្នុងថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩[2]។ ម្យ៉ាងវិញទៀត អ.វ.ត.ក ក៏ត្រូវបានបង្កើតឡើងក្នុងគោលបំណងរកយុត្តិធម៌ជូនប្រជាពលរដ្ឋខ្មែរ ដែលបានទទួលរងទុក្ខវេទនានិងឈានដល់ការស្លាប់បាត់បង់ជីវិត ព្រមទាំងស្វែងរកយុត្តិធម៌ជូនរងគ្រោះដែលទទួលនូវទណ្ឌកម្ម ភាពអត់ស្រេកឃ្លាននាសម័យនោះទាំងខ្លួនមិនបានដឹងអ្វីសោះផងដែរ។

របបខ្មែរក្រហមបានឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយត្រូវទម្លាក់ពីអំណាចនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ ប្រជាជនកម្ពុជាប្រមាណ ១,៧ លាននាក់ បានបាត់បង់ជីវិតដោយសារការបង្អត់អាហារ ទារុណកម្ម ការសម្លាប់ និងការបង្ខំឱ្យធ្វើការហួសកម្លាំង ក្នុងរយៈពេល ៣ឆ្នាំ ៨ខែ ២០ថ្ងៃនៃរបបនោះ។ សង្គ្រាមស៊ីវិលបានបន្តក្រោយពីការដួលរលំនៃរបបខ្មែរក្រហម។ នៅទីបំផុតសង្គ្រាមស៊ីវិលបានត្រូវបញ្ចប់នៅឆ្នាំ ១៩៩៨ នៅពេលដែលរចនាសម្ព័ន្ធនយោបាយនិងយោធារបស់ខ្មែរក្រហមត្រូវកម្ទេចចោល។ នៅឆ្នាំ ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជាបានសំណូមពរឱ្យអង្គការសហប្រជាជាតិជួយឧបត្ថម្ភបង្កើតសាលាជម្រះក្តីដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម។ នៅឆ្នាំ ២០០១ រដ្ឋសភាជាតិកម្ពុជាបានអនុម័តច្បាប់មួយដើម្បីបង្កើតតុលាការកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅប្រទេសកម្ពុជាក្នុងអំឡុងរបបខ្មែរក្រហមពីឆ្នាំ ១៩៧៥-១៩៧៩។ តុលាការនេះមានឈ្មោះថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់ក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា)។ រាជរដ្ឋាភិបាលកម្ពុជាបានទទូចសុំថា ដើម្បីជាផលប្រយោជន៍ដល់ប្រជាជនកម្ពុជាទាំងអស់ តុលាការជម្រះក្តីត្រូវប្រព្រឹត្តទៅនៅក្នុងប្រទេសកម្ពុជា ដោយប្រើប្រាស់មន្ត្រីនិងចៅក្រមកម្ពុជា គួបផ្សំជាមួយមន្ត្រីនិងចៅក្រមអន្តរជាតិ។ កម្ពុជាបានអញ្ជើញសហគមន៍អន្តរជាតិឱ្យចូលរួមសហការក្នុងការកាត់សេចក្តីនេះ ដើម្បីធានាឱ្យមានយុត្តិធម៌ជាលក្ខណៈអន្តរជាតិ ព្រោះកម្ពុជាយល់ឃើញថាខ្លួននៅទន់ខ្សោយផ្នែកតុលាការ និងចរិត

[2] មាត្រា១ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

លក្ខណៈអន្តរជាតិនៃឧក្រិដ្ឋកម្ម ។ ចុងបញ្ចប់ កិច្ចព្រមព្រៀងមួយជាមួយអង្គការសហប្រជាជាតិត្រូវបានចុះហត្ថលេខានៅខែមិថុនា ឆ្នាំ២០០៣ ដែលចែងអំពីថា តើសហគមន៍អន្តរជាតិនឹងជួយឧបត្ថម្ភនិងសហការយ៉ាងដូចម្តេចនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ។ តុលាការថ្មីហើយពិសេសនេះត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៦ ដោយរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ប៉ុន្តែតុលាការនេះគឺជាតុលាការឯករាជ្យម្ចាស់ការ មិនចំណុះរាជរដ្ឋាភិបាលឬអង្គការសហប្រជាជាតិទេ។ តុលាការនេះគឺជាតុលាការកម្ពុជាដែលមានការចូលរួមពីសហគមន៍អន្តរជាតិ ដែលនឹងអនុវត្តទៅតាមស្តង់ដារអន្តរជាតិ ។ តុលាការនេះបានផ្តល់ជាគំរូថ្មីមួយសម្រាប់ដំណើរការកាត់ក្តីនៅកម្ពុជា។

## ២. កិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

- កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់ក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យៈ កិច្ចព្រមព្រៀងនេះបង្កើតឡើងក្នុងគោលបំណងកំណត់អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជា ប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិនិងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ហើយបានប្រព្រឹត្តក្នុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ០៦ មករា ១៩៧៩។ កិច្ចព្រមព្រៀងនេះផ្តល់មូលដ្ឋានគតិយុត្តិគោលការណ៍ និងបែបបទសម្រាប់កិច្ចសហប្រតិបត្តិការនេះ។ កិច្ចព្រមព្រៀងនេះត្រូវអនុវត្តក្នុងប្រទេសកម្ពុជាតាមរយៈច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅពេលអនុម័ត និងធ្វើវិសោធនកម្មរួច[3]។ កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តតាមអនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់នៃសន្ធិសញ្ញា ជាពិសេសមាត្រា២៦ និង ២៧។
- កិច្ចព្រមព្រៀងបន្ថែមលើសន្តិសុខ និងសុវត្ថិភាពៈ រាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកផ្នែកសន្តិសុខ និងសុវត្ថិភាពចំពោះបុគ្គលគ្រប់រូបដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ។
- ព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តលើកិច្ចព្រមព្រៀងរវាងអង្គការ សហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវ ឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

## ៣. លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា

### ៣.១. ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦

[3] មាត្រា២ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់ក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលនៅជាធរមាន ត្រូវបានអនុម័តនៅមុនឆ្នាំ១៩៧៥ ជាពេលវេលាបទល្មើសព្រហ្មទណ្ឌត្រូវបានចាប់ផ្តើមប្រព្រឹត្តដោយកម្មាភិបាលខ្មែរក្រហម។ ការយកច្បាប់មានជាធរមានមុនអំពើល្មើសប្រព្រឹត្តមកប្រើគឺដើម្បីកុំឲ្យមានការខុសឆ្គងនឹងគោលការណ៍នីត្យានុកូលភាព។

យោងតាមមាត្រា ៥០០ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ អាជ្ញាយុកាលសម្រាប់ការចោទប្រកាន់បទឧក្រិដ្ឋមានរយៈពេល ១០ឆ្នាំ ដែលគិតចាប់ពីថ្ងៃប្រព្រឹត្តបទល្មើស។ ការគិតបែបនេះដែលមេធាវីការពារជនត្រូវចោទឌុច ប្រើប្រាស់ជាមូលដ្ឋានដើម្បីបន្ថយការទទួលខុសត្រូវរបស់ឌុច ដោយកត្តាផុតអាជ្ញាយុកាលនៃបទល្មើស។ តាមមាត្រា ៣ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជាត្រូវបានអនុម័តក្នុងឆ្នាំ២០០៤ ហើយចែងរយៈពេលអាជ្ញាយុកាល ៣០ឆ្នាំ ដែលសរុប ៤០ បើបូកបន្ថែមនឹង ១០ឆ្នាំចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ ក្នុងន័យនេះ ចាប់តាំងពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ២០១៥ ឬ ២០១៩ បើគិតពីឆ្នាំ១៩៧៩ អង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា អាចនៅតែបន្តការចោទប្រកាន់បទល្មើសក្រោមច្បាប់ជាតិ។ អង្គជំនុំជម្រះបានធ្វើការសម្រេចរវាងចៅក្រមជាតិ និងចៅក្រមអន្តរជាតិអំពីអាជ្ញាយុកាលនេះ។ យ៉ាងណាមិញចៅក្រមជាតិបានអះអាងថា ប្រព័ន្ធយុត្តិធម៌កម្ពុជាទើបមានដំណើរការពេញលេញចាប់ពីឆ្នាំ១៩៩៨ ដូចនេះរយៈពេល ១០ឆ្នាំ ត្រូវរាប់ចាប់ពីឆ្នាំនេះ រហូតដល់ឆ្នាំ២០០៨ ទើបផុតអាជ្ញាយុកាល ១០ឆ្នាំ។ ប៉ុន្តែចៅក្រមអន្តរជាតិយល់ឃើញថា ប្រព័ន្ធយុត្តិធម៌កម្ពុជាមានដំណើរអាចធ្វើការចោទប្រកាន់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យយ៉ាងហោចណាស់ក្នុងឆ្នាំ១៩៩៣។ រយៈពេល ១០ឆ្នាំ ត្រូវបានបញ្ចប់ក្នុងឆ្នាំ២០០៣ មុនពេលដែលច្បាប់ អង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជាបានអនុម័តក្នុងឆ្នាំ២០០៤។ ចៅក្រមអន្តរជាតិបានធ្វើការអង្កេតលើការអនុវត្តរបស់ប្រទេសមួយចំនួន ហើយរកឃើញថាការពន្យារដែលមិនខុសច្បាប់ លុះត្រាតែធ្វើឡើងតាមរយៈច្បាប់របស់សភា និងនៅមុនពេលដែលរយៈពេលនៃអាជ្ញាយុកាលមិនទាន់ផុតរលត់។ ចៅក្រមមិនបានអះអាងថាសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា ខុសឬយ៉ាងណាទេ ដោយគ្រាន់តែអះអាងថា ក្រុមប្រឹក្សាធម្មនុញ្ញមិនបាននិយាយចំដល់បញ្ហាអាជ្ញាយុកាលនៃបទល្មើស និងថាសេចក្តីសម្រេចនេះមិនមែនជាច្បាប់របស់សភាទេ។ អាស្រ័យហេតុនេះ ការដែលអាជ្ញាយុកាលនៅបន្តចោទប្រកាន់បទល្មើសជាតិ អាចនាំឲ្យខុសពីគោលការណ៍អព្យាក្រឹត្យភាពរបស់ចៅក្រម។ ដូចនេះ អង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា មិនអាចធ្វើការចោទប្រកាន់ឌុចពីបទល្មើសជាតិ ការសម្លាប់ ឬការធ្វើទារុណកម្ម តាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ទេដោយសាររយៈពេលនៃចោទប្រកាន់ ១០ឆ្នាំ បានកន្លងផុតទៅហើយ[4]។ ដោយសារ មិនអាចទទួលសំឡេង ៤ ក្នុង

[4] មាស បូរ៉ា, សង្ខេបយុត្តិសាស្ត្រ សំណុំរឿងលេខ ០០១, អង្គជំនុំជម្រះសាលាដំបូង, សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងថិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ដែលលើកឡើងដោយមេធាវីការពារក្តី, ២៦ ខែ កក្កដា ឆ្នាំ ២០១០

ចំណោម ៥ (ចៅក្រមជាតិចំនួន ៣ និងអន្តរជាតិចំនួន ២) លើសេចក្ដីសម្រេចញ្ញត្តិរបស់មេធាវីទទួលបានជ័យជំនះ[5]។

### ៣.២. ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានធ្វើវិសោធនកម្មនិងប្រកាសអោយប្រើប្រាស់នាថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។ ច្បាប់នេះត្រូវបានរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិនិងទម្លាប់អន្តរជាតិ[6]។ យ៉ាងណាមិញ ច្បាប់នេះត្រូវបានយកមកប្រើប្រាស់ជាមូលដ្ឋានគ្រឹះក្នុងការកាត់ក្ដីមេដឹកនាំខ្មែរក្រហមទាំងឡាយដែលត្រូវយកមកជំនុំជម្រះក្នុងសាលាក្ដីខ្មែរក្រហមនេះ។ ដូចបានបញ្ជាក់ក្នុងមាត្រា៥ នៃច្បាប់នេះបានបង្ហាញថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានអំណាចវិនិច្ឆ័យទោសជនសង្ស័យទាំងឡាយណាដែលប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩។ ក្នុងច្បាប់នេះដែរក៏បានបញ្ជាក់អំពីសមាសភាពរបស់អង្គជំនុំជម្រះ ដូចមានចែងក្នុងមាត្រា ៩(ថ្មី) "សាលាដំបូងជាអង្គជំនុំជម្រះវិសាមញ្ញដោយចៅក្រមវិជ្ជាជីវៈប្រាំរូប មានចៅក្រមខ្មែរបីរូប មួយរូបធ្វើជាប្រធាន និងមានចៅក្រមបរទេសពីររូប និងមានក្រឡាបញ្ជីមួយរូប ឬច្រើនរូប ព្រមទាំងមានសហព្រះរាជអាជ្ញាដែលត្រូវដាក់ពាក្យប្ដឹងនៅចំពោះមុខសាលាដំបូងនេះ។ ឯតុលាការកំពូលដែលជាកន្លែងទទួលពាក្យបណ្ដឹងឧទ្ធរណ៍ផងនិងសម្រេចសេចក្ដីចុងក្រោយផង ត្រូវមានចៅក្រមប្រាំពីររូប ដែលមានចៅក្រមខ្មែរបួនរូប ដែលមួយរូបធ្វើជាប្រធាន និងចៅក្រមបរទេសបីរូប និងក្រឡាបញ្ជីមួយរូប ព្រមទាំងសហព្រះរាជអាជ្ញាដែលត្រូវដាក់ពាក្យបណ្ដឹង"។ ក្នុងច្បាប់នេះបានបង្ហាញពីការសម្រេចសេចក្ដីរបស់អង្គជំនុំជម្រះ សមាសភាពព្រះរាជអាជ្ញា និងកិច្ចស៊ើបអង្កេតនានា។

### ៣.៣. ព្រះរាជក្រឹត្យតែងតាំង

ការឡើងកាន់តំណែងជាចៅក្រម និងសហព្រះរាជអាជ្ញាផ្សេងៗត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យដែលនៅក្នុងនោះចៅក្រមដែលត្រូវបានតែងតាំងនោះមានដូចជា៖

- យោងតាមព្រះរាជក្រឹត្យ នស/រតក/១១០៥/៤៦២ លោក ស៊ាន វិសុទ្ធ ត្រូវបានតែងតាំងជាប្រធានការិយាល័យរដ្ឋបាល និងលោក ហែម ក្រាញ់ តូនី ជាប្រធានការិយាល័យរដ្ឋបាលបំរុង ដើម្បីកាត់

[5] មាត្រា១៤ (ថ្មី) នៃច្បាប់ស្ដីពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, ក. សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ ទាមទារនូវសំឡេងគាំទ្រយ៉ាងតិចណាស់ចៅក្រម ៤ រូប

[6] មាត្រា១ នៃច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។ ព្រះរាជក្រឹត្យនេះត្រូវបានចាប់ចូលជាធរមាននាថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១២

- យោងតាមព្រះរាជក្រឹត្យ នស/រតក/១១០៥/៤៦៦ លោកស្រី Michelle Lee ត្រូវបានតែងតាំងជាអនុប្រធានការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។ ព្រះរាជក្រឹត្យនេះត្រូវបានចាប់ចូលជាធរមាននាថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១២
- យោងតាមព្រះរាជក្រឹត្យ នស/រតក/០១០៩/១២៧ លោកស្រី Florence Mumba សញ្ជាតិ Zambia ត្រូវបានតែងតាំងជាចៅក្រមអន្តរជាតិបំរុងនៅអង្គជំនុំជម្រះនៃអង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា នាថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៩។

ការតែងតាំងនានាត្រូវបានបន្ត ដោយរួមបញ្ចូលទាំងចៅក្រមជាតិ និងចៅក្រមអន្តរជាតិដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មនេះក្នុងសាលាដំបូង និងក្នុងតុលាការកំពូល។

# ជំពូកទី ២

# រចនាសម្ព័ន្ធនៃការគ្រប់គ្រង

# អង្គជំនុំជម្រះវិសាមញ្ញ

# ក្នុងតុលាការកម្ពុជា

# ជំពូកទី ២
# រចនាសម្ព័ន្ធនៃការគ្រប់គ្រងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ១. ផ្នែកតុលាការ និង ការិយាល័យច្បាប់

### ១.១. អង្គបុរេជំនុំជម្រះ

**អង្គបុរេជំនុំជម្រះ** មានភារកិច្ចជំនុំជម្រះក្តីពាក់ព័ន្ធនឹងសំណើរសុំ និងបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចណាមួយរបស់សហចៅក្រមស៊ើបអង្កេត ក្នុងអំឡុងពេលដែលសំណុំរឿងកំពុងស្ថិតក្នុងដំណាក់កាលស៊ើបអង្កេត។ អង្គបុរេជំនុំជម្រះមានចៅក្រមជាតិចំនួនបីរូប និងចៅក្រមអន្តរជាតិពីររូប ហើយរាល់ការសម្រេចចិត្តត្រូវតែមានការអនុម័តពីចៅក្រមយ៉ាងតិចបួនរូប[7]។

### ១.២. អង្គជំនុំជម្រះសាលាដំបូង

បន្ទាប់ពីការធ្វើសេចក្តីសន្និដ្ឋានលើដំណើរការស៊ើបអង្កេតសំណុំរឿងមួយ ប្រសិនបើសំណុំរឿងត្រូវបានបញ្ជូនទៅជំនុំជម្រះ **អង្គជំនុំជម្រះសាលាដំបូង** នឹងបើកសវនាការជំនុំជម្រះក្តី។ អង្គជំនុំជម្រះសាលាដំបូងនឹងសម្រេចថាតើជនជាប់ចោទមានទោសឬមិនមានទោស ដោយផ្អែកទៅលើសក្ខីកម្មរបស់សាក្សី ភស្តុតាង និងអំណះអំណាងរបស់ភាគីនីមួយៗនៅក្នុងតុលាការ។ អង្គជំនុំជម្រះសាលាដំបូងមានចៅក្រមជាតិបីរូប និងចៅក្រមអន្តរជាតិពីររូប ហើយការចេញសាលក្រមត្រូវតែមានការអនុម័តពីចៅក្រមយ៉ាងតិចបួនរូប[8]។

### ១.៣. អង្គជំនុំជម្រះតុលាការកំពូល

អង្គជំនុំជម្រះតុលាការកំពូលនឹងជំនុំជម្រះក្តីលើ បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ឬសេចក្តីសម្រេចចិត្តដែលចេញដោយអង្គជំនុំជម្រះសាលាដំបូង។ មានចៅក្រមជាតិបួនរូបនិងចៅក្រមអន្តរជាតិបីរូបនៅអង្គជំនុំជម្រះតុលាការកំពូល ហើយរាល់ការសម្រេចចិត្តនៅក្នុងអង្គជំនុំជម្រះតុលាការកំពូលត្រូវតែមានការអនុម័តពីចៅក្រមយ៉ាងតិចប្រាំរូប[9]។

### ១.៤. ការិយាល័យសហចៅក្រមស៊ើបអង្កេត

- ❖ សហចៅក្រមស៊ើបអង្កេតរួមមាន៖
  - ចៅក្រម យូ ប៊ុនឡេង(កម្ពុជា ជាសហចៅក្រមស៊ើបអង្កេតជាតិ)
  - ចៅក្រម Michael Bohlander (អាល្លឺម៉ង់ជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ)។

[7] វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា, វិធាន១៧: បទប្បញ្ញត្តិទូទៅ (វិសោធនកម្មលើកទី៩ ថ្ងៃទី១៦ ខែមករា ឆ្នាំ ២០១៥)

[8] មាត្រា៩ ថ្មី នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, កថាខណ្ឌទី១

[9] មាត្រា៩ ថ្មី នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, កថាខណ្ឌទី២

❖ **សំណុំរឿង**

មានសំណុំរឿងចំនួនពីរដែលស្ថិតក្រោមការស៊ើបអង្កេត ដែលគេហៅជាទូទៅថាជាសំណុំរឿង ០០៣ សំណុំរឿង ០០៤ សំណុំរឿង ០០៤/០១ និង សំណុំរឿង ០០៤/០២ ដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទប្រល័យពូជសាសន៍ រួមទាំងបទឧក្រិដ្ឋនានាតាមច្បាប់កម្ពុជាផង។ សហចៅក្រមស៊ើបអង្កេតទាំងពីររូបទទួលខុសត្រូវក្នុងការប្រមូលភស្តុតាង ដើម្បីសម្រេចៈ

- អង្គហេតុដែលត្រូវបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញានៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមបង្កើតជាបទឧក្រិដ្ឋដែលស្ថិតក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
- បុគ្គលដែលត្រូវបានស៊ើបអង្កេត ជាមេដឹកនាំជាន់ខ្ពស់ ឬជាបុគ្គលម្នាក់ក្នុងចំណោមបុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះបទឧក្រិដ្ឋដែលត្រូវបាន ប្រព្រឹត្តក្នុងអំឡុងរបបខ្មែរក្រហម (ហៅថា យុត្តាធិការបុគ្គលឬទេ។
- បុគ្គលដែលស្ថិតក្រោមការស៊ើបអង្កេត នឹងត្រូវចោទប្រកាន់ និងបញ្ជូនទៅជំនុំជម្រះ ឬទេ ឬថាតើសំណុំរឿងប្រឆាំងនឹងពួកគេគួរត្រូវបានលើកលែងការចោទប្រកាន់។

❖ **សហចៅក្រមស៊ើបអង្កេតត្រូវៈ**

- ស៊ើបអង្កេតដោយមិនលម្អៀង និងស្វែងរកភស្តុតាងទោះជាភស្តុតាងដាក់បន្ទុក ឬដោះបន្ទុកក៏ដោយ។
- បំពេញកិច្ចដោយឯករាជ្យ និងមិនទទួលយក ឬស្នើសុំការណែនាំណាមួយពីរដ្ឋាភិបាល ឬពីប្រភពណាផ្សេងទេ។
- រក្សាតុល្យភាពរវាងសិទ្ធិរបស់ភាគីផ្សេងៗ ដោយត្រូវការពារសិទ្ធិរបស់មេធាវីការពារក្តី និងគោរពផលប្រយោជន៍របស់ជនរងគ្រោះ រួមទាំងសិទ្ធិ និងផលប្រយោជន៍របស់សហព្រះរាជអាជ្ញា។
- ធ្វើការស៊ើបអង្កេតដោយសម្ងាត់ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគី ជាពិសេសគឺ សច្ចាធារណ៍និរទោស ដើម្បីអនុញ្ញាតឱ្យមានវិធានការការពារដែលអាចមានចំពោះអត្តសញ្ញាណរបស់សាក្សី និងជនរងគ្រោះ និងដំណើរការស៊ើបអង្កេតឱ្យមានប្រសិទ្ធផល និងប្រសិទ្ធភាព។

បុគ្គលដែលចូលរួមក្នុងការស៊ើបអង្កេតមានកាតព្វកិច្ចរក្សាការសម្ងាត់ ហើយឯកសារ និងសម្ភារៈទាំងអស់ដែលបានបញ្ចូលក្នុងសំណុំរឿង គឺជាការសម្ងាត់ ទោះបីឯកសារក្នុងសំណុំរឿងនោះអាចជាកំណត់ហេតុសាធារណៈក៏ដោយ។ សហចៅក្រមស៊ើបអង្កេត ជួនកាលអាចផ្តល់ជូនសាធារណជននូវព័ត៌មាន ក្នុងកម្រិតអប្បបរមា ដោយព័ត៌មានទាំងនោះពុំប៉ះពាល់ដល់ភាពព័ត៌មានសម្ងាត់នៃការស៊ើបអង្កេតឡើយ[10]។

[10] មាត្រា២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

### ១.៥. ការិយាល័យសហព្រះរាជអាជ្ញា

ការិយាល័យសហព្រះរាជអាជ្ញា (ក.ស.ព) គឺជាការិយាល័យឯករាជ្យមួយនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា[11]។ ក.ស.ព អនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយគ្មានការជ្រៀតជ្រែកពីរដ្ឋាភិបាលឬស្ថាប័នណាមួយឡើយ។ តួនាទីរបស់ ក.ស.ព គឺដើម្បីចោទប្រកាន់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះ ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

ក.ស.ព បើកការស៊ើបអង្កេតបឋម ធ្វើការចោទប្រកាន់ ចាត់ការលើបណ្តឹងរបស់ជនរងគ្រោះ ចូលរួមនៅក្នុងកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតដំណាក់កាលអង្គ បុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងតុលាការកំពូល។ ក.ស.ព មានសហប្រធានដឹកនាំដោយសហព្រះរាជអាជ្ញាកម្ពុជាមួយរូបនិងសហព្រះរាជអាជ្ញាអន្តរជាតិមួយរូប និងមានបុគ្គលិកជាតិនិងអន្តរជាតិមួយចំនួន រួមទាំងកម្មសិក្សាការីផង។

កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា (ដែលបានបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា) យល់ព្រមឱ្យមានព្រះរាជអាជ្ញាខ្មែរមួយរូបនិងព្រះរាជអាជ្ញាអន្តរជាតិមួយរូប ដែលបំពេញតួនាទីជាសហព្រះរាជអាជ្ញា។ សហព្រះរាជអាជ្ញាកម្ពុជាត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជា ហើយសហព្រះរាជអាជ្ញាអន្តរជាតិត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជា ក្រោយពីការជ្រើសរើសឱ្យឈរឈ្មោះដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ[12]។

## ២. ការិយាល័យរដ្ឋបាល

ការិយាល័យរដ្ឋបាលមានតួនាទីជួយគាំទ្រនិងសម្របសម្រួលដល់កិច្ចដំណើរការតុលាការ តាមរយៈការផ្តល់សេវាកម្មប្រកបដោយប្រសិទ្ធិភាព មានការសន្សំសំចៃ និងមានការសម្របសម្រួលល្អ។ ការិយាល័យរដ្ឋបាលស្ថិតនៅក្រោមការដឹកនាំរបស់ ឯកឧត្តម ក្រាញ់ តូនី ជាប្រធានស្តីទី និងលោក Knut Rosandhaug ជាអនុប្រធាន[13]។

ប្រធាននិងអនុប្រធានទាំងពីររូបរួមគ្នាផ្តល់កិច្ចសម្របសម្រួលទូទៅ និងការណែនាំសម្រាប់ផ្នែកនិងអង្គភាពផ្សេងៗនៅក្រោមចំណុះការិយាល័យរដ្ឋបាល ដើម្បីធានានូវការគាំទ្រពេញទំហឹងដល់ដំណើរការតុលា

---

[11] មាត្រា១៦ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

[12] វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិធាន១៣: ប្រតិបត្តិការនៃការិយាល័យសហព្រះរាជអាជ្ញា (វិសោធនកម្មលើកទី៩ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥)

[13] មាត្រា៣០ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

ការ។ ប្រធាននិងអនុប្រធានទាំងពីររូបក៏ទទួលបន្ទុកផងដែរលើទំនាក់ទំនងជាមួយនឹងភាគីពាក់ព័ន្ធជាមួយកិច្ចព្រមព្រៀង និងសហគមន៍អ្នកផ្តល់ជំនួយ។ អ្នកទាំងពីរក៏មានការជួយជ្រោមជ្រែងពីមន្ត្រីច្បាប់របស់ខ្លួនដែលផ្តល់ការណែនាំអំពីក្របខណ្ឌច្បាប់ដែលអាចអនុវត្តបាន ព្រមទាំងធ្វើសេចក្តីព្រាងនិងពិនិត្យឡើងវិញរាល់ឯកសារផ្លូវការទាំងអស់[14]។

## ២.១. ផ្នែកគ្រប់គ្រងតុលាការ

ផ្នែកគ្រប់គ្រងតុលាការ គឺជាផ្នែកមួយដែលបំពេញតួនាទីចម្បងនៅក្នុងការិយាល័យរដ្ឋបាល ក្នុងការសម្របសម្រួល និងផ្តល់សេវាប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលដល់ការិយាល័យតុលាការ និងអង្គជំនុំជម្រះទាំងអស់ ដែលគាំទ្រដល់កិច្ចដំណើរការនីតិវិធីតុលាការ។ តាមទម្លាប់ ផ្នែកគ្រប់គ្រង តុលាការ ត្រូវបានគេយល់ថាជា "តួម៉ាស៊ីន" របស់តុលាការ ក្នុងការផ្តល់ការជួយគាំទ្រផ្នែកសម្ភារៈ បច្ចេកទេស និងរដ្ឋបាលដល់អង្គជំនុំជម្រះក្នុងតុលាការកម្ពុជាទាំងអស់ តាមរយៈការសម្របសម្រួលជាមួយបណ្តាផ្នែក ផ្សេងៗទៀត និងការិយាល័យនានារបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ តាមរយៈមន្ត្រីរដ្ឋបាលតុលាការ ផ្នែកគ្រប់គ្រងតុលាការជានាផ្តល់ការគាំទ្រផ្នែកសម្ភារៈបច្ចេកទេស និង ប្រតិបត្តិការដល់អង្គជំនុំជម្រះទាំងអស់ នៅពេលមន្ត្រីរបស់អង្គតុលាការប្រើប្រាស់សាលសវនាការ និងបន្ទប់សម្ភាសន៍។ ប្រធានផ្នែកគ្រប់គ្រងតុលាការ មានតួនាទីសម្របសម្រួល និងរក្សាទំនាក់ទំនងការងារឱ្យមានប្រសិទ្ធភាព និងភាពរលូន ជាមួយនឹងចៅក្រមនៃអង្គជំនុំជម្រះនីមួយៗ សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា ប្រធានអង្គភាពគាំពារការការពារក្តី ប្រធានអង្គភាពគាំពារជនរងគ្រោះ និងមន្ត្រី តុលាការផ្សេងទៀត។ ប្រធានផ្នែកគ្រប់គ្រងតុលាការបំពេញភារកិច្ចរបស់ខ្លួនដោយមានជំនួយពីមន្ត្រី ផ្នែកគ្រប់គ្រងតុលាការផង និងមន្ត្រីគ្រប់គ្រងសំណុំរឿងឬមន្ត្រីរដ្ឋបាលតុលាការផង។ ផ្នែកគ្រប់គ្រងតុលាការរួមមានបុគ្គលិកជាតិ និង អន្តរជាតិបំពេញការងាររួមគ្នា ក្រោមការដឹកនាំរបស់ឯកឧត្តម គង់ សុភី ជាប្រធានផ្នែកគ្រប់គ្រងតុលាការ[15]។ ផ្នែកគ្រប់គ្រងតុលាការ ត្រូវបានបែងចែកជាអង្គភាពផ្សេងៗរួមមាន៖

- **អង្គភាពសោតទស្សន៍**: អង្គភាពនេះទួលភារកិច្ចថតចម្លងកិច្ចសម្ភាសន៍ និងកិច្ចដំណើរការនីតិវិធីទាំងអស់តាមប្រព័ន្ធឌីជីថល រួចរក្សាទុកជាឯកសារសម្រាប់ចៅក្រម ឬ មេធាវីពិនិត្យឡើងវិញនាពេលក្រោយ នៅក្នុងដំណាក់កាលណាមួយ ដែលមានការលេចឡើងនូវចំណុចអង្គច្បាប់ ឬ ទឡ្ហីករណ៍អង្គច្បាប់។
- **អង្គភាពទំនាក់ទំនងមន្ទីរឃុំឃាំង**: អង្គភាពនេះទទួលខុសត្រូវលើការសម្របសម្រួលនិងទំនាក់ទំនងរវាងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងប្រធានមន្ទីរឃុំឃាំង រួមទាំងភ្នាក់ងារ អាជ្ញាធរ ឬ

[14] វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា, វិធាន៩: មុខងាររបស់ការិយាល័យរដ្ឋបាល (វិសោធនកម្មលើកទី៩ ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៥)

[15] គេហទំព័រ: https://www.eccc.gov.kh/km/node/12075

អង្គការជាតិ ឬ អន្តរជាតិណាមួយ ដែលមានសមត្ថកិច្ច។ អង្គភាពនេះជាអ្នកធានាឱ្យមានការគោរពសិទ្ធិរបស់ជនជាប់ឃុំ នៅគ្រប់ពេលវេលាទាំងអស់ ស្របតាមវិធានផ្ទៃក្នុងនៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (វិធានផ្ទៃក្នុង) និងបទដ្ឋានអន្តរជាតិ។ អង្គភាពនេះក៏ធានាលើការធ្វើរបាយការណ៍ភ្លាមៗ និងចាត់វិធានការសមស្របចំពោះបញ្ហាទាំងឡាយ ដែលពាក់ព័ន្ធនឹងសុខមាលភាព សុខភាព និងលក្ខខណ្ឌឃុំខ្លួនរបស់ជនជាប់ឃុំទាំងអស់។

- **អង្គភាពបកប្រែភាសា**: មន្ត្រីបកប្រែឯកសារជាតិ និងអន្តរជាតិសហការគ្នាបំពេញការងារដើម្បីធានាឱ្យមានការបកប្រែឯកសារតុលាការទាំងអស់ ទៅជាភាសានីមួយៗក្នុងចំណោមភាសាការងារទាំងបី (ភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង)[16]។ មន្ត្រីបកប្រែភាសាផ្ទាល់មាត់ផ្តល់សេវាបកប្រែប្រែដេញក្នុងកិច្ចប្រជុំ និងក្នុងកិច្ចដំណើរការនីតិវិធីតុលាការ ដោយបកប្រែរាល់ពាក្យសំដីដែលបាននិយាយទាំងអស់ ដើម្បីធានាថា ភាគីទាំងអស់យល់នូវអ្វីដែលកំពុងថ្លែងឡើង នៅគ្រប់ពេលទាំងអស់។
- **ការិយាល័យជួរមុខ**: មន្ត្រីគ្រប់គ្រងសំណុំរឿង និងមន្ត្រីរដ្ឋបាលតុលាការ ធ្វើការងាររួម គ្នាក្រោមការគ្រប់គ្រងផ្ទាល់ពីប្រធានផ្នែកគ្រប់គ្រងតុលាការ ដើម្បីផ្តល់ការគាំទ្រផ្នែករដ្ឋបាល និងផ្នែកសម្ភារៈបច្ចេកទេស ជូនដល់ការិយាល័យសហចៅក្រមស៊ើបអង្កេត "ក.ស.ច.ស" ភាគីនានា ព្រមទាំងអង្គជំនុំជម្រះផងដែរ។ មន្ត្រីគ្រប់គ្រងសំណុំរឿងទទួលខុសត្រូវចម្បងលើការទទួលឯកសារ និងការគ្រប់គ្រងសំណុំរឿង ដោយសម្របសម្រួលជាមួយនឹងក្រឡាបញ្ជី លើការធ្វើបម្លាស់ទីសំណុំរឿង (សំណុំរឿងច្បាប់ដើម/ច្បាប់ថតចម្លង) កំណត់ហេតុនៃកិច្ចសម្ភាសន៍ រួមទាំងធ្វើការងាររក្សាសំណុំរឿង និងចាត់ចែងភស្តុតាងដែលផ្តល់ជូនដោយ ក.ស.ច.ស ភាគីនានា ឬ អង្គជំនុំជម្រះទាំងអស់។

មន្ត្រីរដ្ឋបាលតុលាការផ្តល់សេវាតុលាការ និងបំពេញការងារសម្របសម្រួលឬទំនាក់ទំនងរវាងភាគីទាំងអស់ និងអង្គជំនុំជម្រះ (ជាពិសេស ក្រឡាបញ្ជីឬមន្ត្រីច្បាប់) និងអ្នកចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី។ នៅក្នុងពេលសវនាការ និងជំនុំជម្រះ មន្ត្រីទាំងនេះទទួលខុសត្រូវចម្បងលើការអនុវត្តការងាររៀបចំជាក់ស្តែងនៅក្នុងពេលសវនាការជំនុំជម្រះ ដើម្បីឱ្យដំណើរការទៅដោយរលូន និង ស្របតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះ។ មន្ត្រីរដ្ឋបាលតុលាការដើរតួ ជាមន្ត្រីទំនាក់ទំនងរួមលើការងារទាំងឡាយ ដែលក្នុងចំណោមនោះរួមមាន កំណត់ហេតុ និង ភស្តុតាង សាក្សីនានា (សម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ និងអនុវត្តការងារការពារសាក្សី) បញ្ហាសោតទស្សន៍ (សម្របសម្រួលជាមួយនឹងក្រុមសោត ទស្សន៍) សំណើជាក់ស្តែង

[16] មាត្រា៤៥ ថ្មី នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

ស្មើដោយភាគីពាក់ព័ន្ធនឹងសវនាការ ជាដើម។ល។ មន្ត្រីរដ្ឋបាល តុលាការជួយមន្ត្រីគ្រប់គ្រងសំណុំរឿងក្នុងការទទួល ការចាត់ចែង និងការចែកចាយឯកសារ ដោយធ្វើការពិគ្រោះយោបល់ជាមួយនឹងក្រឡាបញ្ជី។

- **អង្គភាពបណ្ណសារ**: ដោយសហការជាមួយនឹងក្រឡាបញ្ជីរដ្ឋបាល អង្គភាពនេះទទួលខុសត្រូវរៀបចំកាតាឡុក ការចែកចាយ ការរក្សាទុក និងការធានាសន្តិសុខលើគ្រប់ឯកសារ និងវត្ថុតាងរបស់តុលាការទាំងអស់។ បណ្ណាល័យដែលអមអង្គភាពបណ្ណសារ ផ្តល់ឱ្យអង្គតុលាការ មេធាវី និងអ្នកប្រើប្រាស់តុលាការផ្សេងទៀត នូវលទ្ធភាពពិនិត្យ និងស្រាវជ្រាវឯកសារច្បាប់ និងឯកសារស្រាវជ្រាវនានាតាមរយៈសៀវភៅ ព្រឹត្តិបត្រស្រាវជ្រាវ អ៊ីនធឺណិត និងមូលដ្ឋានទិន្នន័យច្បាប់តាមប្រព័ន្ធអ៊ិនធើណែត ដូចជា តាមរយៈប្រព័ន្ធ LexisNexis ជាដើម។ សៀវភៅនៅក្នុងបណ្ណាល័យត្រូវបានទិញដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិង សៀវភៅមួយចំនួនទៀតត្រូវបានផ្តល់ឱ្យដោយរដ្ឋម្ចាស់ជំនួយ និងបុគ្គលនានា។ វាមានការសង្ឃឹមទុកថា ក្រោយពីការបញ្ចប់អាណត្តិការងាររបស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សៀវភៅទាំងនេះ នឹងត្រូវផ្តល់ជូនជាអំណោយទៅស្ថាប័នណាមួយនៅក្នុងប្រទេសកម្ពុជា។
- **អង្គភាពប្រតិចារឹក**: អង្គភាពនេះធ្វើប្រតិចារឹកគ្រប់ពាក្យដើម ចេញពីកិច្ចដំណើរការនីតិវិធីទាំងអស់របស់តុលាការ ជាភាសាផ្លូវការនីមួយៗរបស់តុលាការ ពោលគឺ ភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង។ ប្រតិចារឹកគឺជាឧបករណ៍ធ្វើការងារសម្រាប់អង្គជំនុំជម្រះ និងភាគីនៃរឿងក្តី។ ប្រតិចារឹកគឺជាធនធានដ៏មានសារៈសំខាន់សម្រាប់អ្នកតាមដានដំណើរការជំនុំជម្រះ និងសាធារណជន និងជាកំណត់ត្រាប្រវត្តិសាស្ត្រនៃកិច្ចដំណើរការនីតិវិធីប្រចាំថ្ងៃរបស់តុលាការ។ អង្គភាពនេះត្រូវបានបែងចែកចេញជាក្រុមការងាររួមគ្នាតូចៗចំនួនពីរ គឺជាតិ និងអន្តរជាតិ។ ក្រុមការងារជាតិមានបុគ្គលិកចំនួន ១១ នាក់ ជួយការងារបេសកកម្មរបស់ ក.ស.ច.ស បន្ថែមលើការងារធ្វើប្រតិចារឹកភាសាខ្មែរ។ ក្រុមការងារអន្តរជាតិរួមមានមន្ត្រី ប្រតិចារឹកចំនួនបួននាក់ (ពីរនាក់សម្រាប់ភាសាអង់គ្លេស និងពីរនាក់ទៀតសម្រាប់ភាសា បារាំង) ដោយក្នុងនោះមានមន្ត្រីមួយរូបធ្វើជាអ្នកគ្រប់គ្រងផ្ទាល់។
- **អង្គភាពគាំពារសាក្សី និងអ្នកជំនាញ**: អង្គភាពនេះគឺទទួលខុសត្រូវលើសេវាទាំងឡាយដែលត្រូវការក្នុងការផ្តល់ ឱ្យមានបរិយាកាសមួយប្រកបដោយសុវត្ថិភាព និងការគាំទ្រដល់សាក្សី អ្នកជំនាញ និងជនរងគ្រោះ ដើម្បីអាចឱ្យពួកគាត់ចូលរួមនៅក្នុងកិច្ចដំណើរការ នីតិវិធីនៅ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ទទួលខុសត្រូវលើមុខងារចម្បងចំនួនបី៖ ១) ប្រតិបត្តិការ និងផ្តល់សម្ភារៈភស្តុភារដល់សាក្សី និងអ្នកជំនាញ ២) គាំទ្រសាក្សី និង ៣) ការពារសាក្សី។

### ២.១.១. ផ្នែកបុគ្គលិក

ផ្នែកបុគ្គលិក(ផ្នែកជាតិនិងអន្តរជាតិបំពេញការងារស្របទិសគ្នា) ផ្នែកជាតិ ដឹកនាំដោយលោក ចាន់ ខុនវិចិត្រ ផ្នែកនេះទទួលខុសត្រូវ លើការគ្រប់គ្រងផ្នែករដ្ឋបាល និងការទទួលខុសត្រូវចំពោះ ការគ្រប់គ្រង ដឹកនាំបុគ្គលិកជាតិ ហើយធានាបាននូវគុណភាព និងតម្លាភាពក្នុងការជ្រើសរើសជា សាធារណៈ ក្នុងនោះរួមមាន៖

- បង្កើតនិងប្រតិបត្តិគោលនយោបាយនិងសៀវភៅការងារ ជាពិសេសសៀវភៅការងារសំរាប់បុគ្គលិក អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។
- បង្កើតនិងអនុវត្តនីតិវិធីនិងគោលនយោបាយផ្នែកកម្មសិក្សាការី។
- ជ្រើសរើសបុគ្គលិកជាតិថ្មី រួមទាំងចងក្រងលក្ខខណ្ឌការងារ ការប្រកាស់ជ្រើសរើសបុគ្គលិក ការត្រួតពិនិត្យនិងជម្រុះចោល ការធ្វើតេស្ត និងការតែងតាំង។
- ផ្តល់ការគ្រប់គ្រងផ្នែករដ្ឋបាល និងសេវាគាំទ្រដល់បុគ្គលិកសំរាប់បុគ្គលិក អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។
- គ្រប់គ្រងនិងត្រួតពិនិត្យព័ត៌មានបុគ្គលិកទូទៅ។
- កត់ត្រា និងរក្សា បញ្ជីវត្តមានបុគ្គលិក អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទាំងអស់ ដើម្បីរៀបចំបញ្ជីប្រាក់បៀវត្សរ៍ប្រចាំខែ ។
- សហការយ៉ាងជិតស្និទ្ធជាមួយនឹង ជំនួយរបស់អង្គការសហប្រជាជាតិសម្រាប់ការកាត់ក្តីខ្មែរក្រហមដើម្បីធ្វើឱ្យប្រសើរឡើងដល់មុខងារបុគ្គលិក ។
- សហការ និងសម្របសម្រួលជាមួយ គ្រប់ផ្នែក និងការិយាល័យទាំងអស់សំរាប់ការបណ្តុះបណ្តាល និងកម្មសិក្សាការី ។
- រៀបចំការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ និងការវាយតម្លៃផ្សេងៗសំរាប់បុគ្គលិក អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទាំងអស់។

ផ្នែកបុគ្គលិកអន្តរជាតិ ដឹកនាំដោយ លោកស្រី Emmanuelle Dupont ផ្នែកនេះទទួលខុសត្រូវចំពោះ៖

- ការជ្រើសរើសបុគ្គលិកអន្តរជាតិ
  - ដើម្បីផ្តល់ជូន អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នូវបុគ្គលិកអន្តរជាតិមានសមត្ថភាព និង លក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុង លក្ខណៈតម្លាភាព និង បានទាន់ពេលវេលា។
  - ដើម្បីបន្ថែមមុខតំណែងនានាដែលទទួលបានថវិការតាមគ្រោងទុកក្នុងតារាងបុគ្គលិកបច្ចុប្បន្ន ការជ្រើសរើសបុគ្គលិក ធ្វើឡើងតាមរយៈ អ្នកស្ម័គ្រសហប្រជាជាតិ បុគ្គលិកបណ្តោះអាសន្ន ផ្សេងៗដូចជា បុគ្គលិកធ្វើការមិនគិតផលកម្រៃ កម្មសិក្សាការី និងទីប្រឹក្សា ។ល។

- ការគាំទ្រផ្នែករដ្ឋបាល៖ ផ្តល់ការគាំទ្រ ផ្នែករដ្ឋបាលប្រកបដោយប្រសិទ្ធិភាព ជូនបុគ្គលិក UNAKRT [17] ក្នុងកិច្ចការទាំងឡាយដូចជា កិច្ចសន្យាការងារ ការផ្តល់សិទ្ធិ និងប្រាក់បំណាច់។
- ការបណ្តុះបណ្តាល៖ ជួយដល់ការអនុវត្តកម្មវិធីបណ្តុះបណ្តាលពីការគ្រប់គ្រង និង តុលាការ។ សហការជាមួយគ្រូ បណ្តុះបណ្តាល/ទីប្រឹក្សា ដែលមានជំនាញក្នុងការរៀបចំវគ្គបណ្តុះបណ្តាល សំរាប់បុគ្គលិក ជំនួយរបស់អង្គការសហប្រជាជាតិសម្រាប់ការកាត់ក្តីខ្មែរក្រហម។

### ២.១.២. ផ្នែកហិរញ្ញវត្ថុ និងថវិកា

ផ្នែកនេះ (ផ្នែកជាតិនិងអន្តរជាតិ បំពេញការងារស្របទិសគ្នា) ផ្នែកជាតិ ដឹកនាំដោយ ឯកឧត្តម ថោង សុជាតិ ផ្នែកនេះទទួលខុសត្រូវចំពោះ ៖

- ការគ្រប់គ្រងហរិញ្ញវត្ថុ និងការចំណាយផ្សេងៗ
- បង្កើតប្រព័ន្ធហរិញ្ញវត្ថុ និងប្រព័ន្ធគ្រប់គ្រងគណនេយ្យ យោងតាមបទដ្ឋាននិងការអនុវត្តរបស់អន្តរជាតិ
- បើកប្រាក់ឱ្យបានទាន់ពេលវេលាវេលាឱ្យដល់អតិថិជនទាំងអស់រួមទាំងបុគ្គលិកផង
- រៀបចំពាក្យស្នើសុំ ការបំពេញបន្ថែមមូលនិធិ ដាក់ទៅកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងម្ចាស់ជំនួយ[18]
- ធ្វើរបាយការណ៍ហរិញ្ញវត្ថុប្រចាំត្រីមាសជូនកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងម្ចាស់ជំនួយ
- ការគ្រប់គ្រងគណនីទូទៅ
- បង្កើត និងដាក់ឱ្យអនុវត្តនូវផ្នែក Software គណនេយ្យប្រព័ន្ធកុំព្យូទ័រ ដែលអាចទទួលយកបាន ចំពោះបទដ្ឋាន គណនេយ្យអន្តរជាតិ
- ធានាដល់ការចំណាយផ្សេងៗស្របទៅនឹងថវិកា និងផែនការការងារប្រចាំឆ្នាំ ដែលបានព្រមព្រៀង
- តាមដានប្រតិបត្តិការថវិកា និងធ្វើរបាយការណ៍គណនេយ្យប្រចាំត្រីមាសសំរាប់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងម្ចាស់ជំនួយ
- អង្កេត និងតាមដាន
- ដាក់របាយការណ៍ហរិញ្ញវត្ថុ និងរបាយការណ៍វិវត្តន៍ប្រចាំត្រីមាសជូនកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងម្ចាស់ជំនួយ
- ធ្វើការត្រួតពិនិត្យជាទៀតទាត់លើការគ្រប់គ្រងហរិញ្ញវត្ថុ ដោយទីប្រឹក្សាឯករាជ្យ

[17] United Nations Assistance to the Khmer Rouge Trials (UNAKRT): https://www.eccc.gov.kh/km/node/12076
[18] United Nations Development Programme(UNDP): https://www.eccc.gov.kh/km/node/12075

- សវនកម្មផ្ទៃក្នុង
- សវនកម្មផ្ទៃខាងក្រៅប្រចាំឆ្នាំ ធ្វើឡើងដោយទីប្រឹក្សាឯករាជ្យ
- ប្រាក់បំណាច់
- ប្រាក់បៀវត្សរ៍បុគ្គលិកលើមូលដ្ឋានប្រចាំខែ
- ការចំណាយលើការធ្វើដំណើរ តាមអត្រាដែលបានការឯកភាពពីផ្នែកថវិកានិងហរិញ្ញវត្ថុសហប្រជាជាតិ

ផ្នែកអន្តរជាតិ ដឹកនាំដោយ លោក Jürgen Gafke ផ្នែកនេះទទួលខុសត្រូវចំពោះ៖

- ការរៀបចំរបាយការណ៍ហរិញ្ញវត្ថុសហប្រជាជាតិ ធានាបាន៖
  - ការធ្វើរបាយការណ៍ហរិញ្ញវត្ថុត្រឹមត្រូវនិងទាន់ពេលជូនអ្នកត្រួតពិនិត្យហរិញ្ញវត្ថុសហប្រជាជាតិ
  - ប្រកាន់ខ្ជាប់តាមវិធាននិងបទបញ្ញត្តិរដ្ឋបាលនិងហរិញ្ញវត្ថុសហប្រជាជាតិ
  - អនុម័តយកបទដ្ឋានគណនេយ្យអន្តរជាតិ និងការអនុវត្តបានល្អបំផុតរបស់សហប្រជាជាតិ
- ថវិកា
  - ធានាចំពោះការចំណាយស្របជាមួយនឹងផែនការថវិកា។
  - តាមដាន និងធ្វើរបាយការណ៍អំពីប្រតិបត្តិការជូនអ្នកគ្រប់គ្រងទាំងឡាយ និងទីស្នាក់ការធំរបស់សហប្រជាជាតិនៅ ទីក្រុងញូវយ៉ក។
  - ធ្វើការកែប្រែផែនការថវិកា នៅពេលប្រតិបត្តិការចាំបាច់។
- ការចំណាយផ្សេងៗ
  - រៀបចំការបើកប្រាក់ជូនបុគ្គលិក ទាំងអស់ឱ្យបានទាន់ពេលវេលា រួមទាំង មន្ត្រីច្បាប់ និងអង្គភាពពាណិជ្ជកម្ម ទីប្រឹក្សា ។ល។
  - រតនាគារ
  - បើកប្រាក់ជូនអតិថិជន
  - ការគ្រប់គ្រងសាច់ប្រាក់
  - ការទទួលមូលនិធិ
  - ការធ្វើគម្រោងចំណាយ
  - ធ្វើសំណើសុំសាច់ប្រាក់ទៅទីស្នាក់ការធំសហប្រជាជាតិ

### ២.១.៣. ផ្នែកសេវាកម្មទូទៅ

ផ្នែកសេវាទូទៅ (រួមបញ្ចូលគ្នាទាំងផ្នែកជាតិនិងអន្តរជាតិ) ការរួមបញ្ចូលគ្នានូវបុគ្គលិកជាតិ និងអន្តរជាតិ ធ្វើការជាក្រុមតែមួយ ដឹកនាំដោយបុគ្គលិកអន្តរជាតិ មួយរូបគឺលោក Mr. Robert Sully ផ្នែកសេវាទូទៅមានអង្គភាពរបស់ខ្លួនដូចខាងក្រោមៈ

- អង្គភាពអគារៈ គ្រប់គ្រងដោយបុគ្គលិកជាតិតែប៉ុណ្ណោះ។ បុគ្គលិកជាតិទាំងនោះទទួលខុសត្រូវចំពោះការងារថ្មីៗរបស់អគារ ការកែកុនជាថ្មី ការថែរក្សា ទឹកភ្លើង ការផ្គត់ផ្គង់ទឹកញាំ សេវាបោសសំអាត ការបែងចែកទីកន្លែង និងការថែរក្សាបរិស្ថាន។
- អង្គភាពធ្វើដំណើរៈ មានបុគ្គលិកជាតិពីររូប និងបុគ្គលិកអន្តរជាតិមួយរូបបំរើការ។ ការទទួលខុសត្រូវរបស់បុគ្គលិកទាំងនោះរួមមាន ការធ្វើរៀបចំធ្វើដំណើរនិងដឹកជញ្ជូនផ្លូវការ ការនាំចូលទំនិញ និងការត្រួតពិនិត្យរបស់គយ និងបញ្ហាពិធីការផ្សេងៗ។
- អង្គភាពដឹកជញ្ជូនៈ ស្ថិតក្រោមការត្រួតពិនិត្យផ្ទាល់ពីមន្ត្រីជាតិគ្រប់គ្រងរថយន្តនិងដឹកជញ្ជូន ដែលជាអ្នកសហការក្នុងការដាក់ពង្រាយរថយន្ត របស់អង្គការសហប្រជាជាតិចំនួន២៤គ្រឿង ដើម្បីផ្តល់ការដឹកជញ្ជូនផ្លូវការទាំងអស់។
- អង្គភាពគ្រប់គ្រងសម្ភារៈ គ្រប់គ្រងលើការទទួល និងការត្រួតពិនិត្យរាល់ទំនិញ ដែលអង្គការសហប្រជាជាតិបានទិញ ហើយថែរក្សាបញ្ជីសារពើភ័ណ្ឌនូវសម្ភារៈទាំងនោះ។ អង្គភាពនេះមានបុគ្គលិកជាតិពីររូប និងបុគ្គលិកអន្តរជាតិមួយរូបបំរើការ។
- អង្គភាពផ្គត់ផ្គង់ៈ រក្សាទុកនូវសម្ភារៈចាំបាច់សំរាប់ប្រើប្រាស់ក្នុងការិយាល័យ និង តុលាការ។ អង្គភាពនេះទទួលខុសត្រូវចំពោះការ ត្រួតពិនិត្យ ស្តុក និងការស្នើសុំបន្ថែម ហើយមានបុគ្គលិកជាតិចំនួន ២ រូប។
- អង្គភាពនាំសារនិងរត់សំបុត្រៈ ទទួលខុសត្រូវក្នុងការទទួល ប្រមូល និងវិចខ្ចប់សម្ភារៈសំរាប់ កញ្ចប់សំបុត្រកាទូត ប្រគល់និងប្រមូលសំបុត្រទៀតទាត់ ហើយចាត់ចែងអ្នកនាំសារ។ អង្គភាពនេះ មានបុគ្គលិកជាតិចំនួន ៤ រូប។
- អង្គភាពលទ្ធកម្មៈ ការអនុវត្តសកម្មភាពធ្វើឡើងដោយអង្គភាពជាតិ និងអន្តរជាតិពីរដាច់ដោយឡែកពីគ្នា ការទទួលខុសត្រូវរួមមាន ទទួលពាក្យស្នើសុំ ការស្នើឱ្យដេញថ្លៃ និងការចេញបញ្ជាទិញ។

### ២.២. ផ្នែកកិច្ចការសាធារណៈ

ការរួមបញ្ចូលគ្នានូវបុគ្គលិកជាតិ និងអន្តរជាតិធ្វើការជាក្រុមមួយហើយផ្នែកនេះដឹកនាំដោយបុគ្គលិកជាតិមួយរូបគឺ លោក នេត្រ ភក្ត្រា។ ផ្នែកកិច្ចការសាធារណៈរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺផ្នែកទំនាក់ទំនងកិច្ចការខាងក្រៅ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយធ្វើ

ការដើម្បីគាំទ្រនិង សហការ ជាតំណាងទូទៅឱ្យគ្រប់ផ្នែកទាំងអស់របស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងនោះរួមទាំង អង្គជំនុំជម្រះតុលាការ ព្រះរាជអាជ្ញា និងផ្នែកការពារក្ដីផងដែរ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានគោលនយោបាយមួយក្នុងការបង្ហាញពីឆន្ទៈរបស់ខ្លួនយ៉ាងសកម្មចំពោះសហគមន៍សារព័ត៌មាន អង្គទូតនានា អ្នកផ្ដល់ ជំនួយ អ្នកស្រាវជ្រាវនិង ភាគីចាប់អារម្មណ៍ដទៃទៀត។ យើងមានគោលបំណងផ្ដល់ព័ត៌មានឱ្យបានច្រើនតាមដែលធ្វើទៅបាន អំពីសកម្មភាពរបស់តុលាការបំពេញការងារដោយតម្លាភាព ដើម្បីឱ្យសាធារណៈជនទុកចិត្តលើកិច្ចដំណើរការរបស់តុលាការ។ គោលបំណងនេះចាំបាច់ត្រូវថ្លឹងថ្លែងឱ្យបានស្មើជាមួយនឹងភាពជាឯកជន ការរក្សាភាពសម្ងាត់ និង សិទ្ធិរបស់ភាគីទាំងអស់ក្នុងកិច្ចដំណើរការនីតិវិធីរួមទាំងសាក្សីនិងជនរងគ្រោះ និងបញ្ហាកង្វល់ផ្សេងៗចំពោះការជំនុំជម្រះដោយយុត្តិធម៌កិច្ចដំណើរការតាមការកំណត់និងសច្ចាធារណ៍និរទោស។ សកម្មភាពសំខាន់ៗរបស់ផ្នែកកិច្ចការសាធារណៈមានដូចខាងក្រោមៈ

- ការងារផ្សព្វផ្សាយ៖ កម្មវិធីផ្សព្វផ្សាយ មានគោលបំណងជូនដំណឹងដល់ជនជាតិកម្ពុជាទូទាំងប្រទេស អំពីកិច្ចការទូទៅរបស់តុលាការ ជាពិសេសកិច្ចដំណើរជំនុំជម្រះដើម្បីធ្វើយ៉ាងណាជួយសម្របសម្រួលដល់ការចូលរួមនិង យល់ដឹងរបស់ពួកគាត់ជំរុញឱ្យពួកគាត់គាំទ្រដល់កិច្ចការនេះក្នុងបរិបទហេដ្ឋារចនាសម្ព័ន្ធទំនាក់ទំនងរបស់ប្រទេសកម្ពុជាមានកម្រិតនិង ការចេះអក្សរនៅមានកម្រិតទាប។ យើងចូលទៅដល់ប្រជាជនតាមរយៈមធ្យោបាយនៃការបោះពុម្ពផ្សាយវេទិកាទូទាំងប្រទេសកម្មវិធីវិទ្យុនិង ទូរទស្សន៍ វេបសាយរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិង តាមរយៈការចូលរួមយ៉ាងសកម្មក្នុងសិក្ខាសាលានិងកិច្ចប្រជុំផ្សេងៗ (ដែលមធ្យោបាយនេះអាចជួយដល់ការនាំយកព័ត៌មានអំពីតុលាការទៅកាន់បេះដូងសហគមន៍បាន)។ បន្ថែមទៅលើការជំរុញសកម្មភាពឱ្យកាន់តែមានភាពខ្លាំងក្លាយើងធ្វើការក្នុងភាពដៃគូជាមួយនឹងអង្គការផ្សេងៗ ដើម្បីបញ្ជូនសាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ យើងសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល ជាតិនិងអន្តរជាតិ ព្រមទាំងរចនាសម្ព័ន្ធតាមតំបន់រចនាសម្ព័ន្ធតាមខេត្ត រចនាសម្ព័ន្ធជាតិរបស់រដ្ឋាភិបាល ពិសេសគឺដើម្បីផ្សព្វផ្សាយឯកសារមួយចំនួនធំដែលក្នុងនោះមានផ្ទាំងក្រដាសព័ត៌មាន ប័ណ្ណ ប្រកាស ឯកសារអានផ្សេងៗ វីដេអូ និងកម្មវិធីវិទ្យុ និងទូរទស្សន៍។
- ទំនាក់ទំនងព័ត៌មាន៖ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានបំណងផ្ដល់ព័ត៌មានអំពីសកម្មភាពរបស់ខ្លួនទៅឱ្យតំណាងផ្នែកផ្សព្វផ្សាយព័ត៌មានតាមប្រព័ន្ធអេឡិចត្រូនិច និងតាមការបោះពុម្ពផ្សាយទាំងក្នុងប្រទេសកម្ពុជា និងអន្តរជាតិទាន់ពេលវេលាទៅតាការស្នើសុំ។ វេបសាយរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានឯកសារច្រើនប្រភេទ រូបថត ជីវប្រវត្តិ និងព័ត៌មានអំពីប្រវត្តិ ផ្សេងទៀតសំរាប់អ្នកព័ត៌មាន និងសំរាប់សាធារណៈជន។ រាល់ព័ត៌មានទាំងអស់ផ្ដល់ជូន

ដោយឥតគិតថ្លៃ ហើយអនុញ្ញាតឱ្យប្រើឡើងវិញបានដោយមានការអនុញ្ញាតពីប្រភពដើម។ ព័ត៌មានជាក់លាក់បន្ថែមនិងឯកសារផ្សេងៗ អាចទទួលបាន តាមស្នើសុំពីផ្នែកកិច្ចការសាធារណៈ។ នៅពេលអនាគត យើងមានផែនការផលិតរូប ភាពវីដេអូនិងសំលេងខ្លីៗសំរាប់អ្នកព័ត៌មានប្រើប្រាស់ឡើងវិញ សេចក្ដីប្រកាសជូនដំណឹង អំពីសេវាសាធារណៈ និង សកម្មភាពសង្ខេបជារូបភាពវីដេអូ និង សំលេងនៃសាលសវនាការ អំពីតុលាការ សំរាប់ផ្សព្វផ្សាយតាមវិទ្យុ និង ទូរទស្សន៍។ សេចក្ដីប្រកាសព័ត៌មាន និងសេចក្ដីថ្លែងការណ៍នានា ត្រូវផ្សព្វផ្សាយតាមអ៊ីម៉ែលទៅដល់អ្នកទាំងឡាយណា ដែលចុះឈ្មោះជាមួយនឹងយើងខ្ញុំហើយក៏មានដាក់ផ្សាយនៅលើទំព័រវ៉េបសាយផងដែរគឺ http://www.eccc.gov.kh/media-center/press-releases។ អាចមានការរៀបចំឱ្យមាន កិច្ចសម្ភាសន៍ជាមួយអ្នកយកព័ត៌មានជាមួយនឹងមន្ត្រីតុលាការ និងបុគ្គលិកនៅក្នុងការិយាល័យរដ្ឋបាល តាមសមស្របដោយត្រូវស្នើសុំទៅផ្នែកកិច្ចការសាធារណៈ។

- ការអនុញ្ញាតផ្លូវការ៖ មានការរៀបចំផ្ដល់ការអនុញ្ញាតផ្លូវការជាប្រចាំ ឱ្យចូលក្នុងបរិវេណអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសំរាប់អ្នកកាសែត ដែលមានមូលដ្ឋាននៅប្រទេសកម្ពុជាឬសំរាប់អ្នកទាំងឡាយណាដែលចូល អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទៀងទាត់។ តំណាងកាសែតដែលចូលក្នុងបរិវេណ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ម្ដងម្កាល នឹងត្រូវគេស្នើសុំឱ្យទៅទំនាក់ទំនង ជាមួយផ្នែកកិច្ចការសាធារណៈជាមុន ដើម្បីសុំការអនុញ្ញាតផ្លូវការបណ្ដោះអាសន្ន។ ដើម្បីទទួលបាន ការអនុញ្ញាតផ្លូវការជាប្រចាំ ឬជាបណ្ដោះអាសន្ន គឺពុំតម្រូវឱ្យមានការបង់ថ្លៃទេ យើងគ្រាន់តែស្នើសុំឱ្យអ្នកកាសែតបំពេញលើទម្រង់បែបបទ (ទម្រង់បែបបទអេឡិចត្រូនិចលើប្រព័ន្ធកំព្យូទ័រ) ហើយផ្ដល់ប័ណ្ណសុពលភាពជាអ្នកកាសែតឬលិខិតឧទ្ទេសនាមពីចាងហ្វាងកាសែតរបស់ខ្លួនក្នុង ករណីអ្នកកាសែតអន្តរជាតិវិញ ត្រូវផ្ដល់លិខិតឆ្លងដែន និង ទិដ្ឋាការចម្លងមួយច្បាប់។
- ការថតចម្លងរូបភាពវីដេអូនិង សំលេងនៃកិច្ចដំណើរការនីតិវិធី៖ រាល់កិច្ចដំណើរការនីតិវិធីតុលាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាំងអស់ ត្រូវថតទុកសំរាប់ឯកសាររបស់តុលាការ។ ផ្ដល់ការអនុញ្ញាតឱ្យតភ្ជាប់រូបភាពវីដេអូ និងសំលេងអំពីកិច្ចដំណើរនីតិវិធីតុលាការសំរាប់ការផ្សាយជាសាធារណៈ បន្ទាប់ពីការពន្យាពេលមួយដើម្បីអនុញ្ញាតឱ្យមានការពិនិត្យផ្ទៀងផ្ទាត់ស្របទៅនឹងវិធានការការពារណាមួយ ឬដីកាតុលាការផ្សេងទៀត។ ជាងនេះទៅទៀត យើងគ្រោងរៀបចំឱ្យមានការពិនិត្យផ្ទៀងផ្ទាត់នូវកិច្ចដំណើរការនីតិវិធីតុលាការសង្ខេបខ្លីៗនៃរូបភាពវីដេអូនិងសំលេង និងសកម្មភាពផ្សេងៗរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

### ២.២.១. ផ្នែកសន្តិសុខនិងសុវត្ថិភាព

កិច្ចព្រមព្រៀងបន្ថែមលើសុវត្ថិភាពនិងសន្តិសុខគូសបញ្ជាក់អំពីរចនាសម្ព័ន្ធនៃការរៀបចំសន្តិសុខនិងសុវត្ថិភាពនៅ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាមួយប្រធានសន្តិសុខអន្តរជាតិ និងប្រធានសន្តិសុខកម្ពុជា។ កិច្ចព្រមព្រៀងនេះបានបំបែកផ្នែកនៃការទទួលខុសត្រូវ ដូច្នេះជាជាងការមានផ្នែកសន្តិសុខត្រួតគ្នាពីរ។ អង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាមានទំនួលខុសត្រូវផ្សេងៗគ្នាដែលបំពេញគ្នាទៅវិញទៅមកដើម្បីជានាថាគ្រប់ទិដ្ឋភាពនៃសន្តិសុខនិងសុវត្ថិភាពត្រូវបានគ្របដណ្តប់។នេះតម្រូវឱ្យមានការសម្របសម្រួលយ៉ាងជិតស្និតនិងកិច្ចសហប្រតិបត្តិការរវាងប្រធានផ្នែក។ ក្រុមការងារជាតិត្រូវបានដឹកនាំដោយឧត្តមសេនីយ៍ ម៉ៅ ចាន់ដារ៉ា។ ដោយមានការសម្របសម្រួលជាមួយរាជរដ្ឋាភិបាលកម្ពុជាផ្នែកនេះទទួលខុសត្រូវចំពោះ:

- សន្តិសុខខាងក្រៅនៃបរិវេណ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
- ការរៀបចំការការពារយ៉ាងជិតស្និទ្ធសម្រាប់បុគ្គលិកកម្ពុជាដែលបានកំណត់

រដ្ឋាភិបាលក៏ទទួលខុសត្រូវចំពោះការផ្តល់សេវាឆ្លើយតបជាបន្ទាន់ដូចជា៖

- កងពន្លត់អគ្គិភ័យ
- នៅលើការគាំទ្រផ្នែកវេជ្ជសាស្ត្រនិងរថយន្តសង្គ្រោះបន្ទាន់
- ការទម្លាក់គ្រាប់បែក
- ការផ្តល់ជូនប៉ូលីសជាការចាំបាច់សម្រាប់ការការពារច្បាប់និងសណ្តាប់ធ្នាប់នៅលើបរិវេណ
- ប្រតិកម្មរហ័សចំពោះភាពអាសន្នផ្សេងទៀត

រដ្ឋាភិបាលទទួលខុសត្រូវបន្ថែមទៀតចំពោះសុវត្ថិភាពនិងសន្តិសុខរបស់សាក្សីទាំងអស់និងការគ្រប់គ្រងសុវត្ថិភាពនិងសន្តិសុខរបស់ជនជាប់ចោទ។ ក្រុមការងារអន្តរជាតិត្រូវបានដឹកនាំដោយលោក Sassan Rahimi ក្រោមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ផ្នែកនេះទទួលខុសត្រូវចំពោះ៖

- សុវត្ថិភាពផ្ទៃក្នុងនិងសន្តិសុខរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលរួមបញ្ចូលការគ្រប់គ្រង ការគ្រប់គ្រងកងកម្លាំង ការគ្រប់គ្រងការត្រួតពិនិត្យសុវត្ថិភាព និងសន្តិសុខសុវត្ថិភាពរាងកាយអគ្គីភ័យ និងសុវត្ថិភាពសន្តិសុខតុលាការ ។
- ការគ្រប់គ្រងហានិភ័យសន្តិសុខសុវត្ថិភាពព័ត៌មាន ប្រតិបត្តិការអគ្គសញ្ញាណប័ណ្ណ និងប្រតិបត្តិការមជ្ឈមណ្ឌលគ្រប់គ្រងសុវត្ថិភាព។
- ការរៀបចំការការពារយ៉ាងជិតស្និទ្ធសម្រាប់បុគ្គលិកអន្តរជាតិដែលបានកំណត់។

អង្គការសហប្រជាជាតិបានផ្តល់នូវបុគ្គលិកអន្តរជាតិសម្រាប់មុខតំណែងសន្តិសុខដែលមានការចាត់ចែងដូចជាប្រតិបត្តិការសន្តិសុខអគារសុវត្ថិភាព បន្ទប់សវនាការ ប្រតិបត្តិការមជ្ឈមណ្ឌលសុវត្ថិភាពសន្តិសុខ

ព័ត៌មាន ការស៊ើបអង្កេត និងការការពារយ៉ាងជិតស្និទ្ធ។ ដើម្បីជួយដល់អង្គការសហប្រជាជាតិក្នុងការបំពេញភារកិច្ចរបស់ខ្លួនការទទួលខុសត្រូវផ្នែកសន្តិសុខបុគ្គលិកសន្តិសុខកម្ពុជា ត្រូវបានជួលដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងតួនាទីដូចជាឆ្មាំសន្តិសុខ មន្ត្រីអគ្គីភ័យ និងសុវត្ថិភាព និងប្រតិបត្តិករគ្រប់គ្រងផ្នែកសុវត្ថិភាព។

### ២.២.២. ផ្នែកបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង

ដឹកនាំដោយបុគ្គលិកអន្តរជាតិមួយរូបគឺលោក Soe Myint, ផ្នែកនេះមានអង្គភាពដូចខាងក្រោម៖

- **អង្គភាពសេវាប្រព័ន្ធ៖** ទទួលខុសត្រូវក្នុងការបង្កើត និងថែរក្សាបណ្ដាញតាមផ្នែកឱ្យមានប្រសិទ្ធិភាព និងសុវត្ថិភាពសំរាប់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ អង្គភាពនេះផ្ដល់ជូនរាល់សេវាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ដូចជា អ៊ីម៉ែល សេវាមូលដ្ឋានទិន្នន័យ ជាមួយនឹងបណ្ដាញផ្ទុកទិន្នន័យដែលមានសមត្ថភាពរក្សាទុកទិន្នន័យរហូតដល់បានច្រើនបំផុតរហូតដល់ 4Tb[19]។ ផ្នែកនេះក៏ទទួលខុសត្រូវផងដែរចំពោះប្រព័ន្ធបម្រុងទុកប្រចាំថ្ងៃ និងការតាមដានប្រតិបត្តិការបណ្ដាញដោយសុវត្ថិភាព ។
- **អង្គភាពសេវាទំនាក់ទំនង៖** ទទួលខុសត្រូវក្នុងការថែរក្សាស្ថានីយផ្កាយរណបលើដី ដែលផ្ដល់ជូននូវការសន្ទនាអន្តរជាតិ ទិន្នន័យ និងសេវាសន្និសីទវីដេអូសំរាប់ កិច្ចប្រជុំសហប្រតិបត្តិការអន្តរជាតិ និងការធ្វើសក្ខីកម្មសាក្សីពីចំងាយ ។ អង្គភាពនេះទទួលខុសត្រូវ ចំពោះការផ្ដល់ជូន និងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធទំនាក់ទំនង និងឧបករណ៍បរិក្ខាសំរាប់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងបុគ្គលិករបស់ខ្លួនផងដែរ។
- **អង្គភាពសេវាអតិថិជន៖** ទទួលខុសត្រូវចំពោះការបែងចែកធនធាន បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ ដោយអនុលោមតាម តម្រូវការរបស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងការដោះស្រាយបញ្ហានានា ដែលទាក់ទងនឹងប្រតិបត្តិការកុំព្យូទ័រលើតុនិង ការបញ្ចូលកម្មវិធីកុំព្យូទ័រ។ អង្គភាពផ្ដល់ នូវបរិក្ខាបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ជាមួយនឹងកម្មវិធីប្រតិបត្តិការសមស្របដូចជា Case Matrix, Case Map ជូនទៅការិយាល័យច្បាប់នានា ដូចជា ការិយាល័យសហចៅក្រមស៊ើបអង្កេត ការិយាល័យសហព្រះរាជអាជ្ញា និង ផ្នែកគាំទ្រមេធាវីការពារក្ដី ដើម្បីជួយគាំទ្រដល់សកម្មភាពច្បាប់របស់ពួកគេ ។ អង្គភាពនេះមាន ទំនាក់ទំនងជាមួយផ្នែក កិច្ចការសាធារណៈផងដែរ ដើម្បីបង្កើត និងថែរក្សាវែបសាយរបស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។
- **អង្គភាពសេវាគ្រប់គ្រង៖** ទទួលខុសត្រូវចំពោះការបង្កើត និងការថែរក្សាបច្ចេកវិទ្យាព័ត៌មាននិងសារគម

[19] Terabyte: Tb: https://www.eccc.gov.kh/km/node/12079

នាគមន៍ មូលដ្ឋានទិន្នន័យគ្រប់គ្រងទ្រព្យសម្បត្តិដែលគ្រប់គ្រងការបែងចែកធនធាន ព័ត៌មាននិងសារគមនាគមន៍ ទៅឱ្យអ្នកប្រើប្រាស់ ឃ្លាំងទិន្នន័យនិង ប្រព័ន្ធឯកសារ។ អង្គភាពនេះមាន ទំនាក់ទំនងជាមួយ នឹងអង្គភាពលទ្ធកម្មសំរាប់ការស្នើសុំការផ្គត់ផ្គង់ផ្នែក ច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ និងមានទំនាក់ទំនងជាមួយ នឹងផ្នែកហិរញ្ញវត្ថុ និងថវិកា សំរាប់ទិន្នន័យ ទាក់ទងនឹងកិច្ចការផ្សេងៗនិងការចំណាយសំរាប់ថ្លៃទំនាក់ទំនងសំរាប់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

## ២.៣. អង្គភាពគាំពារជនរងគ្រោះ

អង្គភាពគាំពារជនរងគ្រោះជូនដំណឹងដល់ ជនរងគ្រោះអំពីសិទ្ធិរបស់ពួកគាត់ពាក់ព័ន្ធនឹងការចូលរួម និង ការទាមទារសំណង ហើយជួយពួកគាត់ក្នុងការដាក់ពាក្យបណ្តឹងនិងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៅអង្គជំនុំជំម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រសិនបើពួកគាត់មាន ចេតនាធ្វើបៀបនេះ។ (សម្រាប់ព័ត៌មានលម្អិត សូមមើលក្នុងសេចក្តីណែនាំអនុវត្តន៍ស្តីពីការចូលរួមរបស់ជនរងគ្រោះ) សេចក្តីណែនាំនេះបញ្ជាក់អំពីការផ្តល់ដំបូន្មានផ្នែកច្បាប់ ឬការផ្តល់មេធាវីការគាំទ្រដល់តំណាង ផ្នែកច្បាប់និងជួយសម្រួលដល់ការរៀបចំជាក្រុមនៃជនរងគ្រោះនិងការតំណាងជាសមូហភាព [20] ។ អង្គភាពគាំពារជនរងគ្រោះជួយគាំទ្រដល់ការងាររបស់សហព្រះរាជអាជ្ញា និងសហចៅក្រម ស៊ើបអង្កេតដោយជួយរៀបចំទិន្នន័យពាក្យបណ្តឹងនិងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនិងការរៀបចំរបាយការណ៍ជូនការិយាល័យទាំងពីរនេះ។ អង្គភាពគាំពារជនរងគ្រោះក៏រក្សាទំនាក់ទំនងជាមួយជនរងគ្រោះនិងមេធាវីរបស់ពួកគាត់ ពាក់ព័ន្ធនឹង ស្ថានភាពនៃពាក្យបណ្តឹង និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគាត់ និងផ្តល់ព័ត៌មានថ្មីៗដល់ជនរងគ្រោះអំពីការវិវឌ្ឍផ្សេងៗក្នុងរឿងក្តីនីមួយៗ។ អង្គភាពគាំពារជនរងគ្រោះធានាថា ភារកិច្ចរបស់ខ្លួននិងសិទ្ធិរបស់ជនរងគ្រោះត្រូវបានពន្យល់បកស្រាយនៅក្នុងសកម្មភាពផ្សព្វផ្សាយនៅទូទាំងប្រទេស។ ចុងក្រោយគេបង្អស់អង្គភាពគាំពារ ជនរងគ្រោះត្រូវធានាអំពីសុវត្ថិភាព និងសុខុមាលភាពរបស់ជនរងគ្រោះដែលចូលរួមក្នុង ដំណើរការនីតិវិធី។ កិច្ចការនេះរួមមានអង្គភាពគាំពារជនរងគ្រោះត្រូវធានាថា ជនរងគ្រោះបានយល់ច្បាស់អំពីហានិភ័យនានា ដែលអាចកើតឡើងពីការចូលរួមរបស់ពួកគាត់ក៏ដូចជាផ្តល់ជូនពួកគាត់នូវវិធានការការពារ និងទម្រង់នៃការជួយផ្សេងៗទៀត ដូចជាការគាំទ្រផ្លូវចិត្តជាដើម។

### ២.៣.១. អង្គភាពគាំពារការការពារក្តី

តួនាទីរបស់អង្គភាពគាំពារការការពារក្តីគឺធានាការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ តាមរយៈការការពារជនជាប់ចោទប្រកបដោយប្រសិទ្ធិភាព។ អង្គភាពគាំពារការការពារក្តីទទួលខុសត្រូវផ្តល់ដល់ជនជាប់ចោទដែលក្រីក្រនូវបញ្ជីរឈ្មោះមេធាវីដែលអាចការពារពួកគេ និងផ្តល់ជំនួយផ្នែកច្បាប់និងកិច្ចគាំពារផ្នែករដ្ឋបាល

[20] វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា, វិធាន១២: អង្គភាពគាំពារជនរងគ្រោះ (វិសោធនកម្មលើកទី៩ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥)

ដល់មេធាវីដែលចាត់តាំងការពារក្តី រួមទាំងការផ្តល់ប្រាក់កម្រៃផងដែរ។ អង្គភាពនេះក៏មានតួនាទីបញ្ចេញសំឡេងតំណាងអង្គភាពគាំពារការការពារក្តីនៅក្នុងវេទិកាសាធារណៈនៅក្នុងបណ្តាញសារពត៌មាន ក្នុងទំនាក់ទំនងជាមួយស្ថាប័នតុលាការដទៃទៀត និងជាមួយអង្គការក្រៅរដ្ឋាភិបាល និងរៀបចំវគ្គបណ្តុះបណ្តាលនិងកម្មវិធីហ្វឹកហាត់ការងារសម្រាប់មេធាវីដែលទើបនឹងបញ្ចប់ការសិក្សា។ អង្គភាពគាំពារការការពារក្តីមានបុគ្គលិកជាមេធាវីព្រហ្មទណ្ឌជាតិនិងអន្តរជាតិដែលមានបទពិសោធន៍ព្រមទាំងបុគ្គលិកជំនួយការរដ្ឋបាល ជំនួយការភាសា និងអ្នកហ្វឹកហាត់ការងារ[21]។

### ២.៣.២. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ផ្នែកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបង្កើតឡើងដោយអនុលោមតាមវិធាន ១២ និងវិធាន ១២ ស្ទួន នៃវិធានផ្ទៃក្នុងរបស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ វាមានភាពស្វយ័តទាក់ទងនឹងបញ្ហាសំខាន់ៗដែលទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី។ មានសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីម្នាក់និងជនជាតិខ្មែរម្នាក់ ហើយពួកគេត្រូវបានគាំទ្រដោយមន្ត្រីច្បាប់និងអ្នកគ្រប់គ្រងសំណុំរឿង។ ពួកគេត្រូវធ្វើសកម្មភាពរួមគ្នាក្នុងគ្រប់ករណីទាំងអស់លុះត្រាតែពួកគេបានសម្រេចចិត្ត រួមគ្នាប្រគល់សិទ្ធិដល់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីដោះស្រាយបញ្ហាណាមួយ។

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវធានា ឱ្យមានការរៀបចំឱ្យមានប្រសិទ្ធិភាពតំណាងតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណាក់កាលជំនុំជម្រះនិងដំណាក់កាលជំនុំជម្រះ។ ពួកគេមានការទទួលខុសត្រូវខ្ពស់ចំពោះតុលាការសម្រាប់ការតស៊ូមតិទូទៅយុទ្ធសាស្ត្រ និងការបង្ហាញនៅក្នុងតុលាការនៃផលប្រយោជន៍របស់ក្រុមដើមបណ្តឹងរដ្ឋប្បវេណីរួមគ្នាក្នុងដំណាក់កាលជំនុំជម្រះនិងលើសពីនេះ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបំពេញភារកិច្ចរបស់ខ្លួន ដោយការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី[22]។

---

[21] វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា, វិធាន១១: អង្គភាពគាំពារការការពារក្តី (វិសោធនកម្មលើកទី៩ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥)

[22] វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា, វិធាន១២ស្ទួន: សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (វិសោធនកម្មលើកទី៩ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥)

# ជំពូកទី៣

# សំណុំរឿងក្នុង

# អង្គជំនុំជម្រះវិសាមញ្ញ

# ក្នុងតុលាការកម្ពុជា

# ជំពូកទី៣
# សំណុំរឿងក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ១. សំណុំរឿង ០០១

### ១.១. ជនជាប់ចោទ

សំណុំរឿង០០១ ជាសំណុំរឿងដំបូងគេបង្អស់ដែលបានយកមកជំនុំជម្រះនៅអ.វ.ត.ក ។ ជនជាប់ចោទដែលស្ថិតនៅក្នុងសំណុំរឿង០០១ នោះគឺលោក **កាំង ហ្កេកអ៊ាវ** ឬហៅឌុច ដែលមានមុខងារជា អតីតប្រធានមន្ទីរស-២១ ក្នុងទីក្រុងភ្នំពេញ បច្ចុ១«ប្បន្ននេះជាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង។

គួរបញ្ជាក់ផងដែរថា ឌុច កើតនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤២ មានស្រុកកំណើតនៅភូមិពៅវើយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ។ លោកជាកូនកាត់ចិន មានបងប្អូនបង្កើត ៥នាក់ នៅក្នុងត្រកូលជាកសិករក្រីក្រ។ បន្ទាប់ពីប្រឡងជាប់បាក់អង នៅកំពង់ធំ លោកបានមករៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិ ហើយបានស្នាក់នៅវត្តឧណ្ណាឡោម។ នៅឆ្នាំ១៩៦៤ លោកបានប្រឡងជាប់បាក់ឌុប ដោយជាប់ជាសិស្សឆ្នើមទូទាំងប្រទេសផ្នែកគណិតវិទ្យា ហើយក្រោយមកលោកបានទៅចូលរៀននៅវិទ្យាស្ថានគរុកោសល្យ នៅជិតវិមានឯករាជ្យ និងជួបលោក សុន សេន ដែលពេលនោះជានាយកវិទ្យាស្ថាន ហើយដែលក្រោយមកបានក្លាយជារដ្ឋមន្ត្រីក្រសួងការពារជាតិនៃរបបខ្មែរក្រហម។

នៅឆ្នាំ១៩៦៧ នៅពេលធ្វើជាគ្រូបង្រៀននៅកំពង់ធំ កាំង ហ្កេចអ៊ាវ ក៏បានចូលជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា ហើយបានស្គាល់ ទង់ សេងហឿន ដែលក្រោយមកបានក្លាយទៅជាជំនួយការរបស់ ឌុច នៅគុកទួលស្លែង។ នៅឆ្នាំដដែលនោះ កាំង ហ្កេចអ៊ាវ ត្រូវបានប៉ូលិសនៃរដ្ឋាភិបាលសង្គមរាស្ត្រនិយមចាប់ខ្លួន យកទៅដាក់គុកព្រៃស នៅភ្នំពេញ។ នៅក្នុងគុក កាំង ហ្កេចអ៊ាវ បានជួបជាមួយ ម៉ម ណៃ ហៅ ចាន់ ដែលក្រោយមកបានក្លាយទៅជាអនុប្រធានរបស់ ឌុច នៅគុកទួលស្លែង។

នៅឆ្នាំ១៩៧០ ក្រោយពីត្រូវបានគេដោះលែងពីពន្ធនាគារ កាំង ហ្កេចអ៊ាវ បានរត់ទៅចូលរួមតស៊ូជាមួយខ្មែរក្រហម នៅក្នុងព្រៃ ស្ថិតនៅតាមបណ្ដោយជួរភ្នំក្រវាញ។ កាំង ហ្កេចអ៊ាវ បានចាប់ផ្ដើមប្រើឈ្មោះបដិវត្តន៍ថា ឌុច ហើយត្រូវបាន វ៉ន វ៉េត តែងតាំងឱ្យធ្វើជាមេគុក ដែលមានលេខសម្ងាត់ថា ម១៣ ស្ថិតនៅឃុំអមលាំង ខេត្តកំពង់ស្ពឺ។ ក្រោយមក ឌុច បានបង្កើតគុកមួយទៀត ដែលមានលេខសម្ងាត់ថា ម៩៩ ស្ថិតនៅជើងភ្នំឱរ៉ាល់។

ក្រោយពេលដែលខ្មែរក្រហមបានឡើងកាន់អំណាច នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ឌុច ត្រូវបានតែងតាំងឱ្យធ្វើជាប្រធានមន្ទីរសន្តិសុខ ស២១ ហៅ គុកទួលស្លែង នៅក្រុងភ្នំពេញ។ យោងតាមឯកសារនៅគុកទួលស្លែង ដែលបច្ចុប្បន្នរក្សាទុកដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ថ្នាក់លើរបស់ ឌុច គឺ សុន សេន ហៅខៀវ អតីតគ្រូបង្រៀនរបស់ ឌុច នៅវិទ្យាស្ថានគរុកោសល្យ និង នួន ជា ហៅ បងនួន អនុលេខាបក្សកុម្មុយនីស្ត

កម្ពុជា។ នៅក្នុងឯកសារទាំងនេះ គេឃើញមានហត្ថលេខារបស់ ឌុច លើកំណត់ហេតុបញ្ជូនទៅថ្នាក់លើ និងចំណាររបស់ ឌុច បញ្ជាឱ្យអ្នកនៅក្រោមបង្គាប់ ធ្វើទារុណកម្ម និងសម្លាប់អ្នកទោសជាដើម។

នៅឆ្នាំ១៩៩៩ អ្នកកាសែតបរទេសពីររូប គឺ Nate Thayer និង Nic Dunlop បានទៅជួបសម្ភាសន៍ជាមួយ ឌុច។ ក្រោយពីបទសម្ភាសន៍នេះត្រូវបានចុះផ្សាយនៅក្នុងទស្សនាវដ្ដីសេដ្ឋកិច្ចចុងបូព៌ា ឌុច ក៏បានចូលសារភាព ប្រគល់ខ្លួនឱ្យអាជ្ញាធររដ្ឋាភិបាលកម្ពុជា[23]។

## ១.២. នីតិវិធីនៃបណ្ដឹង

លោក កាំង ហ្គេកអ៊ាវ ត្រូវបានសមត្ថកិច្ចយោធាកម្ពុជាចាប់ខ្លួន និងឃុំខ្លួនជនជាប់ចោទនៅពន្ធនាគារតុលាការយោធាក្រុងភ្នំពេញនាថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩។ ជនជាប់ចោទត្រូវបានចោទប្រកាន់ដោយតុលាការយោធាកម្ពុជាពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិសុខជាតិ បទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងជនដែលត្រូវទទួលបានការការពារ[24]។ យ៉ាងណាមិញការឃុំខ្លួនបណ្ដោះអាសន្នចំពោះរូបលោក ត្រូវបានបន្តក្រោមយុត្តាធិការរបស់តុលាការយោធា រហូតដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ លោក កាំង ហ្គេកអ៊ាវ ត្រូវបានបញ្ជូនពីមន្ទីរឃុំឃាំងតុលាការយោធាមកមន្ទីរឃុំឃាំងបណ្ដោះអាសន្នរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ស្របតាមដីកាបង្គាប់របស់សហចៅក្រមស៊ើបអង្កេត។ ប៉ុន្តែនាថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៨ លោកត្រូវចោទបានបញ្ជូនទៅជំនុំជម្រះដោយសហចៅក្រមស៊ើបអង្កេត។

ការចាប់ផ្ដើមនៅសវនាការបឋមនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងទៅលើ ឌុច ត្រូវបានចាប់ដំណើរការនៅថ្ងៃទី ១៧ និង ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៩។ សវនាការនេះពិចារណាលើបញ្ហាអញ្ញត្រកម្មដែលលើកឡើងដោយមេធាវីការពារក្ដី សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំដាក់ភស្តុតាងថ្មី វិធានការពារ និងភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ មេធាវីការពារក្ដីរបស់ជនជាប់ចោទបានដាក់អញ្ញត្រកម្មមួយដោយបញ្ជាក់ថាការចោទប្រកាន់ទៅលើជនជាប់ចោទ អនុលោមតាមមាត្រា ៥០០ មាត្រា ៥០៦ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ស្ដីអំពីបទធ្វើទារុណកម្ម និងបទមនុស្សឃាតនោះមិនអាចធ្វើទៅបាន ព្រោះចិរវេលាអាជ្ញាយុកាលបានផុតរលត់ទៅហើយ។ អង្គជំនុំជម្រះសាលាដំបូងបានជម្រាបថា សេចក្ដីសម្រេចលើអញ្ញត្រកម្មនោះ នឹងចេញនៅពេលដំណាលគ្នា ជាមួយសាលក្រមលើអង្គសេចក្ដី។

សវនាការអង្គសេចក្ដីរបស់អង្គជំនុំជម្រះសាលាដំបូង បានចាប់ផ្ដើមនៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៩ និងការដាក់បង្ហាញភស្តុតាង ត្រូវបានបញ្ចប់នៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០៩។ ក្នុងអំឡុងពេល ៧២ ថ្ងៃ នៃថ្ងៃសវនាការដាក់បង្ហាញភស្តុតាងនេះផងដែរ សាក្សីជំនាញ ៩ រូប សាក្សី ១៧ រូប សាក្សីអត្តចរិត ៧ រូប និងដើម

[23] សេង ឌីណា (០៣ កុម្ភៈ ២០១២), វិទ្យុអាស៊ីសេរី

[24] សេចក្ដីសម្រេចនៃសំណុំរឿង ០០១ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១០

បណ្តឹងរដ្ឋប្បវេណីចំនួន ២២ រូប បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ក្នុងអំឡុងពេលនៃការជំនុំជម្រះនេះ អង្គជំនុំជម្រះពិនិត្យមើលលើប្រធានបទសំខាន់ៗចំនួន ៧ ទាក់ទងនឹងកិច្ចដំណើរការនីតិវិធីដែលទាក់ទងទៅនឹងបញ្ហាដូចជា៖

- បញ្ហាទាក់ទងទៅនឹងមន្ទីរម១៣;
- ការបង្កើតមន្ទីរស២១ និងពន្ធនាគារតាខ្មៅ
- ការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅស២១
- ជម្លោះប្រដាប់អាវុធ
- ប្រតិបត្តិការរបស់មន្ទីរស២១ រួមទាំងសារៈមន្ទីរវាលពិឃាតបឹងជើងឯក;
- ការបង្កើតនិងដំណើរការរបស់ស២៤;
- បញ្ហាពាក់ព័ន្ធនឹងអត្តចរិតរបស់ជនជាប់ចោទ។

សវនាការនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង បានបញ្ចប់ដោយមានការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរយៈពេល៥ថ្ងៃ ពីថ្ងៃទី ២៣ ដល់ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៩។ ឯកសារប្រហែល ១.០០០ ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះនិងត្រូវបានដាក់ឱ្យពិនិត្យ។ ដែលមនុស្សជាង ៣១ ០០០ នាក់បានតាមដានដំណើរការនីតិវិធីនៅអគារតុលាការ។

### ១.៣. សាលដីកាសម្រេច

ក្រោយពីអង្គជំនុំជម្រះលើឧក្រិដ្ឋកម្មដែល ឌុច បានប្រព្រឹត្តសាលាដំបូងបានផ្តន្ទាទោសអោយ ឌុច ជាប់ពន្ធនាគាររយៈពេល៣៥ឆ្នាំ និងបានបន្ថយទោសជាប់ពន្ធនាគារទៅលើគាត់រយៈពេល៥ឆ្នាំ ជាការទូទាត់សងការឃុំខ្លួនមិនប្រក្រតីនៅមន្ទីរឃុំឃាំងរបស់ តុលាការយោធាកម្ពុជាពីខែ ឧសភា ឆ្នាំ ១៩៩៩ ដល់ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៧។

លើសពីនេះទៅទៀត អង្គជំនុំជម្រះសាលាដំបូងបានទទួលយកអ្នកដាក់ពាក្យសុំចំនួន ៦៤ រូប ក្នុងចំណោមអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៩០ នាក់ជាដើមបណ្តឹងរដ្ឋប្បវេណីហើយបានផ្តល់សំណងដូចតទៅ:

- ការបញ្ចូលឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី ដែលបានទទួលស្គាល់និងសមាជិកគ្រួសារដែលបានស្លាប់របស់ពួកគេនៅក្នុងសាលក្រម។
- អង្គជំនុំជម្រះសាលាដំបូងក៏បានបង្គាប់ឱ្យចងក្រងនិងផ្សព្វផ្សាយនូវរាល់ការសុំទោសនិងការទទួលខុសត្រូវដែលធ្វើឡើងដោយឌុច។

សហព្រះរាជអាជ្ញា និងកាំង ហ្គេកអ៊ាវ បានដាក់បណ្ដឹងសាទុក្ខទៅកាន់តុលាការកំពូល។ ដើមបណ្ដឹងរដ្ឋប្បវេណីក៏បានដាក់បណ្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអំពីសំណង និងភាពទទួលយកបាននៃអ្នកដាក់ពាក្យតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែរ។

នាថ្ងៃទី ២៨ ដល់ថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០១១ អង្គជំនុំជម្រះតុលាការកំពូលបានបើកសវនាការផ្ទាល់មាត់នៅក្នុងបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង០០១ និង ថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសសេចក្ដីសម្រេចរបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍ ។

ការផ្ដល់បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញានោះបានធ្វើឱ្យមានការកាត់ទោស ៣៥ ឆ្នាំដែលអង្គជំនុំជម្រះសាលាដំបូងបានចេញកាលពីថ្ងៃទី ៦ ខែកក្កដា ឆ្នាំ ២០១០ មកជាកាត់ទោសលោកឱ្យជាប់គុកអស់មួយជីវិត។ តាមសេចក្ដីសំរេចភាគច្រើនលើសពីនេះតុលាការកំពូល បានបដិសេធសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងឱ្យផ្ដល់សំណង តាមទម្រង់នៃការកាត់ទោស កាំង ហ្គេកអ៊ាវ ដល់ ៥ឆ្នាំ ដោយសារតែលោកបានចំណាយពេលឃុំខ្លួនដោយខុសច្បាប់ដោយយោធាកម្ពុជា។ អង្គជំនុំជម្រះតុលាការកំពូលក៏បានច្រានចោលបណ្ដឹងឧទ្ធរណ៍របស់ ឌុច ដែលក្នុងនោះលោកបានចោទប្រកាន់ថាលោកមិនមែនស្ថិតនៅក្នុងដែនសមត្ថកិច្ចផ្ទាល់របស់តុលាការនោះទេ។

តុលាការកំពូលបានលើកឡើងថាអង្គជំនុំជម្រះសាលាដំបូង បានប្រព្រឹត្តខុសដោយច្បាប់ដោយមិនមានទម្ងន់គ្រប់គ្រាន់ចំពោះភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មកាំងហ្គេកអ៊ាវ ក៏ដូចជាកាលៈទេសៈកាន់តែធ្ងន់ធ្ងរនៅក្នុងករណីនេះហើយថាទម្ងន់ច្រើនពេកត្រូវបានគេភ្ជាប់ទៅនឹងកាលៈទេសៈបន្ធូរបន្ថយ។

អង្គជំនុំជម្រះតុលាការកំពូល ក៏បានផ្ដល់បណ្ដឹងសាទុក្ខប្រឆាំងនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ១០ នាក់ដែលត្រូវបានបដិសេធដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសាលក្រមជំនុំជម្រះ។ នៅលើបណ្ដឹងឧទ្ធរណ៍ដើមបណ្ដឹងរដ្ឋប្បវេណីទាំងនេះបានបញ្ជាក់ពីពាក្យសុំរបស់ខ្លួន ហើយត្រូវបានទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០១ ។ អង្គជំនុំជម្រះតុលាការកំពូលក៏សម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលទាក់ទងនឹងអង្គជំនុំជម្រះសាលាដំបូងផងដែរដោយសម្រេចលើសំណើសុំសំណងសមូហភាពនិងសំណងផ្លូវចិត្ត។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ពីការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការចងក្រងនិងចុះផ្សាយចម្លើយទាំងអស់នៃការសុំទោសនិង ការទទួលខុសត្រូវដែលបានធ្វើឡើងដោយឌុចក្នុងដំណើរការនីតិវិធីរបស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅលើគេហទំព័រ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

បន្ទាប់ពីការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលនៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ដែលបានបញ្ជាក់និងធ្វើវិសោធនកម្មផ្នែកខ្លះនៃសាលដីការបស់អង្គជំនុំជម្រះសាលាដំបូង និងបានចេញសេចក្ដីសម្រេចលើការ

កាត់ទោស លោក កាំង ហ្កេកអ៊ាវ ដោយបានរកឃើញថាមានទោសយោងតាមមាត្រា៥, ៦ និង ២៩ នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៃឧក្រិដ្ឋកម្មដូចតទៅនេះដែលប្រព្រឹត្តនៅរាជធានីភ្នំពេញ និងនៅលើទឹកដីនៃប្រទេសកម្ពុជាចន្លោះថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែមករា ឆ្នាំ ១៩៧៩៖

- ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ
    - ការសម្លាប់រង្គាល
    - ការធ្វើឱ្យទៅជាទាសករ
    - ការដាក់ក្នុងមន្ទីរឃុំឃាំង
    - ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗ
- ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ លើឧក្រិដ្ឋកម្មមួយចំនួនដូចជា៖
    - ការធ្វើមនុស្សឃាតដោយចេតនា
    - ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌
    - ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរឬឱ្យមានការឈឺចាប់លើរាងកាយ ឬសុខភាព
    - ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបាន ការកាត់ទោសដោយយុត្តិធម៌ និងទៀតទាត់
    - ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់

ជារួម ក្នុងកំឡុងពេលសវនការរយៈ ៨០ ថ្ងៃ នៃសំណុំរឿង ០០១ នេះ ប្រជាជនចំនួន ៣៦ ៤៩៣ នាក់បានចូលរួមក្នុងសវនាការ និងសវនាការខុទ្ទរណ៍។ ហើយឌុចបានចាប់ផ្តើមអនុវត្តទោសនៅក្នុងពន្ធនាគារក្នុងមន្ទីរឃុំខ្លួន អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចាប់នៅឆ្នាំ ២០១២ ហើយត្រូវបានបញ្ជូនទៅពន្ធនាគារខេត្តកណ្តាលកាលពីខែមិថុនា ឆ្នាំ ២០១៣ ដើម្បីបំពេញកិច្ចការដែលនៅសេសសល់របស់លោក។ ប៉ុន្តែនាថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០២០ ឌុច បានបាត់បង់ជីវិតក្នុងជន្មាយុ ៧៧ ឆ្នាំដោយសារជម្ងឺមហារីកសួតនៅឯមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត[25]។

## ២. សំណុំរឿង ០០២

### ២.១. ជនជាប់ចោទ

សំណុំរឿង ០០២ មានលក្ខណៈខុសពីសំណុំរឿង ០០១ ដោយមានជនជាប់ចោទចំនួន ៤ រូប ដែលអ្នកទាំងបួនត្រូវបានបញ្ជូនខ្លួនមកជំនុំជម្រះ ពីបទចោទទាំងឡាយពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

[25] Seth Mydans (ថ្ងៃ០២ ខែកញ្ញា ឆ្នាំ២០២០), The New York Times

អំពើប្រល័យពូជសាសន៍ និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០។ ជនជាប់ចោទទាំង ៤ រូបមានដូចជា៖

**២.១.១. នួន ជា**

នួន ជា ជាអនុលេខាបក្សកុម្មុយនីស្ត ហើយត្រូវបានគេគ្រប់គ្នាស្គាល់ថាជា "បងទីពីរ" បន្ទាប់ពី ប៉ុល ពត។ លោកមានឈ្មោះដើមថា ឡុង ប៊ុនរួត កើតនៅឆ្នាំ ១៩២៦ នៅឯភូមិវត្តគរ ក្នុងខេត្តបាត់ដំបង។ នៅក្នុងអំឡុងសង្គ្រាមលោកលើកទី២ ខេត្តបាត់ដំបង ត្រូវបានថៃដណ្តើមយកទៅកាន់កាប់ អ្នកស្រុកបាត់ដំបងទាំងអស់ រួមទាំង នួន ជា ផង ត្រូវបានរដ្ឋាភិបាលថៃ ផ្តល់សញ្ជាតិជាថៃ ហើយលោកក៏បានចេញពីស្រុកកំណើតទៅបន្តការសិក្សានៅទីក្រុងបាងកក ។ នៅឆ្នាំ១៩៤៥ នួន ជា បានប្រឡងជាប់សញ្ញាប័ត្របាក់ឌុប ហើយបានបន្តការសិក្សាផ្នែកច្បាប់ នៅសាកលវិទ្យាល័យធម្មសាត ប្រទេសថៃ។ ក្រោយមក នួន ជា បានទៅធ្វើការជាស្មៀននៅក្រសួងការបរទេសថៃ ហើយបានចូលជាសមាជិកបក្សកុម្មុយនីស្តថៃ។ ការណ៍ដែល នួន ជា សម្រេចចិត្តចូលក្នុងបក្សកុម្មុយនីស្តថៃនេះប្រហែលជាមកពីគាត់ទទួលឥទ្ធិពលពីបងជីដូនមួយរបស់គាត់ គឺ សៀវ ហេង ដែលបានចូលជាសមាជិកបក្សកុម្មុយនីស្តឥណ្ឌូចិន នៅក្នុងអំឡុងពេលជាមួយគ្នានោះ។ ប៉ុន្តែនៅឆ្នាំ ១៩៥០ នួន ជា បានសុំផ្ទេរសមាជិកភាពពីបក្សកុម្មុយនីស្តថៃ ទៅបក្សកុម្មុយនីស្តឥណ្ឌូចិនវិញ។ នួន ជា ក៏បានចេញពីបាងកកចូលមកខេត្តបាត់ដំបងវិញ ដើម្បីចូលរួមក្នុងចលនាតស៊ូ ដឹកនាំដោយបក្សកុម្មុយនីស្តឥណ្ឌូចិន។

នៅចន្លោះពីឆ្នាំ១៩៥២ ដល់ឆ្នាំ១៩៥៤ នួន ជា ត្រូវបានបក្សកុម្មុយនីស្តឥណ្ឌូចិនបញ្ជូនឱ្យទៅរៀនសូត្រខាងនយោបាយនៅក្រុងហាណូយ ប្រទេសវៀតណាម។ នៅពេលមានការចុះកិច្ចព្រមព្រៀងក្រុងហ្សឺណែវ នៅថ្ងៃទី២០ កក្កដា ឆ្នាំ១៩៥៤ ក្រុមខ្មែរកុម្មុយនីស្តត្រូវបែកជាពីរ មួយក្រុមរត់ទៅវៀតណាម មួយក្រុមទៀតលាក់ខ្លួននៅប្រទេសកម្ពុជា។ នៅពេលនោះ នួន ជា មិនទាន់ត្រឡប់ពីប្រទេសវៀតណាមវិញ នៅឡើយទេ។ រហូតដល់ចុងឆ្នាំ១៩៥៤ ទើប នួន ជា វិលត្រឡប់ពីប្រទេសវៀតណាមវិញ ហើយបានទៅចូលរួមធ្វើការជាមួយក្រុមខ្មែរកុម្មុយនីស្ត ដែលនៅលាក់ខ្លួនក្នុងទីក្រុងភ្នំពេញ។ នៅពេលនោះហើយ ដែល នួន ជា បានជួបជាមួយ សាឡុត ស ឬ ប៉ុល ពត។

នៅពេលនោះ នួន ជា ធ្វើការក្រោមបញ្ជាផ្ទាល់របស់ សៀវ ហេង ដែលត្រូវជាបងជីដូនមួយរបស់គាត់ និងជាលេខាបក្សប្រជាជនបដិវត្តន៍ខ្មែរ ទទួលបន្ទុកគ្រប់គ្រងបណ្តាញជនបទ។ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ ទូ សាមុត ត្រូវបានមហាសន្និបាតបក្សបោះឆ្នោតឱ្យធ្វើជាលេខាបក្សជំនួស សៀវ ហេង ដែលបានផ្តាច់ខ្លួនទៅចុះចូលជាមួយសម្តេច នរោត្តម សីហនុ។ នួន ជា ក៏បានឡើងកាន់តំណែងជាអនុលេខាបក្សប្រជាជនបដិវត្តន៍ខ្មែរ ដែលជាតំណែងកំពូលលំដាប់ទីពីរ បន្ទាប់ពី ទូ សាមុត។ នួន ជា បានកាន់តំណែងជាអនុលេខាបក្សកុម្មុយនីស្ត រហូតដល់ពេលដែលគាត់បានផ្តាច់ខ្លួនចុះចូលជាមួយរដ្ឋាភិបាលកម្ពុជា នៅខែធ្នូ ឆ្នាំ១៩៩៨។

នៅថ្ងៃទី២០ កក្កដា ឆ្នាំ១៩៦២ ទូ សាមុត លេខាបក្សពលករកម្ពុជា ដែលជាឈ្មោះដើមរបស់បក្សកុម្មុយនីស្តកម្ពុជា បានបាត់ខ្លួនដោយមិនដឹងមូលហេតុពិតប្រាកដ។ នួន ជា ដែលពេលនោះ គឺជាអនុលេខាបក្សស្រាប់ គួរតែជាអ្នកឡើងមកកាន់តំណែងជាលេខាបក្សស្តីទីជំនួស ទូ សាមុត។ ផ្ទុយទៅវិញបែរជា ប៉ុល ពត ដែលស្ថិតនៅលំដាប់ទីបីឯណោះទៅវិញ ដែលជាអ្នកឡើងវំលង នួន ជា មកធ្វើជាលេខាបក្សស្តីទី។ នៅក្នុងមហាសន្និបាតបក្ស នៅខែកុម្ភៈ ឆ្នាំ១៩៦៣ ប៉ុល ពត ក៏បានជាប់ឆ្នោតជាលេខាបក្សពេញសិទ្ធិ។ ក្នុងសៀវភៅដែលមានចំណងជើងថា "បងទីមួយប៉ុល ពត" លោក David Chandler បានសរសេរថា នួន ជា មិនអាចកាន់តំណែងនោះបានដោយសារនៅពេលនោះ មានលេចឮព័ត៌មានចោទប្រកាន់ នួន ជា ថាមានជាប់ពាក់ព័ន្ធជាមួយ សៀវ ហេង ដែលជាបងជីដូនមួយរបស់ នួន ជា និងជាអតីតលេខាបក្សកុម្មុយនីស្ត ដែលបានទៅចុះចូលជាមួយសម្តេច នរោត្តម សីហនុ។ ព័ត៌មានដែលឮតៗគ្នា ក្នុងចំណោមមន្ត្រីថ្នាក់ដឹកនាំបក្សកុម្មុយនីស្តនៅពេលនោះគឺទាក់ទងនឹងការណ៍ដែល នួន ជា ធ្លាប់បានទទួលលុយកាក់ពី សៀវ ហេង។ ក្រោយពីមានព័ត៌មានចចាមអារាមនេះ នួន ជា ក៏លែងហ៊ានឈរឈ្មោះជាបេក្ខជនលេខាបក្ស ដោយដឹងថា បើទោះជាឈរឈ្មោះក៏មិនមានអ្នកណាបោះឆ្នោតឱ្យដែរ។

ក្រោយពេលដែលខ្មែរក្រហមបានឡើងកាន់អំណាច នៅឆ្នាំ១៩៧៥ នួន ជា ក៏បានក្លាយជាប្រធានសភានៃរបបកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងបក្ស នួន ជា គឺជាអ្នកទទួលខុសត្រូវក្នុងការរៀបចំអង្គការចាត់តាំងបក្ស និងទទួលបន្ទុកកិច្ចការអប់រំផ្នែកនយោបាយ និងមនោគមន៍វិជ្ជា។ យោងតាមឯកសារដែលរក្សាទុកដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា នួន ជា គឺជាអ្នកទទួលខុសត្រូវក្នុងការចេញគោលនយោបាយឱ្យមន្ត្រីថ្នាក់មូលដ្ឋានអនុវត្តក្នុងនោះ រួមទាំងមន្ត្រីមន្ទីរ ស២១ ឬ គុកទួលស្លែងផងដែរ។

នៅថ្ងៃទី២៧ កញ្ញា ឆ្នាំ១៩៧៦ នួន ជា បានឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យ ជំនួស ប៉ុល ពត ដែលបានលាលែងដោយមានបញ្ហាសុខភាព។ ក៏ប៉ុន្តែ ប្រមាណ ៣ សប្តាហ៍ក្រោយមក តំណែងនេះត្រូវ ប៉ុល ពត យកទៅកាន់កាប់វិញ។

ក្រោយពេលដែលរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ នួន ជា បានរត់ទៅរស់នៅជាយដែនខ្មែរ-ថៃ ជាមួយមេដឹកនាំខ្មែរក្រហមផ្សេងៗទៀត។ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨ នួន ជា បានផ្តាច់ខ្លួនចុះចូលជាមួយរដ្ឋាភិបាល ជាថ្នូរនឹងការរួចផុតពីរាល់ការចោទប្រកាន់ពីបទឧក្រិដ្ឋនានាដែលគាត់បានប្រព្រឹត្តក្នុងរបបខ្មែរក្រហម។ ក៏ប៉ុន្តែ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ នួន ជា ត្រូវបានគេចាប់ខ្លួនពីផ្ទះរបស់គាត់ នៅស្រុកសំឡូត មកភ្នំពេញ តាមដីកាចាប់ខ្លួនរបស់តុលាការខ្មែរក្រហម។ នួន ជា ត្រូវបាន

អង្គជំនុំជម្រះចោទប្រកាន់ពីបទឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយកំពុងប្រឈមមុខនឹងការកាត់ទោស[26]។

**២.១.២. ខៀវ សំផន**

ខៀវ សំផន កើតនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៣១ នៅខេត្តស្វាយរៀង។ លោកគឺជាកូនច្បងក្នុងត្រកូលអ្នកចេះដឹង ដែលមានឪពុកជាចៅក្រម។

នៅឆ្នាំ១៩៤២ លោកត្រូវបានជ្រើសរើសឱ្យទៅរៀននៅអនុវិទ្យាល័យមួយ ដែលបារាំងទើបបង្កើតថ្មីនៅខេត្តកំពង់ចាម ឈ្មោះ "វិទ្យាល័យព្រះសីហនុ"។ ក្រោយពីបញ្ចប់ការសិក្សានៅអនុវិទ្យាល័យកំពង់ចាម លោកបានចូលរៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិ នៅទីក្រុងភ្នំពេញ។ នៅឆ្នាំ១៩៥៣ លោកបានទទួលអាហារូបករណ៍ទៅរៀននៅប្រទេសបារាំង។ ខៀវ សំផន ទទួលបានបរិញ្ញាប័ត្រផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅសាកលវិទ្យាល័យ Montpelier បន្ទាប់មកបានបន្តការសិក្សាថ្នាក់បណ្ឌិតសេដ្ឋកិច្ច នៅសាកលវិទ្យាល័យ Panthéon-Sorbonne នៅទីក្រុងប៉ារីស។ លោកបានទទួលសញ្ញាប័ត្របណ្ឌិតសេដ្ឋកិច្ច នៅឆ្នាំ១៩៥៨។ នៅក្នុងនិក្ខេបទបណ្ឌិត ដែលមានចំណងជើងថា "ការអភិវឌ្ឍសេដ្ឋកិច្ច និងឧស្សាហកម្មកម្ពុជា" និងបានប្រកាន់យកនូវទស្សនៈឯករាជ្យម្ចាស់ការនៅក្នុងការអភិវឌ្ឍប្រទេស។

ពេលនៅទីក្រុងប៉ារីសនោះ លោកបានចូលជាសមាជិកក្រុមនិស្សិតកុម្មុយនីស្ត គឺក្រុមម៉ាក់ស៊ីស ដែលមាន អៀង សារី និង រ័ត្ន សាមឿន ជាអ្នកផ្តើមគំនិតបង្កើត។ នៅឆ្នាំ១៩៥៦ លោកបានក្លាយជាអគ្គលេខាធិការនៃសមាគមនិស្សិតខ្មែរនៅប្រទេសបារាំង។ នាពេលវិលត្រឡប់ពីប្រទេសបារាំងវិញមកប្រទេសកម្ពុជា នៅឆ្នាំ១៩៥៩ លោកបានបង្កើតកាសែតមួយមាននិន្នាការនយោបាយឆ្វេងនិយម។ កាសែតនេះសរសេរជាភាសាបារាំង ហើយមានឈ្មោះថា "L'Observateur"។ ក្នុងពេលជាមួយគ្នានោះ ខៀវ សំផន បានធ្វើជាសាស្ត្រាចារ្យនៅមហាវិទ្យាល័យច្បាប់នៅទីក្រុងភ្នំពេញ។ ដោយកាសែត L'Observateur សរសេររិះគន់រដ្ឋាភិបាលសម្តេចនរោត្តម សីហនុ កាសែតនេះបានបើកដំណើរការត្រឹមមួយឆ្នាំហើយក៏ត្រូវបានបិទទៅវិញនៅឆ្នាំ១៩៦០។ លើសពីនោះទៅទៀត យោងតាមលោក Raoul Jennar នៅថ្ងៃទី១៣ កក្កដា ឆ្នាំ១៩៦០ ខៀវ សំផន ដែលជាចាងហ្វាងកាសែត L'Observateur ត្រូវបានប៉ូលិសចាប់វាយ សម្រាតខោអាវ នៅលើដងផ្លូវសាធារណៈ ក្នុងទីក្រុងភ្នំពេញ។ ខៀវ សំផន ត្រូវបានប៉ូលិសចាប់ដាក់គុករយៈពេលជាងមួយខែ ដោយគ្មានការជំនុំជម្រះអ្វីទាំងអស់។

ពីរឆ្នាំក្រោយមក ពោលគឺ នៅឆ្នាំ១៩៦២ ខៀវ សំផន បានជាប់ឆ្នោតជាតំណាងរាស្ត្រមណ្ឌលកណ្តាល ហើយត្រូវបានតែងតាំងជា រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ក្នុងរដ្ឋាភិបាលព្រះអង្គម្ចាស់ នរោត្តម កន្តុល។ ក៏ប៉ុន្តែ ខៀវ សំផន បានលាលែងចេញពីតំណែងជារដ្ឋលេខាធិការ នៅខែកក្កដា ឆ្នាំ១៩៦៣ ក្រោយពី

[26] សេង ឌីណា (២០ កញ្ញា ២០១១), វិគ្គីភីឌាសេរី

មានព្រឹត្តិការណ៍បះបោររបស់សិស្សវិទ្យាល័យនៅខេត្តសៀមរាប។ សម្តេច នរោត្តម សីហនុ បានចោទប្រកាន់ថា ពួកឆ្វេងនិយមគឺជាអ្នកនៅពីក្រោយចលនាបះបោរនេះ។ សម្តេច នរោត្តម សីហនុ បានចេញផ្សាយនូវបញ្ជីឈ្មោះអ្នកនយោបាយឆ្វេងនិយម៣៤រូប ដែលព្រះអង្គកោះហៅឱ្យមកបង្កើតរដ្ឋាភិបាលក្នុងនោះ ក៏មានឈ្មោះ ខៀវ សំផន ផងដែររួមជាមួយនឹងឥស្សរជនខ្មែរកុម្មុយនីស្តមួយចំនួនទៀត។ ដោយភ័យខ្លាចប៉ូលិសរបស់សម្តេច នរោត្តម សីហនុ លបធ្វើឃាត ពួកខ្មែរកុម្មុយនីស្ត ដែលមានឈ្មោះក្នុងបញ្ជីនេះដូចជា សាឡុត ស និង អៀង សារី ជាដើមបានរត់គេចខ្លួនចេញពីទីក្រុងភ្នំពេញទៅលាក់ខ្លួននៅក្នុងព្រៃ។ ឯ ខៀវ សំផន វិញថ្វីត្បិតតែបានលាលែងចេញពីតំណែងជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម តែបន្តនៅធ្វើជាសមាជិកសភាមណ្ឌលកណ្តាលដដែល។ នៅខែកញ្ញា ឆ្នាំ១៩៦៦ ខៀវ សំផន បានជាប់ឆ្នោតជាតំណាងរាស្ត្រមួយអាណត្តិថ្មីទៀត។ អ្នកនយោបាយនិន្នាការឆ្វេងនិយមពីររូបផ្សេងទៀត គឺ ហ៊ូ នឹម និង ហ៊ូ យន់ ក៏បានជាប់ឆ្នោតជាតំណាងរាស្ត្រដែរនៅពេលនោះ។

ក្រោយពីព្រឹត្តិការណ៍បះបោរនៅសំឡូត នៅខែមេសា ឆ្នាំ១៩៦៧ សម្តេច នរោត្តម សីហនុ បានធ្វើការចោទប្រកាន់ជាសាធារណៈលើ ខៀវ សំផន ហ៊ូ យន់ និង ហ៊ូ នឹម ថាជាអ្នកញុះញង់ឱ្យមានអំពើបះបោរនេះ ហើយថែមទាំងគំរាមថានឹងយកអ្នកទាំងបីនេះ ទៅកាត់ទោសនៅតុលាការសឹកទៀតផង។ ខៀវ សំផន រួមជាមួយ ហ៊ូ នឹម និង ហ៊ូ យន់ ក៏បានរត់គេចខ្លួនចូលក្នុងព្រៃ។ ក្រោយពេល ខៀវ សំផន ហ៊ូ នឹម និង ហ៊ូ យន់ បាត់ខ្លួនពីភ្នំពេញ លន់ នល់ ដែលពេលនោះជានាយករដ្ឋមន្ត្រី បានអះអាងថា អ្នកទាំងបីរូបនេះបានស្លាប់បាត់ទៅហើយ។ ហេតុដូចនេះហើយបានជាពេលដែល ខៀវ សំផន ហ៊ូ នឹម និងហ៊ូ យន់បានលេចមុខមកវិញក្នុងជួរថ្នាក់ដឹកនាំខ្មែរក្រហម គេបានហៅអ្នកទាំងបីនាក់នេះថា "ខ្មោចទាំងបី"។

ក្រោយពេលរណសិរ្សរួបរួមជាតិកម្ពុជា ត្រូវបានបង្កើតឡើង ដែលមានសម្តេច នរោត្តម សីហនុ ជាប្រធាន ខៀវ សំផន ត្រូវបានតែងតាំងជាអនុប្រធានរណសិរ្សនេះ។ បន្ទាប់មក ក្រោយពេលដែលរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាត្រូវបានបង្កើតឡើងនៅប៉េកាំង នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧០ ខៀវ សំផន ត្រូវបានតែងតាំងជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ។ ខៀវ សំផន បន្តកាន់តំណែងនេះ រហូតដល់ខែមេសា ឆ្នាំ១៩៧៥ ទើបផ្លាស់ទៅធ្វើជាអគ្គបញ្ជាការកងទ័ពជាតិវិញប៉ុន្តែ រក្សាតំណែងជាឧបនាយករដ្ឋមន្ត្រីដដែល។ ចំណែកឯតំណែងជារដ្ឋមន្ត្រីការពារជាតិ ត្រូវបានផ្ទេរទៅឱ្យ សុន សេន ជាអ្នកគ្រប់គ្រងវិញ[27]។

### ២.១.៣. អៀង សារី

អៀង សារី ដែលមានឈ្មោះក្រៅថា វ៉ាន់ កើតនៅថ្ងៃ២៤ តុលា ១៩២៥ ក្នុងភូមិលឿងវ៉ា ខេត្តត្រាវីញ ។ លោក គឺជាអតីតសិស្សនៅវិទ្យាល័យស៊ីសុវត្ថិ(វៀតណាមខាងត្បូង)ក្នុងក្រុងភ្នំពេញ។ លោកបាន ទទួល

[27] សេង ឌីណា (១៣ តុលា ២០១១), វិទ្យុអាស៊ីសេរី

អាហារូបករណ៍ទៅសិក្សានៅឯវិទ្យាល័យកុងដ័រសេ និងនៅវិទ្យាស្ថានសិក្សា នយោបាយក្រុងប៉ារីសប្រទេសបារាំង។ លោកបានចូលជាសមាជិកបក្សកុម្មុយនីស្ត បារាំងក្នុងឆ្នាំ១៩៥១។ លោក ត្រូវបានគេជឿថាបានចូលរួមជាមួយ ខៀវ សំផន ក្នុងការបង្កើតចលនា ម៉ាក្សស៊ីស ក្នុងស្រទាប់និស្សិតកម្ពុជានៅបារាំង។ បន្ទាប់ពីត្រឡប់មកកម្ពុជាវិញឆ្នាំ១៩៥៧ លោក បានក្លាយជាគ្រូបង្រៀន ប្រវត្តិវិទ្យានៅវិទ្យាល័យស៊ីសុវត្ថិ និងជាសមាជិកសកម្មនៃបក្សកុម្មុយនីស្តកម្ពុជា។ លោក បានរត់ចូលព្រៃដើម្បីចូលរួមជាមួយចលនាខ្មែរក្រហមនៅ ឆ្នាំ១៩៦៣។ ក្នុងអំឡុងសង្គ្រាមស៊ីវិលពីឆ្នាំ១៩៧១១៩៧៥ លោកបានចូលរួមជាមួយរាជរដ្ឋាភិបាល- បង្រួបបង្រួមជាតិកម្ពុជា និងជាបេសកជនពិសេសរបស់រណសិរ្សរួបរួមជាតិខ្មែរ។ ពេលដែលខ្មែរក្រហមឡើងកាន់អំណាចនៅឆ្នាំ១៩៧៥ អៀង សារី ក៏បានក្លាយទៅជា ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស។ លោកបានរត់ភៀសខ្លួនទៅប្រទេសថៃនៅពេលដែលរបបខ្មែរក្រហមដួលរលំ ក្នុងឆ្នាំ១៩៧៩។ គាត់ត្រូវបានកាត់ទោសកំបាំងមុខពីបទប្រល័យពូជសាសន៍ និងត្រូវផ្តន្ទាទោសប្រហារជីវិតដោយ តុលាការប្រជាជនបដិវត្តន៍កម្ពុជា។ អៀង សារី បានបន្តតួនាទីរបស់ខ្លួន ក្នុងរដ្ឋាភិបាលនិរទេស ប៉ុន្តែបានផ្ទេរមុខតំណែងជារដ្ឋមន្ត្រីការបរទេសទៅឱ្យ ខៀវ សំផន បន្ទាប់ពីការបង្កើតរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ១៩៨២។ លោក បានចាកចេញពីចលនាខ្មែរក្រហមជាមួយនឹងកងកម្លាំងយោធា រាប់ពាន់នាក់នៅខែសីហា ឆ្នាំ១៩៩៦ ជាថ្នូរនឹងព្រះរាជក្រឹត្យលើកលែងទោសចំពោះសាលក្រមឆ្នាំ១៩៧៩ និងការលើកលែងទោសពីសំណាក់សម្តេចឪនរោត្តម សីហនុ ពីការកាត់ទោសក្រោមច្បាប់ដាក់ខ្មែរក្រហមនៅក្រៅច្បាប់ក្នុងឆ្នាំ ១៩៩៤។

អៀង សារី ត្រូវបានចាប់ខ្លួននៅថ្ងៃទី១២ ខែវិច្ឆិកា ២០០៧ ហើយត្រូវបានបញ្ជូនទៅជំនុំជម្រះនៅឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ និងអំពើមនុស្សឃាតដែលត្រូវបានប្រព្រឹត្ត នៅចន្លោះពីថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ៦ មករា ១៩៧៩។ លោកទទួលមរណភាពនៅម៉ោង ៨:៤៥ព្រឹកថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដោយរោគាពាធ[28]។

### ២.១.៤. អៀង ធីរិទ្ធ

អ្នកស្រី អៀង ធីរិទ្ធ ដែលមានឈ្មោះដើមថា ខៀវ ធីរិទ្ធ ជាប្អូនបង្កើតរបស់ លោកស្រី ខៀវ ប៉ុណ្ណារី ជាប្រពន្ធទីមួយរបស់ ប៉ុល ពត។ លោកស្រី អៀង ធីរិទ្ធ កើតនៅថ្ងៃទី១២ ខែមីនា ឆ្នាំ ១៩៣២ ជាអតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនៅអំឡុងពេលពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ អ្នកស្រី អៀង ធីរិទ្ធ ឈ្មោះបដិវត្តន៍ហៅថា ភា ឬ ហុង ត្រូវបានអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា តែងតាំងជារដ្ឋមន្ត្រីក្រសួង

[28] ជីវប្រវត្តិសង្ខេបលោក អៀង សារី (១៥ មីនា ២០១៣), ភ្នំពេញប៉ុស្តិ៍

សង្គមកិច្ច នៃរបបកម្ពុជាប្រជាធិបតេយ្យ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥។ អ្នកស្រី អៀង ធីរិទ្ធ កាន់មុខតំណែងនេះរហូតដល់របបកម្ពុជាប្រជាធិបតេយ្យ ឬហៅថារបបខ្មែរក្រហមដួលរលំ នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

ឯកសារសំណុំរឿងរបស់សាលាក្តីខ្មែរក្រហម និងឯកសារស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បង្ហាញថា អ្នកស្រី អៀង ធីរិទ្ធ ដែលមានឈ្មោះដើមថា ខៀវ ធីរិទ្ធ កើតនៅឆ្នាំ១៩៣២ ក្នុងគ្រួសារដែលមានជីវភាពធូរធារមួយនៅខេត្តបាត់ដំបង។ អ្នកស្រី អៀង ធីរិទ្ធ បានបញ្ចប់ការសិក្សានៅវិទ្យាល័យស៊ីសុវត្ថិ រាជធានីភ្នំពេញ ហើយបន្ទាប់មក គាត់ទៅសិក្សាផ្នែកអក្សរសាស្ត្រនៅសាកលវិទ្យាល័យ សបូន (Sorbonne) នៅប្រទេសបារាំង។ អ្នកស្រីរៀបការជាមួយ លោក អៀង សារី ក្នុងទសវត្សរ៍ឆ្នាំ១៩៥០ នៅទីក្រុងប៉ារីស ប្រទេសបារាំង ពេលដែលអ្នកទាំងពីរទៅសិក្សានៅទីនោះ។ នៅទីក្រុងប៉ារីស នោះអ្នកស្រីបានជួបជាមួយជនកុម្មុយនីស្តជាច្រើនរូបទៀតដែលមានជាអាទិ៍ ប៉ុល ពត និងលោក អៀង សារី ដែលជាប្តីរបស់អ្នកស្រី។ អ្នកស្រី អៀង ធីរិទ្ធ ជាស្ត្រីកម្ពុជាទីមួយ ដែលបានទទួលសញ្ញាបត្រផ្នែកអក្សរសាស្ត្រអង់គ្លេស។ អ្នកស្រី អៀង ធីរិទ្ធ បានត្រឡប់មកធ្វើជាសាស្ត្រាចារ្យនៅកម្ពុជា វិញនៅឆ្នាំ១៩៥៧ ហើយអ្នកស្រីបង្កើតសាលាឯកជនបង្រៀនភាសាអង់គ្លេសមួយនៅឆ្នាំ១៩៦០[29]។

ក្នុងតួនាទីជាអតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច នេះ អ្នកស្រី អៀង ធីរិទ្ធ ត្រូវបានសាលាក្តីខ្មែរក្រហម ចាប់ខ្លួនពីផ្ទះរបស់អ្នកស្រីនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ រួមជាមួយនឹងប្តីរបស់អ្នកស្រី គឺលោក អៀង សារី ដែលជាអតីតរដ្ឋមន្ត្រីក្រសួងការបរទេស នៃរបបខ្មែរក្រហមដែរ។

នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ លោកស្រី អៀង ធីរិទ្ធ ត្រូវបានចោទប្រកាន់ នៅក្នុងសំណុំរឿង ០០២ លើបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្ស ជាតិ និងការរំលោភបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ឆ្នាំ១៩៤៩។ នីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង ធីរិទ្ធ នៅតែត្រូវបន្តក្នុងឆ្នាំ ២០១២ បន្ទាប់ពីគាត់ត្រូវបានរកឃើញថា មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ដោយសារតែការវិវឌ្ឍនៃជំងឺវង្វេងវង្វាន់បាត់ការចងចាំ ហើយគាត់ត្រូវបានដោះលែង ដោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ លោកស្រី អៀង ធីរិទ្ធ ស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរហូតដល់គាត់ស្លាប់[30]។

**២.២. សំណុំរឿង ០០២/០១**

ដោយជនជាប់ចោទចំនួនពីររូបមានកាយសម្បទាមិនគ្រប់គ្រងក្នុងការចូលរួមក្នុងការជំនុំជម្រះនេះ ចុងចោទទាំងពីររូបត្រូវបានដកចេញពីសំណុំរឿង ០០២ នេះ។ បុគ្គលទាំងពីរនោះគឺ អៀង ធីរិទ្ធ ដែលអ្នកស្រីមានជម្ងឺមហារីក ហើយបានទទួលមរណភាពនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣។ និងលោក អៀង ធីរិទ្ធ មានស្មារតីមិនគ្រប់គ្រាន់ ត្រូវសំរាកព្យាបាលនៅមន្ទីរពេទ្យដែលស្ថិតក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុង

[29] សារ៉ា (៣០ សីហា ២០១១), កោះសន្តិភាព

[30] អៀង ធីរិទ្ធ ទទួលមរណភាពក្នុងជន្មាយុ៨៣ឆ្នាំ (២២ សីហា ២០១៥), វិទ្យុអាស៊ីសេរី

តុលាការកម្ពុជា។ ដូចនេះ ចុងចោទដែលនៅសេសសល់ក្នុងសំណុំរឿង ០០២ គឺមានតែ ខៀវ សំផន និង នួន ជា តែប៉ុណ្ណោះ។

នៅខែ កញ្ញា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចបំបែកបទចោទនៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០២ ទៅជាការជំនុំជម្រះផ្នែកតូចៗ។ សេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកដំបូង ដោយអង្គជំនុំជម្រះសាលាដំបូង បានកំណត់ទៅលើវិសាលភាពនៃបទចោទក្នុងសំណុំរឿង ០០២/០១ ចំពោះតែឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលទាក់ទងនឹង ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញនៅក្នុងខែមេសា ឆ្នាំ១៩៧៥ និងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទីពីរក្នុងតំបន់ផ្សេងៗទៀត និងការសម្លាប់ទាហានរបបសាធារណរដ្ឋខ្មែរ នៅទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃក្នុងខេត្តពោធិ៍សាត់ ភ្លាមៗក្រោយពីខ្មែរក្រហមបានកាន់កាប់អំណាចចាប់ពីខែកញ្ញា ឆ្នាំ១៩៧៥។សវនាការទីមួយក្នុងសំណុំរឿង ០០២ ដែលសំដៅលើសំណុំរឿង ០០២/០១ ក៏ត្រូវបានចាប់ផ្តើមនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១។

នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធផ្នែកខ្លះ និងបានទទួលយកផ្នែកខ្លះនៃសំណើរបស់សហព្រះរាជអាជ្ញា សុំពង្រីកវិសាលភាពនៃបទចោទនានាក្នុងសំណុំរឿង ០០២/០១ និងបានសម្រេចដាក់បញ្ចូលបទចោទទាំងឡាយ ទាក់ទងនឹងការសម្លាប់ទាហានរបបសាធារណរដ្ឋខ្មែរ នៅទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ ភ្លាមៗក្រោយពីខ្មែរក្រហមបានកាន់កាប់អំណាចក្នុងឆ្នាំ១៩៧៥ ទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធជាបន្តបន្ទាប់ នូវបណ្តឹងសាទុក្ខនានាដែលស្នើសុំឱ្យពង្រីកវិសាលភាពនៃបទចោទ ដោយបង្គាប់ថាបទចោទបន្ថែមទៀតត្រូវតែយកមកជំនុំជម្រះក្នុងសំណុំរឿង ០០២/០២។

### ២.២.១. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់បុគ្គល

#### ២.២.១.១. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា

យោងតាមដីកាដំណោះស្រាយ ដូចដែលបានកំណត់វិសាលភាពក្នុងសំណុំរឿង ០០២/០១ នួន ជា តាមរយៈសហឧក្រិដ្ឋកម្មរួម បានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដូចជា៖

- ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ១)៖ លោក នួន ជា បានទទួលស្គាល់ថា រូបលោកបានចូលរួមនៅក្នុងការធ្វើ សេចក្តីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ដោយលោកបានបញ្ជាក់ថា នៅពេលធ្វើដំណើរទៅកាន់ទីក្រុងភ្នំពេញភ្លាមៗក្រោយមពេលជម្លៀសនោះ លោកផ្ទាល់បានជួបប្រទះនូវសាកសពនិងការរងទុក្ខលំបាកវេទនារបស់ប្រជាជននៅពេលធ្វើដំណើរនោះ។ និងមានការស្លាប់ដោយសារជំងឺ និងការអត់អាហារទាំងក្នុងកំឡុងពេលជម្លៀស និងក្រោយពេលជម្លៀសជាច្រើនផងដែរ។ ដូចនេះ អង្គជំនុំជម្រះជឿជាក់ថា នួន ជា បានដឹងអំពីការប្រព្រឹត្តឧក្រិដ្ឋកម្មនានានៅពេលដែលឧក្រិដ្ឋកម្មនោះបានប្រព្រឹត្តក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី ១នេះ។

- ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ២)៖ លោក នួន ជា ក៏បានទទួលស្គាល់ផងដែរថា បក្ស បានដឹងប្រជាជននឹងត្រូវលះបង់ ហើយនិងជួបប្រទះភាពលំបាលវេទនា ដោយសារតែការជម្លៀស ទាំងនេះ។ ប៉ុន្តែគណៈកម្មាធិការបក្សនៅតែបន្តសម្រេចអោយប្រជាជនជម្លៀសពីទីក្រុងភ្នំពេញដដែល។ លោក បានទទួលស្គាល់ថា រូបលោកបានដឹងពីគោលបំណងរបស់បក្ស ដែលសម្រេចលើការជម្លៀស នោះព្រមទាំងបានចូលរួមចំណោកក្នុងការរៀបចំ និងជំរុញគោលនយោបាយរបស់របបកម្ពុជាប្រជា ធិបតេយ្យ ក្នុងការកំណត់គោលដៅមកលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។
- ការសម្លាប់នៅទួលពោធិ៍ជ្រៃ៖ ក្រោយពីថ្ងៃរំដោះក្នុងប្រទេសកម្ពុជានាឆ្នាំ ១៩៧៥ មានការចាប់ខ្លួន ការសម្លាប់ ការបាត់ខ្លួន និងការធ្វើបាបផ្សេងៗទៅលើអ្នករដ្ឋការនៃរបបសាធារដ្ឋខ្មែរ នៅពេលមុនការ ជម្លៀសបន្តិច ក្នុងពេលជម្លៀស និងក្រោយពេលជម្លៀសបន្តិច។ ដូចគ្នាទៅនឹងវិធីសាស្ត្រអនុវត្ត ដែល កំពុងអនុវត្តនៅពេលនោះ បន្ទាប់ពីរំដោះបានខេត្តពោធិ៍សាត់ អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវ បានប្រមូលផ្តុំតាមរយៈមធ្យោបាយបោកបញ្ឆោត ហើយត្រូវយកទៅសម្លាប់នៅទួលពោធិ៍ជ្រៃ។ ការ សម្លាប់នៅទួលពោធិ៍ជ្រៃនេះបានប្រព្រឹត្តទៅនាថ្ងៃទី២៥ ឬ ២៦ ខែមេសា ឆ្នាំ១៩៧៥។ នាពេលនោះ នួន ជា គឺជាអ្នកនិពន្ធម្នាក់ក្នុងចំណោមរបស់បក្សទាក់ទងនឹង "ខ្មាំង" និងលើកសរសើរអំពីការលុប បំបាត់ខ្មាំង និងការលុបបំបាត់អតីតអ្នករដ្ឋការនៃរបបសាធារដ្ឋខ្មែរ។ អង្គជំនុំជម្រះវិសមញ្ញក្នុង តុលាការកម្ពុជាយល់ឃើញថា គណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុនីស្តកម្ពុជាបានបញ្ជាឱ្យក្រសួង ឃោសនាការ និង ព័ត៌មានរបស់របបប្រជាធិបតេយ្យ ធ្វើការត្រួតពិនិត្យសេចក្តីរាយការណ៍ ព័ត៌មាន បរទេសឱ្យបានដិតដល់ហើយថានីតិវិធីលម្អិតត្រូវបានបង្កើតឡើងសម្រាប់ឱ្យក្រសួឃោសនាការសង្ខេប និងរាយការណ៍ពីព័ត៌មាននានាជូនទៅគណៈកម្មាធិការអចិន្ត្រៃយ៍។ ដូចនេះ អង្គជំនុំជម្រះវិសមញ្ញក្នុង តុលាការកម្ពុជាជឿជាក់ថា តាមរយៈរបាយការណ៍របស់ក្រសួងទាំងនេះ នួន ជា ដែលជាសមាជិកគ ណៈកម្មធិការអចិន្ត្រៃយ៍ ពិតជាបានដឹងអំពីសេចក្តីរាយការណ៍ព័ត៌មានដែលរៀបរាប់លម្អិតអំពីឧក្រិដ្ឋ កម្មទាំងនេះ។

ដីកាដំណោះស្រាយបានចោទប្រកាន់ នួន ជា ថាបានចូលរួមដោយចេតនា ឬ បានរួមចំណែកក្នុងការ រៀបចំ និងអនុវត្តគោលបំណងរួមដែលបណ្តាលឱ្យមានឧក្រិដ្ឋកម្មនេះកើតឡើង។ លោក នួន ជា មានតួនាទី ជាអនុលេខាបក្សកុម្មុនីស្តកម្ពុជា សមាជិកគណៈកម្មធិការយោធា និងជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការ មជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ ដូចនេះដីការដំណោះស្រាយបានចោទប្រកាន់ថា នួន ជា បានចូលរួម នៅក្នុងកិច្ចប្រជុំជាន់ខ្ពស់នានា ដែលមានការបង្កើតគោលនយោបាយ ព្រមទាំងបានចូលរួមនៅក្នុងការពន្យល់ បង្ហាញអំពីឯកសារគោលនយោបាយជាផ្លូវការនានារបស់បក្សកុម្មុនីស្តកម្ពុជា តាមរយៈការធ្វើសុន្ទរកថា ការ ឃោសនា និងវគ្គសិក្សានយោបាយ។ ដោយយោងតាមមូលដ្ឋាននេះ ដីកាដំណោះស្រាយបានចោទប្រកាន់ នួន ជា

បន្ថែមទៀតថាបានរៀបចំផែនការ បញ្ជា ញុះញង់ ជួយ ជំរុញ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១។

**២.២.១.២. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន**

ផ្អែកតាមដីកាដំណោះស្រាយ កំណត់វិសាលភាពក្នុងសំណុំរឿង ០០២/០១ លោក ខៀវ សំផន បានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចខាងក្រោម៖

- ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)៖ ការធ្វើមនុសសឃាត ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ដែលរួមមានការផ្លាស់ទីលំនៅដោយបង្ខំ និងការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស)
- ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាល់ទី២)៖ ការធ្វើមនុសសឃាត ការធ្វើទុក្ខបុកម្នេញដោយមូលហតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ដែលរួមមានការផ្លាស់ទីលំនៅដោយបង្ខំ និងការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស)
- ទួលពោធិ៍ជ្រៃ៖ ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។

ដីការដំណោះស្រាយបានចោទប្រកាន់ លោក ខៀវ សំផន ថាបានចូលរួមដោយចេតនា ឬបានចូលរួមចំណែកក្នុងការរៀបចំ និងការអនុវត្តគោលបំណងរួម ដែលធ្វើឱ្យមាន និង/ឬ មានការប្រព្រឹត្តឧក្រិដ្ឋកម្មជាច្រើនទាំងមុនពេល និងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ដោយសារតែតួនាទីរបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលរួមមានទាំងសមាជិកភាពរបស់គាត់នៅគណៈកម្មាធិការមជ្ឈិម និងមន្ទីរ ៨៧០។ គាត់ក៏បានធ្វើសេចក្ដីថ្លែងការណ៍ជាសាធារណៈបំពេញតួនាទីការទូត និងចូលរួមក្នុងវគ្គបំពាក់បំប៉នមនោគមន៍វិជ្ជាផងដែរ។ ដោយផ្អែកលើមូលដ្ឋាននេះ ដីកាដំណោះស្រាយក៏បានចោទប្រកាន់ជនជាប់ចោទបន្ថែមទៀតថា បានរៀបចំផែនការបញ្ជា ញុះញង់ និងជំរុញ ឬក៏ជាអ្នកទទួលខុសត្រូវក្នុងនាមជាថ្នាក់លើចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១។

**២.២.២. សាលក្រមសម្រេច**

នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ សវនាការសួរដេញដោលលើភស្តុតាងក្នុងសំណុំរឿង ០០២/០១ ត្រូវបានបញ្ចប់ ហើយសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលត្រូវបានបញ្ចប់នៅថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០១៣។ សាលក្រមសាលាដំបូងត្រូវបានប្រកាសនៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤។ នួន ជា និង ខៀវ សំផន ត្រូវបានតុលាការរកឃើញថា មានពិរុទ្ធភាពចំពោះបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ហើយត្រូវបានផ្ដន្ទាទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិត។ យ៉ាងណាមិញអង្គជំនុំជម្រះបានទទួលស្គាល់ថា ជនជាប់ចោទទាំងពីររូប មិនមានទ្រព្យសម្បត្តិ ឬអចលនទ្រព្យផ្ទាល់ខ្លួនដែលទទួលបានដោយខុសច្បាប់ ឬដោយការ

ប្រព្រឹត្តអំពើឧក្រិដ្ឋកម្មឡើយ[31]។ ដូចនេះមិនមានទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការរឹបអូសចំពោះជនជាប់ចោទឡើយ ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា ៣៩ ថ្មីនៃច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ផ្ទុយទៅវិញនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានប្រកាសសាលដីការបស់ខ្លួនលើបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១ ដោយអង្គជំនុំជម្រះតុលាការកំពូលបានបដិសេធចោលការដាក់ពិរុទ្ធភាពមួយចំនួន និងតម្កល់ការផ្ដន្ទាទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិតចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ សម្រាប់ នួន ជា និង ខៀវ សំផន។

**២.៣. សំណុំរឿង ០០២/០២**

សំណុំរឿង ០០២/០២ គឺជាសំណុំរឿងជំនុំជម្រះដំណាក់កាលទីពីរប្រឆាំងនឹង ខៀវ សំផន និង នួន ជា ដែលនឹងត្រូវជំនុំជម្រះទៅលើបទចោទបន្ថែមទៀតក្រៅពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ដែលស្ថិតក្នុងសំណុំរឿង ០០២/០១។

**២.៣.១. ការផ្ដន្ទាទោស**

អង្គជំនុំជម្រះសាលាដំបូងរកឃើញថា ជនជាប់ចោទ **នួន ជា ខៀវ** និង **សំផន** មានពិរុទ្ធដែលបានប្រព្រឹត្តនៅលើទឹកដីនៃប្រទេសកម្ពុជាក្នុងកំឡុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ដូចជា៖

- **ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ៖** តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស អំពើអមនុស្សធម៌ផ្សេងទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការបាត់ខ្លួនដោយបង្ខំ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែឡត្រូវបានកំណត់ថាជាការជម្លៀសដោយបង្ខំដូចជាការរៀបអាពាហ៍ពិពាហ៍ និងការរំលោភផ្លូវភេទនៅក្នុងបរបទនៃការរៀបអាពាហ៍ពិហ៍ដោយបង្ខំ អនុលោមតាមបទបញ្ញត្តិមាត្រា៥ និង មាត្រា២៩ (ថ្មី) នៃច្បាប់ស្ដីពីការបង្កើត អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។
- **ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ៖** តាមរយៈការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព គារដកហូតដោយចេតនាពីឈ្លើយសឹក ឬជន

[31] សាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤

ស៊ីវិល នូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ អនុលោមតាមមាត្រា ៦ និងមាត្រា ២៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

- **ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍៖** តាមរយៈការធ្វើមនុស្សឃាតលើសមាជិកនៃក្រុមជនជាតិវៀតណាម និងជនជាតិចាម អនុលោមតាមមាត្រា ៤ និង មាត្រា ២៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

**២.៣.២.សេចក្តីសម្រេច**

ដោយស្របតាមការពិនិត្យយ៉ាងល្អិតល្អន់ និងការពិភាក្សារវាងអង្គជំនុំជម្រះស្របតាមសាក្សីនិង ភស្តុតាងបានបញ្ជាក់ អង្គជំនុំជម្រះអនុលោមតាមមាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រេចផ្តន្ទាទោសជនជាប់ចោទ ខៀវ សំផន និង នួន ជា ដាក់ពន្ធនាគារអស់មួយជីវិត។

## ៣. សំណុំរឿង ០០៣

### ៣.១. ជនជាប់ចោទ

លោក **មាស មុត** ដែលហៅក្រៅថា មុត កើតនៅថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៣៨ និងមានស្រុកកំណើតនៅ ភូមិពោធិ៍ ឃុំស្រែក្នុង ស្រុកឈូក ខេត្តកំពត។ នៅក្នុងកំឡុងពេលខ្មែរក្រហមកំពុងកាន់កាប់ប្រទេសកម្ពុជា នាឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ នោះ រូបលោកមានមុខងារជា បញ្ជាការកងពលធំ ១៦៤ (កងទ័ពជើងទឹក) សមាជិកបម្រុង គណៈកម្មាធិការអគ្គសេនាធិការ និងជាសមាជិកបម្រុង គណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា។

### ៣.២. នីតិវិធីនៃបណ្តឹង និង ការតវ៉ារបស់ជនជាប់ចោទ

នាថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរចំនួនពីរ ដោយស្នើឱ្យសហចៅក្រមស៊ើបអង្កេតផ្តួចផ្តើមបើកកិច្ចស៊ើបសួរ ពាក់ព័ន្ធនឹងជនសង្ស័យប្រាំនាក់។ ក្រោយមក មាស មុត និង ស៊ូ ម៉េត ត្រូវបានកំណត់ថាជាឈ្មោះជនសង្ស័យនៅក្នុងសំណុំរឿង ០០៣។ យ៉ាងណាមិញកិច្ចស៊ើបសួរប្រឆាំងនឹង ស៊ូ ម៉េត ត្រូវបានបញ្ចប់នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៥ បន្ទាប់ពីការទទួលមរណភាពរបស់គាត់។

កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ សហចៅក្រមស៊ើបសអង្កេត (ស.ច.ស) អន្តរជាតិ បានកោះហៅ មាស មុត ឱ្យចូលបង្ហាញខ្លួនលើកដំបូងនៅ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤។ ប៉ុន្តែ មាស មុត បានប្រកាសថានឹងមិនបង្ហាញខ្លួននៅអង្គជំនុំជម្រះ និងបដិសេធមិនព្រមចុះហត្ថលេខាលើលិខិតទទួលស្គាល់ការប្រគល់ដីកាកោះហៅ។ អនុលោមតាមមាត្រា ៣៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចំណងជើង *"ការស្វែងរកការពិតក្នុងករណីអវត្តមានរបស់ជនជាប់ចោទ"* បានចែងថា *"ទោះបីជា*

*ជនជាប់ចោទ អវត្តមានក៏ដោយ តុលាការត្រូវតែស្វែងរកឱ្យឃើញការពិត ស្តាប់ចម្លើយភាគីដទៃទៀត សាក្សី និងពិនិត្យវត្ថុតាង*។ ការស្វែងរកការពិតក៏ជាភារកិច្ចចម្បងដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ ស.ច.ស នៅអំឡុងពេលស៊ើបអង្កេតនៅ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ យ៉ាងណាមិញ យោងតាមមាត្រា ១៦ នៃលក្ខន្តិកៈរបស់តុលាការពិសេសសម្រាប់លីបង់ ("STL") ចែងថា ជនជាប់ចោទមានសិទ្ធិ *"ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន និងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់តាមការជ្រើសរើសរបស់ខ្លួន [...]"* ។ លក្ខន្តិកៈរបស់តុលាការ STL ក៏អនុញ្ញាតឱ្យមានលទ្ធភាពនៃការរៀបចំការជំនុំជម្រះដោយកំបាំងមុខ តាមលក្ខខណ្ឌមួយចំនួនផងដែរ។ ដែលលក្ខខណ្ឌទាំងនោះមានដូចជា៖

- ជនជាប់ចោទ បានបង្ហាញយ៉ាងច្បាស់ និងមានជាលាយលក្ខណ៍អក្សរថាគាត់បានលះបង់សិទ្ធិមានវត្តមានរបស់គាត់
- ជនជាប់ចោទមិនទាន់ត្រូវបានប្រគល់ជូនតុលាការ ពីអាជ្ញាធរពាក់ព័ន្ធរបស់រដ្ឋ ឬ
- ជនជាប់ចោទ បានរត់គេច ឬមិនអាចរកឃើញ ហើយវិធានការសមហេតុផលទាំងអស់ត្រូវបានអនុវត្តរួចហើយដើម្បីធានាថាគាត់បានចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ និងដើម្បីជូនដំណឹងគាត់ អំពីបទចោទប្រកាន់ដែលបានបញ្ជាក់ដោយចៅក្រមបុរេជំនុំជម្រះ។

ដោយ មាស មុត មានចេតនាមិនចូលបង្ហាញខ្លួននៅចំពោះមុខ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងផ្អែកលើការពិនិត្យមើលច្បាប់កម្ពុជា និងវិធានស្តីពីនីតិវិធី និងភស្តុតាងដែលបង្កើតឡើងនៅថ្នាក់អន្តរជាតិ ស.ច.ស អន្តរជាតិសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ដើម្បីធានាថាកិច្ចដំណើរការនីតិវិធីអនុវត្តបានដោយយុត្តិធម៌និងបានឆាប់រហ័ស។ ដីកាសម្រេចនេះ បានផ្លាស់ប្តូរឋានៈរបស់ មាស មុត ពីជនសង្ស័យ ទៅជា ជនត្រូវចោទ នាថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០១៥ [32]។

នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតទាំងពីរបានចេញដីកាដំណោះស្រាយផ្ទុយគ្នាពីរ នៅក្នុងសំណុំរឿងប្រឆាំងនឹង មាស មុត ដោយសារតែការមិនចុះសម្រុងគ្នាថាតើ មាស មុត ស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងឋានៈជាមេដឹកនាំជាន់ខ្ពស់ ឬជាបុគ្គលម្នាក់ក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យដែរឬយ៉ាងណា។

សហចៅក្រមស៊ើបអង្កេតជាតិយល់ឃើញថា មាស មុត មិនស្ថិតក្រោមយុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ ទោះជាក្នុងប្រភេទបុគ្គលមួយណាក៏ដោយ និងបានច្រានចោលសំណុំរឿងប្រឆាំងនឹង មាស មុត ដោយសារតែមូលហេតុនេះ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា

[32] ដីកាសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការត្រួតពិនិត្យដោយកំបាំងមុខ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥

មាស មុត ស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងឋានៈជាអ្នកទទួលខុសត្រូវជាន់ខ្ពស់ម្នាក់និងថា មានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់គាត់ពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងបទល្មើសជាតិដែលស្ថិតនៅក្រោមច្បាប់កម្ពុជា។

សហមេធាវីរបស់ មាស មុត និងសហព្រះរាជអាជ្ញាជាតិ បានដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំណែកឯសហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងការចោទប្រកាន់) របស់សហចៅក្រមស៊ើបអង្កេតជាតិ។ អង្គបុរេជំនុំជម្រះបានបើកសវនាការចំនួនបីថ្ងៃ ដើម្បីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយទាំងពីរ កាលពីថ្ងៃទី២៧, ២៨ និង ២៩ ខែវិច្ឆិកា ឆ្នាំ២០១៩[33]។

## ៤. សំណុំរឿង ០០៤

### ៤.១. ជនជាប់ចោទ

#### ៤.១.១. យឹម ទិត្យ

លោក យឹម ទិត្យ កើតនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៣៦ មានស្រុកកំណើតនៅ ភូមិត្រពាំងគល់ ឃុំត្រពាំងធំ ស្រុកត្រាំកក់ ខេត្តតាកែវ (អតីតតំបន់ ១៣ នៃភូមិភាគនិរតី)។ លោក មានមុខងារជា សមាជិកស្រុកគិរី វង់ លេខា និងអនុលេខាស្រុកគិរីវង់ សមាជិកគណៈកម្មាធិការតំបន់ ១៣ និងជា លេខាតំបន់ ១៣ កាលពីសម័យកម្ពុជាប្រជាធិបតេយ្យ[34]។

#### ៤.១.២. អោ អាន

លោក អោ អាន ឬ ឌិម យឿង កើតក្នុងឆ្នាំ ១៩៣៣ និងមានស្រុកកំណើតស្នាក់នៅ ភូមិតាំងស្វាយ ឃុំពាម ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។ លោក អោ អានមានមុខតំណែងជា លេខាតំបន់ ៤១ (ភូមិភាគកណ្ដាល) សមាជិកគណៈកម្មាធិការភូមិភាគកណ្ដាល និងជាអនុលេខាភូមិភាគកណ្ដាល (នៅចុងឆ្នាំ១៩៧៧ ដល់ខែមករា ឆ្នាំ១៩៧៩)[35]។

#### ៤.១.៣. អ៊ឹម ចែម

លោកស្រី អ៊ឹម ចែម មានស្រុកកំណើតនៅ ភូមិក្បាលអូ ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ។ លោកស្រី ត្រូវបានចោទប្រកាន់ថាជាលេខាស្រុកព្រះនេត្រព្រះនិងអនុលេខាតំបន់៥ នៃភូមិភាគពាយ័ព្យ។ អ៊ឹម ចែ

[33] ដីកាកំណត់កាលវិភាគសម្រាប់សវនាការរបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១៩

[34] គេហទំព័រ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ស្ដីពីជីវប្រវត្តិលោក យឹម ទិត្យ

[35] គេហទំព័រ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ស្ដីពីជីវប្រវត្តិលោក អោ អាន

ម ត្រូវបានដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យដោយកំបាំងមុខនៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ ហើយសំណុំរឿងនេះបច្ចុប្បន្នកំពុងស្ថិតនៅក្រោមការស៊ើបអង្កេត[36]។

**៤.២. ការបំបែកសំណុំរឿង**

កាលពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរចំនួនពីរ ដោយស្នើឱ្យសហចៅក្រមស៊ើបអង្កេតផ្តួចផ្តើមបើកកិច្ចស៊ើបសួរ ពាក់ព័ន្ធនឹងជនសង្ស័យប្រាំនាក់។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទាំងពីរនេះ ត្រូវបានបំបែកទៅជាសំណុំរឿង ០០៣ និង ០០៤។ សំណុំរឿង ០០៤ នៅតែជាសំណុំរឿងប្រឆាំងនឹង យឹម ទិត្យ ក្រោយពីការបំបែកសំណុំរឿងនេះរួចមក និងការបង្កើតបានជាសំណុំរឿង ០០៤/០១ (អ៊ឹម ចែម) និងសំណុំរឿង ០០៤/០២ (អោ អាន)។ នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចោទប្រកាន់ យឹម ទិត្យ នៅក្នុងសំណុំរឿង ០០៤។ នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧ កិច្ចស៊ើបសួរតាមផ្លូវតុលាការទៅលើសំណុំរឿង ០០៤ ត្រូវបានបិទជាលើកទីពីរ ក្រោយពីការដោះស្រាយលើសំណើសុំបន្ថែមមួយចំនួនពីសំណាក់ភាគីនានារួចមក។

យុត្តាធិការបុគ្គលរបស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងឋានៈជាមេដឹកនាំជាន់ខ្ពស់ ឬជាបុគ្គលម្នាក់ក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យដែរឬយ៉ាងណានោះ។ សហចៅក្រមស៊ើបអង្កេតជាតិយល់ឃើញថា យឹម ទិត្យ មិនស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ ទោះបីជាក្នុងប្រភេទបុគ្គលមួយណាក៏ដោយនិងបានច្រានចោលសំណុំរឿងប្រឆាំងនឹង យឹម ទិត្យ ដោយសារតែមូលហេតុនេះឯង។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា យឹម ទិត្យ ស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងឋានៈជាអ្នកទទួលខុសត្រូវជាន់ខ្ពស់ម្នាក់និងថា មានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់គាត់ពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងបទល្មើសជាតិដែលស្ថិតនៅក្រោមច្បាប់កម្ពុជា។ សហមេធាវីរបស់ យឹម ទិត្យ និងសហព្រះរាជអាជ្ញាជាតិ បានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំណែកឯសហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងការចោទប្រកាន់) របស់សហចៅក្រមស៊ើបអង្កេតជាតិ។ សហមេធាវីបានប្តឹងឧទ្ធរណ៍បន្ថែមទៀតប្រឆាំងនឹងការចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នានេះ។

[36] គេហទំព័រ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ស្តីពីជីវប្រវត្តិលោកស្រី អ៊ឹម ចែម

**៤.២.១. សំណុំរឿង ០០៤/០១**

នៅថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចោទប្រកាន់អ្នកស្រី អ៊ឹម ចែម ដោយកំបាំងមុខនៅក្នុងសំណុំរឿង ០០៤ ។ នៅថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ សំណុំរឿងនេះត្រូវបានបំបែកសំណុំឯកសារជាសំណុំរឿង ០០៤/១ ។ នៅថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតបានច្រានចោលសំណុំរឿងប្រឆាំងនឹង អ៊ឹម ចែមដោយបានរកឃើញថាលោកស្រីមិនត្រូវទទួលរងនូវយុត្តាធិការផ្ទាល់ខ្លួនរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលមានន័យថាលោកស្រីមិនមែនជាមេដឹកនាំជាន់ខ្ពស់ ឬក៏មិនមែនជាមន្ត្រីដែលទទួលខុសត្រូវខ្ពស់បំផុតនៃរបបខ្មែរក្រហមឡើយ។ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បណ្តឹងសាទុក្ខប្រឆាំង និងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅអង្គបុរេជំនុំជម្រះ។ នៅថ្ងៃទី១១ និង ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ អង្គបុរេជំនុំជម្រះបានបើកសវនាការក្នុងសំណុំរឿង ០០៤/១ ដើម្បីស្តាប់នូវអំណះអំណាងរបស់ភាគីនានាមុនពេលចេញសេចក្តីសម្រេចលើបណ្តឹងសាទុក្ខ។

នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨ អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចេញការពិចារណារបស់ខ្លួន លើពាក្យបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ដែលបានសម្រេចលើកលែងការចោទប្រកាន់ប្រឆាំងនឹងអ៊ឹម ចែម លើបទល្មើសព្រហ្មទណ្ឌនានា ដោយមូលហេតុមិនមានយុត្តាធិការបុគ្គល។ ជាឯកច្ឆ័ន្ទ អង្គបុរេជំនុំជម្រះយល់ឃើញថា មានការខ្វះចន្លោះនៃនីតិវិធី ជាពិសេសទាក់ទងនឹងការកំណត់ភស្តុតាង និងការពន្យារពេលដោយមិនសមស្របក្នុងការបិទការស៊ើបអង្កេត។ អង្គបុរេជំនុំជម្រះបានសម្រេចថា ច្បាប់ជាធរមានចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនបានដកហូតនូវសមត្ថកិច្ចរបស់តុលាការជាតិនោះទេ។

ចៅក្រមទាំង ៥ រូបរបស់អង្គបុរេជំនុំជម្រះ មានការយល់ឃើញផ្សេងគ្នាចំពោះអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍នេះ។ ចៅក្រម ៣ រូប បានយល់ឃើញថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនមានយុត្តាធិការបុគ្គលចំពោះអ៊ឹម ចែម។ ចៅក្រម ២ រូប បានយល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់ក្នុងការចោទប្រកាន់ អ៊ឹម ចែម ថាជាជនម្នាក់ក្នុងចំណោមមនុស្សផ្សេងទៀត ដែលជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនិងជឿជាក់ថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានយុត្តាធិការបុគ្គលលើគាត់។ ដើម្បីបដិសេធសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត យើងត្រូវការសំឡេងគាំទ្រ ៤ លើ ៥ ដូច្នេះសេចក្តីសម្រេចអំពីកង្វះយុត្តាធិការបុគ្គលលើ អ៊ឹម ចែម ត្រូវបានតម្កល់។ សេចក្តីសម្រេចនេះនឹងបិទបញ្ចប់នូវសំណុំរឿង អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ០០៤/១។

**៤.២.២. សំណុំរឿង ០០៤/០២**

សហចៅក្រមស៊ើបអង្កេតអន្តរជាតិចោទប្រកាន់ អោ អាន នៅក្នុងសំណុំរឿង ០០៤ កាលពីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ និងបានពង្រីកបទចោទប្រកាន់ នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦។ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ២០១៦ សហចៅក្រមស៊ើបអង្កេតទាំងពីរបានបញ្ចប់កិច្ចស៊ើបសួរប្រឆាំង អោ អាន ហើយសំណុំរឿងនេះត្រូវបានបំបែកចេញពីគ្នា ដោយបង្កើតបានជាសំណុំរឿង ០០៤/០២។ ការបំបែកសំណុំរឿងនេះត្រូវបានសម្រេចឡើង ដោយសារតែជនជាប់ចោទមានសិទ្ធិទទួលបានការជូនដំណឹងអំពីសេចក្ដីសម្រេចលើបទចោទប្រឆាំងនឹងរូបគាត់ដោយមិនត្រូវឱ្យមានការពន្យារពេលហួសហេតុនោះឡើយ និងដើម្បីចេញដីកាដំណោះស្រាយនៅក្នុងពេលវេលាមួយសមស្រប ដោយអនុលោមតាមវិធាន ៦៧ និងវិធាន ២១(៤) នៃវិធានផ្ទៃក្នុង ថាតើវាជាដីកាលើកលែងការចោទប្រកាន់ ឬជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតទាំងពីរបានចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា នៅក្នុងសំណុំរឿងប្រឆាំងនឹង អោ អាន ដោយសារតែការមិនចុះសម្រុងគ្នាថាតើ អោ អាន ស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងឋានៈជាមេដឹកនាំជាន់ខ្ពស់ ឬជាបុគ្គលម្នាក់ក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យដែរឬអត់នោះ។

សហចៅក្រមស៊ើបអង្កេតជាតិយល់ឃើញថា អោ អាន មិនស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នោះទេ ទោះជាក្នុងប្រភេទបុគ្គលមួយណាក៏ដោយ និងបានច្រានចោលសំណុំរឿងប្រឆាំងនឹង អោ អាន ដោយសារតែហេតុផលនេះឯង។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា អោ អាន ស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងឋានៈជាអ្នកទទួលខុសត្រូវជាន់ខ្ពស់ម្នាក់ និងថា មានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់គាត់ពីបទប្រល័យពូជសាសន៍ជនជាតិចាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក៏ដូចជាបទល្មើសជាតិដែលស្ថិតនៅក្រោមច្បាប់កម្ពុជាផងដែរ។ សហមេធាវីរបស់ អោ អាន និងសហព្រះរាជអាជ្ញាជាតិ បានដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំណែកសហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងការចោទប្រកាន់) របស់សហចៅក្រមស៊ើបអង្កេតជាតិ។ អង្គបុរេជំនុំជម្រះបានបើកសវនាការអសាធារណៈចំនួនបីថ្ងៃ ដើម្បីសម្រេចលើបណ្ដឹងឧទ្ធរណ៍នានាប្រឆាំងនឹងដីកាដំណោះស្រាយទាំងពីរ កាលពីថ្ងៃទី១៩, ២០ និង ២១ ខែមិថុនា ឆ្នាំ២០១៩។

នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានដាក់សេចក្ដីពិចារណារបស់ខ្លួន លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយទាំងនេះ។ អង្គបុរេជំនុំជម្រះបានប្រកាសជាឯកច្ឆន្ទថា "ការចេញដីកា

ដំណោះស្រាយពីរផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេតទាំងពីរ គឺខុសច្បាប់" ដោយសារតែអង្គបុរេជំនុំជម្រះ "មិនអាចរកសំឡេងគាំទ្រភាគច្រើនលើសលប់ ដែលតម្រូវឱ្យបួនសំឡេង ដើម្បីឈានដល់ការចេញសេចក្តីសម្រេច ផ្អែកលើសំអាងហេតុរួមគ្នាលើអង្គសេចក្តីបាននោះ" ចៅក្រមទាំងទាំងអស់បានភ្ជាប់នូវមតិយោបល់របស់ពួកគាត់រៀងៗខ្លួនជាមួយនឹងសេចក្តីពិចារណាជាឯកច្ឆន្ទនេះ[37]។

[37] គេហទំព័រ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងសំណុំរឿង ០០៤

# ជំពូកទី៤

# គុណសម្បត្តិ និងគុណវិបត្តិ

# នៃអង្គជំនុំជម្រះវិសាមញ្ញ

# ក្នុងតុលាការកម្ពុជា

# ជំពូកទី៤
# គុណសម្បត្តិ និងគុណវិបត្តិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ១. គុណសម្បត្តិ

### ១.១. ស្វែងរកយុត្តិធម៌ជូនដល់ជនរងគ្រោះនៃរបបខ្មែរក្រហម

ចាប់តាំងពីដំណើរការនៃអង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា មានប្រជាជនកម្ពុជាប្រមាណជាង ៣១,០០០ នាក់ដែលបានចូលរួមតាមដានទស្សនានូវរាល់ការកាត់ក្ដីទៅលើចុងចោទទាំងឡាយតាំងពីដើម រហូតមកដល់ពេលបច្ចុប្បន្ននេះ[38]។

យោងតាមការសិក្សាស្រាវជ្រាវ ប្រជាជនប្រមាណជា ៣.៣ លានអ្នកដែលបានបាត់បង់ជីវិតនារបប ខ្មែរក្រហមនេះ។ ប្រជាជនទូទាំងប្រទេសបានទទួលរងទុក្ខវេទនា បែកបាក់ក្រុមគ្រួសារ និងត្រូវផ្លាស់ប្ដូរទី លំនៅដែលខ្លួនស្នាក់អាស្រ័យទៅកន្លែងនានា ហើយត្រូវជួបប្រទះការស្រេកឃ្លានព្រោះគ្មានចំណីអាហារ បរិភោគគ្រប់គ្រាន់។ យ៉ាងណាមិញ ដោយមានការផ្ដល់ជំនួយពីបណ្ដាប្រទេសនានា និងកិច្ចព្រមព្រៀងផ្សេងៗ ពីអង្គការអន្តរជាតិអង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានដំណើរការដើម្បីស្វែងរកយុត្តិធម៌ ជូន បុគ្គលគ្រប់រូបមិនថាបុគ្គលដែលតស៊ូរស់រានមានជីវិតពីសម័យខ្មែរក្រហមនោះក្ដី និងបុគ្គលដែលស្លាប់បាត់បង់ ជីវិតរួចហើយក្ដី។ ប្រជាពលរដ្ឋគ្រប់រូបដែលជាជនរងគ្រោះនាសម័យខ្មែរក្រហមអាចឃើញការកាត់ក្ដីចំពោះ ជនល្មើសដោយផ្ទាល់ និងស្វែងរកយុត្តិធម៌ជូនសាច់ញាតិរបស់ខ្លួនដែលបានបែកបាក់ ឬបាត់បង់ជីវិតរួច ហើយក្ដី។ អង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា ផ្ដល់សិទ្ធិអោយបុគ្គលគ្រប់រូបក្នុងការដាក់ពាក្យបណ្ដឹង ដើម្បីផ្ដន្ទាទោសមេដឹកនាំខ្មែរក្រហមអោយទទួលខុសត្រូវរាល់ទង្វើប្រល័យពូជសាសន៍ដែលខ្លួនបានប្រព្រឹត្តទៅ លើប្រជាពលរដ្ឋទាំងឡាយដែលជួបប្រទះទុក្ខវេទនា និងស្លាប់បាត់បង់ជីវិតទៅហើយក្ដី។ ការកាត់ក្ដីខ្មែរក្រហម នេះ សបញ្ជាក់អំពីភាពសុក្រឹត្យភាពដែលតុលាការកម្ពុជានឹងកាត់ទោសរាល់បុគ្គលទាំងឡាយណាដែល ប្រព្រឹត្តអំពើខុសច្បាប់ ទោះបីអំពើនោះបានកន្លងផុតជាយូរទៅហើយក្ដី ក៍តុលាការនឹងផ្ដន្ទាទោសបុគ្គលនោះ ស្របតាមវិធានច្បាប់ដែលបានកំណត់ដែរ។ ការកាត់ទោសជនជាប់ចោទទាំងនេះ អាចធ្វើអោយជនរងគ្រោះ ទាំងឡាយបានរស់នៅដោយស្ងប់ចិត្ត លែងទទួលរងភាពភ័យខ្លាចនិងជាសះស្បើយពីស្លាកស្នាម និងអំពើ អយុត្តិធម៌ដែលបង្កឡើយដោយមេដឹកនាំខ្មែរក្រហមនាសម័យនោះ។

### ១.២. តម្លាភាពនៃតុលាការកម្ពុជា

តាមការបញ្ជាក់និងបកស្រាយពីខាងលើ អង្គជំនុំជម្រះវិសមញ្ញក្នុងតុលាកម្ពុជាគឺជាតុលាការកូនកាត់ ដែលមានចៅក្រម នឹងព្រះរាជអាជ្ញាទាំងក្នុងស្រុក និងបរទេស ដើម្បីកាត់ក្ដីជនជាប់ចោទទាំងឡាយដែលប្រព្រឹ

[38] ការណែនាំបំភ្លឺអំពីការជំនុំជម្រះក្ដីមេដឹកនាំខ្មែរក្រហម, ០១ សីហា ២០០៤

គួបទល្មើសប្រល័យពូជសាសន៍នាសម័យខ្មែរក្រហមនោះ។ ចៅក្រម ឬសហចៅក្រុមកម្ពុជាពុំមានសិទ្ធិកាត់ទោស ឬចេញសាលដីកាដោយឯងៗបានឡើយ។ ពោលគឺត្រូវមានការបោះឆ្នោត ឬការចូលរួមសម្រេចពីចៅក្រុមបរទេស។ ការកាត់ផ្តល់អតិភាពដល់ចៅក្រមបរទេស និងផ្តល់សិទ្ធិដល់ចៅក្រមបរទេសដើម្បីចេញសេចក្តីសម្រេចនេះ ជាកត្តាចំបងក្នុងការបញ្ជាក់ពីតម្លាភាពរបស់តុលាការកម្ពុជា ដែលតុលាការកម្ពុជាមិនកាត់ទោសទៅតាមតែនិន្នាការរបស់ខ្លួននោះទេ។

### ១.៣. ផ្នែកចំណេះដឹងទូទៅ

ចាប់តាំងពីពេលដំណើរការនៃអង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា មានការដាក់ពាក្យសំណុំឯកសារជាច្រើនពីសំណាក់ប្រជាជនដែលជួបប្រទះអំពើអយុត្តិធម៌នានា ដែលអាចក្លាយជាភស្តុតាងក្នុងការកាត់ក្តីមេដឹកនាំខ្មែរក្រហមទាំងឡាយ ដែលបានកោះហៅមកកាន់តុលាការខ្មែរក្រហមនេះ។ ពាក្យបណ្តឹងនីមួយៗបកស្រាយអំពីបទឧក្រិដ្ឋផ្សេងៗគ្នាជាច្រើនដែលមេដឹកនាំទាំងនោះបានប្រព្រឹត្តទៅលើប្រជាពលរដ្ឋ នៅក្នុងប្រទេសកម្ពុជានាសម័យនោះ។ ភស្តុតាងទាំងនេះ សបញ្ជាក់អំពីប្រវត្តិសាស្ត្រដល់ជូរចត់ និងសកម្មភាពនានាដែលជនរងគ្រោះបានជួបប្រទះនាសម័យខ្មែរក្រហមនោះ។ ជារួមអង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជាបានប្រមូលឯកសារជាច្រើនពីជនរងគ្រោះ ហើយផ្សព្វផ្សាយជូនប្រជាពលរដ្ឋជំនាន់ក្រោយសិក្សា និងយល់ដឹងពីសោធនាដកម្មដ៏ព្រៃផ្សៃរបស់ប្រទេសកម្ពុជានាសម័យនោះ។

ការផ្សព្វផ្សាយអំពីការកាត់ក្តីមេដឹកនាំនៅអង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជាក៏ បានបង្ហាញទិដ្ឋភាព សំណុំឯកសារ ភស្តុតាង និងសាលដីកានានា ជូនប្រជាពលរដ្ឋគ្រប់រូបអោយបានយល់ដឹងអំពីឃោរឃៅទាំងឡាយដែលមេដឹកនាំទាំងនោះបានធ្វើទៅលើប្រជាជនស្លូតត្រង់នាសម័យនោះ និងផ្តល់ជាដំបូន្មានដល់កូនខ្មែរជំនាន់ក្រោយកុំអោយប្រព្រឹត្តអំពើនេះដូចកាលពីរបបខ្មែរក្រហមនោះទៀត។ មិនតែប៉ុណ្ណោះ ការកាត់ក្តីនេះក៏ផ្តល់ជាដំបូន្មានដល់បុគ្គលគ្រប់អន្តរជាតិ ឬ រដ្ឋាភិបាលអន្តរជាតិនានាចូលតាមគន្លងចាស់នៃរបបខ្មែរក្រហម ដែលអាចបង្កើតសោធនាដកម្មដ៏ជូរចត់ទៅលើប្រជាជនរបស់ខ្លួន។

## ២. គុណវិបត្តិ

ទោះបីជា ការដំណើរការ អ.វ.ត.ក បានផ្តល់យុត្តិធម៌និង អត្ថប្រយោជន៍ជាច្រើនជូនប្រជាពលរដ្ឋកម្ពុជាក្តី ក៏តុលាការនេះមានគុណវិបត្តិដូចជា៖

### ២.១. ផ្នែកហិរញ្ញវត្ថុ

ការចំណាយថវិកាច្រើនដូចដែលបានបញ្ជាក់ពីខាងលើរួចមកហើយ ការកាត់ក្តីបានចំណាយអស់ថវិកាប្រមាណជាង ៥ លានដុល្លារសហរដ្ឋអាមេរិក ដែលជាហេតុធ្វើអោយហើយប្រាក់ជំនួយកាន់តែថយចុះទៅៗ។ ដូចដែលបានដឹងរួចមកហើយថា មានបុគ្គលិកទាំងថ្នាក់ជាតិ និងអន្តរជាតិដែលបានបម្រើការងារនៅ

តុលាការមួយនេះ ដូច្នេះការចំណាយទៅលើប្រាក់ខែ ក៏ដូចជាចំណាយផ្សេងៗក៏ត្រូវកើនឡើងច្រើនទៅតាមនេះដែរ ដំរាបណាការកាត់ក្តីមិនទាន់បានបញ្ចប់ជាស្ថាពរ។

**២.២. ការអូសបន្លាយពេលវេលា**

អង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា បានចាប់បង្កើតឡើងតាំងពីឆ្នាំ ២០០៦ រហូតមកដល់ពេលបច្ចុប្បន្ននេះ។ ការកាត់ក្តីបានបន្តអូសបន្លាយអស់រយៈពេលជាងដប់ឆ្នាំ ប៉ុន្តែការកាត់ក្តីនៅតែបន្តមិនទាន់ចប់នៅឡើយ។ គួរបញ្ជាក់ទៀតថា អ.វ.ត.ក ជាតុលាការកូនកាត់ដែលមានចៅក្រម និង ព្រះរាជអាជ្ញាបរទេស ដែលបណ្តាលអោយមានការមិនចុះសម្រុង និងមិនគាំទ្រលើគំនិតបុគ្គលរៀងៗខ្លួន ដែលធ្វើអោយដំណើរការនៃការកាត់ក្តីកាន់តែមានភាពអូសបន្លាយប៉ុន្តែសំណុំរឿងនៅតែមិនត្រូវបានបញ្ចប់ដោយជនជាប់ចោទនៅមានសិទ្ធិជំទាស់បន្តមិនឈប់ឈរ។

**២.៣. ផ្នែកចិត្តសាស្ត្រ**

របបកម្ពុជាប្រជាធិបតេយ្យ គឺជារបបប្រល័យសាសន៍ដ៏សាហាវព្រៃផ្សៃ ដែលប្រជាជនកម្ពុជាគ្រប់រូបបានជួបប្រទះនាកំឡុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩។ ជនរងគ្រោះរាប់លាននាក់បានទទួលរងនូវការប៉ះទង្គិចទៅលើផ្លូវចិត្ត និងសតិអារម្មណ៍យ៉ាងខ្លាំងខ្លាដែលបណ្តាលមកពីការជិះជាន់ ការធ្វើទារុណកម្ម និងការប៉ះពាល់ដល់សេពសន្ថវៈផ្សេងៗពីសំណាក់ថ្នាក់ដឹកនាំ ឬកងទ័ពរបស់របបកម្ពុជាប្រជាធិបតេយ្យនាសម័យនោះ។

ក្រោយការរំដោះនាថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ នោះមក ប្រជាជនគ្រប់រូបនាំគ្នាប្រកបរបចិញ្ចឹមជីវិតរៀងខ្លួន។ បុគ្គលមួយចំនួនចាប់ផ្តើមរស់នៅដូចសភាពដើម មុននឹងរបបខ្មែរក្រហមចូលមកវាយគ្រប់គ្រងក្នុងប្រទេស។ ទោះបីជាយ៉ាងនេះក្តី ស្នាមជិតដាមដែលជាប់នៅក្នុងខួរក្បាលរបស់ប្រជាជនគ្រប់រូប នៅតែមានជានិច្ច។ ការជីកកកាយយកនូវរឿងដែលហួសកន្លងហើយត្រឡប់មកវិញ គឺជាបញ្ហាចោទឡើងចំពោះជនរងគ្រោះ ដែលខិតខំបំភ្លេចនូវអតីតកាលដ៏សែនជូរចត់នោះ។ សំណុំរឿងនីមួយៗ សុទ្ធសឹងតែត្រូវរងភស្តុងតាង និងសាក្សីរស់ដើម្បីសិក្សាពីដំណើរដើមទង និងដើម្បីមកបំភ្លឺជាក់ច្បាស់នៅមុខសាលាជំបូងក្តី សាលាឧទ្ធរណ៍ក្តីឬ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្តី។ បុគ្គលមួយចំនួនត្រូវបានចូលសាកសួរ និង ត្រូវខិតខំរងចាំនូវទិដ្ឋភាពដល់សែនជូរចត់នោះត្រឡប់មកវិញដើម្បីជាភស្តុតាងក្នុងសំណុំរឿងនីមួយៗ។ កត្តានេះទាំងនេះហើយអាចប៉ះពាល់ដល់ផ្លូវចិត្តរបស់ជនរងគ្រោះ និងអាចបណ្តាលអោយមានការប៉ះពាល់ដល់សតិអារម្មណ៍ឬ អាចឈានដល់ការចងគំនុំដល់អ្នកដទៃផងដែរ។

# សេចក្តីសន្និដ្ឋាន

# និង

# ការផ្តល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន

យោងតាមការសិក្សាស្រាវជ្រាវយើងយល់ថា ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញនេះឡើងគឺមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ប្រជាជនកម្ពុជាទូទាំងប្រទេសដែលធ្លាប់ឆ្លងកាត់របបនេះ ឬក៏ធ្លាប់ឮថាមានរបបនេះ ក៏ត្រូវបានដឹងឮ និងចូលរួមតាមដានជាមួយនឹងដំណើរការរបស់តុលាការនេះដែរ ដើម្បីឱ្យតុលាការនេះកាន់តែមានភាពយុត្តិធម៌និងប្រកបដោយតម្លាភាពសម្រាប់ប្រជាជន ក៏ដូចជាជនរងគ្រោះទាំងអស់ផងដែរ ហើយក៏អាចបង្ហាញឱ្យសហគមន៍អន្តរជាតិបានដឹងថា ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ពិតជាអាចរកយុត្តិធម៌ជូនប្រជាជនបានតាមរយៈតុលាការនេះផងដែរ។

តាមរយៈការចរចារវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ អង្គជំនុំជម្រះវិសាមញ្ញនឹងចាប់ដំណើរការឆាប់ៗនេះ បើទោះបីជាប្រើរយៈពេលយូរបន្តិច ដោយសារតែប្រទេសយើងជួបប្រទះនូវបញ្ហាមួយចំនួនក៏ដោយ។ ទោះជានៅឆ្នាំ១៩៧៩ តុលាការបដិវត្តន៍ប្រជាជនបានកាត់ក្តីចំពោះមេដឹកនាំខ្មែរក្រហមមួយចំនួនហើយក្តី ប៉ុន្តែការកាត់ទោសនោះមានលក្ខណៈកំបាំងមុខ មានន័យថាភាគីជនជាប់ចោទមិនបានបង្ហាញខ្លួននៅចំពោះមុខតុលាការទេ។

ទោះជាមានបញ្ហាមួយចំនួនបានកើតឡើង ក៏រាជរដ្ឋាភិបាលកម្ពុជាបានពុះពារព្យាយាមធ្វើការឆ្លើយឆ្លងតាមសារលិខិតជាមួយអង្គការសហប្រជាជាតិតាំងពីឆ្នាំ១៩៩៧ រហូតដល់ឆ្នាំ២០០៤ ដែលរាជរដ្ឋាភិបាលកម្ពុជាបានចុះកិច្ចព្រមព្រៀងជាមួយអង្គការសហប្រជាជាតិ ហើយបានធ្វើវិសោធនកម្មច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញដែលច្បាប់នេះត្រូវបានសភាជាតិអនុម័តតាំងពីឆ្នាំ២០០១ មកម្ល៉េះ។ ឆ្លងកាត់ការចាំអស់រយៈកាលជាង២៥ឆ្នាំ ទើបបានលេចចេញរូបរាងជាស្រមោលរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលប្រជាជនកម្ពុជាទន្ទឹមរងចាំ ដោយសារតែការឈឺចាប់មិនអាចបំភ្លេចបាន នូវទង្វើដែលពួកមេដឹកនាំទាំងនោះបានប្រព្រឹត្តក្នុងរយៈកាលដែលខ្លួនកាន់កាប់។ មជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរទួលស្លែង បណ្ណាសារដ្ឋានជាតិ និងទីកន្លែងមួយចំនួនទៀតនៅក្នុងប្រទេសកម្ពុជា បានបន្សល់ទុកនូវភស្តុតាង និងមធ្យោបាយដែលត្រូវបានប្រើប្រាស់ជាច្រើនលើកច្រើនសារ ហើយដែលជាទិដ្ឋភាពមួយមិនអាចរំលងបាន។

ប្រជាជនកម្ពុជាយើងនឹងយល់កាន់តែច្បាស់អំពីដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម តាមរយៈច្បាប់ស្តីពី ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ដែលបានបង្ហាញពីធាតុនីត្យានុកូល ដែលជាធាតុផ្សំមួយក្នុងចំណោមធាតុផ្សំទាំងបីនៃបទល្មើសដែលនឹងត្រូវធ្វើការចោទប្រកាន់ចំពោះមេដឹកនាំទាំងនោះ។ ក្នុងចំណោមមេដឹកនាំរបស់របបកម្ពុជាប្រជាធិបតេយ្យ មានមួយចំនួននឹងត្រូវចោទប្រកាន់ពីបទមនុស្សឃាត ការធ្វើទារុណកម្ម ការវាយប្រហារលើសាសនា បទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង

ឧក្រិដ្ឋកម្មសង្គ្រាមជាដើម។ ហើយអ្នកទាំងនោះនឹងត្រូវប្រឈមមុខចំពោះតុលាការ និងប្រជាជនជាច្រើននៅពេលតុលាការបើកសវនាការ។

រាល់អំពើដែលពួកមេដឹកនាំខ្មែរក្រហមបានធ្វើអាចនាំឱ្យពួកគេធ្វើការទទួលខុសត្រូវចំពោះបទល្មើសដែលពួកគេបានប្រព្រឹត្ត និងចំពោះមុខច្បាប់ អាចនឹងត្រូវជាប់ពន្ធនាគារអស់មួយជីវិត ហើយនឹងត្រូវរឹបអូសទ្រព្យសម្បត្តិរបស់ពួកគេ ដែលបានមកពីអំពើខុសច្បាប់របស់គេផងដែរ។ ទាំងនេះ គឺជាអ្វីដែលប្រជាជនចង់បាន និងរង់ចាំតាមដានមើលដំណើរការរបស់តុលាការនេះនៅពេលអនាគតដ៏ខ្លីខាងមុខ។ ទាំងនេះគឺវាមានសារៈសំខាន់ណាស់ក្នុងការចូលរួមជាមួយដំណើរការតុលាការខ្មែរក្រហមនេះហើយក៏ជាការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះដែលបានស្លាប់ និងអ្នកដែលនៅរស់រានមានជីវិត។

# ការផ្តល់អនុសាសន៍

ក្នុងនាមយើងខ្ញុំជានិស្សិត យើងសូមចូលរួមមតិយោបល់មួយចំនួន ចំពោះតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ដូចជា :

- ផ្តល់ឱកាសឱ្យប្រជាជនដែលជាជនរងគ្រោះចូលរួមស្តាប់សវនាការ និងតាមដានរាល់ពេលមានសវនាការម្តងៗ ព្រោះអ្នកទាំងនោះជាជនដែលត្រូវតែបានដឹង តើការកាត់ក្តីរបស់តុលាការនេះត្រឹមត្រូវដូចអ្វីដែលពួកគេចង់បានដែរឬទេ?

❖ បើកចំហដល់មជ្ឈដ្ឋានអន្តរជាតិ ក្នុងការយកពត៌មានដែលមានលក្ខណៈត្រឹមត្រូវ
❖ លើកទឹកចិត្តឱ្យប្រជាជនចូលរួមតាមដានអំពីដំណើរការរបស់តុលាការកាត់ទោសខ្មែរក្រហមនេះ ព្រោះកាលណាមានការគាំទ្រពីប្រជាជន នាំឱ្យតុលាការនោះមានភាពយុត្តិធម៌ស្របតាមឆន្ទៈរបស់ពួកគេ
❖ ប្រជាជនទាំងនោះមានឱកាសនិយាយពីការឈឺចាប់របស់ពួកគេដើម្បីឱ្យធូរស្រាលក្នុងខ្លួន
❖ ការពាររាល់ទង្វើដែលជាអតីតកាលកុំឱ្យត្រលប់មកវិញតាមរយៈការថែរក្សាចងក្រងជាឯកសារ ឬការនិយាយតៗគ្នាសម្រាប់ក្មេងជំនាន់ក្រោយបានដឹងបានយល់ពីការឈឺចាប់របស់ប្រជាជនកម្ពុជា។

# ឯកសារយោង

# ឯកសារយោង


1. ច្បាប់ស្តីពីការបង្កើតអោយមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, លេខ នស/រកម/១០០៤/០០៦, ២៧ តុលា ២០០៤
2. ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦
3. ព្រះរាជក្រឹត្យ នស/រតក/១១០៥/៤៦២ តែងតាំងជាលោក ស៊ាន វិសុទ្ធ ប្រធានការិយាល័យរដ្ឋបាល និងលោក ហែម ក្រាញ់ តូនី ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២
4. ព្រះរាជក្រឹត្យ នស/រតក/១១០៥/៤៦៦ តែងតាំងលោកស្រី Michelle Lee ជាអនុប្រធានការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២
5. ព្រះរាជក្រឹត្យ នស/រតក/០១០៩/១២៧ តែងតាំងលោកស្រី Florence Mumba ជាចៅក្រមអន្តរជាតិបំរុងនៅអង្គជំនុំជម្រះនៃអង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៩ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, គេហទំព័រ: https://www.eccc.gov.kh/en
6. វិធានផ្ទៃក្នុងនៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (វិសោធនកម្មលើកទី៩ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥
7. កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់ក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ ២០០៣
8. សេចក្តីសម្រេចនៃសំណុំរឿង ០០១ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១០
9. សាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤
10. ដីកាសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការត្រួតពិនិត្យដោយកំបាំងមុខ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥
11. សេង ឌីណា (០៣ កុម្ភៈ ២០១២), ប្រវត្តិសង្ខេបរបស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច, RFI, គេហទំព័រ: https://www.rfi.fr/km/biography-of-duch
12. Seth Mydans (០១ កញ្ញា ២០២០), Duch, Prison Chief Who Slaughtered for the Khmer Rouge,Dies at 77, គេហទំព័រ: https://www.nytimes.com/2020/09/01/world/asia/duch-kaing-guek-eav-dead.html
13. សេង ឌីណា (២០ កញ្ញា ២០១១), ប្រវត្តិរបស់ នួន ជា "បងទីពីរ" នៃរបបខ្មែរក្រហម, RFI, គេហទំព័រ: https://www.rfi.fr/km/biography-of-nuon-chea

14. សេង ឌីណា (១៣ តុលា ២០១១), ប្រវត្តិរបស់ខៀវ សំផន ភាគទី១, RFI, គេហទំព័រ: https://www.rfi.fr/km/cambodia/20111013-Biographie%20de%20Khiev%20Samphan %20partie%201
15. ជីវប្រវត្តិសង្ខេបលោក អៀង សារី, ភ្នំពេញប៉ុស្តិ៍ , ១៥ មីនា ២០១៣, គេហទំព័រ: https://www.postkhmer.com/ព័ត៌មានជាតិ/ប្រវត្តិរូបសង្ខេបអៀង-សារី
16. សារ៉ា, លោកស្រីអៀង ធីរិទ្ធ អះអាងថា មានបញ្ហាជង្គង់ ខណៈនួន ជា សន្សាចូលសវនាការពេលមានសុខភាពល្អ (៣០ សីហា ២០១១), កោះសន្តិភាព, គេហទំព័រ: https://kohsantepheapdaily.com.kh/article/24126.html
17. អៀង ធីរិទ្ធ ទទួលមរណភាពក្នុងជន្មាយុ៨៣ឆ្នាំ (២២ សីហា ២០១៥,RFI), គេហទំព័រ: https://www.rfi.fr/km/cambodia/eng-thearith-dead-at-83-22-08-2015
documents/Internal_Rules_Rev_9-KH.pdf
18. United Nations Assistance to the Khmer Rouge Trials (UNAKRT): https://www.eccc.gov.kh/km/node/12076
19. United Nations Development Programme (UNDP): https://www.eccc.gov.kh/km/node /12075
20. ការរៀបចំនិងការប្រព្រឹត្តទៅនៃការចូលរួមរបស់ជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា: https://www.eccc.gov.kh/km/organs/qnggbhaabgaambaarjnrnggrooh
21. មាស បូរ៉ា, សង្ខេបយុត្តិសាស្ត្រ សំណុំរឿងលេខ ០០១, អង្គជំនុំជម្រះសាលាដំបូង, សេចក្តីសម្រេចស្តីពី ងញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ដែលលើកឡើងដោយមេធាវីការពារក្តី, ២៦ ខែ កក្កដា ឆ្នាំ ២០១០, គេហទំព័រ: https://www.bakc.org.kh/images/bulletins/Summarize%20case%20001-ECCC%20by%20Meas%20Bora.pdf
22. Asser Institute Centre for International & European Law, គេហទំព័រ: https://www.asser.nl/nexus/international-criminal-law/the-history-of-icl/hybrid-courts/

# ឧបសម្ព័ន្ធ

ការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញមានតួនាទីផ្តល់សេវាកម្មដល់អង្គជំនុំជម្រះ សហចៅក្រមស៊ើបអង្កេត ការិយាល័យសហព្រះរាជអាជ្ញា និងការិយាល័យផ្សេងទៀត ។



# កាលប្បវត្តិនៃការបង្កើត អ.វ.ត.ក

**១៧ មេសា ១៩៧៥** — ខ្មែរក្រហមដែលដឹកនាំដោយ ប៉ុល ពត បានកាន់កាប់អំណាចនៅកម្ពុជា។ ប្រជាជនកម្ពុជាជាង១,៧លាននាក់ត្រូវបានសម្លាប់មុនពេលដែលរបបនេះត្រូវបានផ្ដួលរំលំនៅថ្ងៃ ៧ មករា ១៩៧៩។

**១៥ សីហា ១៩៧៩** — តុលាការប្រជាជនបដិវត្តន៍កម្ពុជាបានជំនុំជម្រះ អៀង សារី និង ប៉ុល ពត ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ តុលាការនេះពុំមានការទទួលស្គាល់ពីសហគមន៍អន្តរជាតិទេ ព្រោះវាពុំមានបទដ្ឋានយុត្តិធម៌អន្តរជាតិ។

**២១ មិថុនា ១៩៩៧** — រាជរដ្ឋាភិបាលកម្ពុជាស្នើទៅ អ.ស.ប សុំជំនួយអន្តរជាតិដើម្បីបង្កើតតុលាការមួយកាត់សេចក្ដីអតីតមេដឹកនាំខ្មែរក្រហម។

**១៥ មីនា ១៩៩៩** — អ្នកជំនាញ អ.ស.ប លើកសំណើអំពីតុលាការសិទ្ធិមនុស្សមួយនៅក្រៅប្រទេសកម្ពុជា ដោយយកគំរូតាមតុលាការឧក្រិដ្ឋកម្មសម្រាប់ប្រទេសផ្សេងទៀត។ រាជរដ្ឋាភិបាលកម្ពុជាបដិសេធសំណើនេះ ហើយការចរចាបានអូសបន្លាយពេលវេលាយ៉ាងវែង។

**១០ សីហា ២០០១** — **ច្បាប់ស្ដីពីការបង្កើត**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានប្រកាស ក៏ប៉ុន្តែ អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជាពុំទាន់ឈានដល់កិច្ចព្រមព្រៀងនៅឡើយទេ។

**៨ កុម្ភៈ ២០០២** — អ.ស.ប បានប្រកាសដកខ្លួនចេញពីការចរចាជាមួយរាជរដ្ឋាភិបាលកម្ពុជា អំពីតុលាការខ្មែរក្រហម។

**៦ មិថុនា ២០០៣** — នៅរាជធានីភ្នំពេញ រាជរដ្ឋាភិបាលកម្ពុជានិង អ.ស.ប បានចុះហត្ថលេខាលើ**កិច្ចព្រមព្រៀង**ស្ដីពីការជំនុំជម្រះក្ដីនៅក្រោមច្បាប់កម្ពុជាចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងក្រោមរបបកម្ពុជាប្រជាធិបតេយ្យ។

**២៧ តុលា ២០០៤** — សេចក្ដីប្រកាសអំពីវិសោធនកម្មលើច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

**១៨ មករា ២០០៦** — រាជរដ្ឋាភិបាលកម្ពុជាប្រគល់ឲ្យ អ.វ.ត.ក នូវទីតាំងមួយកន្លែងដែលស្ថិតនៅជាប់នឹងអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ។

**៨ កុម្ភៈ ២០០៦** — បុគ្គលិកបានចូលធ្វើការជាលើកដំបូងបំផុត។

**៣ កក្កដា ២០០៦** — ចៅក្រមជាតិនិងអន្តរជាតិធ្វើពិធីស្បថចូលកាន់តំណែង។

**១២ មិថុនា ២០០៧** — អ.វ.ត.ក អនុម័ត**វិធានផ្ទៃក្នុង** ដើម្បីឲ្យតុលាការដំណើរការបានយ៉ាងពេញលេញ។

# ឧបសម្ព័ន្ធ ១

ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញបូកជាមួយច្បាប់វិសោធនកម្មដែលបាន ប្រកាសឱ្យប្រើ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/០០៦)

# ច្បាប់

# ស្ដីពី

# ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដី ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាល នៃកម្ពុជាប្រជាធិបតេយ្យ

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោស មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិនិងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអម្លុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩។

## ជំពូកទី ២

## សមត្ថកិច្ច

**មាត្រា ២ ថ្មី.-**

ត្រូវបានបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់ ពោលគឺសាលាដំបូង និង តុលាការកំពូល ដើម្បីជំនុំជម្រះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជា ដែលពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋ ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និង ទម្លាប់អន្តរជាតិ និងការរំលោភទៅលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអម្លុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ ថ្ងៃ ៦ មករា ១៩៧៩។

មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង អ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើឧក្រិដ្ឋខាងលើនេះ ហៅថា "ជនសង្ស័យ"។

**មាត្រា ៣ ថ្មី.-**

អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យ ដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃ ៦ មករា ឆ្នាំ ១៩៧៩ :

- មនុស្សឃាត មាត្រា ៥០១. ៥០៣. ៥០៤. ៥០៥. ៥០៦. ៥០៧ និងមាត្រា ៥០៨
- ទារុណកម្ម មាត្រា ៥០០
- ការវាយប្រហារលើសាសនា មាត្រា ២០៩ និងមាត្រា ២១០។

អាជ្ញាយុកាលនៃបណ្តឹងអាជ្ញានៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែលទាក់ទងដល់បទល្មើសខាងលើ ត្រូវបានពន្យាពេលបន្ថែម ៣០ ឆ្នាំទៀត ទៅលើអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាសម្រាប់ឧក្រិដ្ឋកម្មទាំងឡាយខាងលើ ដែលស្ថិតក្នុងសមត្ថកិច្ចនៃអង្គជំនុំជម្រះវិសាមញ្ញ។

ទោសប្បញ្ញត្តិចែងក្នុងមាត្រា ២០៩, ៥០០, ៥០៦ និងមាត្រា ៥០៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ត្រូវកំណត់ថាអតិបរិមាត្រឹមទោសដាក់ពន្ធនាគារអស់មួយជីវិត អនុលោមតាមមាត្រា ៣២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ ម្ពុជា និងបញ្ជាក់បន្ថែមដោយមាត្រា ៣៨ និងមាត្រា ៣៩ ថ្មី នៃច្បាប់នេះ។

**មាត្រា ៤.-**

អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យទាំងឡាយដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដូចមានចែងក្នុងអនុសញ្ញាឆ្នាំ ១៩៤៨ ស្តីពីការបង្ការនិងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ហើយ ដែលបានប្រព្រឹត្ត ក្នុងអំឡុងថ្ងៃ ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃ ៦ ខែ មករា ឆ្នាំ ១៩៧៩។

អំពើប្រល័យពូជសាសន៍ដែលគ្មានអាជ្ញាយុកាល គឺជាអំពើមួយក្នុងចំណោមអំពើដូចខាងក្រោមហើយដែលបានប្រព្រឹត្តក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយដូចជា :

- ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម
- ការធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬ សតិបញ្ញាសមាជិកនៃក្រុម

- ការធ្វើដោយចេតនាឱ្យក្រុមនេះ ទទួលរងនូវស្ថានភាពរស់នៅមួយដែលបានរៀបចំឡើង សម្រាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុង ឬមួយផ្នែក
- ការដាក់នូវវិធានការនានា ដែលមានបំណងរារាំងមិនឱ្យមានការផ្ដល់កំណើតទារក
- ការបញ្ជូនកុមារដោយបង្ខំ ពីក្រុមមួយទៅឱ្យក្រុមមួយផ្សេងទៀត។

បទល្មើសខាងក្រោមត្រូវផ្ដន្ទាទោសដូចបទល្មើសខាងលើដែរ :

- ការប៉ុនប៉ងប្រព្រឹត្តអំពើប្រល័យពូជសាសន៍
- ការសមគំនិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍
- ការចូលរួមប្រព្រឹត្តអំពើប្រល័យពូជសាសន៍។

**មាត្រា ៥**.-

អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យទាំងឡាយ ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងអំឡុងថ្ងៃ ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃ ៦ ខែមករា ឆ្នាំ ១៩៧៩។

ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលគ្មានអាជ្ញាយុកាលគឺអំពើណាមួយដូចខាងក្រោម ដែលវាយប្រហារជាទូទៅ ឬដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិលដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា ណាមួយដូចជា :

- ការធ្វើមនុស្សឃាត
- ការសម្លាប់រង្គាល
- ការធ្វើឱ្យទៅជាទាសករ
- ការនិរទេស
- ការដាក់ក្នុងមន្ទីរឃុំឃាំង
- ការធ្វើទារុណកម្ម
- ការរំលោភលើផ្លូវភេទ
- ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា
- អំពើអមនុស្សធម៌ផ្សេងៗទៀត។

**មាត្រា ៦**.-

អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យដែលបានប្រព្រឹត្ត ឬបានបញ្ជាឱ្យប្រព្រឹត្តអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ដូចជាអំពើប្រឆាំង

មនុស្ស ឬទ្រព្យសម្បត្តិ ដែលត្រូវការពារដោយបទប្បញ្ញត្តិនៃអនុសញ្ញានេះ ហើយដែបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ ៦ ខែមករា ឆ្នាំ១៩៧៩ :

- ការធ្វើមនុស្សឃាតដោយចេតនា
- ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌
- ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព
- ការបំផ្លាញ ឬធ្វើឱ្យខូចខាតធ្ងន់ធ្ងរទៅលើទ្រព្យសម្បត្តិ ដោយមិនមានហេតុផលចាំបាច់ខាងយោធា ដែល ធ្វើឡើងដោយខុសច្បាប់ និងគ្មានត្រាប្រណី
- ការបង្ខំឱ្យឈ្លើយសឹក ឬជនស៊ីវិល បម្រើការនៅក្នុងកងកម្លាំងរបស់គូបដិបក្ខ
- ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយ យុត្តិធម៌ និងទៀងទាត់
- ការនិរទេស ការជន្លៀស ឬការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់
- ការយកជនស៊ីវិលជាចំណាប់ខ្មាំង ។

**មាត្រា ៧.-**

អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យទាំងឡាយ ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ក្នុងពេលមានជម្លោះប្រដាប់អាវុធ យោងតាមអនុសញ្ញាក្រុងឡាអេ ឆ្នាំ១៩៥៤ ស្តីពីការការពារសម្បត្តិ វប្បធម៌នៅក្នុងពេលមានជម្លោះប្រដាប់អាវុធ ហើយដែលបាន ប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ ៦ ខែមករា ឆ្នាំ១៩៧៩ ។

**មាត្រា ៨.-**

អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះបទឧក្រិដ្ឋប្រឆាំងទៅលើអ្នកដែលទទួលបានការការពារជាអន្តរជាតិ យោងតាមអនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦១ ស្តីពីទំនាក់ទំនងការទូតហើយ ដែលបានប្រព្រឹត្ត ក្នុងអំឡុងថ្ងៃ ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ ៦ ខែ មករា ឆ្នាំ១៩៧៩ ។

## ជំពូកទី ៣

## សមាសភាពរបស់អង្គជំនុំជម្រះវិសាមញ្ញ

**មាត្រា ៩ ថ្មី.-**

សាលាដំបូងជាអង្គជំនុំជម្រះវិសាមញ្ញដោយចៅក្រមវិជ្ជាជីវៈប្រាំរូប ដែលរួមមានចៅក្រមខ្មែរបីរូប មួយរូបធ្វើជាប្រធាន និងមានចៅក្រមបរទេសពីររូប និងមានក្រឡាបញ្ជីមួយរូប ឬច្រើនរូប តាមការចាត់តាំងរបស់ប្រធានចូលរួម ព្រមទាំងមានសហព្រះរាជអាជ្ញាដែលត្រូវដាក់ពាក្យប្តឹងនៅចំពោះមុខសាលាដំបូងនេះ ។

តុលាការកំពូលដែលជាកន្លែងទទួលពាក្យបណ្តឹងឧទ្ធរណ៍ផងនិងសម្រេចសេចក្តីចុងក្រោយផង ជាអង្គជំនុំជម្រះវិសាមញ្ញដោយចៅក្រមប្រាំពីររូប ដែលរួមមាន ចៅក្រមខ្មែរបួនរូប ដែលមួយរូបធ្វើជាប្រធាន និង ចៅក្រមបរទេសបីរូប និង មានក្រឡាបញ្ជីមួយរូប ឬច្រើនរូប តាមការចាត់តាំងរបស់ប្រធានចូលរួម ប្រមទាំងមានសហព្រះរាជអាជ្ញាដែលត្រូវដាក់ពាក្យប្តឹងនៅចំពោះមុខតុលាការកំពូលនេះ ។

## ជំពូកទី ៤

## ការតែងតាំងចៅក្រមជម្រះក្តី

### មាត្រា ១០ ថ្មី.-

ចៅក្រមជម្រះក្តីនៃអង្គជំនុំជម្រះវិសាមញ្ញ ត្រូវបានជ្រើសតាំងក្នុងចំណោមចៅក្រមក្នុងតំណែងបច្ចុប្បន្ន និងចៅក្រមដែលបានជ្រើសតាំងបន្ថែមតាមនីតិវិធីនៃការជ្រើសតាំងចៅក្រមជាធរមាន ហើយដែលមានចរិតលក្ខណៈនិងស្មារតីខ្ពស់ មិនលំអៀង និងសុចរិត មានបទពិសោធន៍ក្នុងការងារជំនាញ ជាពិសេសខាងច្បាប់ព្រហ្មទណ្ឌ ឬច្បាប់អន្តរជាតិ ក្នុងនោះរួមមាន ច្បាប់មនុស្សធម៌អន្តរជាតិ និង ច្បាប់សិទ្ធិមនុស្សផង ។

ចៅក្រមជម្រះក្តីត្រូវឯករាជ្យក្នុងការបំពេញការងាររបស់ខ្លួន ហើយមិនត្រូវទទួល ឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬពីប្រភពណាមួយផ្សេងទៀតឡើយ ។

### មាត្រា ១១ ថ្មី.-

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងចៅក្រមខ្មែរយ៉ាងតិចប្រាំពីររូប ឱ្យធ្វើជាចៅក្រមជម្រះក្តីសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ និងជ្រើសតាំងចៅក្រមជម្រះក្តីបម្រុងមួយចំនួនតាមតម្រូវការ ព្រមទាំងត្រូវជ្រើសតាំងផងដែរនូវប្រធាននៃអង្គជំនុំជម្រះវិសាមញ្ញក្នុងចំណោមចៅក្រមខ្មែរខាងលើ តាមនីតិវិធីនៃការជ្រើសតាំងចៅក្រមជាធរមាន ។

ចៅក្រមបម្រុងខ្មែរត្រូវជំនួស ចៅក្រមជម្រះក្តីខ្មែរពេញសិទ្ធិ នៅពេលដែលចៅក្រមនេះអវត្តមាន ឬមានធុរៈ ។ ចៅក្រមជម្រះក្តីទាំងនេះ អាចបន្តបំពេញការងារប្រចាំថ្ងៃ នៅក្នុងសាលាជម្រះក្តីដែលខ្លួនកំពុងបំពេញ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងយ៉ាងតិច បុគ្គលប្រាំរូប ដែលមានសញ្ជាតិបរទេស ឱ្យធ្វើជាចៅក្រមជម្រះក្តីបរទេសសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ក្រោយពីការជ្រើសរើសឱ្យឈរឈ្មោះដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវរៀបចំបញ្ជីបេក្ខជនជាចៅក្រមបរទេស ដែលមានចំនួនយ៉ាងតិចប្រាំពីររូប ជូនរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ហើយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំង

ចៅក្រមពេញសិទ្ធិប្រាំរូប និងចៅក្រមបម្រុងយ៉ាងតិចពីររូបពីក្នុងបញ្ជីឈ្មោះនោះ។ បន្ថែមពីលើចៅក្រមបរទេស ដែលចូលរួមក្នុងអង្គជំនុំជម្រះវិសាមញ្ញ និងដែលមានវត្តមាននៅគ្រប់ដំណាក់កាលនៃដំណើរការជំនុំជម្រះ ប្រធានអង្គជំនុំជម្រះវិសាមញ្ញ អាចចាត់តាំងតាមករណីនីមួយៗ នូវចៅក្រមបម្រុងមួយរូប ឬច្រើនរូប ដែលត្រូវបានជ្រើសរើសរួចហើយ ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមឱ្យមានវត្តមាននៅដំណាក់កាលជំនុំជម្រះនីមួយៗ ហើយឱ្យជំនួសចៅក្រមបរទេស ប្រសិនបើចៅក្រមរូបនោះ ពុំមានលទ្ធភាពអាច បន្តការជំនុំជម្រះតទៅទៀតបាន។

**មាត្រា ១២.-**

ចៅក្រមជម្រះក្តីទាំងអស់ ដែលស្ថិតក្រោមច្បាប់នេះ មានឋានៈ និងលក្ខខណ្ឌការងារស្មើៗគ្នាទៅតាមលំដាប់ថ្នាក់នៃអង្គជំនុំជម្រះវិសាមញ្ញនីមួយៗ។

ចៅក្រមជម្រះក្តីមួយរូបៗត្រូវបានជ្រើសតាំងសម្រាប់រយៈពេលនៃការជំនុំជម្រះ។

**មាត្រា ១៣.-**

ចៅក្រមជម្រះក្តីត្រូវមានបុគ្គលិកខ្មែរ និងបុគ្គលិកអន្តរជាតិជាជំនួយការ ទៅតាមតម្រូវការជាក់ស្តែងសម្រាប់បម្រើការងារនៅការិយាល័យរបស់ខ្លួន។

ក្នុងការជ្រើសរើសបុគ្គលិកជាជំនួយការ និងអ្នកជំនួយការច្បាប់ ប្រធានការិយាល័យរដ្ឋបាលត្រូវធ្វើសម្ភាសន៍ក្នុងករណីចាំបាច់ និងត្រូវមានការយល់ព្រមដោយមតិភាគច្រើនពីចៅក្រមខ្មែរ ក្នុងការជួលបុគ្គលិកដែលនឹងត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា។ អនុប្រធានការិយាល័យរដ្ឋបាលត្រូវមានភារកិច្ចទទួលខុសត្រូវចំពោះការជ្រើសរើស និងការគ្រប់គ្រងបុគ្គលិកអន្តរជាតិទាំងអស់។ ចំនួនបុគ្គលិក និងអ្នកជំនួយការច្បាប់ត្រូវជ្រើសរើសទៅតាមសមាមាត្រនៃចៅក្រមខ្មែរ និងចៅក្រម បរទេស។

បុគ្គលិកជាជំនួយការខ្មែរត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការក្នុងក្របខ័ណ្ឌរដ្ឋ ឬ ជនជាតិខ្មែរដ៏ទៃទៀតដែលមាន សមត្ថភាពក្នុងករណីចាំបាច់។

## ជំពូកទី ៥

## ការសម្រេចសេចក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញ

**មាត្រា ១៤ ថ្មី.-**

១-ចៅក្រមទាំងអស់ត្រូវព្យាយាមសម្រេចឱ្យបានភាពឯកច្ឆ័ន្ទក្នុងសេចក្តីសម្រេចរបស់ខ្លួន។ ប្រសិនបើភាពឯកច្ឆ័ន្ទនេះ ពុំអាចរកបានទេ ត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម :

ក/ ការសម្រេចសេចក្តីដោយអង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូង តម្រូវឱ្យមានការបោះឆ្នោតគាំទ្រពីចៅក្រមបួនរូបយ៉ាងតិច ។

ខ/ ការសម្រេចសេចក្តីដោយអង្គជំនុំជម្រះវិសាមញ្ញរបស់តុលាការកំពូល តម្រូវឱ្យមានការបោះឆ្នោតគាំទ្រពីចៅក្រមប្រាំរូបយ៉ាងតិច ។

២-នៅពេលដែលពុំមានឯកភាពឯកច្ឆ័ននោះទេ សេចក្តីសម្រេចនៃអង្គជំនុំជម្រះត្រូវកត់ត្រាទុកនូវយោបល់របស់មតិភាគច្រើន និងមតិភាគតិច ។

**មាត្រា ១៥.-**

ប្រធានត្រូវធ្វើការកោះប្រជុំចៅក្រមដែលបានតែងតាំង នៅក្នុងរយៈពេលសមស្របដើម្បីដំណើរការងារនៃអង្គជំនុំជម្រះវិសាមញ្ញ ។

## ជំពូកទី ៦

## សហព្រះរាជអាជ្ញា

**មាត្រា ១៦.-**

រាល់ការសន្និដ្ឋានចោទប្រកាន់ជូនទៅអង្គជំនុំជម្រះវិសាមញ្ញ គឺជាការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញាពីរនាក់ ម្នាក់ជាកម្ពុជា និងម្នាក់ទៀតជាបរទេសដែលហៅថា "សហព្រះរាជអាជ្ញា" ដែលត្រូវធ្វើការរួមគ្នាដើម្បីរៀបចំឯកសារ និងធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ជនសង្ស័យសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ។

**មាត្រា ១៧ ថ្មី.-**

សហព្រះរាជអាជ្ញានៃសាលាដំបូងមានសិទ្ធិប្តឹងឧទ្ធរណ៍ ពីសេចក្តីសម្រេចនៃអង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូង។

**មាត្រា ១៨ ថ្មី.-**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងព្រះរាជអាជ្ញា និងព្រះរាជអាជ្ញាបម្រុងខ្មែរមួយចំនួនតាមតម្រូវការពីក្របខ័ណ្ឌចៅក្រមវិជ្ជាជីវៈខ្មែរ ។

ព្រះរាជអាជ្ញាបម្រុងត្រូវជំនួសព្រះរាជអាជ្ញាពេញសិទ្ធិ នៅពេលដែលព្រះរាជអាជ្ញានោះអវត្តមាន ឬមានធុរៈ ។

ព្រះរាជអាជ្ញាទាំងនេះអាចបន្តបំពេញការងារប្រចាំថ្ងៃនៅក្នុងសាលាជំនុំជម្រះក្តីដែលខ្លួនកំពុងបំពេញ ។

ព្រះរាជអាជ្ញាបរទេសមួយរូប ដែលមានសមត្ថកិច្ចបង្ហាញខ្លួនក្នុងគ្រប់លំដាប់ថ្នាក់ នៃអង្គជំនុំជម្រះវិសាមញ្ញ ត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រោយពីការជ្រើសរើសឱ្យឈរឈ្មោះដោយ អគ្គលេខាធិការអង្គការសហប្រជាជាតិ ។

អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវរៀបចំបញ្ជីបេក្ខជនយ៉ាងតិចពីររូប ជាសហព្រះរាជអាជ្ញាបរទេស ជូនរាជរដ្ឋាភិបាលកម្ពុជា ហើយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងព្រះរាជអាជ្ញាពេញសិទ្ធិមួយរូប និង ព្រះរាជអាជ្ញាបម្រុង មួយរូប ចេញពីបញ្ជីបេក្ខជននេះ ។

## មាត្រា ១៩.-

សហព្រះរាជអាជ្ញាត្រូវបានជ្រើសតាំងក្នុងចំណោមបុគ្គលទាំងឡាយ ដែលបានជ្រើសតាំងតាមនីតិវិធីនៃការជ្រើសតាំងព្រះរាជអាជ្ញា ហើយដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់ សុចរិតនិងមានបទពិសោធន៍ជំនាញក្នុងការធ្វើការស៊ើបអង្កេត និងក្នុងការចោទប្រកាន់រឿងក្តីព្រហ្មទណ្ឌ ។

សហព្រះរាជអាជ្ញាត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន និងមិនត្រូវទទួល ឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬប្រភពណាមួយផ្សេងទៀតឡើយ ។

## មាត្រា ២០ ថ្មី.-

សហព្រះរាជអាជ្ញាត្រូវធ្វើការចោទប្រកាន់ដោយអនុវត្តតាមនីតិវិធីដែលនៅជាធរមាន ។ ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬ អនុវត្តនីតិវិធីនោះ ឬ ប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ សហព្រះរាជអាជ្ញាអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។

ក្នុងករណីដែលមានភាពខ្វែងយោបល់គ្នារវាង សហព្រះរាជអាជ្ញា ត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម :

ការចោទប្រកាន់ត្រូវបន្ត ដរាបណាសហព្រះរាជអាជ្ញា ឬក៏សហព្រះរាជអាជ្ញាម្នាក់ពុំបានស្នើក្នុងរយៈពេលសាមសិបថ្ងៃថា ភាពខ្វែងយោបល់គ្នាត្រូវបានដោះស្រាយ ដោយអនុលោមតាមបទប្បញ្ញត្តិដូចខាងក្រោម :

សហព្រះរាជអាជ្ញាត្រូវដាក់ជូននូវកំណត់ហេតុជាលាយលក្ខណ៍អក្សរអំពីអង្គហេតុ និងហេតុផលទាំងឡាយចំពោះ គោលជំហរខុសគ្នារបស់គេ ដល់ប្រធានការិយាល័យរដ្ឋបាល ។

ភាពខ្វែងយោបល់គ្នាត្រូវតែដោះស្រាយភ្លាម ដោយអង្គបុរេជំនុំជម្រះដែលមានចៅក្រមប្រាំរូប ចៅក្រមខ្មែរបីរូប ត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយមានចៅក្រមមួយរូបជាប្រធាន ហើយនិង

ចៅក្រមបរទេស ពីររូប ត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បន្ទាប់ពីមានការជ្រើសរើសឱ្យឈរឈ្មោះ ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

ការជ្រើសរើសចៅក្រមខាងលើនេះត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ១០ ថ្មី នៃច្បាប់នេះ ។

បន្ទាប់ពីទទួលបានកំណត់ហេតុដូចដែលមានចែងនៅក្នុងកថាខ័ណ្ឌទី ៣ ប្រធានការិយាល័យរដ្ឋបាលត្រូវកោះប្រជុំអង្គបុរេជំនុំជម្រះជាបន្ទាន់ ហើយត្រូវជូនដំណឹងអំពីកំណត់ហេតុដល់សមាជិកអង្គបុរេជំនុំជម្រះ ។

សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលពុំបើកផ្លូវឱ្យមានបណ្តឹងឧទ្ធរណ៍ តម្រូវឱ្យមានសំឡេងវិជ្ជមានពីចៅក្រម បួនរូបយ៉ាងតិច ។ សេចក្តីសម្រេចនេះត្រូវជូនដំណឹងដល់ប្រធានការិយាល័យរដ្ឋបាលដែលត្រូវផ្សព្វផ្សាយសេចក្តីសម្រេចនេះ ហើយជូនដំណឹងដល់សហព្រះរាជអាជ្ញា ។ សហព្រះរាជអាជ្ញាត្រូវចាត់ការបន្តជាបន្ទាន់ដោយអនុវត្តតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ។ ប្រសិនបើពុំមានមតិភាគច្រើន ដូចតម្រូវឱ្យមានចំពោះការធ្វើសេចក្តីសម្រេចទេ ការចោទប្រកាន់ត្រូវធ្វើបន្ត ទៅទៀត ។

ក្នុងពេលធ្វើការចោទប្រកាន់ សហព្រះរាជអាជ្ញាអាចស្វែងរកការជួយឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជា ប្រសិនបើការ ជួយឧបត្ថម្ភនេះពិតជាមានប្រយោជន៍ចំពោះការចោទប្រកាន់ ហើយការជួយឧបត្ថម្ភនេះត្រូវតែផ្តល់ជូន ។

**មាត្រា ២១ ថ្មី.-**

សហព្រះរាជអាជ្ញាទាំងអស់ដែលស្ថិតក្រោមច្បាប់នេះមានឋានៈ និងលក្ខខណ្ឌការងារស្មើៗគ្នា ទៅតាមលំដាប់ថ្នាក់នៃអង្គជំនុំជម្រះវិសាមញ្ញនីមួយៗ ។

ព្រះរាជអាជ្ញាមួយរូបៗ ត្រូវបានជ្រើសតាំងសម្រាប់រយៈពេលនៃការជំនុំជម្រះ ។

ក្នុងករណីដែលព្រះរាជអាជ្ញាបរទេសអវត្តមាន ឬមានធុរៈ ត្រូវជំនួសដោយព្រះរាជអាជ្ញាបម្រុងបរទេស ។

**មាត្រា ២២ ថ្មី.-**

សហព្រះរាជអាជ្ញាមួយរូបៗមានសិទ្ធិជ្រើសរើសព្រះរាជអាជ្ញារងមួយរូប ឬច្រើនរូប ដើម្បីជួយខ្លួនក្នុងការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់នៅចំពោះមុខអង្គជំនុំជម្រះ ។ ព្រះរាជអាជ្ញារងបរទេស ត្រូវតែងតាំងដោយសហព្រះរាជអាជ្ញាបរទេសពីបញ្ជីផ្តល់ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

សហព្រះរាជអាជ្ញាត្រូវមានបុគ្គលិកខ្មែរ និងបុគ្គលិកអន្តរជាតិ ជាជំនួយការ ទៅតាមតម្រូវការជាក់ស្តែងសម្រាប់បម្រើការងារនៅការិយាល័យរបស់ខ្លួន ។

ក្នុងការជ្រើសរើសបុគ្គលិកជាជំនួយការ ប្រធានការិយាល័យរដ្ឋបាលត្រូវធ្វើសម្ភាសន៍ ក្នុងករណីចាំបាច់ និងត្រូវមានការយល់ព្រមពីសហព្រះរាជអាជ្ញាខ្មែរ ក្នុងការជួលបុគ្គលិកដែលត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា ។

អនុប្រធានការិយាល័យ រដ្ឋបាលត្រូវទទួលខុសត្រូវចំពោះការជ្រើសរើស និងការគ្រប់គ្រងបុគ្គលិកបរទេសទាំងអស់។ ចំនួនបុគ្គលិក ជំនួយការត្រូវជ្រើសរើសតាមសមាមាត្រព្រះរាជអាជ្ញាខ្មែរ និងព្រះរាជអាជ្ញាបរទេស។

បុគ្គលិកជាជំនួយការខ្មែរត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការក្នុងក្របខ័ណ្ឌរដ្ឋ ឬជនជាតិខ្មែរដទៃទៀត ដែលមាន សមត្ថភាពក្នុងករណីចាំបាច់។

## ជំពូកទី ៧
## អំពីការស៊ើបអង្កេត

**មាត្រា ២៣ ថ្មី.-**

រាល់ការស៊ើបអង្កេត គឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមពីរនាក់ ម្នាក់ជាកម្ពុជា និងម្នាក់ទៀតជាបរទេស ដែលហៅថា "សហចៅក្រមស៊ើបអង្កេត" ដោយអនុវត្តតាមនីតិវិធីដែលនៅជាធរមាន។ ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬ អនុវត្តនីតិវិធីនោះ ឬ ប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។

ក្នុងករណីដែលមានភាពមិនយល់ស្របគ្នា រវាងសហចៅក្រម ត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម :

ការស៊ើបអង្កេតត្រូវធ្វើបន្ត ដរាបណាសហចៅក្រមស៊ើបអង្កេតទាំងពីរ ឬមួយរូប ក្នុងចំណោមពួកគេពុំបានប្ដឹងមិនសុខចិត្តក្នុងរយៈពេលសាមសិបថ្ងៃ ថាភាពខ្វែងយោបល់គ្នាត្រូវដោះស្រាយដោយអនុវត្តតាមបទប្បញ្ញត្តិដូចខាងក្រោម :

សហចៅក្រមស៊ើបអង្កេតត្រូវជូនកំណត់ហេតុជាលាយល័ក្ខណ៍អក្សរ អំពីអង្គហេតុ និងហេតុផលទាំងឡាយចំពោះគោលជំហរខុសគ្នាដល់ប្រធានការិយាល័យរដ្ឋបាល។

ភាពខ្វែងយោបល់គ្នាត្រូវដោះស្រាយភ្លាមដោយអង្គបុរេជំនុំជម្រះដូចមានចែងក្នុងមាត្រា២០ នៃច្បាប់នេះ។

បន្ទាប់ពីទទួលបាននូវកំណត់ហេតុដូចមានចែងក្នុងកថាខ័ណ្ឌទី៣ រួចមកប្រធានការិយាល័យរដ្ឋបាល ត្រូវកោះប្រជុំអង្គ បុរេជំនុំជម្រះជាបន្ទាន់ ហើយជូនដំណឹងអំពីកំណត់ហេតុដល់សមាជិកអង្គបុរេជំនុំជម្រះ។

សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលពុំបើកផ្លូវឱ្យមានបណ្ដឹងឧទ្ធរណ៍ តម្រូវឱ្យមានសំឡេងវិជ្ជមាន ពីចៅក្រម បួនរូបយ៉ាងតិច។ សេចក្ដីសំរេចនេះត្រូវជូនដំណឹងដល់ប្រធានការិយាល័យរដ្ឋបាលដែលត្រូវផ្សព្វផ្សាយសេចក្ដីសម្រេចនេះ ហើយជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេតត្រូវចាត់ការបន្តជាបន្ទាន់ ដោយអនុវត្តតាមសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះនេះ។ ប្រសិនបើពុំមានមតិភាគច្រើនដូចដែលតម្រូវឱ្យមានចំពោះសេចក្ដីសម្រេចការស៊ើបអង្កេតត្រូវ ធ្វើបន្តទៀត។

សហចៅក្រមស៊ើបអង្កេត អាចផ្អែកទៅលើមូលដ្ឋាននៃពត៌មាន ដែលទទួលបានពីស្ថាប័ននានា រួមមាន រដ្ឋាភិបាល ស្ថាប័ននានារបស់អង្គការសហប្រជាជាតិ ឬអង្គការក្រៅរដ្ឋាភិបាលជាដើម។

សហចៅក្រមស៊ើបអង្កេតមានអំណាច ក្នុងការសួរចម្លើយជនសង្ស័យ ជនរងគ្រោះ និងស្តាប់ចម្លើយសាក្សី និងប្រមូលភស្តុតាងដោយអនុវត្តតាមនីតិវិធីជាធរមាន។ ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេត យល់ថាជាការចាំបាច់ខានមិនបានសហ ចៅក្រមស៊ើបអង្កេតអាចចេញដីកាសុំឱ្យសហព្រះរាជអាជ្ញា ធ្វើការសាកសួរសាក្សីបន្ថែមបាន។

ក្នុងការអនុវត្តភារកិច្ចនេះ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការជួយឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជាបាន ប្រសិនបើយល់ឃើញថាសមស្រប និងមានប្រយោជន៍ដល់ការស៊ើបអង្កេត ហើយការជួយឧបត្ថម្ភនេះត្រូវតែបានផ្តល់ជូន។

## មាត្រា ២៤ ថ្មី.-

ក្នុងដំណាក់កាលស៊ើបអង្កេត ជនសង្ស័យមានសិទ្ធិទទួលបានការការពារពីមេធាវី ដែលជ្រើសរើសដោយខ្លួនឯងដោយខានមិនបាន និងមានជំនួយផ្នែកច្បាប់ផល់ពួកគេដោយឥតគិតថ្លៃ ប្រសិនបើខ្លួនគ្មានលទ្ធភាពគ្រប់គ្រាន់ដើម្បីពឹងមេធាវី ព្រមទាំងមានសិទ្ធិទទួលបាន នូវការបកប្រែចាំបាច់ជាភាសាដែលជនសង្ស័យនិយាយនិងយល់បាន។

## មាត្រា ២៥.-

សហចៅក្រមស៊ើបអង្កេតត្រូវបានជ្រើសតាំងក្នុងចំណោមចៅក្រមក្នុងតំណែងបច្ចុប្បន្ន និងចៅក្រមដែលបានជ្រើសតាំងបន្ថែមតាមនីតិវិធីនៃការជ្រើសតាំងចៅក្រមជាធរមាន ហើយដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់សុចរិតមានបទពិសោធន៍ក្នុងការងារជំនាញ។ សហចៅក្រមស៊ើបអង្កេតត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួនហើយមិនត្រូវទទួល ឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬពីប្រភពណាមួយផ្សេងទៀតឡើយ។

## មាត្រា ២៦.-

សហចៅក្រមស៊ើបអង្កេតខ្មែរ និងចៅក្រមស៊ើបអង្កេតបម្រុងខ្មែរត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមក្នុងចំណោមចៅក្រមវិជ្ជាជីវៈខ្មែរ។

ចៅក្រមស៊ើបអង្កេតបម្រុងត្រូវជំនួសចៅក្រមស៊ើបអង្កេតពេញសិទ្ធិ នៅពេលណាដែលចៅក្រមនេះអវត្តមាន ឬមានធុរៈ។ ចៅក្រមស៊ើបអង្កេតទាំងនេះអាចបន្តបំពេញការងារប្រចាំថ្ងៃនៅក្នុងសាលាជម្រះក្តីដែលខ្លួនកំពុងបំពេញ។

ចៅក្រមស៊ើបអង្កេតបរទេសត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រាប់រយៈពេលនៃការស៊ើបអង្កេត បន្ទាប់ពីការជ្រើសរើសឱ្យឈរឈ្មោះដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ។ អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវរៀបចំបញ្ជីបេក្ខជនយ៉ាងតិចពីររូបជាចៅក្រមស៊ើបអង្កេតបរទេស ជូនរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ហើយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងសហចៅក្រមស៊ើបអង្កេតពេញសិទ្ធិមួយរូប និងបម្រុងមួយរូបពីបញ្ជីបេក្ខជននេះ។

**មាត្រា ២៧ ថ្មី**.-

ចៅក្រមស៊ើបអង្កេតទាំងអស់ ដែលស្ថិតក្រោមច្បាប់នេះ មានឋានៈ និងលក្ខខណ្ឌការងារស្មើៗគ្នា។

ចៅក្រមស៊ើបអង្កេតមួយរូបៗត្រូវបានជ្រើសតាំងសម្រាប់រយៈពេលនៃការស៊ើបអង្កេត។

ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតបរទេសណាមួយអវត្តមាន ឬមានធុរៈ ត្រូវជំនួសដោយចៅក្រមស៊ើបអង្កេតបម្រុងបរទេស។

**មាត្រា ២៨**.-

សហចៅក្រមស៊ើបអង្កេតមានបុគ្គលិកខ្មែរ និងបុគ្គលិកអន្តរជាតិជាជំនួយការទៅតាមតម្រូវការជាក់ស្តែងសម្រាប់បម្រើការនៅការិយាល័យរបស់ខ្លួន។

ក្នុងការជ្រើសរើសបុគ្គលិកជាជំនួយការ សហចៅក្រមស៊ើបអង្កេត ត្រូវអនុវត្តតាមស្មារតីនៃបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១៣ នៃច្បាប់នេះ។

## ជំពូកទី ៨

## ការទទួលខុសត្រូវជាបុគ្គល

**មាត្រា ២៩ ថ្មី**.-

ជនសង្ស័យណាមួយ ដែលមានផែនការព្យុះញុង់ បញ្ជា ប្រព្រឹត្ត ឬជួយនិងជំរុញក្នុងការរៀបចំផែនការ ឬការប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងមាត្រា ៣ថ្មី, ៤, ៥, ៦, ៧ និងមាត្រា ៨ នៃច្បាប់នេះ ត្រូវទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មនេះ។

តួនាទី ឬឋានៈរបស់ជនសង្ស័យមិនអាចជួយជននេះឱ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ឬជយយបន្ថយទណ្ឌកម្មដល់ជននេះបានឡើយ។

ប្រការដែលថាសកម្មភាពណាមួយក្នុងចំណោមសកម្មភាពដែលមានចែងក្នុងមាត្រា ៣ថ្មី, ៤, ៥, ៦, ៧ និង មាត្រា ៨ នៃច្បាប់នេះ ត្រូវបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់នោះមិនអាចជួយឱ្យថ្នាក់លើរួចផុតពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនោះបានទេ ប្រសិនបើថ្នាក់លើមានបញ្ជា និងមានការគ្រប់គ្រងដ៏មានប្រសិទ្ធិភាព ឬមានអំណាច និងការត្រួតពិនិត្យទៅលើអ្នក នៅក្រោមបង្គាប់ ហើយថ្នាក់លើបានដឹង និងមានហេតុផលដឹងថាអ្នកនៅក្រោមបង្គាប់ ប្រព្រឹត្ត ឬបានប្រព្រឹត្តនូវសកម្មភាព បែបនេះ ហើយខ្លួនមិនបានចាត់វិធានការចាំបាច់និងសមស្រប ដើម្បីបង្ការអំពើបែបនេះ ឬដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តបទឧក្រិដ្ឋនេះ ។

ប្រការដែលថាជនសង្ស័យបានប្រព្រឹត្តអំពើឧក្រិដ្ឋ ទៅតាមបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬរបស់ថ្នាក់ លើណាមួយ មិនអាចជួយជនសង្ស័យនេះ ឱ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនេះបានឡើយ ។

## ជំពូកទី ៩
## ការិយាល័យរដ្ឋបាល

**មាត្រា ៣០.-**

បុគ្គលិកនៃអង្គជំនុំជម្រះវិសាមញ្ញសម្រាប់ចៅក្រមជម្រះក្តី ចៅក្រមស៊ើបអង្កេត និងព្រះរាជអាជ្ញាត្រូវគ្រប់គ្រងដោយការិយាល័យរដ្ឋបាលមួយ ។

ការិយាល័យនេះមានប្រធានខ្មែរមួយរូប អនុប្រធានបរទេសមួយរូប និងបុគ្គលិកមួយចំនួនតាមតម្រូវការជាក់ស្តែង ។

**មាត្រា ៣១ ថ្មី.-**

ប្រធានការិយាល័យរដ្ឋបាលត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជាសំរាប់រយៈពេល ២ឆ្នាំ ហើយអាចត្រូវបានតែងតាំងបន្តទៀតបាន ។ ប្រធានការិយាល័យរដ្ឋបាលមានភារកិច្ចគ្រប់គ្រងទូទៅលើការងាររបស់ការិយាល័យរដ្ឋបាល លើកលែងតែការងារដែលស្ថិតនៅក្រោមបទបញ្ញត្តិ និងនីតិវិធីរបស់អង្គការសហប្រជាជាតិ ។

ប្រធានការិយាល័យរដ្ឋបាល ត្រូវបានជ្រើសរើសក្នុងចំណោមអ្នកដែលមានបទពិសោធន៍ខ្ពស់ក្នុងការងាររដ្ឋបាល តុលាការ មានភាពស្ទាត់ជំនាញលើភាសាណាមួយក្នុងចំណោមភាសាបរទេសដែលប្រើការក្នុងអង្គជំនុំជម្រះវិសាមញ្ញ ជាមនុស្សមានចរិតលក្ខណៈ និងស្មារតីខ្ពស់ និងសុចរិត ។

អនុប្រធានបរទេសនៃការិយាល័យរដ្ឋបាល ត្រូវជ្រើសតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ និងតែងតាំងដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវទទួលខុសត្រូវចំពោះការជ្រើសរើស និងការគ្រប់គ្រងបុគ្គលិកអន្តរជាតិទាំងអស់ ដូចដែលបានតម្រូវឱ្យមានដោយសមាសភាគបរទេសនៃអង្គជំនុំជម្រះវិសាមញ្ញ សហ

ចៅក្រមស៊ើបអង្កេតការិយាល័យនៃសហព្រះរាជអាជ្ញា និងការិយាល័យរដ្ឋបាល។ អនុប្រធានការិយាល័យរដ្ឋបាលត្រូវគ្រប់គ្រងប្រាក់ធនធានដែលផ្តល់ជូនតាមរយៈមូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិ។

ការិយាល័យរដ្ឋបាលត្រូវមានបុគ្គលិកខ្មែរ និង បុគ្គលិកអន្តរជាតិជាជំនួយការ តាមតម្រូវការជាក់ស្តែង។

បុគ្គលិកខ្មែរទាំងអស់នៃការិយាល័យរដ្ឋបាល ត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា តាមសំណើរបស់ប្រធានការិយាល័យ។ បុគ្គលិកបរទេសត្រូវតែងតាំងដោយអនុប្រធានការិយាល័យរដ្ឋបាល។

បុគ្គលិកខ្មែរត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការក្នុងក្របខ័ណ្ឌរដ្ឋ ឬជនជាតិខ្មែរដទៃទៀត ដែលមានសមត្ថភាពក្នុងករណីចាំបាច់។

**មាត្រា ៣២.-**

បុគ្គលិកទាំងអស់ដែលមានភារកិច្ចជួយជាជំនួយការដល់ចៅក្រមជម្រះក្តី ចៅក្រមស៊ើបអង្កេត ព្រះរាជអាជ្ញា និងការិយាល័យរដ្ឋបាល ទទួលបាននូវលក្ខខណ្ឌការងារដូចៗគ្នា ទៅតាមលំដាប់ថ្នាក់នៃអង្គជំនុំជម្រះវិសាមញ្ញនីមួយៗ។

## ជំពូកទី ១០
## កិច្ចដំណើរការនៃអង្គជំនុំជម្រះវិសាមញ្ញ

**មាត្រា ៣៣ ថ្មី.-**

អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ និងមាន ការការពារឱ្យបានត្រឹមត្រូវចំពោះជនរងគ្រោះ និងសាក្សី។ ប្រសិនបើនីតិវិធី ដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬ អនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុង កម្រិតអន្តរជាតិ។ អង្គជំនុំជម្រះវិសាមញ្ញរបស់សាលា ដំបូងត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្រប តាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនឹងដំណើរការសមស្របនៃច្បាប់ដូចដែលបានចែងក្នុងមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ។ ជនសង្ស័យដែលត្រូវបានចោទប្រកាន់ ហើយត្រូវបានចាប់ខ្លួនត្រូវបញ្ជូនខ្លួនមកសាលាដំបូងតាមនីតិវិធីជាធរមាន។ រាជរដ្ឋាភិបាលត្រូវទទួលខុសត្រូវក្នុងការធានាសន្តិសុខចំពោះការចូលខ្លួន និងក្នុងការចាត់ការឱ្យចាប់ខ្លួនជនសង្ស័យ ដែលត្រូវបានចោទប្រកាន់តាមច្បាប់នេះ។ នគរបាលយុត្តិធម៌ត្រូវបានជួយឧបត្ថម្ភដោយអង្គភាពអនុវត្តច្បាប់ផ្សេងៗ ទៀតរបស់រាជរដ្ឋាភិបាលដែលរួមមានកងកម្លាំងប្រដាប់

អាវុធ ដើម្បីធានាឱ្យជនដែលត្រូវបានចោទប្រកាន់ត្រូវបាននាំខ្លួនមកក្នុងមន្ទីរឃុំឃាំងភ្លាមៗ។ លក្ខខណ្ឌនៃការចាប់ខ្លួននិងឃុំខ្លួនត្រូវអនុវត្តតាមច្បាប់ជាធរមាន។

តុលាការត្រូវផ្តល់ការការពារដល់ជនរងគ្រោះនិងសាក្សី។ វិធានការការពារទាំងនេះមិនត្រូវកម្រិតត្រឹមតែកិច្ចដំណើរការជំនុំជម្រះជាសម្ងាត់ និងការការពារនូវអត្តសញ្ញាណរបស់ជនរងគ្រោះឡើយ។

**មាត្រា ៣៤ ថ្មី.-**

អង្គជំនុំជម្រះវិសាមញ្ញត្រូវធ្វើជាសាធារណៈនិងបើកចំហសំរាប់តំណាងរបស់រដ្ឋបរទេស តំណាងរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ តំណាងបណ្តាញព័ត៌មាន និងតំណាងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ លើកលែងតែក្នុងកាលៈទេសៈពិសេស អង្គជំនុំជម្រះវិសាមញ្ញសម្រេចថា ត្រូវជំនុំជម្រះជាសម្ងាត់ដោយមានមូលហេតុត្រឹមត្រូវ ដោយយោងតាមនីតិវិធីជាធរមាន ដែលការផ្សព្វផ្សាយជាសាធារណៈធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌។

**មាត្រា ៣៥ ថ្មី.-**

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។

នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងស្មើៗគ្នាសមស្របតាមមាត្រា១៤ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ ១៩៦៦ :

**ក**/ ទទួលពតិមានភ្លាមៗ និងលម្អិតជាភាសាដែលខ្លួនយល់បានអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ចំពោះខ្លួន

**ខ**/ មានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដើម្បីរៀបចំការពារខ្លួន និងទាក់ទងជាមួយមេធាវីរបស់ខ្លួនដែលជ្រើសរើសដោយខ្លួនឯង

**គ**/ ត្រូវបានទទួលការជំនុំជម្រះដោយគ្មានការអូសបន្លាយ

**ឃ**/ ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ជនសង្ស័យ និង ការពារខ្លួនដោយខ្លួនឯង ឬតាមរយៈ មេធាវីដែលជ្រើសរើសដោយខ្លួនឯង ត្រូវបានប្រាប់អោយដឹងអំពីសិទ្ធិនេះ និងទទួលបាននូវជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ ប្រសិនបើជនជាប់ចោទ គ្មានលទ្ធភាពជួលដោយខ្លួនឯង

**ង**/ ពិនិត្យភស្តុតាងដាក់បន្ទុក និងទទួលបាននូវការចូលរួម និងការពនិត្យភស្តុតាងដោះបន្ទុក ក្នុងលក្ខខ័ណ្ឌដូចគ្នា និងភស្តុតាងដាក់បន្ទុកដែរ

**ច**/ មានការជួយឧបត្ថម្ភដោយសេរីពីអ្នកបកប្រែភាសា ប្រសិនបើជនជាប់ចោទមិនយល់ ឬមិនអាចនិយាយបាននូវ ភាសាដែលប្រើនៅក្នុងតុលាការ

ឆ/ មិនត្រូវបានគេបង្ខំឱ្យឆ្លើយប្រឆាំងនឹងខ្លួនឯង ឬបង្ខំឱ្យឆ្លើយសារភាពថាមានកំហុស។

**មាត្រា ៣៦ ថ្មី.-**

អង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកំពូលជំនុំជម្រះលើបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ របស់ជនរងគ្រោះ និងរបស់ សហព្រះរាជអាជ្ញា ពីសាលដីការបស់អង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូង ក្នុងករណីនេះ តុលាការកំពូល ពិនិត្យ សម្រេច ជាចុងក្រោយទាំងអង្គហេតុ ទាំងអង្គច្បាប់ដោយមិនបង្វិលសំណុំរឿងមកអង្គជំនុំជម្រះវិសាមញ្ញ នៃសាលាដំបូងវិញទេ។

**មាត្រា ៣៧ ថ្មី.-**

ប្រការដែលបានចែងនៅក្នុងមាត្រា៣៣ ៣៤ និង៣៥ ត្រូវអនុវត្តដូចគ្នាចំពោះការជំនុំជម្រះក្តីនៅក្នុងអង្គ ជំនុំជម្រះវិសាមញ្ញនៃតុលាការកំពូល។

## ជំពូកទី ១១

## ទោសបញ្ញត្តិ

**មាត្រា ៣៨.-**

ទណ្ឌកម្មទាំងអស់ដែលត្រូវយកមកដាក់ត្រូវកំណត់ត្រឹមទោសដាក់ពន្ធនាគារ។

**មាត្រា ៣៩ ថ្មី.-**

ជនទាំងឡាយដែលប្រព្រឹត្តបទឧក្រិដ្ឋណាមួយដូចមានចែងក្នុងមាត្រា ៣ថ្មី, ៤, ៥, ៦, ៧, និងមាត្រា ៨ នៃ ច្បាប់នេះ ត្រូវផ្តន្ទាទោសឧក្រិដ្ឋ ដាក់ពន្ធនាគារ ពី ៥ ឆ្នាំ រហូតដល់មួយជីវិត។

ក្រៅពីទោសដាក់ពន្ធនាគារ អង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូង អាចសម្រេចរឹបអូសទ្រព្យសម្បត្តិ ជា ចលនវត្ថុ និងអចលនវត្ថុ និងលុយកាក់ដែលទទួលបានដោយខុសច្បាប់ ឬក៏បានដោយការប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម។ ទ្រព្យសម្បត្តិដែលរឹបអូសបាននេះត្រូវប្រគល់ជូនរដ្ឋ។

## ជំពូកទី ១២

## ការលើកលែងទោសនិងការអនុគ្រោះទោស

**មាត្រា ៤០ ថ្មី.-**

រាជរដ្ឋាភិបាលកម្ពុជាមិនអាចស្នើសុំឱ្យមានការលើកលែងទោស ឬការអនុគ្រោះទោសដល់ជនទាំងឡាយណា ដែលអាច ត្រូវបានស៊ើបអង្កេត ឬត្រូវបានផ្តន្ទាទោសអំពីឧក្រិដ្ឋកម្ម ដែលមានចែងក្នុងមាត្រា ៣ថ្មី, ៤, ៥, ៦, ៧, និង

មាត្រា៨ នៃច្បាប់នេះបានឡើយ។ វិសាលភាពនៃការលើកលែងទោស ឬ អនុគ្រោះទោសដែលអាចត្រូវបានផ្តល់អោយមុនការអនុម័តច្បាប់នេះ គឺត្រូវសំរេចដោយអង្គជំនុំជម្រះវិសាមញ្ញ។

## ជំពូកទី ១៣
## ឋានៈ សិទ្ធិ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ

**មាត្រា ៤១**.-

ចៅក្រមបរទេស សហចៅក្រមស៊ើបអង្កេតបរទេស សហព្រះរាជអាជ្ញាបរទេស និងអនុប្រធានការិយាល័យរដ្ឋបាល រួមបញ្ចូលទាំងក្រុមគ្រួសាររបស់ពួកគេ ដែលជាផ្នែកនៃគ្រួសាររបស់ពួកគេ ត្រូវមានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិទាំងអស់ ការរួចពន្ធ និងគ្រឿងបរិក្ខារប្រើប្រាស់ ដូចដែលផ្តល់ជូនដល់ភ្នាក់ងារការទូត ដោយអនុលោមតាមអនុសញ្ញាទីក្រុងវីយ៉ែនស្តីពីទំនាក់ ទំនងការទូតនាឆ្នាំ១៩៦១។ មន្ត្រីទាំងអស់នេះត្រូវបានរួចពីការជាប់ពន្ធលើប្រាក់បៀវត្សបរិលាភ និង វិភាជន៍របស់ពួកគេនៅក្នុងប្រទេសកម្ពុជា។

**មាត្រា ៤២ ថ្មី**.-

១-ចៅក្រមខ្មែរ សហចៅក្រមស៊ើបអង្កេតខ្មែរ សហព្រះរាជអាជ្ញាខ្មែរ និង បុគ្គលិកខ្មែរត្រូវបានផ្តល់អភ័យឯកសិទ្ធិឱ្យរួចផុត ពីដំណើរក្តីតាមផ្លូវច្បាប់ ចំពោះពាក្យពេចន៍ដែលបាននិយាយ ឬសរសេរ និងសកម្មភាពទាំងអស់ដែលបានបំពេញក្នុងតំណែងផ្លូវការរបស់គេ។ អភ័យឯកសិទ្ធិបែបនេះនៅតែមានជាបន្ត ក្រោយពីពួកគេបញ្ចប់ការងារជាមួយអង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល។

២-បុគ្គលិកអន្តរជាតិ ត្រូវបានផ្តល់បន្ថែមនូវ :

**ក**- អភ័យឯកសិទ្ធិឱ្យរួចផុតពីដំណើរក្តីតាមផ្លូវច្បាប់ចំពោះពាក្យពេចន៍ ដែលបាននិយាយ ឬសរសេរ និងសកម្មភាពទាំងអស់ដែលបានបំពេញក្នុងតំណែងផ្លូវការរបស់ពួកគេ។ អភ័យឯកសិទ្ធិបែបនេះនៅតែមានជាបន្ត ក្រោយពីពួកគេបញ្ចប់ការងារជាមួយសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល។

**ខ**- អភ័យឯកសិទ្ធិឱ្យរួចផុតពីការបង់ពន្ធលើប្រាក់បៀវត្ស វិភាជន៍ និងបរិលាភដែលបើកជូនពួកគេដោយអង្គការសហប្រជាជាតិ។

**គ**- អភ័យឯកសិទ្ធិឱ្យរួចផុតពីការដាក់កំហិតព្រំដែនអន្តោប្រវេសន៍។

ឃ- សិទ្ធិនាំចូលដោយរួចពន្ធអាករ គ្រឿងសង្ហារឹម និងសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនរបស់ពួកគេលើកលែងតែការចំណាយសម្រាប់សេវាកម្ម នៅពេលដែលមកទទួលភារកិច្ចផ្លូវការជាលើកដំបូងនៅប្រទេសកម្ពុជា ។

៣-មេធាវីរបស់ជនសង្ស័យ ឬជនជាប់ចោទដែលត្រូវបានទទួលស្គាល់ថាជាមេធាវី ដោយអង្គជំនុំជម្រះ មិនត្រូវស្ថិតនៅក្រោមអំណាចរដ្ឋាភិបាល នូវវិធានការណាមួយដែលអាចប៉ះពាល់ដល់ការបំពេញមុខងារ ដោយសេរី និងឯករាជ្យរបស់ខ្លួន នៅក្រោមច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។

ជាពិសេស មេធាវីត្រូវបានផ្ដល់នូវៈ

ក- អភ័យឯកសិទ្ធិឱ្យរួចផុតពីការចាប់ ឬឃុំខ្លួន និងការរឹបអូសរបស់របរផ្ទាល់ខ្លួន ក្នុងក្របខ័ណ្ឌនៃការបំពេញភារកិច្ចរបស់ខ្លួនក្នុងរឿងក្ដីនេះ

ខ- ភាពមិនអាចរំលោភបំពានបាន នូវឯកសារទាំងអស់ ដែលទាក់ទងដល់ការបំពេញមុខងាររបស់ខ្លួនជាមេធាវីរបស់ជនសង្ស័យ ឬជនជាប់ចោទ

គ- អភ័យឯកសិទ្ធិឱ្យរួចផុតពីយុត្តាធិការរដ្ឋប្បវេណី និងព្រហ្មទណ្ឌចំពោះពាក្យពេចន៍ដែលបាននិយាយ ឬសរសេរ និងសកម្មភាពដែលបានបំពេញ ក្នុងដំណែងផ្លូវការរបស់គេក្នុងនាមជាមេធាវី ។ អភ័យឯកសិទ្ធិបែបនេះនៅបន្តផ្ដល់ចំពោះពួកគេ ក្រោយពួកគេបញ្ចប់មុខងារជាមេធាវីរបស់ជនសង្ស័យ ឬជនជាប់ចោទ ។

៤-បណ្ណសារដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល និងជាទូទៅឯកសារនិងសម្ភារៈទាំងអស់ដែលអាចរកបាន ហើយដែលជាកម្មសិទ្ធិរបស់អ្នកទាំងនោះ ឬប្រើប្រាស់ដោយអ្នកទាំងនោះ ទោះជាស្ថិតនៅកន្លែងណានៃព្រះរាជាណាចក្រកម្ពុជាក៏ដោយ និងគ្រប់គ្រងដោយជនណាក៏ដោយ គឺមិនអាចត្រូវបានរំលោភបំពានបាន ក្នុងរយៈពេលនៃកិច្ចដំណើរការជំនុំជម្រះនេះឡើយ ។

## ជំពូកទី ១៤
## ទីតាំងរបស់អង្គជំនុំជម្រះវិសាមញ្ញ

### មាត្រា ៤៣ ថ្មី.-

អង្គជំនុំជម្រះវិសាមញ្ញដែលធ្វើឡើងនៅថ្នាក់សាលាដំបូង និងតុលាការកំពូល មានទីតាំងនៅក្នុងទីក្រុងភ្នំពេញ ។

## ជំពូកទី ១៥

## ការចំណាយ

**មាត្រា ៤៤ ថ្មី.-**

ការចំណាយ និងប្រាក់បៀវត្ស របស់អង្គជំនុំជម្រះវិសាមញ្ញមានៈ

១-ការចំណាយនិងប្រាក់បៀវត្សចំពោះមន្ត្រីរដ្ឋបាល និងបុគ្គលិកខ្មែរ ចំពោះចៅក្រមជម្រះក្តីនិងចៅក្រមជម្រះក្តីបម្រុង ចៅក្រមស៊ើបអង្កេត និងចៅក្រមស៊ើបអង្កេតបម្រុង ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញាបម្រុងខ្មែរទាំងអស់ ជាបន្ទុករបស់ថវិកាជាតិខ្មែរ។

២-ការចំណាយចំពោះមន្ត្រីរដ្ឋបាល និងបុគ្គលិកបរទេស ចៅក្រមជម្រះក្តី សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតបរទេស ដែលបញ្ជូនមកដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ជាបន្ទុករបស់អង្គការសហប្រជាជាតិ។

៣-មេធាវីការពារក្តី អាចទទួលប្រាក់កម្រៃពីកិច្ចការពារក្តីរបស់ខ្លួន។

៤-ការចំណាយសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក៏អាចទទួលបន្ថែមនូវមូលនិធិស្ម័គ្រចិត្តដទៃទៀត ដូចជារដ្ឋាភិបាលបរទេស ស្ថាប័នអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលនានា ហើយនិងបុគ្គលដែលមានបំណងចង់ជួយដល់កិច្ចដំណើរការនេះ។

## ជំពូកទី ១៦

## ភាសាការងារ

**មាត្រា ៤៥ ថ្មី.-**

ភាសាដែលប្រើប្រាស់ជាផ្លូវការក្នុងការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ គឺភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង។

## ជំពូកទី ១៧

## ករណីគ្មានចៅក្រមជម្រះក្តី ចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាបរទេស

**មាត្រា ៤៦ ថ្មី.-**

ដើម្បីធានាការអនុវត្តច្បាប់នេះបានទាន់ពេលវេលា និងមិនរអាក់រអួល ក្នុងករណីដែលចៅក្រមជម្រះក្តី ឬចៅក្រមស៊ើបអង្កេត ឬ ព្រះរាជអាជ្ញាបរទេសណាមួយមិនបានចូលរួម ឬ បដិសេធមិនចូលរួមក្នុងអង្គជំនុំជម្រះវិសាមញ្ញ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជ្រើសតាំងចៅក្រមជម្រះក្តី ឬចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាផ្សេងទៀត ឱ្យបំពេញកន្លែងទំនេរក្នុងចំណោមបញ្ជីបេក្ខជនបរទេសដែលមានចែងក្នុងមាត្រា១១ ថ្មី, ១៨ ថ្មី និងមាត្រា២៦

នៃ ច្បាប់នេះ។ ក្នុងករណីដែលឈ្មោះក្នុងបញ្ជីត្រូវបានប្រើអស់ ហើយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិពុំបានផ្តល់បញ្ជីឈ្មោះបេក្ខជនថ្មីបន្ថែម ឬក្នុងករណីដែលអង្គការសហប្រជាជាតិដកការគាំទ្រពីអង្គជំនុំជម្រះវិសាមញ្ញ កន្លែងទំនេរទាំងនោះ ត្រូវបំពេញបន្ថែម ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ពីបណ្តាបេក្ខជនដែលបានស្នើឡើងដោយរដ្ឋាភិបាលនៃបណ្តារដ្ឋជាសមាជិកនៃអង្គការសហប្រជាជាតិ ឬពីក្នុងចំណោមឥស្សរជនច្បាប់បរទេសដទៃទៀត។

បន្ទាប់ពីអនុវត្តនីតិវិធីនេះហើយ បើនៅតែគ្មានចៅក្រមជម្រះក្តី ឬចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាបរទេស ចូលរួមក្នុងការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ ហើយគ្មានបេក្ខជនបរទេសណាត្រូវបានជ្រើសរើសឱ្យបំពេញតំណែងទំនេរនេះទេ នៅពេលនោះ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអាចជ្រើសតាំងចៅក្រមជម្រះក្តី ឬចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាខ្មែរជំនួស។

## ជំពូកទី ១៨

## អត្ថិភាពនៃអង្គជំនុំជម្រះវិសាមញ្ញ

### មាត្រា ៤៧.-

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវរលាយខ្លួនជាស្វ័យប្រវត្តិ ក្រោយពេលដែលការវិនិច្ឆ័យទោសក្នុងរឿងក្តីនេះបានចប់ជាស្ថាពរ។

### មាត្រា ៤៧ ស្ទួន.-

ក្រោយពេលផ្តល់សច្ចាប័នសមស្របតាមបទបញ្ញត្តិនៃច្បាប់ព្រះរាជាណាចក្រកម្ពុជា ទាក់ទងទៅនឹងសមត្ថកិច្ចនៃការចុះសន្ធិសញ្ញាកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ធ្វើនៅភ្នំពេញថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ត្រូវអនុវត្តជាច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ១៩

## អវសានប្បញ្ញត្តិ

### មាត្រា ៤៨.-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

# ឧបសម្ព័ន្ធ ២

00775641



# សេចក្តីសង្ខេបនៃសាលដីកា

**សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក (កាំង ហ្គេកអ៊ាវ ហៅ "ឌុច" )**

**ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 03-Feb-2012, 15:15
CMS/CFO: Uch Arun

## ក. សេចក្តីផ្តើម

១. ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបសំអាងហេតុដែលដកស្រង់ចេញពីសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០១។ ផ្នែកសំអាងហេតុដែលមានអានុភាពតាមផ្លូវច្បាប់មាននៅក្នុងសាលដីកាពេញលេញរបស់អង្គជំនុំជម្រះតុលាការកំពូល។ អត្ថបទសាលដីកាពេញលេញ ជាភាសាខ្មែរ និងជាភាសាអង់គ្លេស នឹងមានក្នុងពេលឆាប់ៗខាងមុខ ហើយនឹងត្រូវបកប្រែជាភាសាបារាំងតាមក្រោយ។

២. អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមរបស់ខ្លួននៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០។ ការដាក់សារណាបណ្តឹងសាទុក្ខជាលាយលក្ខណ៍អក្សរត្រូវបានបញ្ចប់ត្រឹមថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១ ហើយសវនាការលើបណ្តឹងសាទុក្ខបានធ្វើឡើងចាប់ពីថ្ងៃទី ២៨ ដល់ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១។ រយៈពេលនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ និងទំហំនៃសាលដីកា បានឆ្លុះបញ្ចាំងអំពីចរិតលក្ខណៈជាប្រវត្តិសាស្ត្រនៃរឿងក្តីនេះ ដែលជារឿងក្តីទីមួយនៅចំពោះមុខ អ.វ.ត.ក និងបង្ហាញអំពីភាពថ្មីស្រឡាង និងស្មុគស្មាញនៃបញ្ហាគតិយុត្តនៅក្នុងទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខ។

៣. នៅក្នុងសាលក្រមរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ក្នុងនាមជាអនុលេខាហើយបន្ទាប់មកជាលេខាមន្ទីរ ស ២១ ជនជាប់ចោទបានចាត់ចែង និងពង្រឹងប្រព័ន្ធគ្រប់គ្រងអស់រយៈពេលជាងបីឆ្នាំដែលបណ្តាលឲ្យមានការសម្លាប់ជនរងគ្រោះមិនតិចជាង ១២.២៧២ នាក់ ដែលជនរងគ្រោះភាគច្រើនត្រូវបានទទួលរងនូវការធ្វើទារុណកម្មជាប្រព័ន្ធ។ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសផ្តន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារ ៣៥ ឆ្នាំ ដោយផ្អែកលើការរកឃើញថាមានពិរុទ្ធភាពពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញ (ដោយស្រូបបញ្ចូលនូវបទឧក្រិដ្ឋមូលដ្ឋាននៅក្នុងឧក្រិដ្ឋកម្ម

ប្រឆាំងមនុស្សជាតិ មានដូចជា ការសម្លាប់រង្គាល(រួមបញ្ចូលអំពើមនុស្សឃាត) ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម (រួមបញ្ចូលការរំលោភផ្លូវភេទមួយករណី) និងអំពើអមនុស្សធម៌ផ្សេងៗទៀត) និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ រួមមាន ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌ ការបង្កឱ្យមានការឈឺចាប់ដោយចេតនា ឬឱ្យមានរបួសធ្ងន់ធ្ងរដល់រូបរាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបាននូវការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចកាត់បន្ថយទោសចំនួន ៥ ឆ្នាំ ពីរយៈពេលផ្តន្ទាទោស ដោយសារការរំលោភលើសិទ្ធិរបស់ជនជាប់ចោទក្នុងអំឡុងពេលឃុំខ្លួនខុសច្បាប់នីតិវិធីដោយតុលាការយោធាកម្ពុជាចាប់ពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ រហូតដល់ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៧។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចផងដែរថាជនជាប់ចោទត្រូវទទួលបានការទូទាត់នូវថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នទាំងស្រុង ចាប់ពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ រហូតដល់ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៧ (ក្រោមសមត្ថកិច្ចរបស់តុលា-ការយោធាកម្ពុជា) និងពីថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៧ រហូតដល់សាលក្រមចូលជាស្ថាពរ។

៤. អង្គជំនុំជម្រះសាលាដំបូង បានផ្តល់សំណងពីរប្រភេទដល់ដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចនៅក្នុងសាលក្រមរបស់ខ្លួនថា ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ ពិតជាបានទទួលរងគ្រោះដែលជាផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋទាំងឡាយដែលជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធភាព ហើយអង្គជំនុំជម្រះសាលាដំបូងបានយល់ព្រមធ្វើការចងក្រងពាក្យសម្តីសុំអភ័យទោសទាំងអស់ និងពាក្យសម្តីទទួលស្គាល់ការទទួលខុសត្រូវដែលជនជាប់ចោទបានធ្វើនៅក្នុងអំឡុងពេលសវនាការ ហើយកម្រងពាក្យសម្តីទាំងនេះនឹងត្រូវដាក់នៅលើគេហទំព័រផ្លូវការរបស់ អ.វ.ត.ក ក្នុងរយៈពេល ១៤ ថ្ងៃបន្ទាប់ពីសាលក្រមរបស់ខ្លួនចូលជាស្ថាពរ។

៥. អង្គជំនុំជម្រះតុលាការកំពូលធ្វើសេចក្តីសង្ខេបសំអាងហេតុរបស់ខ្លួនទៅលើទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខដូចខាងក្រោម។

## ខ. យុត្តាធិការលើរូបបុគ្គល

៦. ជនជាប់ចោទបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការលើរូបបុគ្គលចំពោះខ្លួននោះទេ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលគប្បីបដិសេធការសម្រេចដាក់ពិរុទ្ធភាព និងការផ្តន្ទាទោសលើខ្លួន។ យោងតាមការលើកឡើងរបស់ជនជាប់ចោទថា ទាំងការទទួលខុសត្រូវផ្នែកប្រតិបត្តិ និងតួនាទីដែលខ្លួនបានបំពេញ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពុំបានធ្វើឱ្យខ្លួនគាត់ស្ថិតក្នុងអត្ថន័យជា "មេដឹកនាំជាន់ខ្ពស់"មួយរូបនៃរបបកម្ពុជាប្រជាធិបតេយ្យ ឬជាជនម្នាក់ក្នុងចំណោម"ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្តក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិប-តេយ្យនោះទេ។ សហព្រះរាជអាជ្ញាបានលើកឡើងថា ទឡ្ហីករណ៍បណ្តឹងសាទុក្ខរបស់ជនជាប់ចោទទាក់ទងនឹងយុត្តាធិការលើរូបបុគ្គលមិនអាចទទួលយកបានឡើយ ដោយសារតែសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ពុំបានបំពេញនូវបទដ្ឋានអប្បបរមានៃសារណាការពារបណ្តឹងសាទុក្ខ។ សហព្រះរាជអាជ្ញាក៏បានលើកឡើងផងដែរថា អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិបដិសេធសារណារបស់មេធាវីការពារក្តីស្តីពីយុត្តាធិការលើរូបបុគ្គល ដោយសារតែសារណានេះមិនត្រូវបានធ្វើឡើងឱ្យបានទាន់ពេលវេលា ហើយអង្គជំនុំជម្រះសាលាដំបូងយល់ឃើញត្រឹមត្រូវក្នុងការសន្និដ្ឋានថា ពាក្យពេចន៍"មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"សំដៅលើជនសង្ស័យពីរប្រភេទដាច់ដោយឡែកពីគ្នា និងអង្គជំនុំជម្រះសាលាដំបូងយល់ឃើញត្រឹមត្រូវក្នុងការសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងមានយុត្តាធិការលើរូបបុគ្គលជនជាប់ចោទ ដោយផ្អែកទៅលើឋានៈរបស់ជនជាប់ចោទជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែល"ទទួលខុសត្រូវខ្ពស់បំផុត"ចំពោះឧក្រិដ្ឋកម្មទាំងឡាយ ដែលត្រូវបានប្រព្រឹត្តក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣បានឆ្លើយតបដោយគាំទ្រការលើកឡើងរបស់សហព្រះរាជអាជ្ញា។

៧. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការជំនុំជម្រះប្រកបដោយយុត្តិធម៌តម្រូវថា ជនជាប់ចោទត្រូវមានសិទ្ធិលើកឡើងនូវការជំទាស់អំពីកង្វះយុត្តាធិការដែលស្តែងឱ្យឃើញច្បាស់ ឬមិនស្តែងឱ្យឃើញច្បាស់ដែលអាចប៉ះពាល់ដល់ការជំនុំជម្រះក្តី នៅពេលណាដែលជនជាប់ចោទសម្រេចថា ខ្លួនត្រូវការពារផលប្រយោជន៍របស់ខ្លួន។ អង្គជំនុំជម្រះសាលាដំបូងត្រូវតែសម្រេចលើការជំទាស់ណាមួយ

ឬទាំងអស់ទៅនឹងយុត្តាធិការដែលជនជាប់ចោទបានលើកឡើង យ៉ាងយូរបំផុត"នៅពេលដំណាលគ្នានឹងសាលក្រមលើអង្គសេចក្តី"។ នៅក្នុងករណីដែលជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋណាមួយនោះ ជនជាប់ចោទមាន"សិទ្ធិស្នើសុំឲ្យសាលាជម្រះក្តីជាន់ខ្ពស់ពិនិត្យឡើងវិញទៅលើការសម្រេចដាក់ពិរុទ្ធភាព និងការផ្តន្ទាទោស ដោយអនុលោមតាមច្បាប់"។ ដោយផ្អែកទៅលើសិទ្ធិនេះ ជនជាប់ចោទមានសិទ្ធិប្តឹងសាទុក្ខទៅលើកំហុសអង្គច្បាប់ ឬអង្គហេតុនានាដែលអាចធ្វើឲ្យមោឃៈសាលក្រម ឬបណ្តាលឲ្យសាលក្រមមានភាពមិនយុត្តិធម៌ ដែលរួមបញ្ចូលទាំងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអំពីយុត្តាធិការលើរូបបុគ្គលផងដែរ។

៨. ទាក់ទងនឹងបទដ្ឋាននៃសារណាបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា បញ្ហាសំខាន់ដែលត្រូវសម្រេចនោះគឺ ថាតើម្ចាស់បណ្តឹងសាទុក្ខបានលើកហេតុផលរបស់ខ្លួន ក្នុងលក្ខណៈដែលអាចឲ្យភាគីផ្សេងទៀតមានលទ្ធភាពដឹងអំពីបញ្ហាដែលខ្លួនត្រូវប្រឈម និងដែលអាចឲ្យអង្គជំនុំជម្រះតុលាការកំពូលមានលទ្ធភាពកំណត់ និងសម្រេចបានលើបញ្ហាវិវាទ ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា បញ្ហាសំខាន់ៗនៅក្នុងបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ដែលត្រូវបានលើកឡើងសម្រាប់ការសម្រេចសេចក្តីពុំមានលក្ខណៈពិបាកក្នុងការកំណត់នោះទេ ហើយផ្នែកពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក៏មានលក្ខណៈអាចកត់សម្គាល់បានយ៉ាងងាយដែរ និងអាចកំណត់បានយ៉ាងច្បាស់ចំពោះសំអាងហេតុដែលនាំឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការសន្និដ្ឋានថា ជនជាប់ចោទគឺជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែល"ទទួលខុសត្រូវខ្ពស់បំផុត"។

៩. ចំពោះបញ្ហាសំខាន់នៃយុត្តាធិការលើរូបបុគ្គល យោងតាមអត្ថន័យធម្មតានៃពាក្យពេចន៍ដែលមាននៅក្នុងបរិបទ និងដោយពិចារណាអំពីកម្មវត្ថុ និងគោលបំណងនៃកិច្ចព្រមព្រៀងរវាង អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពាក្យពេចន៍"មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"សំដៅទៅលើកម្មាភិបាលខ្មែរក្រហមពីរប្រភេទខុសគ្នា ប៉ុន្តែប្រភេទទាំងពីរនេះមានទំនាក់ទំនងគ្នា។ ប្រភេទទីមួយគឺជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ដែលស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ពីព្រោះមេដឹកនាំជាន់ខ្ពស់ម្នាក់មិន

មែនជាជនសង្ស័យដោយផ្អែកតែទៅលើតួនាទីជាមេដឹកនាំរបស់ខ្លួនប៉ុណ្ណោះទេ។ ប្រភេទមួយផ្សេងទៀត គឺអ្នកដែលមិនមែនជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ប៉ុន្តែជាអ្នកដែលស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតផងដែរ។ ជនទាំងពីរប្រភេទនេះ គឺជា"ជនសង្ស័យ"ដែលជាកម្មវត្ថុនៃការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌនៅចំពោះមុខ អ.វ.ត.ក។

១០. អង្គជំនុំជម្រះតុលាការកំពូលក៏ត្រូវពិចារណាផងដែរ ថាតើការបកស្រាយពាក្យពេចន៍ "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"ថាជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការនោះមានលក្ខណៈស្របគ្នាជាមួយកម្មវត្ថុ និងគោលបំណងនៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដែរ ឬយ៉ាងណា ហើយ ថាតើការបកស្រាយបែបនេះនឹងនាំឲ្យមានលទ្ធផលមួយ "ដែលពុំសមហេតុផល និងមិនមានភាពស៊ីសង្វាក់គ្នាយ៉ាងច្បាស់ក្រឡែត" ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា យុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក គ្របដណ្តប់លើកម្មាភិបាលខ្មែរក្រហម ហើយបញ្ហាចោទដែល ថាតើជនជាប់ចោទគឺជាកម្មាភិបាលខ្មែរក្រហម ដែរ ឬយ៉ាងណានោះ គឺជាបញ្ហាដែលអាចវិនិច្ឆ័យបាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ទោះបីជាយ៉ាងណាក៏ដោយ ពាក្យពេចន៍"ទទួលខុសត្រូវខ្ពស់បំផុត" មិនអាចជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការនោះទេដោយសារមូលហេតុជាច្រើនរួមមាន៖ សញ្ញាណនៃការទទួលខុសត្រូវដែលយកមកប្រៀបធៀបពុំមានលក្ខណៈស្របទៅនឹងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលហាមឃាត់មិនឲ្យប្រើប្រាស់មធ្យោបាយការពារខ្លួនដោយយកមូលហេតុបញ្ជាថ្នាក់លើ។ ការកំណត់ ថាតើជនជាប់ចោទជា "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ដែរ ឬយ៉ាងណានោះ តម្រូវឲ្យមានការប្រើឆន្ទានុសិទ្ធិយ៉ាងច្រើន ។ ហេតុដូច្នេះអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពាក្យពេចន៍"ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"គប្បីបកស្រាយថា មិនមែនជាបញ្ហាដែលអាចធ្វើការវិនិច្ឆ័យបាននោះទេ ប៉ុន្តែជាគោលការណ៍ណែនាំដល់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត ក្នុងការប្រើឆន្ទានុសិទ្ធិរបស់ខ្លួនទាក់ទងនឹងវិសាលភាពនៃការចោទប្រកាន់ និងការស៊ើបអង្កេត។ ចំពោះពាក្យពេចន៍"មេដឹកនាំជាន់ខ្ពស់" អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញផងដែរថា ពាក្យពេចន៍នេះមិនមែនជាកម្មវត្ថុដែលអាចធ្វើការវិនិច្ឆ័យបានទេ ប៉ុន្តែជាគោលការណ៍ណែនាំ ជាជាងលក្ខខណ្ឌតម្រូវយុត្តាធិការដោយសារមានហេតុផលផ្សេងៗចំពោះភាពបទបែនក្នុងការកំណត់និយមន័យនៃពាក្យនេះ ។ ប្រសិនបើមិនមាន

ភស្តុតាងបញ្ជាក់ថា ការប្រើឆន្ទានុសិទ្ធិនេះត្រូវបានធ្វើឡើងដោយអសុទ្ធចិត្ត ឬការវិនិច្ឆ័យមិនត្រឹមត្រូវប្រកបដោយវិជ្ជាជីវៈនោះទេ អង្គជំនុំជម្រះសាលាដំបូងពុំមានអំណាចពិនិត្យឡើងវិញអំពីបញ្ហារំលោភឆន្ទានុសិទ្ធិរបស់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតឡើយ ដោយអនុលោមតាមមាត្រា ៥(៣) និងមាត្រា ៦(៣) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងគោលបំណងនៃការចោទប្រកាន់ និងការស៊ើបអង្កេត។ ចំពោះបញ្ហា ថាតើជនជាប់ចោទគឺជាមេដឹកនាំជាន់ខ្ពស់មួយរូប ឬជាជនមួយរូបក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតដែរ ឬយ៉ាងណានោះ គឺជាសេចក្តីសម្រេចផ្នែកគោលការណ៍ណែនាំសម្រាប់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតដែលជាអ្នកទទួលខុសត្រូវ ហើយពុំមែនជាសមត្ថកិច្ចរបស់អង្គជំនុំជម្រះឡើយ។ អាស្រ័យហេតុនេះ បណ្តឹងសាទុក្ខរបស់ជនជាប់ចោទទាក់ទងនឹងយុត្តាធិការលើរូបបុគ្គលត្រូវបដិសេធចោលទាំងស្រុង។

## គ. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

### ក. គោលការណ៍នីត្យានុកូលភាព

១១. សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ជាច្រើនចំណុចចំពោះការសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទ ពីបទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានចោទប្រកាន់លើជនជាប់ចោទ ដោយអនុលោមតាម មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

១២. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ដើម្បីដោះស្រាយទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខទាំងនេះ អង្គជំនុំជម្រះត្រូវតែពិចារណាអំពីយុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការកំណត់និយមន័យរបស់អង្គជំនុំជម្រះសាលាដំបូងលើបទឧក្រិដ្ឋមូលដ្ឋាននៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជាការធ្វើឲ្យទៅជាទាសករ ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ និងការធ្វើទុក្ខបុកម្នេញ។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងអង្គជំនុំជម្រះសាលាដំបូងថា ដើម្បីឲ្យបទល្មើសដែលត្រូវបានចោទប្រកាន់ និងទម្រង់នៃការចូលរួមស្ថិតនៅក្នុងយុត្តាធិការលើ

រឿងក្ដីរបស់ អ.វ.ត.ក បទល្មើស និងទម្រង់នៃការចូលរួមទាំងនោះត្រូវតែមានចែងនៅក្នុងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ដោយច្បាស់លាស់ ឬដោយប្រយោល។ បន្ថែមពីលើនេះ ដោយសារតែច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ត្រូវបានអនុម័តក្រោយការប្រព្រឹត្តអំពើឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ ដូចនេះ អំពើឧក្រិដ្ឋទាំងនោះ ត្រូវតែពិចារណាដោយផ្អែកលើគោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់ចែង (nullum crimen sine lege)*(គោលការណ៍នីត្យានុកូលភាព)។ អនុលោមតាមមាត្រា ៣៣ ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយ រាល់បទល្មើស ឬរាល់ទម្រង់នៃការទទួលខុសត្រូវដែលចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក ត្រូវតែមានអត្ថិភាពក្រោមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ នៅពេលដែលអំពើល្មើសដែលបានចោទប្រកាន់នោះ បានកើតឡើងនៅក្នុងអំឡុងពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩។ បន្ថែមពីលើនេះ ជនជាប់ចោទត្រូវតែអាចយល់ដឹងជាមុនថាជាបទល្មើស និងដឹងជាមុនថាមានច្បាប់ចែង។

## ខ. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចន្លោះពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ ១៩៧៩

១៣. ទាក់ទងនឹងយុត្តាធិការរបស់ អ.វ.ត.ក ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ អង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យមើលឡើងវិញអំពីដំណើរការវិវឌ្ឍនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងច្បាប់អន្តរជាតិ ដោយចាប់ផ្ដើមពីសញ្ញាណដំបូងទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងទសវត្សរ៍ ១៦០០ និងតាមលំនាំនៃការអនុវត្តតៗគ្នារបស់រដ្ឋ និង*ការប្រកាសពីឆន្ទៈទទួលយកជាច្បាប់ (opinion juris)* ក្រោយសង្គ្រាមលោកលើកទី I និងក្រោយសង្គ្រាមលោកលើកទី II។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយអង្គជំនុំជម្រះសាលាដំបូងថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺជាឧក្រិដ្ឋកម្មអន្តរជាតិក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក។ បន្ថែមពីលើនេះអង្គជំនុំជម្រះសាលាដំបូងសម្រេចថា និយមន័យទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងគោលការណ៍ Nuremberg ឆ្នាំ ១៩៥០ ឆ្លុះបញ្ចាំងឲ្យឃើញពីស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនាពេលនោះ។ នៅពេលពិចារណាអំពីទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវសម្រេច ថាតើនិយមន័យនោះមានចែងនៅក្នុងច្បាប់អន្តរជាតិចាប់ពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ដែរឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលនឹងបន្តសម្រេចទៅលើបទឧក្រិដ្ឋមូលដ្ឋាននៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

**គ. ការធ្វើឱ្យទៅជាទាសករ**

១៤. ចំពោះការធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ សហព្រះរាជអាជ្ញាលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយមិនបានសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទពីបទធ្វើឱ្យទៅជាទាសករចំពោះអ្នកជាប់ឃុំឃាំងទាំងអស់នៅមន្ទីរ ស ២១។ សហព្រះរាជអាជ្ញាលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសបែបនេះ ដោយសារតែអង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យមានធាតុផ្សំនៃពលកម្មដោយបង្ខំ នៅក្នុងនិយមន័យនៃការធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

១៥ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំបានកំណត់អំពីការធ្វើពលកម្មដោយបង្ខំថា ជាធាតុផ្សំចាំបាច់មួយនៅក្នុងនិយមន័យនៃការធ្វើឱ្យទៅជាទាសករនោះឡើយ។ ប៉ុន្តែអង្គ-ជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ការធ្វើពលកម្មដោយបង្ខំគ្រាន់តែជាកត្តាមួយដែលត្រូវយកមកពិចារណាតែប៉ុណ្ណោះ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អំណះអំណាងរបស់សហព្រះរាជអាជ្ញាលើបញ្ហានេះពុំមានមូលដ្ឋានត្រឹមត្រូវនោះទេ។

១៦. ទោះបីជាយ៉ាងណាក៏ដោយ ផ្អែកតាមការពិចារណាលើនិយមន័យនៃទាសភាព តាមអនុសញ្ញាស្តីពីទាសភាពឆ្នាំ១៩២៦ និងការពិចារណាលើការវិនិច្ឆ័យពីអំពើធ្វើឱ្យទៅជាទាសករដែលជាបទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងយុត្តិសាស្ត្ររបស់តុលាការក្រោយសង្គ្រាមលោកលើកទី II អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមិនបានបញ្ជាក់ឱ្យបានច្បាស់អំពីនិយមន័យជាធរមាននៃអំពើធ្វើឱ្យទៅជាទាសករនោះទេ។ និយមន័យនៃអំពើធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចដែលមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិចន្លោះឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ គឺជា ១) ការប្រើប្រាស់អំណាចក្នុងនាមជាម្ចាស់ (*ធាតុផ្សំសត្យានុម័ត)* (*actus reus*) និង ២) ចេតនាក្នុងការបង្កើនផលចំណេញ តាមរយៈការប្រើប្រាស់អំណាចក្នុងនាមជាម្ចាស់ (*ធាតុផ្សំអត្តនោម័ត)* (*mens rea*)។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ជនជាប់ចោទអាចយល់ដឹងជាមុន និងអាចដឹងថា មានច្បាប់ចែងអំពីនិយមន័យនេះ។

១៧. នៅពេលយកនិយមន័យនៃការធ្វើឱ្យទៅជាទាសករ ដែលមានលក្ខណៈច្បាស់លាស់មកអនុវត្តចំពោះសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងការប្រព្រឹត្តលើអ្នកជាប់ឃុំឃាំងនៅ មន្ទីរ ស ២១ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានភស្តុតាងបង្ហាញអំពីចេតនារបស់ជនជាប់ចោទនៅក្នុងការទទួលផលចំណេញសម្រាប់ខ្លួន ពីអ្នកជាប់ឃុំឃាំងទាំងអស់នៅមន្ទីរ ស ២១ នោះទេ ឬភស្តុតាងបង្ហាញពីការចាត់ទុកអ្នកជាប់ឃុំឃាំងទាំងអស់នោះជាទំនិញនោះឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូង មិនមានកំហុសក្នុងការកម្រិតសំអាងហេតុរបស់ខ្លួននៃការធ្វើឱ្យទៅជាទាសករចំពោះតែអ្នកជាប់ឃុំឃាំងដែលបានទទួលរងនូវពលកម្មដោយបង្ខំនោះឡើយ។ ដោយផ្អែកតាមមូលដ្ឋាននេះ ត្រូវបដិសេធចោលនូវទឡ្ហីករណ៍ទី៣ នៃបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។

### ឃ. ការធ្វើទារុណកម្ម និងការរំលោភលើផ្លូវភេទ

១៨. សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូល សម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទពីបទរំលោភលើផ្លូវភេទ និងបទធ្វើទារុណកម្មនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាបទល្មើសត្រួតគ្នា។

១៩. ដោយសារពុំមានភស្តុតាងគាំទ្រគ្រប់គ្រាន់ចំពោះអត្ថិភាពនៃការរំលោភលើផ្លូវភេទ ដែលជាបទឧក្រិដ្ឋមួយដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ស្ថិតក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា ហេតុការណ៍ដែលបានកើតឡើងនៅមន្ទីរ ស ២១ គឺជាការរំលោភលើផ្លូវភេទដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ អាស្រ័យហេតុនេះ ការលើកឡើងផ្នែកនេះនៅក្នុងបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ត្រូវបដិសេធចោលជាស្វ័យប្រវត្តិ។

២០. ជាបន្ត អង្គជំនុំជម្រះតុលាការកំពូលនឹងសម្រេច ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុស ដែរ ឬយ៉ាងណាក្នុងការយល់ឃើញថា អំពើរំលោភលើផ្លូវភេទអាចចាត់ជាអំពើធ្វើទារុណកម្មនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក នោះ។ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា ទាក់ទងនឹង*ធាតុផ្សំសត្យានុម័ត*នៃអំពើធ្វើទារុណកម្ម "អំពើមួយចំនួនត្រូវបានចាត់ទុក

ថា ជាអំពើដែលនឹងនាំឲ្យមានការឈឺចាប់ និងរងទុក្ខធ្ងន់ធ្ងរ *ដោយផ្អែកលើចរិតនៃអំពើទាំងនោះ*។ អំពើទាំងនោះរួមមាន ការរំលោភលើផ្លូវភេទ [...]”។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ស្រប និងយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសនោះទេ ក្នុងការស្របបញ្ចូលអំពើរំលោភលើផ្លូវភេទទៅក្នុងនិយមន័យនៃអំពើធ្វើទារុណកម្មនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

២១. ទាក់ទងនឹងគោលការណ៍នីត្យានុកូលភាព អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា មានការបង្ហាញយ៉ាងច្បាស់ថា អំពើធ្វើទារុណកម្ម គឺជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើសិទ្ធិជាសារវន្តរបស់បុគ្គលនៅពេលដែលជនជាប់ចោទប្រព្រឹត្តអំពើឧក្រិដ្ឋនេះ។ ការទទួលស្គាល់យ៉ាងទូលំទូលាយដោយបណ្តាសហគមន៍ប្រជាជាតិនានាអំពីស្ថានទម្ងន់នៃអំពើធ្វើទារុណកម្ម បានបង្ហាញពីភាពអាចយល់ដឹងជាមុនអំពីបទល្មើសព្រហ្មទណ្ឌដែលបានចោទប្រកាន់ចំពោះអំពើបែបនេះថា ជាបទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

### ង. ការធ្វើទុក្ខបុកម្នេញ

២២. អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ការធ្វើទុក្ខបុកម្នេញគឺជាបទល្មើសដែលត្រូវបានទទួលស្គាល់ថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមច្បាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយអង្គជំនុំជម្រះសាលាដំបូងថា លក្ខខណ្ឌតម្រូវនៃធាតុផ្សំ *អត្តនោម័ត* គឺជាការប្រព្រឹត្តអំពើសកម្ម ឬអកម្ម“ដោយមានចេតនា” ក្នុងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយពូជសាសន៍ ឬសាសនា។ បន្ថែមពីលើនេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា មតិភាគច្រើនរបស់អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសនោះទេ នៅក្នុងការអនុវត្តធាតុផ្សំ *អត្តនោម័ត* ចាំបាច់ចំពោះការធ្វើទុក្ខបុកម្នេញដើម្បីសម្រេចថា ជនជាប់ចោទបានបំពេញទៅតាមលក្ខខណ្ឌតម្រូវនៃធាតុផ្សំ *អត្តនោម័ត*នៅក្នុងរឿងក្តីនេះ។

២៣. អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយអង្គជំនុំជម្រះសាលាដំបូងថា ចំណុចទីមួយនៃធាតុផ្សំ *សត្យានុម័ត*នៃការធ្វើទុក្ខបុកម្នេញ គឺថា ធាតុផ្សំសត្យានុម័តនៃការធ្វើទុក្ខបុកម្នេញបង្កើតបានជាអំពើ

សកម្ម ឬអកម្ម ដែលដកហូត ឬរំលោភទៅលើសិទ្ធិជាសារវន្តដែលមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬច្បាប់សន្ធិសញ្ញា។ ចំណុចសំខាន់បំផុតនៃការវិភាគនោះ ឋិតនៅលើការកំណត់ ថាតើ អំពើសកម្ម ឬអកម្មនេះ នៅពេលដែលពិចារណាជារួម និងតាមបរិបទ *មានភាពធ្ងន់ធ្ងរ ឬស្ថានទម្ងន់ស្មើគ្នាទៅនឹងបទល្មើសមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ ឬយ៉ាងណា* ដែលនាំឱ្យមានការរំលោភលើសិទ្ធិជាសារវន្ត ដោយកំភោល ឬឥតលាក់លៀម។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របផងដែរ ទៅនឹងចំណុចទីពីរនៃការកំណត់និយមន័យធាតុផ្សំ*សត្យានុម័ត* ដោយអង្គជំនុំជម្រះសាលាដំបូងដែលថា អំពើសកម្ម ឬអកម្មនៃការធ្វើទុក្ខបុកម្នេញត្រូវតែ"មានការរើសអើងជាក់ស្តែង" ទើបនាំឱ្យមានផលវិបាកដែលមានលក្ខណៈរើសអើសជាក់ស្តែង។

២៤. ជាចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលពិចារណា ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុសដែរ ឬយ៉ាងណា ចំពោះការសន្និដ្ឋានផ្នែកអង្គហេតុដែលថា អ្នកជាប់ឃុំឃាំងទាំងអស់នៅមន្ទីរ ស ២១ បានក្លាយជាជនរងគ្រោះនៃការធ្វើទុក្ខបុកម្នេញ ដោយសារអ្នកជាប់ឃុំឃាំងទាំងនេះត្រូវបានកំណត់ជាគោលដៅដោយមូលហេតុនយោបាយ។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ក្នុងអំឡុងពេលនៃរបបគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជាមានក្រុមមនុស្សខុសៗគ្នា ត្រូវបានកំណត់ជាគោលដៅថាជាខ្មាំងនយោបាយពិតប្រាកដ ឬដោយសន្មត ហើយត្រូវបានឃុំឃាំងនៅមន្ទីរ ស ២១ ក្រោមលក្ខណៈវិនិច្ឆ័យផ្សេងៗដែលបង្កើតឡើងដោយបក្សកុម្មុយនីស្តកម្ពុជា។ ខណៈពេលដែលបដិវត្តកំពុងឆ្ពោះទៅមុខ បុគ្គលទាំងឡាយត្រូវបានចាប់ខ្លួនត្រូវបានធ្វើបាប និងត្រូវបានបោសសម្អាតដោយមិនរើសមុខ និងដោយគ្មានការធ្វើយុត្តិកម្មដ៏សមហេតុផល ដោយមូលហេតុនយោបាយនោះទេ។ សកម្មភាពបែបនេះមិនមែនជាការធ្វើទុក្ខបុកម្នេញតទៅទៀតនោះទេ ប៉ុន្តែបង្កើតឱ្យមានការភ័យខ្លាចដែលពុំមានលក្ខណៈវិនិច្ឆ័យដែលស្តែងឱ្យឃើញក្នុងការកំណត់គោលដៅលើជនរងគ្រោះឡើយ។ ជនជាប់ចោទទទួលខុសត្រូវលើការឃុំខ្លួន ការសួរចម្លើយ ការធ្វើទារុណកម្ម ការធ្វើឱ្យទៅជាទាសករ និងការសម្លាប់បុគ្គលជាច្រើន ដែលមិនមែនជាខ្មាំងនយោបាយនោះទេ។ ទាក់ទងនឹងជនទាំងនោះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ជនរងគ្រោះទាំងនោះមិនស្ថិតនៅក្នុងសញ្ញាណនៃការធ្វើទុក្ខបុកម្នេញនោះទេ។

## ច. ការសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសត្រួតគ្នា

២៥. សហព្រះរាជអាជ្ញាអះអាងថា សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយធ្វើការស្រូបបញ្ចូលនូវរាល់បទឧក្រិដ្ឋមូលដ្ឋាននៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទៅក្នុងបទឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញ ជំនួសឱ្យការសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទពីរាល់បទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ជនជាប់ចោទជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះ។

២៦. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា នៅក្នុងការពិចារណាលើបញ្ហាដាក់ពិរុទ្ធភាពពីបទល្មើសច្រើន អង្គជំនុំជម្រះសាលាដំបូងយល់ឃើញត្រឹមត្រូវក្នុងការជ្រើសរើសនូវលក្ខណៈវិនិច្ឆ័យក្នុងរឿងក្តី *Čelebići* ដែលមានបញ្ជាក់យ៉ាងលម្អិតនៅក្នុងយុត្តិសាស្ត្ររបស់តុលាការ ICTY និង ICTR។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ក្នុងការយកលក្ខណៈវិនិច្ឆ័យនេះមកអនុវត្តចំពោះការធ្វើទុក្ខបុកម្នេញ ព្រមទាំងចំពោះបទឧក្រិដ្ឋដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ អង្គជំនុំជម្រះនេះយល់ឃើញថា នៅពេលវិភាគអំពីការសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសច្រើន គឺត្រូវធ្វើការប្រៀបធៀបជាមួយធាតុផ្សំនីត្យានុកូលអរូបិយនៃបទល្មើសជាជាងប្រៀបធៀបកាលៈទេសៈនៃអង្គហេតុដែលកើតឡើងជុំវិញអំពើជាមូលដ្ឋាន។ អង្គជំនុំជម្រះសាលាដំបូងពុំបានផ្តោតការវិភាគរបស់ខ្លួនឱ្យបានត្រឹមត្រូវទៅលើការសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសច្រើនចំពោះអំពើដែលជាមូលដ្ឋាននៃបទចោទ ជាជាងផ្តោតទៅលើធាតុផ្សំនៃការកំណត់និយមន័យតាមផ្លូវច្បាប់នៃបទល្មើសដែលខ្លួនយល់ឃើញថាអាចអនុវត្តបាន។ ជាលទ្ធផល អង្គជំនុំជម្រះសាលាដំបូងពុំបានសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសច្រើនចំពោះអំពើធ្វើទុក្ខបុកម្នេញ និងចំពោះបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលជនជាប់ចោទមានការទទួលខុសត្រូវ នោះទេ។

២៧. ហេតុដូច្នេះ ទទួលយកផ្នែកខ្លះនៃទឡ្ហីករណ៍ទីពីរនៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។ បន្ថែមពីលើការសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទ ពីបទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នោះមានការសម្រេចដាក់ពិរុទ្ធភាពដាច់ដោយឡែកផ្សេងទៀតដែលត្រូវបានធ្វើឡើង ចំពោះការ

សម្លាប់រង្គាល (ដោយរួមបញ្ចូលការធ្វើមនុស្សឃាត) ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំ-ឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត។

**ឃ. ការប្រកាសទោស**

២៨. មេធាវីការពារក្តីអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសម្រេចផ្តន្ទាទោសពុំបានសមស្រប ដោយសារការខកខានក្នុងការពិចារណាទៅលើមាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ ដែលចែងថា កាលណាបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ចៅក្រមដែលផ្តល់ "ស្ថានសម្រាលទោសអាចប្រកាសទោសដាក់ពន្ធនាគារក្នុងចន្លោះរវាង ១៥ (ដប់ប្រាំ) និង ៣០ (សាមសិប) ឆ្នាំ"។ មេធាវីការពារក្តីអះអាងថា នៅ អ.វ.ត.ក អាចអនុញ្ញាតឲ្យមានការកំណត់ទោសរយៈពេល ៣០ (សាមសិប) ឆ្នាំ គឺជាការផ្តន្ទាទោសដែលមានរយៈពេលកំណត់អតិបរមា។

២៩. សហព្រះរាជអាជ្ញាអះអាងតបថា មាត្រា ៣៩ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងអំពីរយៈពេលនៃទោសជាប់ពន្ធនាគារ "ពី ០៥ (ប្រាំ) ឆ្នាំ រហូតដល់មួយជីវិត" និងថា យោងតាមមាត្រា ៦៦៨ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៩ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ត្រូវមានអាទិភាពជាងច្បាប់ព្រហ្ម-ទណ្ឌជាតិក្នុងករណីដែលមានទំនាស់គ្នា។

៣០. ដោយពិចារណាទៅលើពាក្យពេចន៍ និងខ្លឹមសារនៃមាត្រា ៨ និងមាត្រា ៦៦៨ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ អង្គជំនុំជម្រះតុលាការកំពូលយល់ស្រប ជាមួយនឹងសហព្រះរាជអាជ្ញាដែលថា ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក គឺជា "ច្បាប់ព្រហ្មទណ្ឌដែលមានចរិតពិសេស" យោងតាមអត្ថន័យនៃមាត្រា ៦៦៨(៣) នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩។ ហេតុដូច្នេះបទប្បញ្ញត្តិនៃគន្ថីទី ១ (បទប្បញ្ញត្តិទូទៅ) នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ មិនមានអាទិភាពជាងបទប្បញ្ញត្តិណាមួយនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ក្នុងករណីដែលមានទំនាស់រវាងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក នោះទេ។ ហេតុដូច្នេះកម្រិតនៃទណ្ឌកម្មនៅ អ.វ.ត.ក អាចស្ថិតនៅចន្លោះណាមួយរវាង

ទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ រហូតដល់ទោសអស់មួយជីវិត ដូចមានចែងនៅក្នុងមាត្រា ៣៩ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

៣១. យោងតាមសំអាងហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធចោលទឡ្ហីករណ៍ទី ២ នៃបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ត្រង់ចំណុចប្រឆាំងនឹងការផ្តន្ទាទោស។

៣២. សហព្រះរាជអាជ្ញាលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការផ្តន្ទាទោសដែលមានកម្រិតស្រាលពេក។ យោងតាមការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងចំណោមកត្តាស្ថានសម្រាលទោសទាំងបួន មានកត្តាស្ថានសម្រាលទោសចំនួនពីរដែលមានអានុភាព"តិចតួច"ប៉ុណ្ណោះ រីឯអានុភាពនៃកត្តាស្ថានសម្រាលទោសទីបី"ត្រូវបានកាត់បន្ថយ" និង "ស្ទើរតែមិនមាន"។ ប៉ុន្តែ នៅក្នុងផ្នែកក្រោយទៀតនៃសាលក្រមរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូង បែរជាបានរៀបរាប់អំពីកត្តាស្ថានសម្រាលទោសទាំងបួនថា ជាកត្តាដែល "មានសារៈសំខាន់" ទៅវិញដោយមិនមានការពន្យល់អ្វីនោះទេ។

៣៣. ទោះបីជាអង្គជំនុំជម្រះសាលាដំបូង មានឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយក្នុងការកំណត់អំពីទម្ងន់នៃកត្តាស្ថានសម្រាលទោសក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ឥទ្ធិពលដែលកើតចេញពីការប្រើប្រាស់កត្តាស្ថានសម្រាលទោសក្នុងការប្រកាសទោសរបស់អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ស្ថានសម្រាលទោសទាំងនោះមានឥទ្ធិពលបន្តិចបន្តួចប៉ុណ្ណោះ។ លើសពីនេះទៀត ស្ថានទម្ងន់ទោស និងស្ថានទម្ងន់ដ៏ពិសេសនៃឧក្រិដ្ឋកម្មបានធ្វើឱ្យបាត់បង់ឥទ្ធិពលនៃស្ថានសម្រាលទោសទាំងនេះ។

៣៤. ទម្ងន់តិចតួចនៃកត្តាស្ថានសម្រាលទោសនៅក្នុងរឿងក្តីបច្ចុប្បន្ននេះ មានលក្ខណៈគ្រប់គ្រាន់ដើម្បីធ្វើការបដិសេធនូវការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា កត្តាស្ថានសម្រាលទោសទាំងនេះមាន"សារៈសំខាន់""តម្រូវឱ្យមាន"ការប្រកាសទោសដាក់ពន្ធនាគារមានរយៈពេលកំណត់ ដោយមិនបានយោងលើសំអាងផ្លូវច្បាប់ណាមួយនោះ។ អង្គជំនុំជម្រះសាលាដំបូងថែមទាំងមិនបានពិចារណា

លើច្បាប់ជាតិ និងអន្តរជាតិដែលបានអនុញ្ញាតឱ្យមានការប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិត ទោះបីជាមានកត្តាស្ថានសម្រាលទោសក៏ដោយ ហេតុដូច្នេះអាចសន្និដ្ឋានបានថា អង្គជំនុំជម្រះសាលាដំបូងមិនបានផ្តល់នូវទម្ងន់ណាមួយទៅលើច្បាប់ជាតិ និងអន្តរជាតិដែលពាក់ព័ន្ធទាំងនោះទេ។

៣៥. អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ទម្ងន់មិនសមហេតុផលចំពោះស្ថានសម្រាលទោស និងមិនបានផ្តល់ទម្ងន់ឱ្យបានគ្រប់គ្រាន់ចំពោះស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម និងស្ថានទម្ងន់ទោស ។ ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងនេះ គឺជាកំហុសអង្គច្បាប់ដែលនាំឱ្យមោឃៈការប្រកាសទោសនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ ក្នុងករណីនេះអង្គជំនុំជម្រះតុលាការកំពូលត្រូវអន្តរាគមជាចាំបាច់ ដើម្បីធ្វើការប្រកាសទោសមួយដ៏សមស្រប។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល ទទួលយកទឡ្ហីករណ៍ទីមួយនៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។

៣៦. ដោយសារតែមិនមានយុត្តិសាស្ត្រប្រហាក់ប្រហែលគ្នានៅតុលាការកម្ពុជានោះ ដូចនេះ អង្គជំនុំជម្រះតុលាការកំពូល បានធ្វើការពិនិត្យទៅលើការប្រកាសទោសរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិផ្សេងៗទៀតដែលដោះស្រាយបញ្ហាអង្គហេតុ និងអង្គច្បាប់ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានេះ។

៣៧. នៅក្នុងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិជាច្រើនបានបង្ហាញយ៉ាងច្បាស់ថា ស្ថានទម្ងន់នៃឧក្រិដ្ឋកម្មរបស់ពិរុទ្ធជនគឺជាកត្តាចំបងនៅក្នុងការប្រកាសទោស។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់បន្ថែមថា តុលាការ *មិនអចិន្ត្រៃយ៍* ភាគច្រើនបានសម្រេចប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិតចំពោះរឿងក្តីដែលជនជាប់ចោទបានរំលោភបំពានលើមុខដំណែងដឹកនាំ តាមរយៈការរៀបចំផែនការឬការបញ្ជាឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ព្រមទាំងរឿងក្តីនានាដែលមានភស្តុតាងបង្ហាញថា ពិរុទ្ធជនរូបនេះធ្វើអំពើឃោរឃៅ ឬបានបំពេញភារកិច្ចរបស់ខ្លួនដោយពេញចិត្ត។ ហេតុដូច្នេះ ដើម្បីធ្វើការប្រកាសទោសឱ្យបានសមស្រប អង្គជំនុំជម្រះតុលាការកំពូលនឹងពិចារណាអំពីស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម ព្រមទាំងកត្តាស្ថានទម្ងន់ទោសនានា ដូចជា តួនាទីដឹកនាំរបស់ កាំង ហ្កេក-អ៊ាវ និងការប្រព្រឹត្តឧក្រិដ្ឋកម្មដោយភាពឃោរឃៅ និងពេញចិត្ត។

៣៨. នៅក្នុងរឿងក្តីបច្ចុប្បន្ននេះ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា ឧក្រិដ្ឋកម្មដែល កាំង ហ្គេក អ៊ាវ បាន ប្រព្រឹត្ត គឺមាន“លក្ខណៈសាហាវយង់ឃ្នង និងគួរឲ្យព្រឺខ្លាច” ដោយផ្អែកតាមចំនួនជនរងគ្រោះដែល ត្រូវបានសម្លាប់មិនតិចជាង ១២.២៧២ នាក់ ព្រមទាំងការធ្វើទារុណកម្មជាប្រព័ន្ធ និងស្ថានភាព អាក្រក់ទូទៅដែលជនរងគ្រោះទទួលរងថែមទៀតផង។ ចំនួនអ្នកស្លាប់យ៉ាងច្រើនដែល កាំង ហ្គេក អ៊ាវ ជាអ្នកទទួលខុសត្រូវ រួមជាមួយនិងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរយៈពេលដ៏វែង (លើសពី បី ឆ្នាំ) គឺពិតជាធ្វើឲ្យសំណុំរឿងនេះ ជាសំណុំរឿងមួយដែលមានលក្ខណៈធ្ងន់ធ្ងរជាងគេបំផុតនៅចំពោះ មុខតុលាការឧក្រិដ្ឋកម្មអន្តរជាតិនានា។

៣៩. ពាក់ព័ន្ធនឹងកត្តាស្ថានទម្ងន់ទោស កាំង ហ្គេកអ៊ាវ មានតួនាទីជាមេដឹកនាំធំជាងគេនៅមន្ទីរ ស ២១ ហើយជនជាប់ចោទបានបំពានតួនាទីរបស់ខ្លួន ដោយបានបង្ហាត់បង្រៀន បញ្ជា និងគ្រប់គ្រងទៅលើ បុគ្គលិកក្នុងការធ្វើទារុណកម្មជាប្រព័ន្ធ និងការសម្លាប់អ្នកជាប់ឃុំឃាំងដែលត្រូវបានចាត់ទុកថា ជា សត្រូវរបស់របបកម្ពុជាប្រជាធិបតេយ្យ ដោយបង្ហាញពី“ការខិតខំប្រឹងប្រែងបំពេញភារកិច្ចដើម្បីធ្វើឲ្យ មន្ទីរ ស ២១ ដំណើរការទៅបានយ៉ាងរលូន”។ ជាការពិតដែលថា កាំង ហ្គេកអ៊ាវ មិនមែនជាជន កំពូលនៅក្នុងខ្សែសង្វាក់បញ្ជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនអាចធ្វើជាយុត្តិកម្មសម្រាប់ការ ផ្តន្ទាទោសស្រាលជាងនោះទេ។ ជាការពិត ពុំមានវិធានណាមួយដែលតម្រូវឲ្យផ្តន្ទាទោសខ្ពស់បំផុត ចំពោះចារីដែលជាជនកំពូលនៃខ្សែសង្វាក់បញ្ជានោះទេ។ ការផ្តន្ទាទោស កាំង ហ្គេកអ៊ាវ ត្រូវតែមាន លក្ខណៈសមស្របទៅនឹងឧក្រិដ្ឋកម្មដែលខ្លួនគាត់បានប្រព្រឹត្តដោយមិនគិត ថាតើមានមេដឹកនាំខ្ពស់ ជាងជនជាប់ចោទបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរជាង ដែរ ឬយ៉ាងណា នោះទេ។

៤០ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា តួនាទីដឹកនាំរបស់ កាំង ហ្គេកអ៊ាវ និងការពេញចិត្តយ៉ាង ខ្លាំងក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយ គឺស្ថានទម្ងន់ទោសដែលផ្តល់ទម្ងន់គ្រប់គ្រាន់ក្នុងការប្រកាស ទោសលើជនជាប់ចោទ។

៤១. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ដោយសារស្ថានទម្ងន់នៃឧក្រិដ្ឋកម្មរបស់ កាំង ហ្គេកអ៊ាវ ការដាក់ទោសដែលសមនឹងទទួល និងការធ្វើឲ្យរាងចាល គឺជាគោលបំណងសំខាន់នៅក្នុងរឿងក្តីនេះ។

ការដាក់ទណ្ឌកម្មត្រូវតែមានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង និងរារាំងមិនឲ្យឧក្រិដ្ឋកម្មដូចគ្នានេះកើតឡើងម្តងទៀត។ ឧក្រិដ្ឋកម្មដែល កាំង ហ្គេកអ៊ាវ បានប្រព្រឹត្តក្នុងរឿងក្តីនេះ គឺពិតជាឧក្រិដ្ឋកម្មមួយនៅក្នុងចំណោមឧក្រិដ្ឋកម្មដ៏អាក្រក់បំផុតនៅក្នុងកំណត់ត្រាប្រវត្តិសាស្ត្ររបស់មនុស្សជាតិ។ ឧក្រិដ្ឋកម្មទាំងនេះសមនឹងទទួលនូវទណ្ឌកម្មធ្ងន់ធ្ងរបំផុត ដើម្បីជាការឆ្លើយតបប្រកបដោយយុត្តិធម៌ និងគ្រប់គ្រាន់ចំពោះអំពើសាហាវឃោរឃៅដែលឧក្រិដ្ឋកម្មទាំងនោះបង្កឡើងទៅលើជនរងគ្រោះ ក្រុមគ្រួសារ និងសាច់ញាតិ ក៏ដូចជាប្រជាជនកម្ពុជា និងមនុស្សជាតិទាំងមូល។

៤២. សហព្រះរាជអាជ្ញាមិនបានបំផ្លើសឡើយ នៅពេលដែលសហព្រះរាជអាជ្ញាបានសំដៅទៅលើមន្ទីរ ស ២១ ថា ជា“ទីកន្លែងសម្លាប់មនុស្សដ៏ធំដោយមានការរៀបចំ”។ កាំង ហ្គេកអ៊ាវ បានបញ្ជា និងបានប្រតិបត្តិការទីកន្លែងសម្លាប់មនុស្សនេះអស់រយៈពេលជាងបីឆ្នាំ។ កាំង ហ្គេកអ៊ាវ ជាអ្នកទទួលខុសត្រូវក្នុងការសម្លាប់មនុស្សមិនតិចជាង ១២.២៧២ នាក់ ដោយគ្មានធម៌មេត្តា ដែលក្នុងនោះរួមមានស្ត្រី និងកុមារផងដែរ។

៤៣. ទោះបីជាឧក្រិដ្ឋកម្មទាំងឡាយបានកើតឡើងជាង ៣០ ឆ្នាំហើយក៏ដោយ ក៏ការកន្លងផុតដ៏យូរនេះមិនអាចសម្រាលភាពចាំបាច់ក្នុងការដាក់ទណ្ឌកម្មធ្ងន់ធ្ងរបាននោះទេ។ ការឈឺចាប់របស់ជនរងគ្រោះ ព្រមទាំងក្រុមគ្រួសារ និងសាច់ញាតិ គឺមិនត្រឹមតែជារឿងអតីតកាលប៉ុណ្ណោះទេ ក៏ប៉ុន្តែការឈឺចាប់អស់ទាំងនេះបានបន្ត និងនៅតែបន្តរហូតអស់មួយជីវិត។ ឧក្រិដ្ឋកម្មរបស់ កាំង ហ្គេកអ៊ាវ គឺជាបញ្ហាប្រឈមសម្រាប់មនុស្សជាតិទាំងមូល និងជាពិសេសសម្រាប់ប្រជាជនកម្ពុជា ដែលបង្កឲ្យមានការឈឺចាប់ដែលមិនអាចព្យាបាលជាសះស្បើយបាន។ ប្រជាជនកម្ពុជានៅតែប្រឈមមុខជាមួយបញ្ហាដែលមិនធ្លាប់ជួបប្រទះ ក្នុងការធ្វើឲ្យធូរស្បើយពីសោកនាដកម្មដែលបណ្តាលមកពីឧក្រិដ្ឋកម្មដែល កាំង ហ្គេកអ៊ាវ បានប្រព្រឹត្ត។

៤៤. យោងតាមសំអាងហេតុទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ការប្រកាសទោសដាក់ពន្ធនាគាររយៈពេល ៣៥(សាមសិបប្រាំ)ឆ្នាំ ដោយអង្គជំនុំជម្រះសាលាដំបូង មិនបានឆ្លុះបញ្ចាំងឲ្យបាន

សមរម្យទៅនឹងស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម និងស្ថានភាពបុគ្គលរបស់ កាំង ហ្កេកអ៊ាវ ឡើយ។ អង្គជំនុំជម្រះសាលាដំបូង ពិតជាមានកំហុសក្នុងការប្រកាសទោសដែលមានលក្ខណៈមិនគ្រប់គ្រាន់យ៉ាងច្បាស់ក្រឡែត។ ដូច្នេះអង្គជំនុំជម្រះតុលាការកំពូលសម្រេចប្រកាសទោសដាក់ពន្ធនាគារ កាំង ហ្កេកអ៊ាវ អស់មួយជីវិត។

៤៥. ការដោះលែងដោយមានលក្ខខណ្ឌ គឺជានីតិវិធីដាច់ដោយឡែកមួយនៅក្នុងដំណាក់កាលនៃការអនុវត្តទោសពន្ធនាគារ។ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ភាពកង្វះបទប្បញ្ញត្តិពិសេសស្តីពីការដោះលែងដោយមានលក្ខខណ្ឌនៅក្នុងឯកសារផ្លូវច្បាប់នានារបស់ អ.វ.ត.ក បង្ហាញឱ្យឃើញថា បញ្ហានេះគួរត្រូវបានដោះស្រាយទៅតាមនីតិវិធីក្នុងស្រុកជាធរមាន នាពេលដែលការដោះលែងដោយមានលក្ខ-ខណ្ឌនេះ ត្រូវបានលើកមកពិចារណា។ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ខ្លួនមិនមានសមត្ថកិច្ចសម្រេចអំពីសិទ្ធិរបស់ កាំង ហ្កេកអ៊ាវ ក្នុងការទទួលបានការដោះលែងដោយមានលក្ខខណ្ឌនោះទេ។

៤៦. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ការកាត់បន្ថយទោសចំនួន ៥(ប្រាំ)ឆ្នាំ និងការគិតបញ្ចូលរយៈពេលដែលបានជាប់ឃុំក្រោមសមត្ថកិច្ចរបស់តុលាការយោធាកម្ពុជា គឺជាការផ្តល់សំណងសម-រម្យចំពោះការរំលោភលើសិទ្ធិរបស់ កាំង ហ្កេកអ៊ាវ ដោយសារការឃុំខ្លួនខុសច្បាប់នីតិវិធីដោយតុលាការយោធាកម្ពុជាចាប់ពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ រហូតដល់ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៧។

៤៧. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ច្បាប់ដែលអាចយកមកអនុវត្តបាននៅ អ.វ.ត.ក រួមទាំងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិមិនបានបង្ហាញថា ការរំលោភសិទ្ធិរបស់ កាំង ហ្កេកអ៊ាវ គួរត្រូវបានទូទាត់សងដោយ អ.វ.ត.ក ឡើយ នៅពេលដែលពុំមានភស្តុតាងបង្ហាញថា អ.វ.ត.ក ជាអ្នករំលោភកិច្ចដំណើរការនីតិវិធី ឬជាអ្នកទទួលខុសត្រូវចំពោះការរំលោភសិទ្ធទាំងនោះ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបកស្រាយយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិដែលពាក់ព័ន្ធត្រង់ចំណុចដែលមានខ្លឹមសារថា ការរំលោភបំពានទៅលើសិទ្ធិរបស់ជនជាប់ចោទដែលបានកើតឡើងមុនការបង្កើតឱ្យមាន អ.វ.ត.ក គប្បីត្រូវទទួលបានការទូទាត់ពី

អ.វ.ត.ក ទោះបីជាមិនមែនជាការរំលោភបំពានរបស់ អ.វ.ត.ក និងទោះបីជាមិនមានការរំលោភលើកិច្ចដំណើរការនីតិវិធីក៏ដោយ។ ដោយពុំមានស្ថានភាពទាំងពីរនេះ អង្គជំនុំជម្រះសាលាដំបូងគួរតែបានបដិសេធសំណើសុំសំណងរបស់ជនជាប់ចោទ។

៤៨. យោងតាមហេតុផលដែលបានបញ្ជាក់ខាងលើ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា នេះមិនមែនជាករណីដែល អ.វ.ត.ក គប្បីសម្រេចផ្តល់សំណងចំពោះការរំលោភសិទ្ធិរបស់ កាំង ហ្កេកអ៊ាវឡើយ។ ប៉ុន្តែចៅក្រម Klonowiecka-Milart និងចៅក្រម Jayasinghe មានមតិជំទាស់ចំពោះការយល់ឃើញនេះ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដែលនាំឲ្យមោឃៈការប្រកាសទោសក្នុងការសម្រេចកាត់បន្ថយរយៈពេលផ្តន្ទាទោសចំនួន ៥ (ប្រាំ) ឆ្នាំ និងការគិតបញ្ចូលនូវរយៈពេលនៃការឃុំខ្លួន ចាប់ពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ រហូតដល់ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលជាការផ្តល់សំណងសមស្របចំពោះការរំលោភសិទ្ធិ កាំង ហ្កេកអ៊ាវ នោះ។ ចំពោះការយល់ឃើញនេះ ចៅក្រម Klonowiecka-Milart និងចៅក្រម Jayasinghe ក៏មានមតិជំទាស់ដែរ។

៤៩. ចៅក្រម Klonowiecka-Milart និងចៅក្រម Jayasinghe បានជំទាស់ទៅនឹងសេចក្តីសម្រេចរបស់ចៅក្រមមតិភាគច្រើនដែលសម្រេចមិនផ្តល់សំណង កាំង ហ្កេកអ៊ាវ ដោយសារហេតុផលដូចខាងក្រោម។ ដោយឈរលើមូលដ្ឋានយុត្តិធម៌ និងសមធម៌នៅគ្រប់កាលៈទេសៈទាំងអស់ អ.វ.ត.ក ដែលជាតុលាការចម្រុះពិសេស គប្បីទទួលខុសត្រូវចំពោះការឃុំខ្លួនមុនអង្គសេចក្តីហួសរយៈពេលកំណត់ដោយតុលាការជាតិ។ នៅក្នុងរឿងក្តីនេះ កាលៈទេសៈទាំងនេះមានដូចតទៅ: ទីមួយ ដោយហេតុថា អង្គជំនុំជម្រះត្រូវបានបង្កើតឡើងនៅក្នុង“រចនាសម្ព័ន្ធតុលាការកម្ពុជាដែលមានស្រាប់” ដូច្នេះ អ.វ.ត.ក ត្រូវបានបញ្ចូលយ៉ាងពេញលេញទៅក្នុងប្រព័ន្ធតុលាការកម្ពុជា។ ទីពីរ មានទំនាក់ទំនងយ៉ាងខ្លាំងរវាងរឿងក្តីប្រឆាំងនឹង កាំង ហ្កេកអ៊ាវ នៅ អ.វ.ត.ក និងបទចោទនៅចំពោះមុខតុលាការយោធាកម្ពុជា។ ទាក់ទងនឹងបញ្ហានេះចៅក្រម Klonowiecka-Milart និងចៅក្រម Jayasinghe កត់សម្គាល់ថា តុលាការយោធាបានឃុំខ្លួន កាំង ហ្កេកអ៊ាវ អស់រយៈពេល ៨ ឆ្នាំ ដែលនៅក្នុងអំឡុងពេលនោះ ពុំបានធ្វើការស៊ើបអង្កេតឲ្យបានស៊ីជម្រៅ មុននឹងផ្ទេរជនជាប់ចោទមក អ.វ.ត.ក ភ្លាមៗ បន្ទាប់ពី

អ.វ.ត.ក ត្រូវបានបង្កើតឡើងតាមអំណាចរដ្ឋរបស់កម្ពុជា។ ទីបី ភាពធ្ងន់ធ្ងរនៃការដកហូតសិទ្ធិសេរីភាពជនជាប់ចោទ មានលក្ខណៈធ្ងន់ធ្ងរយោងតាមបទដ្ឋានអន្តរជាតិ។ អ.វ.ត.ក ផ្តល់នូវសំណងដែលមានលក្ខណៈជាការស្តារស្ថានភាពដើមប៉ុណ្ណោះ។ ទីបួន ហេតុដូច្នេះ ចៅក្រម Klonowiecka-Milart និងចៅក្រម Jayasinghe នឹងផ្តល់សំណងដល់ កាំង ហ្កេកអ៊ាវ ដោយកាត់បន្ថយការប្រកាសទោសពីដាក់ពន្ធនាគារអស់មួយជីវិតមកត្រឹមការដាក់ពន្ធនាគារមានរយៈពេលកំណត់ ៣០ ឆ្នាំវិញ។

៥០. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា កាំង ហ្កេកអ៊ាវ មានសិទ្ធិទទួលបានការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នទាំងស្រុង ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការយោធាកម្ពុជា ចាប់ពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ រហូតដល់ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៧ និងនៅក្រោមសមត្ថកិច្ចរបស់ អ.វ.ត.ក ចាប់ពីថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៧ រហូតដល់ពេលសាលក្រមនេះចូលជាស្ថាពរ។ យោងតាមអង្គជំនុំជម្រះសាលាដំបូង ចំពោះរយៈពេលនៃការឃុំខ្លួនដំបូងនៅក្រោមសមត្ថ-កិច្ចរបស់តុលាការយោធាកម្ពុជា ត្រូវបានផ្តល់ឲ្យជនជាប់ចោទជាផ្នែកមួយនៃការទូទាត់សំណងសម្រាប់ការឃុំខ្លួនខុសច្បាប់ រីឯរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នបន្ទាប់ដែលស្ថិតក្រោមសមត្ថ-កិច្ច អ.វ.ត.ក ត្រូវបានគិតបញ្ចូលទៅក្នុងថិរវេលានៃទោស ដោយផ្អែកតាមសិទ្ធិដែលមានចែងនៅក្នុងមាត្រា ៥០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧។ ដោយហេតុថា ការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នសម្រាប់រយៈពេលបន្ទាប់មិនមានបញ្ហាចោទនោះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា គប្បីឲ្យមានការពិចារណាអំពីការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នសម្រាប់រយៈពេលដំបូង។

៥១. អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយអង្គជំនុំជម្រះសាលាដំបូងថា ការចោទប្រកាន់ទាំងឡាយដែលតុលាការយោធាកម្ពុជាបានយកមកធ្វើជាសំអាងដើម្បីឃុំខ្លួន កាំង ហ្កេកអ៊ាវ គឺ "មានលក្ខណៈប្រហាក់ប្រហែលគ្នាយ៉ាងខ្លាំង" ទៅនឹងការចោទប្រកាន់ទាំងឡាយនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក។ ដោយពិចារណាលើច្បាប់ និងការអនុវត្តកម្រិតជាតិ និងអន្តរជាតិ អង្គជំនុំជម្រះតុលាការកំពូលសម្រេចជាឯកច្ឆន្ទថា កាំង ហ្កេកអ៊ាវ មានសិទ្ធិទទួលបានការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នទាំងស្រុង ពោលគឺ ចាប់ពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ មក។

អង្គជំនុំជម្រះតុលាការកំពូល សម្រេចអនុវត្តការគិតបញ្ចូលទៅក្នុងថិរវេលានៃការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតចំពោះ កាំង ហ្គេកអ៊ាវ ដោយយល់ឃើញថា កាំង ហ្គេកអ៊ាវ បានទទួលរងទោសរបស់ខ្លួនអស់រយៈពេល ១២ ឆ្នាំ និង ២៦៩ ថ្ងៃរួចហើយដែលជារយៈពេលជននេះស្ថិតក្នុងការឃុំខ្លួនជាបណ្តោះអាសន្នចាប់ពី ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ ដល់ ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១២។

## ខ. ភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

៥២. អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ក្រុម ២ និងក្រុម ៣ សរុបចំនួន ២២ នាក់ បានប្តឹងសាទុក្ខប្រឆាំងនឹងការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។

៥៣. ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានអនុម័តតាមទំនើងចិត្តនូវលក្ខណៈវិនិច្ឆ័យនៃចំណងពិសេសនៃក្តីស្រលាញ់ ឬការរស់នៅក្នុងបន្ទុកជាមួយជនរងគ្រោះផ្ទាល់ នៅក្នុងការសម្រេចអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះមិនផ្ទាល់។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា លក្ខណៈវិនិច្ឆ័យនៃចំណងពិសេសនៃក្តីស្រឡាញ់ ឬការរស់នៅក្នុងបន្ទុកដែលជាប់ទាក់ទងរវាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាមួយនឹងជនរងគ្រោះផ្ទាល់ គឺគ្របដណ្តប់ទៅលើសារៈសំខាន់នៃទំនាក់ទំនងផ្ទាល់ខ្លួនទៅវិញទៅមក ហើយការបំផ្លាញទំនាក់ទំនងនេះនាំឲ្យមានព្យសនកម្មដែលប៉ះពាល់ដល់ជនរងគ្រោះមិនផ្ទាល់។ លក្ខណៈវិនិច្ឆ័យនេះអនុវត្តចំពោះបុគ្គលគ្រប់រូបដែលបានអះអាងថា ខ្លួនជាជនរងគ្រោះមិនផ្ទាល់ ទោះបីជាសមាជិកគ្រួសារក្តី ឬមិនមែនជាសមាជិកគ្រួសារក្តី ដោយហេតុថា ប្រសិនបើមិនមានចំណងទាក់ទងពីមុន ដែលចងភ្ជាប់ម្ចាស់បណ្តឹងទាមទារសំណងតាមផ្លូវមនោសញ្ចេតនា ញាតិលោហិត ឬសេដ្ឋកិច្ច ជាមួយនឹងជនរងគ្រោះផ្ទាល់ទេនោះ ព្យសនកម្មដែលបណ្តាលមកពីការប្រព្រឹត្តបទល្មើសនេះ មិនអាចកើតមានចំពោះម្ចាស់បណ្តឹងទាំងនេះបានទេ។ ទោះបីជាពាក្យពេចន៍បែបនេះអាចត្រូវបានបង្ហាញជាលើកដំបូងនៅក្នុងសាលក្រមនេះក៏ដោយ ក៏លក្ខណៈវិនិច្ឆ័យដែលបាន

បញ្ជាក់ក្នុងសាលក្រមនេះ គឺជាប់ទាក់ទងទៅនឹងសញ្ញាណនៃព្យសនកម្មនៅក្នុងអត្ថន័យនៃមាត្រា ១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ ដែលអាចអនុវត្តចំពោះជនរងគ្រោះមិនផ្ទាល់បាន។ ហេតុដូច្នេះ ការប្រើប្រាស់លក្ខខណ្ឌតម្រូវនេះ គឺត្រឹមត្រូវតាមផ្លូវច្បាប់ និងអាចយល់ដឹងជាមុនបាន ដូចគ្នាទៅនឹងលក្ខខណ្ឌតម្រូវឱ្យបង្ហាញព្យសនកម្ម ដែលត្រូវតែអាចយល់ដឹងជាមុនបានចំពោះដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់។ អាស្រ័យហេតុនេះ បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលលើកឡើងពីកំហុសអង្គច្បាប់ និងកង្វះភាពអាចយល់ដឹងជាមុន ត្រូវបដិសេធចោលទាក់ទងទៅនឹងលក្ខណៈវិនិច្ឆ័យ។

៥៤. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ចំណងពិសេសនៃក្តីស្រឡាញ់ និងការរស់នៅក្នុងបន្ទុកគឺជាឥទ្ធិពលដែលមានជាធម្មតានៅក្នុងចំណោមសមាជិកគ្រួសារជិតស្និទ្ធបំផុត។ អាស្រ័យហេតុនេះ ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងការសម្លាប់ជាយថាហេតុនូវសមាជិកគ្រួសារណាម្នាក់ អាចនាំឱ្យមានការឈឺចាប់ ប៉ះទង្គិចផ្លូវចិត្ត និងប្រភេទនៃព្យសនកម្មដទៃទៀតដែលកើតឡើងចំពោះសមាជិកគ្រួសារជិតស្និទ្ធបំផុត ដូចជា ការបាត់បង់ផ្នែកហិរញ្ញវត្ថុជាដើម។ សេចក្តីសន្និដ្ឋាននេះមានការគាំទ្រដោយភស្តុតាងដែលមាននៅក្នុងរឿងក្តីនេះ ដោយសុភវិនិច្ឆ័យ និងដោយការយល់ឃើញដែលមានភស្តុតាងជាសំអាង អនុលោមតាមអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស និងតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ហេតុដូច្នេះ គឺជាការត្រឹមត្រូវ ឬសមហេតុផលក្នុងការមិនដាក់បន្ទុកទៅលើគ្រួសារសាច់ញាតិផ្ទាល់ឱ្យបង្ហាញភស្តុតាងអំពីព្យសនកម្ម នៅពេលដែលនិយមន័យនៃគ្រួសារសាច់ញាតិផ្ទាល់ត្រូវបានកំណត់ច្បាស់លាស់ ហើយភាគីនានាត្រូវបានជ្រួតជ្រាបពីនិយមន័យនេះរួចហើយ។

៥៥. ទាក់ទងទៅនឹងវិសាលភាពនៃការសន្មតទុកជាមុនអំពីព្យសនកម្ម ជាការសមហេតុសមផលក្នុងការកំណត់និយមន័យនៃគ្រួសារសាច់ញាតិផ្ទាល់ ដោយគិតអំពីប្រភេទព្យសនកម្មដែលទាមទារនៅក្នុងបរិបទនៃចំណងគ្រួសារក្នុងសង្គមកម្ពុជា។ ក្នុងករណីនេះ អ្នកជំនាញមួយរូបដែលបានចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូង បានផ្តល់សក្ខីកម្មថា ជាទូទៅ គ្រួសារក្នុងសង្គមកម្ពុជារស់នៅជិតស្និទ្ធនឹងគ្នា និងពឹងអាស្រ័យគ្នាទៅវិញទៅមក ដែលជាទូទៅបង្កើតបានជាចំណងទាក់ទងដ៏រឹងមាំបែបនេះ។

គ្រួសារមិនមែនរាប់បញ្ចូលត្រឹមតែប្តីប្រពន្ធ និងកូនប៉ុណ្ណោះទេ ប៉ុន្តែរាប់បញ្ចូលទាំង"សមាជិកផ្សេងទៀតដែរ ដូចជា ឪពុកម្តាយចាស់ជរា" ឬ "បងប្អូនបង្កើត និងក្រុមគ្រួសាររបស់ពួកគេ" ឬ "ជីដូនជីតាបងប្អូនជីដូនមួយ និងមីងមា"។ ក្នុងកាលៈទេសៈភាគច្រើន មនុស្សដែលមានវ័យចាស់ជាងត្រូវធ្វើជាគំរូនៅក្នុងជីវិតរស់នៅសម្រាប់មនុស្សជំនាន់ក្រោយ។ ហេតុដូច្នេះ កត្តាទាំងនេះបង្កើតបានជាចំណងពិសេស និងភាពជិតស្និទ្ធបំផុត។ អង្គជំនុំជម្រះសាលាដំបូងបានទទួលយកសញ្ញាណដ៏ទូលំទូលាយស្តីពីសមាជិកគ្រួសារសាច់ញាតិផ្ទាល់*ទៅតាមព្រឹត្តិហេតុ* ប៉ុន្តែ ក្រោយមកយល់ឃើញថា "នៅក្នុងករណីលើកលែងតែប៉ុណ្ណោះ" សមាជិកគ្រួសារដែលមិនមែនជាសាច់ញាតិផ្ទាល់ត្រូវបានចាត់ទុកថា មាន "ចំណងពិសេសនៃក្តីស្រលាញ់ ឬជាអ្នករស់នៅក្នុងបន្ទុក"ជាមួយជនរងគ្រោះផ្ទាល់។ ដោយហេតុថាសេចក្តីសន្និដ្ឋាននេះបានកំណត់និយមន័យនៃវិសាលភាពការសន្មតទុកជាមុនក្នុងន័យចង្អៀតជាងវិសាលភាពដែលបានបញ្ជាក់អះអាងក្នុងសក្ខីកម្មរបស់អ្នកជំនាញដែលបានចាត់តាំងនោះ ដូច្នេះសេចក្តីសន្និដ្ឋាននេះមិនបានរំលោភសិទ្ធិរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ដោយហេតុថាការបង្កើតការសន្មតទុកជាមុននេះគឺផ្អែកលើឆន្ទានុសិទ្ធិរបស់តុលាការ មិនមែនផ្អែកលើសិទ្ធិរបស់ភាគីដើម្បីទទួលបានអត្ថប្រយោជន៍ពីការសន្មតទុកជាមុននេះទេ។

៥៦. ប្រហាក់ប្រហែលគ្នានេះដែរ ការដែលមិនបានជូនដំណឹងជាមុននោះ មិនធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ដោយហេតុថា ដើមបណ្តឹងរដ្ឋប្បវេណីមានបន្ទុកក្នុងការបង្ហាញភស្តុតាងអំពីព្យសនកម្ម។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលនឹងពិចារណា ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្នែកអង្គហេតុ ដែរ ឬយ៉ាងណា ក្នុងការសម្រេចអំពីលក្ខណៈសម្បត្តិគ្រប់គ្រាន់នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងសាទុក្ខ។

៥៧. ពាក់ព័ន្ធនឹងសេចក្តីអះអាងជាវិជ្ជមានដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការទទួលយកប្រព័ន្ធនៃការពិនិត្យឡើងវិញពីរដំណាក់កាល ទៅលើភាពទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ អង្គជំនុំជម្រះតុលាការកំពូលរំឭកឡើងវិញថា វិធាន ១០០(១) នៃវិធានផ្ទៃក្នុងដែលមានអត្ថន័យដូចគ្នាទៅនឹងមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ បានចែងយ៉ាងច្បាស់ថា៖"នៅក្នុងសាលក្រមតែមួយជាមួយរឿងព្រហ្មទណ្ឌ តុលាការ[សាលាដំបូង]សម្រេចអំពី

ផលប្រយោជន៍ផ្នែករដ្ឋប្បវេណី។ តុលាការវិនិច្ឆ័យអំពីភាពអាចទទួលយកបាននៃការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយសម្រេចអំពីពាក្យប្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅលើជនជាប់ចោទ និងលើអ្នកទទួលខុសត្រូវរដ្ឋប្បវេណី"។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានមូលដ្ឋានផ្លូវច្បាប់ តាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ក្នុងការសម្រេចអំពីលក្ខណៈសម្បត្តិគ្រប់គ្រាន់នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះ នៅក្នុងសាលក្រមរបស់ខ្លួនបាន។

៥៨. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខ្លឹមសារច្បាស់លាស់នៃមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧ និងវិធាន ១០០(១) នៃវិធានផ្ទៃក្នុង មានភាពគ្រប់គ្រាន់សម្រាប់ជាពត៌មានដល់ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីថា ពាក្យសុំរបស់ខ្លួននឹងត្រូវបានវាយតម្លៃសាជាថ្មីនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ ជាងនេះទៀត អង្គជំនុំជម្រះសាលាដំបូងពិតជាបានផ្តល់នូវសញ្ញាយ៉ាងទូលំទូលាយចំពោះដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសវនាការបឋម និងក្នុងអំឡុងពេលសវនាការលើអង្គសេចក្តីថា ការវាយតម្លៃជាបឋមដោយផ្អែកលើសេចក្តីបញ្ជាក់ដំបូងរបស់អង្គជំនុំជម្រះសាលាដំបូង លើភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណីនោះមិនទាន់ចាត់ទុកជាស្ថាពរនៅឡើយទេ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមិនបានប្រព្រឹត្តកំហុសអង្គច្បាប់ឡើយ ក្នុងការវាយតម្លៃនៅក្នុងសាលក្រមរបស់ខ្លួនអំពី ថាតើភាពរងគ្រោះពិតប្រាកដ ត្រូវបានលើកបង្ហាញយ៉ាងគ្រប់គ្រាន់ នៅក្នុងដំណាក់កាលសម្រេចអំពីសំណង ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានបន្ថែមទៀតថា ទោះបីមានភាពមិនច្បាស់លាស់កើតឡើងចំពោះតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅពេលចាប់ផ្តើមសវនាការក៏ដោយ ក៏ចំណុចនេះ មិនចាត់ទុកជាបុរេវិនិច្ឆ័យចំពោះម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសវនាការនោះដែរ។

៥៩. បើទោះជាអង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសអង្គច្បាប់ក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ហាក់បីដូចជាមានការយល់ច្រឡំជាសារវន្តរវាងអង្គជំនុំជម្រះសាលាដំបូង និងម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងទៅនឹងលក្ខណៈសម្បត្តិគ្រប់គ្រាន់នៃពាក្យសុំ និងអានុភាពតាមផ្លូវច្បាប់នៃការពិនិត្យជាបឋមលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះ

តុលាការកំពូលក៏ទទួលស្គាល់ផងដែរថា ដំណើរការទទួលស្គាល់ និងការបដិសេធឋានៈរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ពិតជាអាចបណ្ដាលឱ្យមានការប៉ះពាល់ដល់ផ្លូវចិត្ត និងការខកចិត្តដោយសារការចូលរួមដោយឥតប្រយោជន៍នៅក្នុងកិច្ចដំណើរការនីតិវិធីកន្លងមក។ ក្រោយពីបានពិចារណាអំពីចរិតលក្ខណៈថ្មីនៃក្របខ័ណ្ឌដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក និងភាពមិនច្បាស់លាស់ដែលអាចមើលឃើញទាក់ទិនទៅនឹងការរៀបចំជាក់លាក់អំពីការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដូចបានរៀបរាប់ខាងលើ អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់នូវលទ្ធភាពដែលអាចកើតមានឡើងថា អាចមានម្ចាស់បណ្ដឹងសាទុក្ខជាដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួន មានការយល់ច្រឡំចំពោះបញ្ហា ថាតើនៅតែមានការទាមទារឱ្យពួកគាត់ដាក់ភស្តុតាងបន្ថែមទៀត ដែរ ឬយ៉ាងណា។ ហេតុដូច្នេះដើម្បីទូទាត់ដល់ដើមបណ្ដឹងរដ្ឋប្បវេណីនូវឱកាសដែលខ្លួនបានបាត់បង់កន្លងមក អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចទទួលយកសំណើរបស់ម្ចាស់បណ្ដឹងសាទុក្ខជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការសុំដាក់ភស្តុតាងបន្ថែម ដោយមិនចាំបាច់ពិចារណា ថាតើភស្តុតាងទាំងនេះបានដាក់រួចហើយនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង ដែរ ឬយ៉ាងណា នោះឡើយ។

៦០. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ម្ចាស់បណ្ដឹងសាទុក្ខជាដើមបណ្ដឹងរដ្ឋប្បវេណីខាងក្រោមនេះ ពិតជាបានបង្ហាញភស្តុតាងគ្រប់គ្រាន់នៅក្នុងបណ្ដឹងសាទុក្ខរបស់ខ្លួន ហេតុនេះត្រូវបានទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០១ បន្ថែមលើដើមបណ្ដឹងរដ្ឋប្បវេណីដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចទទួលស្គាល់នៅក្នុងសាលក្រមរបស់ខ្លួន គឺ៖

- លី ហ៊ា ហៅ អ៊ា ហ៊ារ (E2/61)
- ហ៊ឹម មុំ (E2/62)
- JAMES Jeffrey, ROTHSCHILD Joshua (E2/86 និង E2/88)
- ឆាយ កន ហៅ លៀង កន (E2/35)
- ហុង សាវ៉ាត (E2/83)

- ភោគ ខន (E2/33)
- ម៉ន សុផា (E2/82)
- ឈឹម ស៊ីថា (E2/22)
- ណាំ ម៉ុន (E2/32)។

៦១. អង្គជំនុំជម្រះតុលាការកំពូល សម្រេចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត ដោយហេតុថា មិនអាចទទួលយកបាន។

៦២. ទាក់ទងនឹងបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជុំ ស៊ីរ៉ាត (**D25/6**) អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា ពិតជាមានការភ្លេចបញ្ចូលឈ្មោះអ្នកស្រី កឹម សុវណ្ណារី និងកូនរបស់គាត់នៅក្នុងបញ្ជីឈ្មោះជនរងគ្រោះ ក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដែលនេះគឺ ជាកំហុសសម្ភារៈ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលធ្វើការកែតម្រូវកំហុសនេះដោយខ្លួនឯងក្នុងការដាក់បញ្ចូលឈ្មោះអ្នកស្រី កឹម សុវណ្ណារី និងកូនរបស់គាត់ទៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ។

## ច. សំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី

៦៣. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចទៅលើសំណើសុំសំណងដែលមានដូចជា៖ (ក) យល់ព្រមបញ្ចូលឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីទៅក្នុងសាលក្រម និង (ខ) ចងក្រង និងផ្សព្វផ្សាយពាក្យសម្តីសុំអភ័យទោស និងពាក្យសម្តីទទួលស្គាល់ការទទួលខុសត្រូវទាំងអស់ដែល កាំង ហ្គេកអ៊ាវ បានធ្វើឡើងក្នុងអំឡុងពេលសវនាការ។ សំណើសុំសំណងដទៃទៀតរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបដិសេធ ដោយសំអាងថា សំណើសុំទាំងនោះខ្វះភាពជាក់លាក់ ឬហួសពីវិសាលភាពនៃសំណងដែលមាននៅចំពោះមុខ អ.វ.ត.ក។

៦៤. ទោះបីជាដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ មិនបានប្តឹងសាទុក្ខប្រឆាំងនឹងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើបញ្ហាសំណងក៏ដោយ ក៏ក្រុមនេះបានស្នើថា នៅក្នុងស្ថានភាពដែលទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខអំពីសំណងដែលបានដាក់ដោយម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ និងក្រុម ៣ ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចទទួលយកនោះ នោះផលប្រយោជន៍ដែលបានពីសំណងទាំងនេះ ក៏នឹងមានវិសាលភាពផងដែរ ដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងក្រុម ១។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ បានលើកឡើងពីទឡ្ហីករណ៍យ៉ាងទូលំទូលាយអំពីសំណង ហើយបានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលច្រានចោលនូវការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើសំណើសុំសំណងរបស់ខ្លួនចំនួន ៩ ចំណុច និងបានស្នើសុំឱ្យសម្រេចផ្តល់សំណងទាំងអស់នេះវិញ។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ ក៏ស្នើសុំផងដែរដល់អង្គជំនុំជម្រះតុលាការកំពូលឱ្យសម្រេចផ្តល់សំណងទៅតាមសំណើដើមដែលខ្លួនបានដាក់ជូនអង្គជំនុំជម្រះសាលាដំបូង ហើយត្រូវបានបដិសេធនៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង។

៦៥. ជាបឋម អង្គជំនុំជម្រះតុលាការកំពូលនឹងលើកបង្ហាញនូវក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធនឹងសំណងនៅចំពោះមុខ អ.វ.ត.ក។ ទោះបីជាម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីបានពឹងផ្អែកលើសំអាងផ្លូវច្បាប់អន្តរជាតិខុសៗគ្នាជាច្រើនសម្រាប់ជាប្រភពក្នុងការរៀបចំវិធីសាស្ត្រ ដែលមានលក្ខណៈបត់-បែនស្តីពីសំណងក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលសង្កត់ធ្ងន់ថា អ.វ.ត.ក ត្រូវបានបង្កើតឡើងជាផ្នែកមួយនៃប្រព័ន្ធច្បាប់ពិសេស ហើយមានតែសទិសភាព និងការណែនាំដែលមានកំរិតប៉ុណ្ណោះ ដែលអាចទាញយកពីក្របខណ្ឌដាច់ដោយឡែកទាំងនោះបាន។ ទោះបីជាមានការលើកឡើងដ៏ត្រឹមត្រូវថា ប្រទេសកម្ពុជាជារដ្ឋភាគីមួយនៃលិខិតុបករណ៍អន្តរជាតិជាច្រើន ដែលបានចែងអំពីសិទ្ធិរបស់ជនរង-គ្រោះក្នុងការទទួលបាននូវដំណោះស្រាយប្រកបដោយប្រសិទ្ធភាពក៏ដោយ ក៏ អ.វ.ត.ក មិនមានអំណាចក្នុងការវាយតម្លៃពីការអនុវត្តកាតព្វកិច្ចជាអន្តរជាតិរបស់ប្រទេសកម្ពុជានេះដែរ។ អង្គជំនុំជម្រះតុលាការកំពូលក៏បានយល់ឃើញផងដែរថា ខ្លួនពុំមានយុត្តាធិការក្នុងការសម្រេចផ្តល់សំណងទៅតាមសំណើសុំទាំងឡាយណា ដែលតម្រូវឱ្យមានការចូលរួមយ៉ាងសកម្មរបស់អាជ្ញាធរកម្ពុជា សម្រាប់អនុវត្តវិធានការនានាក្នុងការផ្តល់សំណងឡើយ ដែលទោះជាកាតព្វកិច្ចដែលមានកំណត់ច្បាស់លាស់ក្តី

ឬគ្រាន់តែជាភាពចាំបាច់ក្តី។ អ.វ.ត.ក ក៏ពុំមានសមត្ថកិច្ចក្នុងការអនុវត្តសេចក្តីសម្រេចផ្តល់សំណង នេះផងដែរ។

៦៦. អាស្រ័យហេតុនេះ ទោះបីជា អ.វ.ត.ក ពិតជាមានសមត្ថកិច្ចក្នុងការផ្តល់សំណងក៏ដោយ ក៏សមត្ថកិច្ច នេះត្រូវតែបកស្រាយទៅតាមអាណត្តិការងារ និងគោលបំណងក្នុងន័យចង្អៀត។ វិធាន ២៣ នៃវិធាន ផ្ទៃក្នុងចែងថា "សំណងកំហិតត្រឹមតែសំណង ជា"សមូហភាព និងផ្លូវចិត្ត""។ ពាក្យថា "ផ្លូវចិត្ត" បង្ហាញពីគោលដៅនៃព្យសនកម្មផ្លូវចិត្តដែលអាចជួសជុលបានហើយពុំមែនជាសម្ភារៈទេ ចំណែកឯ ពាក្យថា "សមូហភាព" គឺ មិនរាប់បញ្ចូលនូវសំណងជាបុគ្គលទេ បើទោះបីពាក់ព័ន្ធ ឬមិនពាក់ព័ន្ធ នឹងស្ថានភាពហិរញ្ញវត្ថុក៏ដោយ និងពាក្យ "សមូហភាព"នេះក៏សំដៅទៅលើវិធានការទាំងឡាយណា ដែលជាប្រយោជន៍ដល់ជនរងគ្រោះដែលមានចំនួនកាន់តែច្រើន តាមដែលអាចធ្វើទៅបាន។

៦៧. កត្តាគន្លឹះមួយទៀតទាក់ទងនឹងប្រព័ន្ធនៃការផ្តល់សំណងនៅ អ.វ.ត.ក គឺថាការផ្តល់សំណងដែលជា កាតព្វកិច្ចផ្តាច់មុខរបស់ពិរុទ្ធជន។ រឿងក្តីបច្ចុប្បន្ននេះពាក់ព័ន្ធនឹងពិរុទ្ធជនដែលត្រូវបានរកឃើញថា ជាជនក្រីក្រ។ គឺជាចំណុចសំខាន់ដំបូងបំផុតក្នុងការកម្រិតអំពីសំណងបែបនេះ ដើម្បីឱ្យការអនុវត្ត សំណងអាចធ្វើបានយ៉ាងពិតប្រាកដ ដើម្បីបញ្ចៀសនូវការចេញសេចក្តីបង្គាប់ទាំងឡាយណាដែលមិន អាចយកទៅអនុវត្តបាន និងដែលនាំឱ្យជនរងគ្រោះមានការភ័ន្តច្រឡំ និងខកចិត្ត។ ហេតុដូច្នេះ អង្គជំនុំ ជម្រះតុលាការកំពូលនឹងមិនទទួលយកនូវសំណើណា ដែលពឹងផ្អែកលើហិរញ្ញវត្ថុរបស់ កាំង ហ្កេកអ៊ាវ ក្នុងការអនុវត្តសំណងនោះឡើយ។

៦៨. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សំណើមួយចំនួនត្រូវបានបដិសេធចោល ដោយហេតុថា ការសម្រេចទទួលយកសំណើទាំងនេះ មានអត្ថន័យជាសេចក្តីបង្គាប់ចំពោះរដ្ឋរបស់កម្ពុជា។ នេះជា ករណីមួយដែលអាចកើតឡើង ឧទាហរណ៍ ដូចជាករណីដែលស្នើសុំឱ្យមានការសុំអភ័យទោសពីរដ្ឋ ការរៀបចំឱ្យមានការថែទាំសុខភាព ការបង្កើតឱ្យមានថ្ងៃរំលឹកវិញ្ញាណក្ខន្ធថ្នាក់ជាតិ និងយកឈ្មោះ ជនរងគ្រោះដាក់ជាឈ្មោះអគារសាធារណៈ ជាដើម។ រីឯសំណើដទៃទៀតត្រូវបានបដិសេធចោល ដោយហេតុថា ពុំមានមធ្យោបាយហិរញ្ញវត្ថុសម្រាប់ធានាការអនុវត្តតាមសំណើទាំងនោះ។ ករណីនេះ នឹងអាចកើតឡើង ឧទាហរណ៍ ដូចជា សំណើសុំឱ្យសាងសង់បូជនីយដ្ឋាន និងដំណើរទស្សនកិច្ចដោយ

ឥតគិតថ្លៃរបស់ជនរងគ្រោះទៅកាន់ទីប្ញជនីយដ្ឋានទាំងនោះ។ សំណើដែលសុំឱ្យតុលាការបង្គាប់ឱ្យ កាំង ហ្កេកអ៊ាវ សរសេរលិខិតទៅរដ្ឋាភិបាល ក៏ជាសំណើដែលត្រូវបានបដិសេធចោលដែរ ដោយហេតុថា ជាសំណើដែលមិនអាចអនុវត្តបាន។ ចំពោះសំណើដែលទាក់ទិននឹងការផ្សព្វផ្សាយសម្ភារៈ និងឯកសារនានា ដែលពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា កិច្ចការទាំងនោះស្ថិតក្នុងអាណត្តិរបស់ផ្នែកកិច្ចការសាធារណៈ និងអង្គភាពគាំពារជនរងគ្រោះនៃ អ.វ.ត.ក រួចហើយ។

## ឆ. ផ្នែកសម្រេចសេចក្ដី

៦៩. អង្គជំនុំជម្រះតុលាការកំពូល អានបន្តនូវផ្នែកសម្រេចសេចក្ដីរបស់អង្គជំនុំជម្រះតុលាការកំពូល។ ផ្នែកសម្រេចសេចក្ដីដែលភ្ជាប់នៅក្នុងសាលដីកាសង្ខេបនេះ មានលក្ខណៈពេញលេញ និងចូលជាស្ថាពរ ហើយត្រូវបានចុះហត្ថលេខាដោយចៅក្រមអង្គជំនុំជម្រះតុលាការកំពូល។

# ផ្នែកសម្រេចសេចក្តី

យោងតាមសំអាងហេតុខាងលើ **អង្គជំនុំជម្រះតុលាការកំពូលៈ**

**ដោយអនុលោមតាម** មាត្រា ១៤ថ្មី (១)(ខ) និង មាត្រា ៣៦ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៤(១)(ខ) នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ឆ្នាំ ២០០៣ និងវិធាន ១១១ នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៨)

**បានឃើញ** សារណាបណ្តឹងសាទុក្ខជាលាយលក្ខណ៍អក្សររបស់ភាគីនីមួយៗ និងអំណះអំណាងដែលភាគីបានលើកឡើងនៅក្នុងសវនាការបណ្តឹងសាទុក្ខ ចាប់ពីថ្ងៃទី ២៨ ដល់ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១។

<u>**ចំពោះបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ *ហៅ*“ឌុច”**</u>

**សម្រេចបដិសេធ** បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី។

<u>**ចំពោះបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា**</u>

**សម្រេចទទួលយក** ផ្នែកខ្លះនៃទឡ្ហីករណ៍ទី ២ នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា និង **សម្រេចបដិសេធ** ផ្នែកខ្លះនៃទឡ្ហីករណ៍នេះ។

> **សម្រេចបដិសេធ** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ត្រង់ចំណុចស្រូបបញ្ចូលបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទៅក្នុងបទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលអង្គជំនុំជម្រះសាលាដំបូង បានរកឃើញថា កាំង ហ្គេកអ៊ាវ ជាអ្នកទទួលខុសត្រូវ។

**សម្រេចតម្កល់ការដាក់ពិរុទ្ធភាព** លើ **កាំង ហ្គេកអ៊ាវ** ពីបទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

**សម្រេចដាក់ពិរុទ្ធភាពបន្ថែម** លើ **កាំង ហ្គេកអ៊ាវ** ពីបទសម្លាប់រង្គាល (រួមបញ្ចូលអំពើមនុស្សឃាត) បទធ្វើឱ្យទៅជាទាសករ បទដាក់ក្នុងមន្ទីរឃុំឃាំង បទធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀត។

**សម្រេចទទួលយក** ទឡ្ហីករណ៍ទី ១ នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។

**សម្រេចបដិសេធ** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រង់ចំណុចសម្រេចផ្តន្ទាទោសលើ **កាំង ហ្គេកអ៊ាវ** ដាក់ពន្ធនាគាររយៈពេល ៣៥ ឆ្នាំ ។

**សម្រេចបដិសេធ** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រង់ចំណុចសម្រេចផ្តល់សំណង ចំពោះការរំលោភសិទ្ធិរបស់ជនជាប់ចោទដែលបណ្តាលមកពីការឃុំខ្លួនខុសច្បាប់នីតិវិធី របស់តុលាការយោធាកម្ពុជាចាប់ពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ ដល់ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៧។ និង

**សម្រេចផ្តន្ទាទោស** លើ **កាំង ហ្គេកអ៊ាវ** ដាក់ពន្ធនាគារអស់មួយជីវិត ដោយចាប់គិតពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ តទៅ ដែលគិតមកទល់ពេលនេះ **កាំង ហ្គេកអ៊ាវ** បានទទួលរងទោសអស់រយៈពេល ១២ ឆ្នាំ និង ២៦៩ ថ្ងៃរួចហើយ។

**សម្រេចបដិសេធ** ទឡ្ហីករណ៍ទី ៣ នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។

<u>ចំពោះបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ក្រុម **២** និង ក្រុម ៣</u>

**សម្រេចទទួលយក** ផ្នែកខ្លះនៃទឡ្ហីករណ៍បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និង**បដិសេធ** ផ្នែកខ្លះនៃទឡ្ហីករណ៍ទាំងនេះ។

**សម្រេចទទួលស្គាល់** ជាដើមបណ្តឹងរដ្ឋប្បវេណីចំពោះម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានភស្តុតាងបង្ហាញនៅក្នុងដំណាក់កាលបណ្តឹងសាទុក្ខថា ពិតជាបានទទួលរងព្យសនកម្មដែលជាផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្មដែល **កាំង ហ្គេកអ៊ាវ** ត្រូវបានសម្រេចដាក់ពិរុទ្ធភាព បន្ថែមលើដើមបណ្តឹងរដ្ឋប្បវេណី ដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចនៅក្នុងកថាខណ្ឌ ៦៨២ នៃសាលក្រម ដូចមានរាយនាមខាងក្រោម:

- លី ហ៊ា ហៅ អ៊ា ហ៊ារ (E2/61)

- ហ៊ឹម មុំ (E2/62)

- JAMES Jeffrey, ROTHSCHILD Joshua (E2/86 និង E2/88)

- ឆាយ កន ហៅ លៀង កន (E2/35)

- ហុង សាវ៉ាត (E2/83)

- ភោគ ខន (E2/33)

- ម៉ន សុធា (E2/82)

- ឈឹម ស៊ីថា (E2/22)

-ណាំ ម៉ុន (E2/32)។

**សម្រេចបដិសេធ** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំពោះម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត។

**សម្រេចបដិសេធ** ទឡ្ហីករណ៍បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីស្តីពីសំណង។

**សម្រេចតម្កល់** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រង់ចំណុចស្តីពីការចងក្រង និងផ្សព្វផ្សាយនៅក្នុងគេហទំព័រជាផ្លូវការរបស់ អ.វ.ត.ក នូវសេចក្តីថ្លែងសុំអភ័យទោស និងការទទួលស្គាល់នូវការទទួលខុសត្រូវ ដែលបានធ្វើឡើងដោយ **កាំង ហ្គេកអ៊ាវ** ក្នុងអំឡុងពេលជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូង ព្រមទាំងនៅអង្គជំនុំជម្រះតុលាការកំពូល។

**សម្រេចតម្កល់** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រង់ចំណុចបដិសេធសំណើសុំសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

**ដោយអនុលោមតាម** វិធាន ១១១ (៥) និង ១១៣(១)-(៣) នៃវិធានផ្ទៃក្នុង

**បង្គាប់ថា កាំង ហ្គេកអ៊ាវ** ត្រូវស្ថិតនៅក្នុងមន្ទីរឃុំឃាំងនៃ អ.វ.ត.ក រហូតដល់ពេលបញ្ចប់នៃកិច្ចរៀបចំនានាក្នុងការផ្ទេរ **កាំង ហ្គេកអ៊ាវ** ទៅកាន់ពន្ធនាគារដែលខ្លួនត្រូវអនុវត្តទោស ដោយអនុលោមតាមច្បាប់ជាធរមាន។

ធ្វើជាភាសាខ្មែរ ភាសាអង់គ្លេស ។

រាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២

**ក្រុមប្រឹក្សា**

**ស៊ា ម៉ៅ** **Christopher RYAN** **ផន ធឿន** Paolo LOBBA

ចៅក្រម **គង់ ស្រីម** ប្រធាន

ចៅក្រម **Motoo NOGUCHI**

ចៅក្រម **សោម សិរិវឌ្ឍ**

ចៅក្រម **Agnieszka KLONOWIECKA-MILART**

ចៅក្រម **ស៊ិន រិទ្ធ**

ចៅក្រម **Chandra Nihal JAYASINGHE**

ចៅក្រម **យ៉ា ណារិន**

ចៅក្រម Klonowiecka-**Milart** និងចៅក្រម **Chandra Nihal Jayasinghe** ភ្ជាប់មតិជំទាស់រួមគ្នាលើផ្នែកខ្លះ។

**សាលដីកានេះចូលជាធរមាន នៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២**

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម នៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២

**ក្រុមចៅក្រម**

| | | | |
|---|---|---|---|
| **ស៊ា ម៉ៅ** | Christopher RYAN | **ផន ធឿន** | Paolo LOBBA |

# ឧបសម្ព័ន្ធ ៣

# មាតិកា
# សេចក្តីសង្ខេបសាលក្រមសំណុំរឿង ០០២/០២

១.១. សេចក្តីផ្តើម និងប្រវត្តិសំណុំរឿងដោយសង្ខេប ........................................ ២
១.២. បទចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ ..................................................៤
១.៣. សំអាងហេតុសំខាន់ៗរបស់អង្គជំនុំជម្រះសាលាដំបូង.................................. ៧
១.៣.១. បរិបទប្រវត្តិសាស្ត្រ ...............................................................៩
១.៣.២. សហករណ៍ និងការដ្ឋានការងារ ................................................ ១១
១.៣.៣. មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស ........................................១៤
១.៣.៤. ការកំណត់គោលដៅលើក្រុមមនុស្សជាក់លាក់ .............................. ១៧
១.៣.៤.១. ជនជាតិចាម .................................................................១៨
១.៣.៤.២. ជនជាតិវៀតណាម ...........................................................២០
១.៣.៤.៣. ពុទ្ធសាសនិក .................................................................២២
១.៣.៤.៤. អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ............................២២
១.៣.៥. ការចេញបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍.............................២៣
១.៣.៦. សហឧក្រិដ្ឋកម្មរួម .............................................................២៥
១.៤. ការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណ:បុគ្គលរបស់ជនជាប់ចោទ ................ ២៦
១.៤.១. ការទទួលខុសត្រូវរបស់ នួន ជា ................................................ ២៦
១.៤.២. ការទទួលខុសត្រូវរបស់ ខៀវ សំផន ..........................................៣២
១.៥. សំណងចំពោះដើមបណ្តឹងរដ្ឋប្បវេណី ..................................................៣៧
១.៦. ផ្នែកសេចក្តីសម្រេច និងការផ្តន្ទាទោស.................................................៣៩

# សេចក្តីសង្ខេបសាលក្រមសំណុំរឿង ០០២/០២

## ១.១. សេចក្តីផ្តើម និងប្រវត្តិសំណុំរឿងដោយសង្ខេប

១. ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២។ សំអាងហេតុដែលមានអានុភាពតាមផ្លូវច្បាប់មានសរសេរនៅក្នុងសាលក្រមពេញលេញជាលាយលក្ខណ៍អក្សរ ដែលនឹងមានជាភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំងនៅពេលវេលាសមស្របខាងមុខ។ ជាបញ្ហាបឋម អង្គជំនុំជម្រះកត់សម្គាល់ថា ក្នុងចំណោមបញ្ហាទាំងឡាយ ភាគីបានលើកឡើងអំពីបញ្ហានានាពាក់ព័ន្ធនឹងការជូនដំណឹងអំពីការចោទប្រកាន់ និងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២។ អង្គជំនុំជម្រះ ដោះស្រាយសំណើសុំទាំងអស់នេះដោយលម្អិតនៅក្នុងសាលក្រមពេញលេញជាលាយលក្ខណ៍អក្សរ។

២. សំណុំរឿង ០០២ ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ នួន ជា និង ខៀវ សំផន ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ ក្រោយពីសហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ដែលបានបញ្ចប់ការស៊ើបសួរតាមផ្លូវតុលាការដោយប្រើរយៈពេលអស់ជិត ៣ឆ្នាំ មក នួន ជា និង ខៀវ សំផន ត្រូវបានបញ្ជូនមកជំនុំជម្រះ។ ដំបូងឡើយ សំណុំរឿងនេះមានរួមបញ្ចូលជនជាប់ចោទពីរនាក់ផ្សេងទៀតគឺ អៀង ធីរិទ្ធ និង អៀង សារី។ នៅ ក្នុងឆ្នាំ២០១១ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹង អៀង ធីរិទ្ធ ត្រូវបានផ្អាក ហើយបទចោទប្រកាន់ទាំងឡាយប្រឆាំងនឹងរូបគាត់ត្រូវបានបំបែកចេញពីសំណុំរឿង បន្ទាប់ពីអង្គជំនុំជម្រះរកឃើញថា គាត់មិនមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមក្នុងសវនាការ ដោយសារតែជំងឺវង្វេងវង្វាន់ស្មារតីដែលចេះតែវិវត្តទៅមុខ។ អៀង ធីរិទ្ធ បានទទួលមរណភាពនៅក្នុងឆ្នាំ២០១៥។ អៀង សារី ដែលជាស្វាមីរបស់គាត់បានទទួលមរណភាពពីរឆ្នាំមុន ពោលគឺនៅដើមឆ្នាំ២០១៣។ មរណភាពរបស់ជនជាប់ចោទទាំងពីរនាក់នាំឲ្យរំលត់បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីទាំងអស់ប្រឆាំងនឹងពួកគាត់នៅចំពោះមុខ អ.វ.ត.ក.។

៣. សវនាការបឋមក្នុងសំណុំរឿង ០០២ ត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១។ នៅខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២ ទៅជាការជំនុំជម្រះតូចៗមួយចំនួន ដោយសារតែទំហំ និងភាពស្មុគស្មាញនៃដីកាដំណោះស្រាយ ព្រមទាំងបញ្ហាវ័យចាស់ និងសុខភាពរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះសាលាដំបូងបានកម្រិតវិសាលភាពសម្រាប់ការជំនុំជម្រះវគ្គដំបូងនៃសំណុំរឿង ០០២ (ដែលចាប់ពីពេលនោះមកត្រូវបានហៅថាជា "សំណុំរឿង ០០២/០១") ត្រឹមឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តពាក់ព័ន្ធនឹង៖ ទីមួយ ក្នុងអំឡុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ (ត្រូវបានហៅថាជា "ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១") និងទីពីរ ក្នុងអំឡុងការផ្លាស់ទីលំនៅប្រជាជននៅតាមតំបន់ផ្សេងៗទៀតក្នុងប្រទេសកម្ពុជា ចាប់ពីខែកញ្ញា ឆ្នាំ១៩៧៥ រហូតដល់ខែធ្នូ ឆ្នាំ១៩៧៧ (ត្រូវបានហៅថាជា "ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២") និងចុងក្រោយ ទាក់ទងនឹងការចោទប្រកាន់អំពីការសម្លាប់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ។ អង្គជំនុំជម្រះបានកម្រិតវិសាលភាពសម្រាប់ការជំនុំជម្រះវគ្គទីពីរនៅក្នុងសំណុំរឿង ០០២ (ត្រូវបានហៅថា "សំណុំរឿង ០០២/០២") ត្រឹមឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តនៅតាមសហករណ៍ តាមការដ្ឋានការងារ តាមមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សមួយចំនួន (រួមទាំងមន្ទីរសន្តិសុខ ស-២១ និងជើងឯក) ពាក់ព័ន្ធនឹងការកំណត់គោលដៅលើក្រុមមនុស្សជាក់លាក់មួយចំនួន គឺជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិក និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ការរៀបអាពាហ៍ពិពាហ៍ និងនៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធជាមួយវៀតណាម។ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ អង្គជំនុំជម្រះ បានបញ្ចប់កិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុផ្សេងទៀតនៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០២ ដែលមិនត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿង ០០២/០១ ឬ សំណុំរឿង ០០២/០២ នេះ។

៤. នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ អង្គជំនុំជម្រះបានចាប់ផ្តើមដំណើរការសវនាការលើអង្គសេចក្តី នៅក្នុងសំណុំរឿង០០២/០២។ ក្នុងអំឡុងសវនាការលើភ័ស្តុតាងដែលមានរយៈពេល ២៤ខែ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មរបស់បុគ្គលចំនួន ១៨៥នាក់ ដែលរួមមាន

សាក្សីចំនួន ១១៤នាក់ ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៦៣នាក់ និងអ្នកជំនាញចំនួន ៨នាក់។ ឯកសារភស្តុតាងជិត ៥.០០០ឯកសារ ត្រូវបានយកមកពិនិត្យដេញដោល និងទទួលយកដាក់បញ្ចូលទៅក្នុងសំណុំរឿង ដោយសរុបទៅ ឯកសារទាំងបីភាសាជាផ្លូវការមានចំនួនជាង ៨២.០០០ ទំព័រ នៅក្នុងសំណុំរឿង ០០២/០២ តែមួយ។ ដោយសារតែសំណុំរឿង ០០២/០១ និង ០០២/០២ មានលេខសំណុំរឿងដូចគ្នា ឯកសារភស្តុតាងសរុបរួមមានចំនួនជាង ១០.០០០ឯកសារ ដែលមានជាង ៣០៤.០០០ទំព័រ។ សវនាការលើភស្តុតាងក្នុងសំណុំរឿង ០០២/០២ បានបញ្ចប់នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧ បន្ទាប់ពីបានបើកសវនាការអស់រយៈពេលចំនួន ២៧៤ថ្ងៃ។ សេចក្ដីសន្និដ្ឋានផ្ទាល់មាត់បិទបញ្ចប់ការពិភាក្សាដេញដោលត្រូវបានធ្វើឡើងនៅក្នុងខែមិថុនា ឆ្នាំ២០១៧។

### ១.២. ការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ

៥. នៅក្នុងអំឡុងចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ នួន ជា ត្រូវបានចោទប្រកាន់ថា ជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា ជាសមាជិកពេញសិទ្ធនៃគណៈ កម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស ជាប្រធានសភាតំណាងប្រជាជន ហើយពេលខ្លះជានាយករដ្ឋមន្ត្រីស្ដីទីនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។ ខៀវ សំផន ត្រូវបានចោទប្រកាន់ថា មានតួនាទីជាច្រើនក្នុងបក្សកុម្មុយនីស្តកម្ពុជា និងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយធ្លាប់ធ្វើជាប្រធានគណៈប្រធានរដ្ឋផង។ គាត់ក៏ត្រូវបានចោទប្រកាន់ថាជាប្រធានមន្ទីរនយោបាយ ៨៧០ និងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា។

៦. ជនជាប់ចោទទាំងពីររូបត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តឧក្រិដ្ឋកម្មជាច្រើនប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាមរយៈការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម។ ជនជាប់ចោទត្រូវបានគេយល់ថាមានគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម ជាមួយនឹងមេដឹកនាំជាន់ខ្ពស់ផ្សេងៗទៀត ដូចជា ប៉ុល ពត ជាលេខាបក្សកុម្មុយនីស្តកម្ពុជា សុន សេន ជាប្រធានសេនាធិការ និង រស់ ញឹម ជាលេខាភូមិភាគ ដើម្បីអនុវត្តបដិវត្តសង្គមនិយមឆាប់រហ័សនៅក្នុងប្រទេសកម្ពុជា តាមរយៈដំណើរការ "មហាលោតផ្លោះ មហាអស្ចារ្យ" និងដើម្បីការពារបក្ស ប្រឆាំងនឹងខ្មាំងតាមគ្រប់មធ្យោបាយដែលចាំបាច់។ ជនជាប់ចោទត្រូវបានចោទប្រកាន់ទៀតថា ដើម្បីសម្រេចគោលបំណងរួមនេះ ជនជាប់ចោទបាន

រៀបចំបង្កើតនូវគោលនយោបាយចំនួន ៥ រួមជាមួយអ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមផ្សេងៗទៀត ដែលការអនុវត្តគោលនយោបាយនេះបានបណ្តាលឲ្យ និង/ឬ មានឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០២ ហើយដែលជនជាប់ចោទមានចេតនាប្រព្រឹត្ត។ គោលនយោបាយទាំងនេះរួមមាន (១) ការផ្លាស់ទីលំនៅប្រជាជនម្តងហើយម្តងទៀតចេញពីទីក្រុង និងទីប្រជុំជនទៅកាន់ជនបទ និងពីទីជនបទមួយទៅទីជនបទមួយទៀត (២) ការបង្កើត និងដំណើរការសហករណ៍ និងការដ្ឋានការងារ (៣) ការបង្កើត និងដំណើរការរបស់មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស (៤) ការកំណត់គោលដៅលើក្រុមមនុស្សជាក់លាក់មួយចំនួន រួមទាំង ជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិក និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (រួមទាំងអ្នករដ្ឋការស៊ីវិល និងទាហាន ព្រមទាំងក្រុមគ្រួសាររបស់ពួកគេ) និង (៥) ការចេញបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍។ ជនជាប់ចោទក៏ត្រូវបានចោទប្រកាន់ថែមទៀតថា បានរៀបចំផែនការ បញ្ជា ញុះញង់ ជួយ និងជំរុញ ឲ្យមានឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលបានរៀបរាប់ខាងលើ។ លើសពីនេះទៅទៀត ជនជាប់ចោទក៏ត្រូវបានចោទប្រកាន់ថា ត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើផងដែរ។

៧. នាពេលនេះ អង្គជំនុំជម្រះនឹងរៀបរាប់អំពីបទចោទប្រកាន់នានាដែលត្រូវបែងចែកទៅតាមគោលនយោបាយ។ យ៉ាងណាក៏ដោយ ដោយសារតែការផ្លាស់ទីលំនៅប្រជាជនត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០២ ពាក់ព័ន្ធតែនឹងការប្រព្រឹត្តចំពោះជនជាតិចាមនោះ គោលនយោបាយនេះនឹងត្រូវយកមកពិភាក្សាតែលើចំណុចពាក់ព័ន្ធនឹងជនជាតិចាមប៉ុណ្ណោះ។ វិសាលភាពនៃបទចោទប្រកាន់នានាដែលទាក់ទងនឹងសំណុំរឿង ០០២/០២ រួមមាន ការចោទប្រកាន់ទៅលើអង្គហេតុនានាពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ជនជាប់ចោទ ចំពោះឧក្រិដ្ឋកម្មដូចតទៅនេះ៖

- ពាក់ព័ន្ធនឹងការបង្កើត និងដំណើរការសហករណ៍ និងការដ្ឋានការងារ ជនជាប់ចោទត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស

និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការបាត់ខ្លួនដោយបង្ខំ។

- ពាក់ព័ន្ធនឹងការបង្កើត និងដំណើរការរបស់មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស ជនជាប់ចោទត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការបាត់ខ្លួនដោយបង្ខំ។

- ពាក់ព័ន្ធនឹងការកំណត់លើក្រុមគោលដៅជាក់លាក់ ជនជាប់ចោទត្រូវបានចោទប្រកាន់ពី៖

    - ទីមួយ ពាក់ព័ន្ធនឹងជនជាតិចាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការជម្លៀសដោយបង្ខំ និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការបាត់ខ្លួនដោយបង្ខំ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយការធ្វើមនុស្សឃាត។

    - ទីពីរ ពាក់ព័ន្ធនឹងជនជាតិវៀតណាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ តាមរយៈការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ ការនិរទេសជនស៊ីវិលដោយខុស

ច្បាប់ ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយការធ្វើមនុស្សឃាត។

- ទីបី ពាក់ព័ន្ធនឹងពុទ្ធសាសនិក ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា។

- ទីបួន ពាក់ព័ន្ធនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (រួមទាំងអ្នករដ្ឋការស៊ីវិល និងទាហាន) និងក្រុមគ្រួសាររបស់ពួកគេ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។

- ពាក់ព័ន្ធនឹងការចេញបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍ ជនជាប់ចោទត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

## ១.៣. សំអាងហេតុសំខាន់ៗរបស់អង្គជំនុំជម្រះសាលាដំបូង

៨. អង្គជំនុំជម្រះនឹងលើកឡើងអំពីសំអាងហេតុ និងសំអាងច្បាប់ ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនីមួយៗ ដោយសារតែវាពាក់ព័ន្ធនឹងគោលនយោបាយដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០២ នេះ។ បន្ទាប់មក អង្គជំនុំជម្រះនឹងលើកឡើងអំពីសហឧក្រិដ្ឋកម្មរួម មុនពេលលើកឡើងអំពីសេចក្តីសន្និដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ នួន ជា និង ខៀវ សំផន។

៩. មុនពេលលើកឡើងអំពីទីតាំងឧក្រិដ្ឋកម្ម ជាបឋម អង្គជំនុំជម្រះនឹងលើកឡើងអំពីធាតុផ្សំទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩។ អង្គជំនុំជម្រះយល់ឃើញថា ចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងបន្តយ៉ាងហោចណាស់ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ជាពេលវេលាស្ថិតក្រោមយុត្តាធិការនៃសំណុំរឿង ០០២/០២ នោះ មានការវាយប្រហារជាទូទៅ និងជាប្រព័ន្ធប្រឆាំងនឹងប្រជាជនស៊ីវិលនៅកម្ពុជា។ ការវាយប្រហារបានកើតឡើងក្នុងទម្រង់ជាច្រើន ដែលក្នុងនោះមានការជម្លៀសប្រជាជនដោយបង្ខំ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការបាត់ខ្លួនដោយបង្ខំ ការធ្វើឲ្យប៉ះពាល់ដល់

សេចក្តីថ្លៃថ្នូររបស់មនុស្ស និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។ ការវាយប្រហារនេះបានបណ្តាលឲ្យប្រជាជនស៊ីវិលរាប់លាននាក់ក្នុងប្រទេសកម្ពុជារងគ្រោះ ហើយធ្វើឲ្យជនភៀសខ្លួនជាច្រើនរត់គេចទៅប្រទេសជិតខាង។ ការវាយប្រហារនេះត្រូវបានធ្វើឡើង ដើម្បីជំរុញ និងអនុលោមតាមគោលនយោបាយ និងផែនការរបស់បក្សក្នុងការកសាងសង្គមនិយម និងការការពារប្រទេស។ អង្គជំនុំជម្រះជឿជាក់ថា ការវាយប្រហារនេះមានទ្រង់ទ្រាយធំទាំងផ្នែកវិសាលភាពភូមិសាស្ត្រ ក៏ដូចជាចំនួនជនរងគ្រោះ។ អង្គជំនុំជម្រះក៏យល់ឃើញផងដែរថា ការវាយប្រហារនេះមានលក្ខណៈជាប្រព័ន្ធ ដោយសារតែឧក្រិដ្ឋកម្មដែលមានវិសាលភាព និងទំហំធំបែបនេះ មិនអាចត្រូវបានធ្វើឡើងដោយគ្មានការគ្រោងទុកឡើយ ហើយត្រូវធ្វើឡើងដើម្បីជំរុញ និងអនុលោមតាមគោលនយោបាយរបស់បក្ស។ អង្គជំនុំជម្រះយល់ឃើញថា ការវាយប្រហារនេះមានគោលដៅប្រឆាំងនឹងប្រជាជនស៊ីវិលក្នុងប្រទេសកម្ពុជា។ អង្គជំនុំជម្រះយល់ឃើញទៀតថា ការវាយប្រហារត្រូវបានធ្វើឡើងដោយមូលហេតុនយោបាយ ជាតិសាសន៍ ជាតិពន្ធុ ពូជសាសន៍ និងសាសនា ហើយថា មានទំនាក់ទំនងរវាងការវាយប្រហារនេះនិងអំពើដែលបានប្រព្រឹត្ត។ អង្គជំនុំជម្រះក៏យល់ឃើញដែរថា នួន ជា និង ខៀវ សំផន បានដឹងពីការវាយប្រហារនេះ ហើយថា ពួកគាត់ទាំងពីរនាក់បានដឹងថាអំពើរបស់ខ្លួនគឺជាផ្នែកមួយនៃការវាយប្រហារនេះ។

១០. អង្គជំនុំជម្រះយល់ឃើញថា អត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិរវាងវៀតណាមនិងកម្ពុជាប្រជាធិបតេយ្យ មានចាប់តាំងពីខែឧសភា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ ទាក់ទងនឹងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ដែលបានចោទប្រកាន់នៅមន្ទីរសន្តិសុខ ស-២១ អង្គជំនុំជម្រះយល់ឃើញថា ជនរងគ្រោះនៃឧក្រិដ្ឋកម្មទាំងនេះគឺជាប្រជាជនស៊ីវិលវៀតណាម ឬឈ្លើយសឹកវៀតណាម ហេតុនេះ ពួកគេជាបុគ្គលដែលត្រូវទទួលបានការការពារពីអនុសញ្ញាទីក្រុងហ្សឺណែវ។ ផ្ទុយទៅវិញ ចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅមន្ទីរសន្តិសុខអូរកន្សែង អង្គជំនុំជម្រះមិនអាចជឿជាក់ឲ្យហួសពីវិមតិសង្ស័យបានទេថា ជនជាតិចារ៉ាយជាបុគ្គលដែលទទួលបានការការពារ ទៅតាមអត្ថន័យនៃអនុសញ្ញាទីក្រុងហ្សឺណែវនោះ។ អង្គជំនុំជម្រះយល់ឃើញថា ឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តទៅលើបុគ្គលដែលទទួលបានការការពារនៅមន្ទីរសន្តិសុខ ស-២១ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យនិងវៀតណាម។ អង្គជំនុំជម្រះយល់ឃើញទៀតថា នួន ជា និង ខៀវ

សំផន បានដឹងពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធជាមួយវៀតណាម ហើយថា ពួកគេទាំងពីររូបបាន ដឹងអំពីឋានៈជាបុគ្គលដែលត្រូវទទួលបានការការពាររបស់ជនរងគ្រោះនៅមន្ទីរសន្តិសុខ ស-២១។

### ១.៣.១. បរិបទប្រវត្តិសាស្ត្រ

១១. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ក្នុងឆ្នាំ១៩៥៩ ទូ សាមុត, ប៉ុល ពត និង នួន ជា បានចាប់ផ្តើមដំណើរការបង្កើតបក្សកុម្មុយនីស្តកម្ពុជាថ្មីមួយ ដើម្បីគេចចេញពីឥទ្ធិពលរបស់វៀតណាមដែលមានចរិតលក្ខណៈជាបក្សកុម្មុយនីស្តឥណ្ឌូចិន។ គោលការណ៍គ្រឹះរបស់បក្សនេះគឺប្រជាធិបតេយ្យប្រមូលផ្តុំ និងម៉ាក្សលេនីននិយម។ សន្និបាតបក្សលើកទីមួយត្រូវបានធ្វើឡើង ចាប់ពីថ្ងៃទី៣០ ខែកញ្ញា ដល់ថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៦០ ដែលនៅក្នុងពេលនោះមានការអនុម័តលក្ខន្តិកៈបក្ស និងមានការជ្រើសតាំងគណៈកម្មាធិការដឹកនាំ។ ទូ សាមុត ត្រូវបានជ្រើសតាំងជាលេខាបក្ស ចំណែក នួន ជា ត្រូវបានជ្រើសតាំងជាអនុលេខាបក្ស។ បុគ្គលទាំងពីរនាក់នេះត្រូវបានជ្រើសតាំងទៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ជាមួយនឹង ប៉ុល ពត ក្នុងនាមជាសមាជិកពេញសិទ្ធិ ហើយ អៀង សារី ជាសមាជិកត្រៀម។ សុន សេន, សោ ភឹម និង តាម៉ុក ក៏បានចូលរួមក្នុងសន្និបាតនោះដែរ ដោយ សុន សេន និង សោ ភឹម ត្រូវបានជ្រើសតាំងជាសមាជិកត្រៀមនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍។ វន វេត ត្រូវបានជ្រើសតាំងទៅក្នុងគណៈកម្មាធិការមជ្ឈិមបក្សជាមួយនឹង ទូ សាមុត, នួន ជា, ប៉ុល ពត, អៀង សារី និង សុន សេន។ នៅក្នុងសន្និបាតបក្សលើកទីពីរ នៅខែកុម្ភៈ ឆ្នាំ ១៩៦៣ ប៉ុល ពត ត្រូវបានជ្រើសតាំងជាលេខាបក្ស នៅពេល ទូ សាមុត បានបាត់ខ្លួន ចំណែក នួន ជា នៅតែជាអនុលេខាបក្ស ហើយការប្រើប្រាស់ហិង្សានយោបាយ និងហិង្សាបដិវត្តន៍ត្រូវបានបញ្ជាក់សាជាថ្មីទៀត។ អៀង សារី និង សោ ភឹម ត្រូវបានតម្លើងឋានៈជាសមាជិកពេញសិទ្ធិនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស ចំណែក វន វេត, រស់ ញឹម, សុន សេន និង តាម៉ុក ត្រូវបានជ្រើសតាំងទៅក្នុងគណៈកម្មាធិការមជ្ឈិម។ នៅក្នុងសន្និបាតបក្សលើកទីបី ដែលត្រូវបានធ្វើឡើងនៅក្នុងខែកញ្ញាឆ្នាំ១៩៧១ បានបញ្ជាក់សាជាថ្មីអំពីមាគ៌ាយុទ្ធសាស្ត្ររបស់បក្ស ដែលត្រូវបានអនុម័តនៅក្នុងសន្និបាតបក្សលើកទីមួយ និងលើកទីពីរ។ នេះជាលើកទីមួយដែល ខៀវ សំផន បានចូលរួមនៅក្នុងសន្និបាតបក្ស ហើយគាត់ត្រូវបានជ្រើសតាំងទៅក្នុងគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាក្នុងនាមជាសមាជិកបម្រុង រួមជាមួយនឹង ជូ ជេត, កែ ពក និង កុយ ធួន។

១២. រហូតដល់ឆ្នាំ១៩៦៩ សេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាបានធ្លាក់ចុះ ហើយមានភាពមិនច្បាស់លាស់អំពី ថាតើកម្ពុជាអាចនឹងធ្លាក់ចូលក្នុងសង្គ្រាមនៅក្នុងប្រទេសវៀតណាមដែរឬយ៉ាងណា បើទោះបីជា សម្តេច នរោត្តម សីហនុ មានគោលនយោបាយអព្យាក្រឹត្យជាផ្លូវការក៏ដោយ។ ចាប់ពីឆ្នាំ ១៩៦៩ មក ភាពហិនហោច ការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកនៅក្នុងប្រទេសកម្ពុជា បានរុញច្រានឲ្យកងទ័ពវៀតណាមខាងជើងកាន់តែខិតចូលមកក្នុងប្រទេសកម្ពុជា ដែលធ្វើឲ្យវិបត្តិនេះកាន់ តែមានភាពតានតឹងថែមទៀត។ នៅក្នុងឆ្នាំ១៩៧០ លន់ នល់ ក្រោមការគាំទ្រពីសហរដ្ឋអាមេរិក បានធ្វើរដ្ឋប្រហារទម្លាក់សម្តេច នរោត្តម សីហនុ ដែលនៅពេលនោះទ្រង់កំពុងស្ថិតនៅក្រៅប្រទេសកម្ពុជា។ សម្តេច នរោត្តម សីហនុ ក្រោយមកបានបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា ដែលជាចលនានយោបាយមួយដើម្បីប្រយុទ្ធប្រឆាំងនឹងអ្នកទម្លាក់ព្រះអង្គ។ នៅក្នុងខែឧសភា ឆ្នាំដដែលនោះ សម្តេច នរោត្តម សីហនុ ដោយមានការគាំទ្រយ៉ាងស្ងៀមស្ងាត់ពីបក្សកុម្មុយនីស្តកម្ពុជា បានបង្កើតរដ្ឋាភិបាលនិរទេសថ្មីមួយដែលមានឈ្មោះថា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ ខៀវ សំផន គឺជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារជាតិនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលតាមរយៈតួនាទីនេះ គាត់បានដើរតួធ្វើជាអ្នកសម្របសម្រួលទំនាក់ទំនងរវាងសម្តេច នរោត្តម សីហនុ និង ប៉ុល ពត។ រដ្ឋបាលរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាមិនមានអំណាចជាក់ស្តែងនៅក្នុងប្រទេសកម្ពុជាឡើយ បើទោះបីជា សម្តេច នរោត្តម សីហនុ នៅបន្តមានឥទ្ធិពលនៅលើឆាកអន្តរជាតិក៏ដោយ។ តាមពិតទៅ បក្សកុម្មុយនីស្តកម្ពុជាឯណោះទេដែលជាអ្នកទទួលខុសត្រូវលើការតស៊ូប្រដាប់អាវុធ នៅក្នុងប្រទេសកម្ពុជានោះ។ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាមានគោលនយោបាយតឹងរ៉ឹងក្នុងការរក្សាការសម្ងាត់ ហើយមិនបង្ហាញអត្តសញ្ញាណរបស់ពួកគេជាសាធារណៈឡើយ។ ពួកគេនិយមប្រើប្រាស់ពាក្យ “អង្គការ” ដែលជាពាក្យមិនច្បាស់លាស់ និងជាពាក្យបិទបាំង សំដៅជាស្ថាប័នដែលបានដឹកនាំប្រទេស ហើយដែលប្រជាជនធម្មតាយល់ថាមានអំណាចគ្រប់គ្រងលើប្រទេសទាំងមូល។ ពួកគេថែមទាំងបានប្រើប្រាស់បុគ្គលសាធារណៈដែលទទួលបានការគោរព ដូចជា ខៀវ សំផន និង សម្តេចនរោត្តម សីហនុ ទាំងក្នុងប្រទេស និងលើឆាកអន្តរជាតិដើម្បីជាការបិទបាំងចំពោះសកម្មភាព និងគោលនយោបាយរបស់ពួកគេ។

១៣. នៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងកម្លាំងបក្សកុម្មុយនីស្តកម្ពុជាបានចូលក្នុងទីក្រុងភ្នំពេញ ក្នុងនាមជាកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា ហើយបានចាប់ផ្តើមបណ្តេញប្រជាជនឱ្យចាកចេញពីទីក្រុងភ្នំពេញភ្លាម ដែលជាការចាប់ផ្តើមនៃរបបកម្ពុជាប្រជាធិបតេយ្យ។

**១.៣.២. សហករណ៍ និងការដ្ឋានការងារ**

១៤. អង្គជំនុំជម្រះយល់ឃើញថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានគោលនយោបាយបង្កើត និងដំណើរការសហករណ៍ និងការដ្ឋានការងារ ដែលត្រូវបានចាត់ទុកជាឧបករណ៍សំខាន់សម្រាប់ការតស៊ូវណ្ណៈ និងមានគោលដៅបង្កើតកម្លាំងពលកម្ម និងកម្លាំងផលិតរបស់ប្រជាជន ក្រោមការគ្រប់គ្រងយ៉ាងតឹងរ៉ឹង។ ទីតាំងឧក្រិដ្ឋកម្មដែលជាផ្នែកមួយនៃសំណុំរឿង ០០២/០២ គឺ សហករណ៍ត្រាំកក់ ការដ្ឋានការងារទំនប់ត្រពាំងថ្ម ការដ្ឋានការងារទំនប់ ១ មករា និងការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង។

១៥. ចំពោះសហករណ៍ត្រាំកក់ដែលស្ថិតនៅស្រុកត្រាំកក់ តំបន់ ១៣ ភូមិភាគនិរតី (បច្ចុប្បន្ន ខេត្តតាកែវ) អង្គជំនុំជម្រះយល់ឃើញថា ប្រជាជនត្រូវបានគេបង្ខំដោយចេតនាឱ្យធ្វើការងារក្រោមបរិយាកាសនៃការគ្រប់គ្រង ការគំរាមកំហែង ភាពភ័យខ្លាច ការអត់អាហារ និងរើសអើង។ កង្វះអាហារខ្លាំងបានកើតមានច្រើនដងនៅក្នុងស្រុកត្រាំកក់ ហើយបានធ្វើឱ្យមនុស្សស្លាប់។ មនុស្សជាច្រើនបានស្លាប់ដោយសារតែកង្វះអាហារូបត្ថម្ភ ធ្វើការបាក់កម្លាំង និងមានជំងឺ។ ប្រជាជនថ្មីដែលមកពីទីក្រុង និងទីរួមខេត្ត ខុសពីប្រជាជនមកពីតំបន់ជនបទដែលគេហៅថា ប្រជាជនមូលដ្ឋាន ឬប្រជាជនចាស់នោះ បានទទួលរងផលប៉ះពាល់ទាំងនេះ ជាពិសេស។ លើសពីនេះទៀត ប្រជាជនបានស្លាប់ក្នុងមន្ទីរពេទ្យស្រុក ក្នុងចំណោមទីតាំងដទៃៗទៀត ដោយសារតែការព្យាបាលមិនសមស្រប កង្វះអាហារូបត្ថម្ភ និងធ្វើការបាក់កម្លាំង។ អង្គជំនុំជម្រះក៏យល់ឃើញដែរថា មនុស្សជាច្រើននាក់បានបាត់ខ្លួននៅស្រុកត្រាំកក់ ដោយគ្មានដំណើរការតាមផ្លូវច្បាប់ ដែលតាមរយៈដំណើរការនេះ ប្រជាជនអាចស្វែងរក និងទទួលបានព័ត៌មានយ៉ាងត្រឹមត្រូវអំពីជោគវាសនាសាច់ញាតិរបស់ខ្លួន។ ស្ថានភាពនេះបានបង្កើតឱ្យមានបរិយាកាសភ័យខ្លាច និងភាពមិនច្បាស់លាស់ជាបន្តទៅទៀត។ លើសពីនេះ ការប្រណិប័តន៍សាសនា និងវប្បធម៌ប្រពៃណី ត្រូវបានលុបបំបាត់ដោយបង្ខំនៅស្រុកត្រាំកក់។ អង្គជំនុំជម្រះក៏យល់ឃើញថា ប្រជាជនត្រូវគេគ្រប់គ្រងទាំងផ្លូវកាយ និង

ផ្លូវចិត្ត ដោយសារថា ពួកគេត្រូវបានរឹតត្បិតសេរីភាពក្នុងការដើរហើរ ត្រូវចូលរួមប្រជុំទិតៀន និង ស្វ័យទិតៀន បាត់បង់រចនាសម្ព័ន្ធគ្រួសារដែលមាន និងទទួលរងការគំរាមកំហែងថា នឹងបញ្ជូនទៅ អប់រំ ចាប់ខ្លួន ឬបាត់ខ្លួន។ ទង្វើទាំងនេះ គឺជាការបំពាក់បំប៉ន ការគំរាមកំហែង ការរឹតត្បិត សេរីភាពក្នុងការដើរហើរ ការធ្វើពលកម្មដោយបង្ខំ ការភ័យខ្លាច និងអំពើហិង្សា ដែលស្ថិតក្រោម ការគ្រប់គ្រងយ៉ាងតឹងរ៉ឹង។

១៦. ចំពោះការដ្ឋានការងារទំនប់ត្រពាំងថ្មដែលស្ថិតនៅតំបន់ ៥ ភូមិភាគពាយព្យ (បច្ចុប្បន្ន ខេត្តបន្ទាយមានជ័យ) អង្គជំនុំជម្រះយល់ឃើញថា អ្នកធ្វើការត្រូវបានគេបង្ខំឱ្យសង់ទំនប់មួយ និង អាងស្តុកទឹកពីរ ដែលជារចនាសម្ព័ន្ធសំណង់រួមមួយ ដែលដំណើរការរហូតមកទល់សព្វថ្ងៃនេះ ហើយនៅតែមានទ្រង់ទ្រាយដើមដដែល។ អ្នកធ្វើការនៅទំនប់នេះគ្មានជម្រើសអ្វីផ្សេងក្រៅពីត្រូវធ្វើ ការដោយមិនគិតពីស្ថានភាពអាកាសធាតុ ត្រូវធ្វើការធ្ងន់ជាច្រើនម៉ោង មិនត្រូវបានគេអនុញ្ញាតឱ្យ មានថ្ងៃឈប់សម្រាក ត្រូវបានមេកងតាមដានជាប្រចាំ ដើម្បីពិនិត្យមើលថា តើពួកគេបំពេញ ការងារបានប៉ុន្មាន និងត្រូវដាក់ពិន័យបើសិនពួកគេមិនបានសម្រេចការងារតាមផែនការ។ អ្នកធ្វើ ការត្រូវគេគំរាមកំហែងថា នឹងត្រូវសម្លាប់ ឬបាត់ខ្លួន ឬត្រូវគេកាត់បន្ថយរបបអាហារ បើពួកគេ មានអាកប្បកិរិយាដែលគេចាត់ទុកថាប្រឆាំងនឹងអង្គការ ឬបើពួកគេមិនសម្រេចភារកិច្ចដែលបាន ប្រគល់ឱ្យ។ សាក្សីបានឃើញអ្នកធ្វើការត្រូវបានគេសម្លាប់នៅនឹងមុខ ហើយត្រូវបានគេគំរាម កំហែងថា នឹងត្រូវគេសម្លាប់ដែរ បើមិនប្រឹងធ្វើការ។ អង្គជំនុំជម្រះយល់ឃើញថា ការស្លាប់នៅ ការដ្ឋានមិនត្រឹមតែបណ្តាលមកពីលក្ខខណ្ឌការងារ និងលក្ខខណ្ឌរស់នៅលំបាកវេទនាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដោយសារតែការសម្លាប់ដោយចេតនាផងដែរ។

១៧. ចំពោះការដ្ឋានការងារទំនប់ ១ មករា ដែលស្ថិតនៅតំបន់ ៤២ និងតំបន់ ៤៣ ភូមិភាគ កណ្តាល (ឧត្តរចាស់) (បច្ចុប្បន្នខេត្តកំពង់ធំ) អង្គជំនុំជម្រះយល់ឃើញថា លក្ខខណ្ឌការងារ និង លក្ខខណ្ឌរស់នៅមានភាពលំបាកវេទនាដូចគ្នា ខ្វះអាហារ និងមានការព្យាបាលមិនគ្រប់គ្រាន់ដូចគ្នា។ អ្នកធ្វើការនៅទីនោះក៏គ្មានជម្រើសអ្វីឡើយ ដោយពួកគេត្រូវគេបង្ខំឱ្យធ្វើការផ្ទុយនឹងឆន្ទៈរបស់ខ្លួន និងក្រោមលក្ខខណ្ឌលំបាកខ្លាំងបំផុត ដែលជាហេតុបណ្តាលឱ្យស្លាប់ក្នុងករណីខ្លះ។ លើសពីនេះ ទៀត អ្នកធ្វើការខ្លះត្រូវបានគេសម្លាប់ដោយចេតនា។ វត្តបារាយណ៍ជាន់ដែក នៅក្បែរនោះ ជា

កន្លែងដែលគេបានរកឃើញអដ្ឋិធាតុ និងសម្លៀកបំពាក់ជាច្រើន ក្រោយរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ត្រូវបានគេប្រើប្រាស់ធ្វើជាកន្លែងឃុំឃាំង និងសម្លាប់មនុស្ស។ អ្នកធ្វើការខ្លះត្រូវបានគេផ្ទេរពីការដ្ឋានការងារទំនប់ ១ មករា ទៅកន្លែងនោះ ហើយត្រូវបានគេសម្លាប់ ចំណែកឯអ្នកធ្វើការខ្លះទៀតបានបាត់ខ្លួនតែម្តង។ អង្គជំនុំជម្រះយល់ឃើញទៀតថា ជនជាតិចាម និងប្រជាជនថ្មី ត្រូវបានគេរើសអើងខ្លាំងនៅការដ្ឋានការងារនេះ។ ក្នុងអំឡុងសាងសង់ អ្នកធ្វើការនៅការដ្ឋានទំនប់ ១ មករា មានចំនួនរាប់ម៉ឺននាក់ គឺចន្លោះពី ២០.០០០នាក់ ទៅ ៤០.០០០នាក់ ក្នុងពេលការងារមមាញឹកបំផុត។

១៨. ចំពោះការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំងដែលស្ថិតនៅតំបន់ ៣១ ភូមិភាគបស្ចិម (បច្ចុប្បន្នខេត្តកំពង់ឆ្នាំង) អង្គជំនុំជម្រះយល់ឃើញថា អ្នកធ្វើការនៅការដ្ឋាននេះ គឺជាកងទ័ពមកពីតាមកងពលនានានៃកងទ័ពបដិវត្តន៍កម្ពុជា។ ការងារដែលពួកគេធ្វើ គឺសម្រាប់គោលបំណងយោធា។ ទោះជាយ៉ាងណាក៏ដោយ អ្នកធ្វើការត្រូវគេប្រើឲ្យធ្វើការងារដូចជាទាសករ និងមិនអាចប្រកែកមិនធ្វើការងារបានឡើយ បើមិនដូច្នេះទេពួកគេទទួលរងការគំរាមកំហែង ហើយក្នុងករណីខ្លះបាត់ខ្លួន។ ពួកគេទទួលដំណឹងថា អ្នកមិនគោរពតាមការណែនាំនឹងត្រូវដកចេញ ឬសម្លាប់ចោល។ អង្គជំនុំជម្រះយល់ឃើញទៀតថា អ្នកធ្វើការប្រឈមមុខនឹងលក្ខខណ្ឌការងារគ្មានសុវត្ថិភាព និងត្រូវគេបង្ខំឲ្យធ្វើការច្រើនម៉ោងដោយគ្មានអាហារគ្រប់គ្រាន់ ដែលជាហេតុធ្វើឲ្យមនុស្សជាច្រើនស្លាប់។ កងទ័ពមកពីភូមិភាគបូព៌ាឬកងពល ដែលមេដឹកនាំរបស់ពួកគេត្រូវបានគេចាត់ទុកថាជាជនក្បត់ ត្រូវធ្វើការងារធ្ងន់ឬប្រកបដោយគ្រោះថ្នាក់ខ្លាំង ដើម្បីកសាងខ្លួន។ ជាពិសេស ការវាយថ្មមាន ហានិភ័យខ្ពស់ ហើយអ្នកធ្វើការស្ទើរតែគ្មានមធ្យោបាយអ្វីដើម្បីការពារខ្លួនឡើយ។ ជីវិតរបស់ពួកគេត្រូវបានចាត់ទុកដូចជាឧបករណ៍ប្រើប្រាស់។ នៅទីបំផុត អ្នកធ្វើការជាច្រើននាក់បានបាត់ខ្លួនដោយគ្មានដំណឹង និងលែងឃើញនៅការដ្ឋានការងារទៀត ចំណែកឯអ្នកផ្សេងទៀតត្រូវបានគេចាប់ខ្លួន ហើយក្រោយមក ក៏បាត់ខ្លួន ឬត្រូវគេបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១។

១៩. អង្គជំនុំជម្រះយល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដូចតទៅនេះត្រូវបានប្រព្រឹត្តទាក់ទងនឹងការបង្កើត និងដំណើរការសហករណ៍ និងការដ្ឋានការងារ។ ឧក្រិដ្ឋកម្មទាំងនោះមានការធ្វើមនុស្សឃាត ការធ្វើឲ្យទៅជាទាសករ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ អំពើ

អមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការបាត់ខ្លួនដោយបង្ខំ។

### ១.៣.៣. មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស

២០. អង្គជំនុំជម្រះយល់ឃើញថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានគោលនយោបាយបង្កើត និងដំណើរការមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស ដើម្បីកំណត់អត្តសញ្ញាណ ចាប់ខ្លួន ដាក់ឲ្យនៅដាច់ដោយឡែកតែម្នាក់ឯង និង "កម្ទេច" អ្នកដែលគេចាត់ទុកជាខ្មាំងប្រភេទធ្ងន់ធ្ងរបំផុត។ ទីតាំងឧក្រិដ្ឋកម្មដែលជាផ្នែកមួយនៃសំណុំរឿង ០០២/០២ គឺមន្ទីរសន្តិសុខ ស-២១ (រួមទាំង ទីតាំងសម្លាប់មនុស្សនៅជើងឯក) មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល។

២១. ចំពោះមន្ទីរសន្តិសុខ ស-២១ ដែលស្ថិតនៅវិទ្យាល័យពញាយ៉ាត ក្នុងទីក្រុងភ្នំពេញ ស្ទើរតែពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ អង្គជំនុំជម្រះយល់ឃើញថា មន្ទីរសន្តិសុខ ស-២១ បានចាប់ផ្តើមដំណើរការយូរបំផុត នៅខែតុលា ឆ្នាំ១៩៧៥។ មន្ទីរសន្តិសុខ ស-២១ មានមុខងារចម្បងក្នុងការឃុំខ្លួនបក្ខជន និងយុទ្ធជនបដិវត្តន៍ ដែលត្រូវគេសង្ស័យថាជាខ្មាំង។ អង្គជំនុំជម្រះយល់ឃើញថា អ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ ត្រូវគេឃុំឃាំង ដោយគ្មានការការពារតាមនីតិវិធីច្បាប់ឡើយ ហើយលក្ខខណ្ឌឃុំឃាំងមានសភាពគួរឲ្យអាណោចអាធ័ម ដែលជាហេតុធ្វើឲ្យអ្នកជាប់ឃុំខ្លះស្លាប់។ ថ្វីត្បិតតែអ្នកជាប់ឃុំខ្លះ ត្រូវគេប្រើឲ្យធ្វើការងារជាបណ្តោះអាសន្ន តែអ្នកជាប់ឃុំស្ទើរតែទាំងអស់ត្រូវគេសួរចម្លើយ ដោយប្រើវិធីធ្វើបាបខុសៗគ្នាមុននឹងយកទៅសម្លាប់ចោល។ អង្គជំនុំជម្រះយល់ឃើញថា អ្នកជាប់ឃុំត្រូវគេនាំទៅបន្ទប់សួរចម្លើយទាំងដៃជាប់ខ្នោះ បិទមុខ និងជើងជាប់ច្រវ៉ាក់ ក្នុងពេលសួរចម្លើយ។ វិធីសួរចម្លើយរួមមាន ការវាយដំនឹងដំបង ព្រនង់ ខ្សែភ្លើងរំពាត់ និងឧបករណ៍ផ្សេងៗទៀត ការឆក់ខ្សែភ្លើង ការគ្របក្បាលនឹងថង់ប្លាស្ទិកឲ្យថប់ដង្ហើម ការយកក្រណាត់រុំមុខ ការចាក់ទឹកត្រជាក់ពីកំសៀវ និងការដកក្រចកដៃក្រចកជើង។ អ្នកជាប់ឃុំខ្លះបានស្លាប់ ក្រោយពីត្រូវបានគេបូមឈាមចេញ យកឈាមទៅព្យាបាលកងទ័ពបដិវត្តន៍កម្ពុជា ដែលបានរងរបួស។ អង្គជំនុំជម្រះយល់ឃើញទៀតថា យ៉ាងហោចណាស់អ្នកជាប់ឃុំចំនួន ១១.៧៤២

នាក់ ត្រូវបានគេសម្លាប់នៅមន្ទីរសន្តិសុខ ស-២១ ឬនៅជុំវិញនោះ និងនៅជើងឯក។ ឧទាហរណ៍ នៅជើងឯក អ្នកជាប់ឃុំត្រូវគេសម្លាប់ដោយវាយនឹងដែកគ្រង់កញ្ចឹងក រួចអារកនឹងកាំបិត ហើយសាកសពត្រូវគេវះពោះ និងកប់ក្នុងរណ្តៅសាកសពរួម។ អង្គជំនុំជម្រះក៏យល់ឃើញដែរថា មានការណែនាំផ្ទាល់ពីថ្នាក់លើរួមទាំង នួន ជា និង សុន សេន ឲ្យសម្លាប់អ្នកជាប់ឃុំ ឬក្រុមអ្នកជាប់ឃុំ។ ក្នុងចំណោមអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ មានបក្ខជនសំខាន់ៗ ដូចជា រស់ ញឹម និង វន វ៉េត ព្រមទាំងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក៏ដូចជាទាហាន និងជនស៊ីវិលវៀតណាម។ បញ្ជីអ្នកជាប់ឃុំនៃមន្ទីរសន្តិសុខ ស-២១ ក៏បង្ហាញឲ្យឃើញផងដែរថា កុមារជាច្រើនត្រូវបានគេឃុំឃាំង និងសម្លាប់នៅមន្ទីរសន្តិសុខនេះ និងនៅជើងឯក នៅពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ។

២២. មន្ទីរសន្តិសុខក្រាំងតាចាន់ដែលស្ថិតនៅស្រុកត្រាំកក់ ខាងលិចក្រុងតាកែវ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧៣ និងបន្តដំណើរការពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះយល់ឃើញថា អ្នកជាប់ឃុំនៅមន្ទីរសន្តិសុខនេះ ត្រូវបានឃុំខ្លួនដោយគ្មានការការពារតាមនីតិវិធីច្បាប់ និងក្រោមលក្ខខណ្ឌគួរឲ្យខ្លាច ត្រូវគេបង្ខំឲ្យអង្គុយទាំងជាប់ខ្នោះ និងច្រវាក់ រួមគ្នាជាជួរ លើកម្រាលអគារឃុំឃាំង។ អ្នកជាប់ឃុំមួយចំនួនដែលភាគច្រើនជាប្រជាជនថ្មីត្រូវគេសម្លាប់ភ្លាមៗក្រោយពីត្រូវបានបញ្ជូនទៅដល់មន្ទីរសន្តិសុខក្រាំងតាចាន់ ដោយគ្មានសួរចម្លើយឡើយ។ អ្នកជាប់ឃុំជាច្រើនទៀត ត្រូវបានគេសួរចម្លើយរយៈពេលពីរបីសប្តាហ៍ ក្រោយពីមកដល់។ អង្គជំនុំជម្រះយល់ឃើញថា ជារឿយៗ ការសួរចម្លើយនៅមន្ទីរសន្តិសុខក្រាំងតាចាន់មាន ការវាយដំ ការទាត់ធាក់ និងការធ្វើឲ្យថប់ដង្ហើមស្ទើរស្លាប់ ហើយការធ្វើបាបបែបនេះបានបណ្តាលឲ្យអ្នកជាប់ឃុំខ្លះបានស្លាប់។ អ្នកជាប់ឃុំជាច្រើនក៏បានបាត់ខ្លួនផងដែរ។ អង្គជំនុំជម្រះយល់ឃើញទៀតថាមានរបបការងារសម្រាប់អ្នកជាប់ឃុំមួយចំនួនតូចដែលត្រូវគេប្រើដើម្បីជាប្រយោជន៍បក្ស ហើយក្នុងករណីជាច្រើន ពួកគេត្រូវបានសម្លាប់ចោលផងដែរ។

២៣. មន្ទីរសន្តិសុខអូរកន្សែងដែលស្ថិតនៅតំបន់ ១០២ ភូមិភាគឦសាន (បច្ចុប្បន្នខេត្តរតនគិរី) ត្រូវបានបង្កើតឡើងនៅចុងឆ្នាំ១៩៧៦ និងដើមឆ្នាំ១៩៧៧ ហើយបន្តដំណើរការពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះយល់ឃើញថាមន្ទីរសន្តិសុខអូរកន្សែងត្រូវគេប្រើជាជំនួយ

ដល់មន្ទីរសន្តិសុខ ស-២១ សម្រាប់ឃុំខ្លួននិងលត់ដំអ្នកប្រព្រឹត្តកំហុសស្រាលមកពីភូមិភាគឦសាន ចំណែកឯកម្មាភិបាលជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា និងកម្មាភិបាលនៃកងពល ៨០១ ដែលត្រូវបានចាប់ខ្លួនមកពីភូមិភាគឦសាន ត្រូវបានគេបញ្ជូនទៅឃុំខ្លួន និងសម្លាប់ជាញឹកញាប់នៅមន្ទីរសន្តិសុខ ស-២១។ ចាប់ពីពាក់កណ្ដាលឆ្នាំ១៩៧៧ មក ជនស៊ីវិលដែលមិនមានតំណែងជាន់ខ្ពស់ រួមទាំងអ្នកធ្វើការមកពីសហករណ៍ និងសហជីពចម្ការកៅស៊ូ នៅទូទាំងភូមិភាគឦសានក៏ត្រូវគេឃុំខ្លួននៅមន្ទីរសន្តិសុខអូរកន្សែងផងដែរ។ អង្គជំនុំជម្រះយល់ឃើញថា លក្ខខណ្ឌនៃការឃុំខ្លួនមានភាពខុសគ្នារវាងអ្នកដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តកំហុសធ្ងន់ និងអ្នកប្រព្រឹត្តកំហុសស្រាល ស្ត្រី និងកុមារ។ អ្នកដែលគេចាត់ទុកថាគ្រោះថ្នាក់ ត្រូវគេដាក់ច្រវាក់ ឬខ្នោះជាប់រហូតក្នុងអគារឃុំឃាំងដាច់ដោយឡែក។ អ្នកប្រព្រឹត្តកំហុសស្រាល ក៏ដូចជាស្ត្រី និងកុមារ មិនត្រូវបានគេដាក់ខ្នោះ ច្រវាក់ ឬមិនត្រូវបានគេដាក់ក្នុងបន្ទប់ឃុំឃាំងឡើយ។ អង្គជំនុំជម្រះក៏យល់ឃើញថា អ្នកជាប់ឃុំត្រូវគេសួរចម្លើយតាមរយៈការវាយដំ ការទាត់ធាក់ និងការឆក់ខ្សែភ្លើងដោយប្រើខ្សែទូរស័ព្ទ ឬមធ្យោបាយប្រហាក់ប្រហែល។ អង្គជំនុំជម្រះមិនអាចជឿឲ្យហួសពីវិមតិសង្ស័យថា អ្នកជាប់ឃុំដែលគេគិតថា មិនអាចកែប្រែបានត្រូវគេសម្លាប់ទាំងអស់ ដោយគ្មានការលើកលែងនោះទេ ក៏ប៉ុន្តែអង្គជំនុំជម្រះជឿជាក់ថា ការសម្លាប់ពិតជាកើតមានមែន។ លើសពីនេះទៀត អ្នកខ្លះស្លាប់ដោយសារលក្ខខណ្ឌនៃការឃុំខ្លួន។ អង្គជំនុំជម្រះយល់ឃើញទៀតថា ជនជាតិចារ៉ាយយ៉ាងហោចណាស់ ១០០នាក់ ដែលក្នុងនោះ រួមមានទាំងបុរស កុមារ និងស្ត្រីប្រហែល ៥នាក់ ត្រូវគេឃុំខ្លួននៅមន្ទីរសន្តិសុខអូរកន្សែង នៅពាក់កណ្ដាលឆ្នាំ១៩៧៧។ ក្រោយពីត្រូវបានឃុំខ្លួននៅមន្ទីរសន្តិសុខនេះបានប្រហែលមួយសប្ដាហ៍ ជនជាតិចារ៉ាយទាំងនេះត្រូវបានគេប្រើលេសបណ្ដើរចេញពីកន្លែងឃុំឃាំង រួចនាំទៅសម្លាប់ចោល។ អង្គជំនុំជម្រះជឿជាក់ថា បទបញ្ជាឲ្យសម្លាប់ជនជាតិចារ៉ាយ ត្រូវបានបញ្ជូនតាមរយៈ សុន សេន និង ស្វ សារឿន មេបញ្ជាការកងពល ៨០១ ដោយមានការចូលរួមពីគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ទៅឲ្យបុគ្គលិកនៅមន្ទីរសន្តិសុខនេះដើម្បីអនុវត្ត។ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះមិនអាចជឿឲ្យហួសពីវិមតិសង្ស័យថា ជនជាតិចារ៉ាយដែលទំនងជាអតីតទាហាននៃរបបសាធារណរដ្ឋវៀតណាមខាងត្បូង ឬត្រូវបានគេសន្មតបែបនេះ គឺជាជនដែលត្រូវទទួលបានការការពារ នៅក្នុងអត្ថន័យនៃអនុសញ្ញាទីក្រុងហ្សឺណែវនោះឡើយ។

២៤. មន្ទីរសន្តិសុខភ្នំក្រោលស្ថិតនៅតំបន់ ១០៥ (បច្ចុប្បន្នខេត្តមណ្ឌលគិរី) មានមន្ទីរ ក-១៧ និង ក-១១ គុកភ្នំក្រោល និងកន្លែងកប់សាកសពត្រពាំងព្រីង។ អង្គជំនុំជម្រះយល់ឃើញថា ពុំមានការការពារតាមប្រព័ន្ធតុលាការ ឬតាមនីតិវិធីច្បាប់ទេ នៅពេលចាប់ខ្លួនអ្នកដែលត្រូវបានគេសន្មតថាជាអ្នកទោស និងពេលឃុំខ្លួនពួកគេនាពេលក្រោយមកនៅមន្ទីរសន្តិសុខភ្នំក្រោល ហើយនៅក្នុងអំឡុងពេលនោះ ពួកគេត្រូវបានបង្ខំឲ្យធ្វើការ។ អង្គជំនុំជម្រះយល់ឃើញទៀតថា អ្នកជាប់ឃុំម្នាក់បានស្លាប់ដោយសារតែលក្ខខណ្ឌនៃការឃុំខ្លួន ហើយអ្នកជាប់ឃុំម្នាក់ត្រូវគេសម្លាប់ដោយចេតនា។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះមិនអាចរកភ័ស្តុតាងបង្ហាញឲ្យឃើញថា តើកន្លែងកប់សាកសពត្រពាំងព្រីងត្រូវបានគេប្រើសម្រាប់កប់សាកសពអ្នកជាប់ឃុំទាំងនោះ ឬយ៉ាងណានោះទេ។ លើសពីនេះទៀត ទោះបីជាអង្គជំនុំជម្រះជឿថា ត្រពាំងព្រីងពិតជាកន្លែងកប់សាកសពនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថាត្រពាំងព្រីងត្រូវគេប្រើជាទីតាំងសម្លាប់មនុស្សបានឡើយ។

២៥. អង្គជំនុំជម្រះយល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដូចតទៅនេះត្រូវបានប្រព្រឹត្តពាក់ព័ន្ធនឹងការបង្កើត និងដំណើរការរបស់មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស។ ឧក្រិដ្ឋកម្មទាំងនោះរួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការបាត់ខ្លួនដោយបង្ខំ។ អង្គជំនុំជម្រះនឹងលើកឡើងអំពីការសន្និដ្ឋានរបស់ខ្លួនទាក់ទងនឹងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខ ស-២១ ដោយបង្ហាញអំពីការប្រព្រឹត្តលើជនជាតិវៀតណាម។

### ១.៣.៤. ការកំណត់គោលដៅលើក្រុមមនុស្សជាក់លាក់

២៦. អង្គជំនុំជម្រះយល់ឃើញថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានគោលនយោបាយកំណត់គោលដៅលើក្រុមមនុស្សដូចតទៅនេះ ដើម្បីបង្កើតសង្គមមួយដែលមិនជឿលើសាសនា និងមានលក្ខណៈតែមួយដោយគ្មានការបែងចែកវណ្ណៈ តាមរយៈការលុបបំបាត់នូវភាពខុសគ្នាខាងជាតិពន្ធុ ជាតិ សាសនា ពូជសាសន៍ វណ្ណៈ និងវប្បធម៌។ ក្រុមទាំងនោះរួមមាន ជនជាតិចាម ជនជាតិ

វៀតណាម ពុទ្ធសាសនិក ព្រមទាំងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (រួមទាំងអ្នករដ្ឋការស៊ីវិល និងទាហាន) និងក្រុមគ្រួសាររបស់ពួកគេ។

**១.៣.៤.១. ជនជាតិចាម**

២៧. ទាក់ទងនឹងជនជាតិចាម អង្គជំនុំជម្រះយល់ឃើញថា ក្រោយការបះបោរនៅកោះផល ក្នុងខែកញ្ញា ឆ្នាំ១៩៧៥ និងនៅស្វាយឃ្លាំង ក្នុងខែតុលា ឆ្នាំ១៩៧៥ ប្រជាជនចាមនៅភូមិភាគបូព៌ាភាគច្រើនជាអ្នករស់នៅតាមដងទន្លេមេគង្គត្រូវបានគេបញ្ជូនឲ្យទៅរស់នៅបែកខ្ញែកគ្នា នៅភូមិភាគកណ្តាល (ឧត្តរចាស់)។ ជនជាតិចាម ត្រូវបានកងទ័ពបក្សកុម្មុយនីស្តកម្ពុជាបញ្ជូនចេញ ដោយគ្មានការយល់ព្រម និងក្រោមការគំរាមកំហែងថានឹងចាត់ទុកជាខ្មាំង បើពួកគេមិនស្តាប់បញ្ជា។ ទោះបីជាការបំបែកនេះ គឺជាផ្នែកមួយនៃការជម្លៀសប្រជាជនក្នុងទ្រង់ទ្រាយធំពីភូមិភាគបូព៌ាទៅភូមិភាគកណ្តាល (ឧត្តរចាស់) ក្នុងគោលដៅដាក់ពង្រាយប្រជាជននៅទូទាំងប្រទេសកម្ពុជាក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា ជនជាតិចាមនៅភូមិភាគបូព៌ាត្រូវបានកំណត់ជាគោលដៅជាក់លាក់ដោយសារតែការបះបោរប្រឆាំងនឹងការរឹតត្បិតពីមុនលើ សាសនា ប្រពៃណី និងវប្បធម៌ចាម។ អង្គជំនុំជម្រះយល់ឃើញទៀតថា គេមិនត្រឹមតែជម្លៀសជនជាតិចាមពីកន្លែងដើមទៅកន្លែងថ្មីដើម្បីបំពេញសេចក្តីត្រូវការខាងកម្លាំងពលកម្មក្នុងស្រុកប៉ុណ្ណោះទេ គឺថែមទាំង បំបែកជនជាតិចាមឲ្យរស់នៅរាយប៉ាយនៅតាមភូមិខ្មែរ ដើម្បីរំលាយសហគមន៍ជនជាតិចាម និងច្របាច់បញ្ចូលពួកគេជាមួយប្រជាជនកម្ពុជា។ ហេតុដូច្នេះ ជនជាតិចាមត្រូវបានកំណត់ជាគោលដៅ មិនមែនជាបុគ្គលទេ ប៉ុន្តែផ្អែកលើសមាជិកក្រុមរបស់ពួកគេ។

២៨. លើសពីនេះទៀត អង្គជំនុំជម្រះយល់ឃើញថា ប្រជាជនចាមបានទទួលរងការរើសអើង ឧទាហរណ៍ នៅការដ្ឋានការងារទំនប់ ១ មករា ពួកគេត្រូវបានបង្ខំឲ្យហូបសាច់ជ្រូក ហើយត្រូវបានរារាំងមិនឲ្យគោរពបូជាសាសនា និងនិយាយភាសាចាមឡើយ។ អង្គជំនុំជម្រះក៏យល់ឃើញផងដែរថា បក្សកុម្មុយនីស្តកម្ពុជាបានដាក់កំហិតលើការប្រណិប័តន៍សាសនា និងវប្បធម៌ចាម នៅស្រុកក្រូចឆ្មារ តាមទីតាំងជាច្រើនក្នុងភូមិភាគកណ្តាល (ឧត្តរចាស់) និងតាមទីតាំងនានាផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា ពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ។ ការដាក់កំហិតបែបនេះរួមមាន ការហាមសំឃាំងជារៀងរាល់ថ្ងៃ ការបង្ខំជនជាតិចាមឲ្យហូបសាច់ជ្រូក ព្រមទាំងស្លៀក

សម្លៀកបំពាក់ និងកាត់សក់ដូចប្រជាជនខ្មែរ ការបង្ខំឲ្យនិយាយតែភាសាខ្មែរ ក៏ដូចជា ការដុតគម្ពីរអាល់គូរ៉អាន និងការរុះរើព្រះវិហារ ឬការប្រើប្រាស់ព្រះវិហារសម្រាប់គោលបំណងខុសពីការបួងសួង។ អ្នករឹងទទឹងត្រូវគេចាប់ខ្លួន និង/ឬសម្លាប់ចោល។

២៩. លើសពីនេះទៀត អង្គជំនុំជម្រះយល់ឃើញថា មនុស្សជាច្រើន រួមទាំងជនជាតិចាមភាគច្រើនមកពីស្រុកកងមាស (បច្ចុប្បន្នខេត្តកំពង់ចាម) តំបន់ ៤១ ភូមិភាគកណ្ដាល (ឧត្តរចាស់) ត្រូវគេចាប់យកទៅសម្លាប់នៅវត្តអូរត្រកួន ក្នុងឆ្នាំ១៩៧៧។ អង្គជំនុំជម្រះយល់ឃើញទៀតថា នៅឆ្នាំ ១៩៧៨ ប្រជាជនចាមជាច្រើនមកពីស្រុកក្រូចឆ្មារ (បច្ចុប្បន្នខេត្តត្បូងឃ្មុំ) ត្រូវគេចាប់យកទៅមន្ទីរសន្តិសុខភូមិទ្រា ក្នុងស្រុកក្រូចឆ្មារដដែល ហើយនៅទីនោះ សមាជិកក្រុមចាមត្រូវបានគេពិនិត្យផ្ទៀងផ្ទាត់។ អ្នកដែលគេចាត់ទុកថាជាចាម ត្រូវគេសម្លាប់ ចំណែកឯអ្នកដែលមិនមែនជាចាម ត្រូវគេទុកឲ្យរួចជីវិត។ អង្គជំនុំជម្រះក៏យល់ឃើញផងដែរថា បញ្ជាឲ្យកំណត់គោលដៅលើជនជាតិចាមនៅភូមិភាគកណ្ដាល (ឧត្តរចាស់) និងជាពិសេស នៅតំបន់ ៤១ ចេញមកពីថ្នាក់លើ។ អង្គជំនុំជម្រះក៏យល់ឃើញដែរថា បញ្ជាឲ្យកំណត់គោលដៅលើជនជាតិចាមនៅភូមិភាគបូព៌ា និងជាពិសេស នៅស្រុកក្រូចឆ្មារ ចេញមកពីថ្នាក់លើ។ ថ្វីត្បិតតែអង្គជំនុំជម្រះមិនអាចកំណត់ចំនួនជនរងគ្រោះបានជាក់លាក់ក៏ដោយ ក៏អង្គជំនុំជម្រះជឿជាក់ថា ជនស៊ីវិលចាមជាច្រើន ត្រូវគេនាំយកទៅមន្ទីរសន្តិសុខវត្តអូរត្រកួន និងមន្ទីរសន្តិសុខភូមិទ្រា រួចត្រូវបានគេសម្លាប់ចោលក្នុងទ្រង់ទ្រាយធំ។ អង្គជំនុំជម្រះជឿជាក់ថា ចារឹនៅមន្ទីរសន្តិសុខវត្តអូរត្រកួន និងមន្ទីរសន្តិសុខភូមិទ្រា បានបង្ហាញអំពីស្ថានភាពផ្លូវចិត្តក្នុងការប្រល័យពូជសាសន៍ជនជាតិចាម ដែលត្រូវបានរកឃើញថា ត្រូវបានគេសម្លាប់នៅទីតាំងទាំងនោះ។ អង្គជំនុំជម្រះយល់ឃើញទៀតថា នៅឆ្នាំ១៩៧៨ ជនជាតិចាមមកពីស្រុកក្រូចឆ្មារត្រូវគេចាប់យកទៅមន្ទីរសន្តិសុខភូមិទ្រា ឃុំខ្លួនតាមទំនើងចិត្ត និងដកហូតសិទ្ធិទទួលបានដំណើរការក្ដីតាមផ្លូវច្បាប់ ហើយនៅទីនោះ អ្នកខ្លះត្រូវបានគេសួរចម្លើយ និងវាយដំ។

៣០. ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានប្រព្រឹត្តលើជនជាតិចាម តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងការ

ធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការជម្លៀសដោយបង្ខំ។

### ១.៣.៤.២. ជនជាតិវៀតណាម

៣១. ចំពោះជនជាតិវៀតណាម អង្គជំនុំជម្រះយល់ឃើញថា ចាប់ពីឆ្នាំ១៩៧៥ ដល់ចុងឆ្នាំ១៩៧៦ មានគោលនយោបាយថ្នាក់ជាតិសំដៅបណ្ដេញជនជាតិវៀតណាមដែលរស់នៅប្រទេសកម្ពុជា។ គោលនយោបាយនេះត្រូវបានអនុវត្ត ក្រោយពីមានការព្រមព្រៀងគ្នាជាមួយអាជ្ញាធរវៀតណាម។ កម្មាភិបាលខ្មែរក្រហមបានរៀបចំ និងឃ្លាំមើលការដឹកជញ្ជូនប្រជាជនវៀតណាមទៅព្រំដែនវៀតណាម តាមកាណូត និងរថយន្ត។ ប្ដីឬប្រពន្ធជាជនជាតិខ្មែរដែលមានគ្រួសារចម្រុះជាតិសាសន៍ត្រូវនៅកម្ពុជា។ អង្គជំនុំជម្រះក៏យល់ឃើញដែរថា ថ្នាក់លើរបស់បក្សកុម្មុយនីស្តកម្ពុជាបានបញ្ជាឲ្យកំណត់អត្តសញ្ញាណជនជាតិវៀតណាម ហើយក្រោយមក ចាប់ពីខែមេសា ឆ្នាំ១៩៧៥ ថ្នាក់ក្រោមបានរៀបចំបញ្ជីឈ្មោះនិងប្រវត្តិរូប រួចបញ្ជូនទៅថ្នាក់លើ ដើម្បីចាត់វិធានការបន្តទៀត។ ចាប់ពីឆ្នាំ១៩៧៥ មក បក្សកុម្មុយនីស្តកម្ពុជាបានចាត់ទុកថា ប្រសិនបើគ្រួសារណាមានម្ដាយជាជនជាតិវៀតណាម ហើយឪពុកជាខ្មែរនោះ ត្រូវបញ្ជូនម្ដាយនិងកូនៗទៅប្រទេសវៀតណាម ដោយទុកឪពុក។ ស្រដៀងគ្នានេះដែរ ប្រសិនបើគ្រួសារណាមានឪពុកជាជនជាតិវៀតណាម ហើយម្ដាយជាខ្មែរ ត្រូវបញ្ជូនឪពុកទៅប្រទេសវៀតណាមវិញ ដោយទុកម្ដាយនិងកូនៗនៅប្រទេសកម្ពុជា។ អង្គជំនុំជម្រះយល់ឃើញថា ជនជាតិវៀតណាមដែលចេញពីខេត្តព្រៃវែង ខេត្តស្វាយរៀង និងស្រុកត្រាំកក់ ក្នុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦ ត្រូវគេបង្ខំឲ្យធ្វើបែបនេះក្នុងបរិយាសបង្ខិតបង្ខំ។

៣២. អង្គជំនុំជម្រះក៏យល់ឃើញដែរថា មានភ័ស្តុតាងបង្ហាញពីករណីជាក់លាក់មួយចំនួននៃការសម្លាប់ជនស៊ីវិលវៀតណាម ឧទាហរណ៍ នៅខេត្តស្វាយរៀង ក្នុងឆ្នាំ១៩៧៨ ក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ ក្រោយខែមេសា ឬខែឧសភា ឆ្នាំ១៩៧៧ និងនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧៨, នៅខេត្តកំពង់ឆ្នាំង ក្នុងឆ្នាំ១៩៧៧, នៅវត្តខ្សាច់ (ខេត្តសៀមរាប) នៅចុងឆ្នាំ១៩៧៨ និងនៅក្រចេះ ក្នុងខែកញ្ញា ឆ្នាំ១៩៧៨។ ការសម្លាប់ដោយចេតនាទ្រង់ទ្រាយធំទាំងនេះ ត្រូវបានរៀបចំឡើងជាប្រព័ន្ធ និងកំណត់គោលដៅទៅលើជនជាតិវៀតណាម។ ក្នុងករណីនីមួយៗ ជនជាតិវៀតណាមត្រូវបានគេកំណត់គោលដៅមិនមែនជាបុគ្គលទេ គឺដោយសារតែសមាជិកក្រុមរបស់ពួកគេ និងដោយសារ

តែពួកគេត្រូវបានសន្មតថា ជាជនជាតិវៀតណាម។ ករណីទាំងនេះបានកើតឡើងក្រោមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការកំណត់គោលដៅជាក់លាក់ទៅលើក្រុមជនជាតិវៀតណាម រួមទាំងជនស៊ីវិលផង។ រហូតដល់ចុងឆ្នាំ១៩៧៦ ជនជាតិវៀតណាមត្រូវគេកំណត់គោលដៅ ដើម្បីបណ្តេញចេញ និងដើម្បីកម្ទេច ចាប់ពីខែមេសា ឆ្នាំ១៩៧៧ មក។

៣៣. ទាក់ទងនឹងការប្រព្រឹត្តលើជនជាតិវៀតណាមដែលត្រូវបានឃុំខ្លួននៅមន្ទីរសន្តិសុខ ស-២១ អង្គជំនុំជម្រះយល់ឃើញថា ជនស៊ីវិល និងទាហានវៀតណាមរាប់រយនាក់ត្រូវបានគេសម្លាប់ក្រោយពីសួរចម្លើយ ដោយប្រើវិធីបង្ខិតបង្ខំ និងទទួលរងនូវលក្ខខណ្ឌលំបាកវេទនា នៅមន្ទីរសន្តិ-សុខ ស-២១។ អ្នកដែលត្រូវបានគេសម្លាប់ជាជនស៊ីវិល ឬឈ្លើយសឹកវៀតណាម ដែលជាជនត្រូវទទួលបានការការពារតាមអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩។ ចម្លើយសារភាពដែលយកពីអ្នកជាប់ឃុំជាជនជាតិវៀតណាម ត្រូវគេចុះផ្សាយក្នុងឯកសារនានារបស់កម្ពុជាប្រជាធិបតេយ្យ ក្នុងគោលដៅបង្ហាញអំពី "ការឈ្លានពាន" របស់វៀតណាមមកលើកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះយល់ឃើញទៀតថា អ្នកជាប់ឃុំជាជនជាតិវៀតណាមដែលចូលមកមន្ទីរសន្តិសុខ ស-២១ មិនទទួលបានការការពារតាមនីតិវិធី ឬសិទ្ធិដែលអាចឲ្យពួកគេការពារខ្លួនបាននៅក្រោយពេលចាប់ខ្លួន ត្រូវបានគេដកហូតដំណើរការមួយដែលស្រដៀងនឹងការកាត់ក្តីដោយយុត្តិធម៌ ហើយត្រូវគេបង្ខំឲ្យឆ្លើយសារភាពថាជាគិញ មុនពេលត្រូវបានគេសម្លាប់។ ទាហាន និងជនស៊ីវិលវៀតណាមទាំងអស់ ដែលចូលមកមន្ទីរសន្តិសុខ ស-២១ ត្រូវគេចោទថាជាគិញ និងចាត់ទុកថាជាខ្មាំង។ ជោគវាសនារបស់អ្នកជាប់ឃុំទាំងនេះត្រូវបានសន្និដ្ឋានទុកជាមុន ដោយសារជាចុងក្រោយ ពួកគេទាំងអស់ត្រូវបានសម្លាប់ចោល។

៣៤. ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ ត្រូវបានប្រព្រឹត្តលើជនជាតិវៀតណាម។ លើសពីនេះទៀត ដោយរម្លឹកអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិដែលកំពុងកើតមាននៅពេលនោះ រវាងវៀតណាម និងកម្ពុជាប្រជាធិបតេយ្យ ចាប់ពីខែឧសភា ឆ្នាំ១៩៧៥ និងឋានៈទទួលបានការការពាររបស់ជនរងគ្រោះ អង្គជំនុំជម្រះយល់ឃើញថា ការបំពារបំពានយ៉ាងធ្ងន់ធ្ងរជាច្រើនលើអនុសញ្ញាទីក្រុងហ្សឺ

ណែរ ក៏ត្រូវបានប្រព្រឹត្តផងដែរលើក្រុមនេះ នៅមន្ទីរសន្តិសុខ ស-២១ រួមទាំងការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនានូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការឃុំខ្លួនដោយខុសច្បាប់។

### ១.៣.៤.៣. ពុទ្ធសាសនិក

៣៥. ចំពោះការប្រព្រឹត្តលើពុទ្ធសាសនិក ដែលបទចោទទាំងនេះ ត្រូវបានកម្រិតត្រឹមតែសហករណ៍ត្រាំកក់ អង្គជំនុំជម្រះយល់ឃើញថា ព្រះពុទ្ធសាសនាត្រូវបានហាមឃាត់ និមិត្តរូបតំណាងឲ្យព្រះពុទ្ធត្រូវបានបំផ្លិចបំផ្លាញ ហើយវត្តអារាមមិនត្រូវបានអនុញ្ញាតឲ្យប្រើសម្រាប់គោលបំណងសាសនាទៀតទេ។ អង្គជំនុំជម្រះក៏យល់ឃើញផងដែរថា ព្រះសង្ឃជាង ១០០អង្គ ត្រូវបានគេប្រមូលដោយចេតនាយកទៅដាក់នៅវត្តអង្គរកា និងបង្ខំឲ្យសឹក។ ព្រះសង្ឃក៏ត្រូវគេបង្ខំឲ្យសឹកនៅតាមវត្តផ្សេងៗទៀត ហើយករណីនេះឆ្លុះបញ្ចាំងអំពីលំនាំទូទៅនៅទូទាំងស្រុកត្រាំកក់។ ថ្វីត្បិតតែភស្តុតាងមិនអនុញ្ញាតឲ្យអង្គជំនុំជម្រះសន្និដ្ឋានឲ្យបានច្បាស់លាស់អំពីចំនួនព្រះសង្ឃ ដែលលាចាកសិក្ខាបទសរុបនៅស្រុកត្រាំកក់ក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថាមានភស្តុតាងអាចឲ្យជឿទុកចិត្តបានដែលបង្ហាញថា ព្រះសង្ឃរាប់រយអង្គត្រូវបានគេផ្សឹកនៅតាមឃុំនានា។ ចេតនារើសអើងនៅពីក្រោយដំណើរការនេះ ត្រូវបានបញ្ជាក់ដោយការហៅព្រះសង្ឃថាជា "តេនញ៉ា" ឬជា "ឈ្លើង" សង្គម និងការប្រកាសបដិសេធព្រះពុទ្ធសាសនា ដោយថាជា អបិយជំនឿសុទ្ធសាធ និងថា ព្រះពុទ្ធបដិមា "គ្រាន់តែជាស៊ីម៉ង់ត៍ប៉ុណ្ណោះ"។

៣៦. ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ត្រូវបានប្រព្រឹត្តឡើងលើពុទ្ធសាសនិក។

### ១.៣.៤.៤. អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ

៣៧. ចំពោះអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដែលបទចោទប្រកាន់ត្រូវបានកម្រិតត្រឹមសហករណ៍ត្រាំកក់ ការដ្ឋានការងារទំនប់ ១ មករា មន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់ អង្គជំនុំជម្រះយល់ឃើញថា ក្រុមនេះត្រូវបានគេធ្វើទុក្ខបុកម្នេញនៅតាមទីតាំងឧក្រិដ្ឋកម្មទាំង

ប្អូននេះ។ ឧទាហរណ៍ អង្គជំនុំជម្រះយល់ឃើញថា នៅក្នុងស្រុកត្រាំកក់ ភ្លាមៗក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អតីតទាហាននិងនគរបាលនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានគេសម្រិតសម្រាំងនៅវត្តចម្ប៉ា ហើយក្រោយពីបានប្រាប់អត្តសញ្ញាណរបស់ខ្លួនរួចហើយ ពួកគេជាច្រើនត្រូវបាននាំយកទៅ រួចបាត់ខ្លួន។ ដំណើរការដូចគ្នានេះបានកើតឡើងនៅតាមកន្លែងផ្សេងៗទៀតក្នុងស្រុកត្រាំកក់។ ថ្វីត្បិតតែមានផែនការច្បាស់លាស់ក្នុងការបោសសម្អាត និងសម្លាប់អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅស្រុកត្រាំកក់ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក៏ដោយ ក៏យ៉ាងហោចណាស់ នៅពេលមួយនោះ មានការផ្សព្វផ្សាយមិនឲ្យប៉ះពាល់អតីតទាហាន ចាប់ពីស័ក្តិ ១ ដល់ស័ក្តិ ៥។ អង្គជំនុំជម្រះយល់ឃើញថា ទោះជាយ៉ាងនេះក្តី ក្រោយមក អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវគេកំណត់គោលដៅជាថ្មីម្តងទៀត ដើម្បីចាប់ខ្លួននិងសម្លាប់។ គ្រួសារអតីតទាហានជាច្រើនត្រូវគេកម្ទេចនៅឃុំពពេល ក្នុងខែឧសភា ឆ្នាំ១៩៧៧ ហើយប្រតិបត្តិការសម្លាប់ដោយមានការរៀបចំត្រូវបានធ្វើឡើងនៅស្រុកត្រាំកក់ ចាប់ពីខែមេសា ឆ្នាំ១៩៧៧ ដោយមនុស្សជាច្រើនត្រូវគេយកទៅមន្ទីរសន្តិសុខក្រាំងតាចាន់។ អង្គជំនុំជម្រះជឿជាក់ថា អ្នកទាំងនេះត្រូវគេកំណត់គោលដៅ ដោយផ្អែកលើតួនាទីពិតប្រាកដរបស់ពួកគេនៅក្នុងរបបមុន ឬតាមការសន្មត។

៣៨. អង្គជំនុំជម្រះយល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយត្រូវបានប្រព្រឹត្តនៅសហករណ៍ត្រាំកក់ ពីថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥ ដល់ចុងខែឧសភា ឆ្នាំ១៩៧៥ និងពីដើមឆ្នាំ១៩៧៧ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ នៅការដ្ឋានការងារទំនប់ ១ មករា មន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់។ លើសពីនេះទៀត អង្គជំនុំជម្រះយល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានប្រព្រឹត្តលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅមន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់។

### ១.៣.៥. ការចេញបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍

៣៩. អង្គជំនុំជម្រះយល់ឃើញថា មានគោលនយោបាយនៅទូទាំងប្រទេសក្នុងការកំណត់បទបញ្ជាលើការកសាងគ្រួសារ និងការរៀបអាពាហ៍ពិពាហ៍ ដែលត្រូវកម្មាភិបាលបក្សអនុវត្តនៅតាមបណ្តាញរដ្ឋបាល និងអង្គភាពយោធាគ្រប់ជាន់ថ្នាក់។ បក្សកុម្មុយនីស្តកម្ពុជាបានបង្កើតគោល

នយោបាយនេះឡើង ដើម្បីឲ្យបក្សអាចជំនួសតួនាទីរបស់ឪពុកម្តាយក្នុងការជ្រើសរើសគូស្រករសមស្រប ហើយបង្ខំបុរសនិងស្ត្រីឲ្យរៀបការនឹងគ្នា និងបង្ខំឲ្យបង្កើតកូនក្នុងគោលបំណងបង្កើនចំនួនប្រជាជននៅក្នុងប្រទេសក្នុងរយៈពេលពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ ខាងមុខ។

៤០. អង្គជំនុំជម្រះយល់ឃើញថា ការរៀបអាពាហ៍ពិពាហ៍តាមការរៀបចំនៅក្នុងវប្បធម៌កម្ពុជាមានភាពខុសគ្នាពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ។ ការរៀបអាពាហ៍ពិពាហ៍តាមការរៀបចំនៅក្នុងវប្បធម៌កម្ពុជាមុនរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានធ្វើឡើងដោយផ្អែកទៅលើការជឿទុកចិត្តគ្នាទៅវិញទៅមក រវាងកូនៗ និងឪពុកម្តាយដែលជាអ្នកជ្រើសរើសគូស្រករឲ្យកូន ហើយមិនមានចំណុចនេះទេ នៅពេលដែលបក្សមកជំនួសតួនាទីជាឪពុកម្តាយ នៅក្នុងការរៀបចំអាពាហ៍ពិពាហ៍នោះ។ ភ័ស្តុតាងដែលមាននៅចំពោះមុខអង្គជំនុំជម្រះ បង្ហាញយ៉ាងច្បាស់អំពីការអនុវត្តនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលមិនបានឆ្លុះបញ្ចាំងទាល់តែសោះអំពីការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ដោយគ្រួសាររបស់អនាគតប្តីប្រពន្ធនោះមិនបានចូលរួមទាល់តែសោះនៅក្នុងការចរចាសហគមន៍មិនត្រូវបានឲ្យចូលរួម មិនមានប្រពៃណីនៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍ ហើយសាមីខ្លួនយល់ព្រមរៀបការដោយខ្លាចបក្សដាក់ទណ្ឌកម្ម។ អង្គជំនុំជម្រះយល់ឃើញថា អាជ្ញាធររបបកម្ពុជាប្រជាធិបតេយ្យបានរៀបចំអាពាហ៍ពិពាហ៍នៅគ្រប់ពេលវេលាក្នុងរបបនេះ និងនៅតាមទីតាំងភូមិសាស្ត្រជាច្រើននៅទូទាំងប្រទេសកម្ពុជា។ បុគ្គលទាំងឡាយបានរៀបអាពាហ៍ពិពាហ៍នៅក្នុងបរិយាកាសភ័យខ្លាច ហើយនៅក្នុងករណីភាគច្រើនការព្រមព្រៀងនៅមុនពេល ឬក្នុងអំឡុងពិធីរៀបអាពាហ៍ពិពាហ៍ ដែលបានលើកឡើងនោះ មិនមែនជាការយល់ព្រមពិតប្រាកដឡើយ។ អង្គជំនុំជម្រះយល់ឃើញថាក្រោយពិធីរៀបអាពាហ៍ពិពាហ៍ ជាធម្មតាអាជ្ញាធរបានរៀបចំឲ្យប្តីប្រពន្ធថ្មីថ្មោងនោះផ្សំដំណេកជាមួយគ្នានៅក្នុងទីតាំងកំណត់មួយ ក្រោមការតាមដានពីកងឈ្លប ជាពិសេសដើម្បីឲ្យមានការរួមភេទ។ ទាំងបុរស និងស្ត្រីយល់ថាពួកគេត្រូវបានគេបង្ខំឱ្យរួមភេទជាមួយប្តីឬប្រពន្ធថ្មីថ្មោងរបស់ពួកគេ ហេតុដូច្នេះ ពួកគេបានធ្វើផ្ទុយនឹងឆន្ទៈរបស់ពួកគេ។ ប្តីប្រពន្ធដែលត្រូវបានរកឃើញថាមិនបានរួមភេទ ត្រូវបានយកមកអប់រំ ឬគំរាមកំហែងថានឹងដាក់ទណ្ឌកម្ម ឬសម្លាប់ចោល ។

៤១. អង្គជំនុំជម្រះយល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានប្រព្រឹត្តឡើង។

### ១.៣.៦. សហឧក្រិដ្ឋកម្មរួម

៤២. អង្គជំនុំជម្រះយល់ឃើញថា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងបន្ត យ៉ាងហោចណាស់រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ មេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាមួយចំនួនមានគោលបំណងរួមក្នុងការអនុវត្តបដិវត្តន៍សង្គមនិយមនៅកម្ពុជាឲ្យបានលឿនតាមរយៈ "មហាលោតផ្លោះ មហាអស្ចារ្យ" ដែលត្រូវបានបង្កើតឡើង ដើម្បីកសាងនិងការពារប្រទេសពីខ្មាំង ហើយផ្លាស់ប្ដូរប្រជាជនឱ្យក្លាយទៅជាសង្គមកម្មករ-កសិករ ដែលមានជាតិសាសន៍ខ្មែរតែមួយ។ គោលបំណងរួមនេះ ត្រូវបានអនុវត្តគ្រប់ពេលក្នុងរបបកម្ពុជាប្រជាធិបតេយ្យដោយបណ្ដាញរដ្ឋបាលទាំងមូលរបស់បក្ស គឺលេខាភូមិភាគ តំបន់ ស្រុក និងថ្នាក់មូលដ្ឋាន និងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាតាមរយៈការអនុវត្តយ៉ាងហោចណាស់គោលនយោបាយចំនួនប្រាំ។ គោលនយោបាយដែលត្រូវបានរៀបចំ និងអនុវត្តឡើងដើម្បីសម្រេចគោលបំណងរួម គឺ (១) ការផ្លាស់ទីលំនៅប្រជាជនម្ដងហើយម្ដងទៀតពីទីប្រជុំជន និងទីក្រុង ទៅកាន់តំបន់ជនបទ ព្រមទាំងពីទីជនបទមួយទៅកាន់ទីជនបទមួយទៀត (២) ការបង្កើត និងដំណើរការសហករណ៍ និងការដ្ឋានការងារ (៣) ការបង្កើត និងដំណើរការមន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្ស ដើម្បីកំណត់អត្តសញ្ញាណ ចាប់ខ្លួន ដាក់ឲ្យនៅដាច់ដោយឡែក និង "កម្ទេច" អ្នកដែលត្រូវបានគេចាត់ទុកថាជាប្រភេទខ្មាំងធ្ងន់ធ្ងរបំផុត និងដើម្បីអប់រំ "សមាសភាពមិនល្អ" (៤) ការកំណត់គោលដៅទៅលើក្រុមជាក់លាក់ រួមទាំង ជនជាតិចាម និងវៀតណាម ពុទ្ធសាសនិក និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ រួមទាំង អ្នករដ្ឋការស៊ីវិល ទាហាន និងក្រុមគ្រួសាររបស់ពួកគេ និង (៥) ការចេញបទបញ្ជាស្ដីពីការរៀបអាពាហ៍ពិពាហ៍។ អង្គជំនុំជម្រះយល់ឃើញថា គោលនយោបាយទាំងនេះមានទំនាក់ទំនងយ៉ាងខ្លាំងទៅនឹងគោលបំណងរួម ហើយមានការប្រព្រឹត្តឧក្រិដ្ឋកម្ម។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា គោលបំណងរួមនេះមានលក្ខណៈឧក្រិដ្ឋ។

៤៣. អង្គជំនុំជម្រះយល់ឃើញទៀតថា គោលបំណងនេះគឺជាគោលបំណងរួមនៅក្នុងចំណោមមនុស្សជាច្រើន រួមទាំងមេដឹកនាំជាន់ខ្ពស់ ប៉ុល ពត, នួន ជា, ខៀវ សំផន, អៀងសារី,អៀង ធីរិទ្ធ, សុន សេន និង វន វ៉េត(រហូតដល់ពេលចាប់ខ្លួននៅចុងឆ្នាំ១៩៧៨) ព្រមទាំងលេខាភូមិភាគ រួមទាំង តាម៉ុក,កែ ពក,កុយ ធួន(រហូតដល់ពេលមានការឃុំខ្លួនក្នុងផ្ទះនៅពាក់កណ្ដាលឆ្នាំ១៩៧៦) ជូ ជេត (រហូតដល់ពេលមានការចាប់ខ្លួននៅក្នុងខែមីនា ឆ្នាំ១៩៧៨) រស់ ញឹម (រហូតដល់ពេលមានការចាប់ខ្លួននៅក្នុងខែឧសភា-ខែមិថុនា ឆ្នាំ១៩៧៨) និង សោ ភឹម (រហូតដល់ពេលធ្វើអត្តឃាតនៅខែមិថុនា ឆ្នាំ១៩៧៨)។ មេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាបានត្រួតពិនិត្យផ្ទាល់ទៅលើការអនុវត្តគោលនយោបាយជាច្រើន និងបានប្រើប្រាស់ចារីផ្ទាល់ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម ដើម្បីសម្រេចគោលបំណងរួមនេះ។ អង្គជំនុំជម្រះយល់ឃើញថាជាការត្រឹមត្រូវដែលថា សមាជិកសហឧក្រិដ្ឋកម្មរួមនេះ ត្រូវបានកំណត់ឲ្យទទួលខុសត្រូវលើឧក្រិដ្ឋកម្មទាំងនេះ។

## ១.៤. ការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ជនជាប់ចោទ

៤៤. នៅពេលនេះ អង្គជំនុំជម្រះពិនិត្យមើលការសន្និដ្ឋានរបស់ខ្លួនទាក់ទងនឹងការទទួលខុសត្រូវរបស់ នួន ជា និង ខៀវ សំផន វិញម្ដង។

### ១.៤.១. ការទទួលខុសត្រូវរបស់ នួន ជា

៤៥. អង្គជំនុំជម្រះយល់ឃើញថា ក្នុងនាមជាបុគ្គលម្នាក់ដែលមានតួនាទីនាំមុខក្នុងការកសាងមូលដ្ឋានគ្រឹះសម្រាប់របបកម្ពុជាប្រជាធិបតេយ្យ នួន ជា បានចូលរួមសន្និបាតបក្ស និងកិច្ចប្រជុំរបស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស ចាប់ពីពេលចាប់ផ្ដើមការធ្វើបដិវត្តន៍រហូតមក។ នួន ជា ត្រូវបានជ្រើសតាំងជាអនុលេខាបក្សនៅក្នុងខែកញ្ញា ឆ្នាំ១៩៦០ ហើយបានបន្តកាន់មុខតំណែងនេះនៅគ្រប់ពេល ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់ក៏ជាសមាជិកពេញសិទ្ធិមួយរូបផងដែរ ទាំងនៅក្នុងគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ព្រមទាំងជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជន។ នួន ជា បានចូលរួមក្នុងកិច្ចប្រជុំសំខាន់ៗទាំងអស់ ហើយក៏ចូលរួមនៅក្នុងការសម្រេចចិត្តសំខាន់ៗទាំងអស់របស់បក្ស នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ពេញមួយរបបនេះ នួន ជា នៅតែ

ជាឥស្សរជនដ៏សំខាន់មួយនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ដោយគាត់គឺជាបុគ្គលដៃស្តាំដ៏ស្មោះត្រង់របស់ ប៉ុល ពត។ លើសពីនេះទៀត នួន ជា ត្រូវបានតែងតាំងឱ្យជំនួស ប៉ុល ពត ធ្វើជានាយករដ្ឋមន្ត្រីស្តីទី នៅពេលដែល ប៉ុល ពត សុំការអនុញ្ញាតសម្រាកជាផ្លូវការចាប់ពីខែកញ្ញា ឆ្នាំ១៩៧៦ រហូតដល់ ខែកញ្ញា ឆ្នាំ១៩៧៧។ ដោយសារតែតួនាទីខ្ពង់ខ្ពស់នៅក្នុងថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា នួន ជា ធ្វើការគ្រប់គ្រងលើសកម្មភាពទាំងអស់របស់បក្សដោយលើសពីតួនាទី និងការទទួលខុសត្រូវ ដែលត្រូវបានប្រគល់ឱ្យគាត់ជាផ្លូវការនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យទៅទៀត។ អង្គជំនុំជម្រះយល់ឃើញថា នៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ នួន ជា និង ប៉ុល ពត មានអំណាចធ្វើសេចក្តីសម្រេចចុងក្រោយរបស់បក្ស។ ក្នុងឋានៈជាអនុលេខាបក្ស ការគ្រប់គ្រងរបស់គាត់មិនមែនមានត្រឹមតែការធ្វើសេចក្តីសម្រេចផ្នែកនយោបាយប៉ុណ្ណោះទេ ប៉ុន្តែមានរហូតដល់ខាងផ្នែករដ្ឋាភិបាល និងរដ្ឋបាលរបស់របបកម្ពុជាប្រជាធិបតេយ្យ រួមទាំង កិច្ចការយោធាផងដែរ។ ហេតុដូច្នេះហើយ អង្គជំនុំជម្រះជឿជាក់ថា នួន ជា មិនត្រឹមតែបានគាំទ្ររួមគ្នាលើគោលបំណងរួមប៉ុណ្ណោះទេ ប៉ុន្តែគាត់បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការបង្កើត និងគ្រប់គ្រងលើដំណើរការនៃគោលបំណងរួមនោះដែរ។

៤៦. ការគាំទ្ររបស់ នួន ជា លើគោលបំណងរួមដែលគាត់បានចូលរួមបង្កើតឡើង គឺមិនមានការប្រែប្រួលទេក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ។ គាត់បានបន្តអនុវត្ត និងផ្សព្វផ្សាយពីគោលបំណងរួមនេះ ដោយក្តាប់យ៉ាងតឹងណែនទៅលើការអះអាងដែលត្រូវបានបង្កើតឡើងយ៉ាងប្រុងប្រយ័ត្នដោយបក្សកុម្មុយនីស្តកម្ពុជា តាមរយៈការឃោសនា និងសកម្មភាពបណ្តុះបណ្តាលនានា។ នួន ជា ទទួលខុសត្រូវជាចម្បងទៅលើបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងការឃោសនា និងការអប់រំកសិករ កម្មាភិបាល និងសមាជិកបក្សផ្សេងទៀត ដោយផ្តោតជាពិសេសទៅលើគោលការណ៍សំខាន់ៗ និងគោលនយោបាយសេដ្ឋកិច្ចរបស់បក្ស។ នៅក្នុងតួនាទីនេះ នួន ជា បានថ្លែងសុន្ទរកថា និងដឹកនាំវគ្គរៀនសូត្រសម្រាប់កម្មាភិបាលមកពីតាមតំបន់ផ្សេងៗទាំងនៅក្នុងក្រុងភ្នំពេញ និងនៅកន្លែងផ្សេងៗទៀតក្នុងប្រទេស រួមទាំង សហករណ៍ និងការដ្ឋានការងារផងដែរ។ នួន ជា គឺជាអ្នកនិពន្ធដ៏សំខាន់ម្នាក់នៃទស្សនាវដ្តីអប់រំឈ្មោះថា *ទង់បដិវត្តន៍* ដែលជាឧបករណ៍ឃោសនាចម្បងរបស់បក្សក្នុងការផ្សព្វផ្សាយយ៉ាងទៀងទាត់នូវសុន្ទរកថាដែល ប៉ុល ពត, នួន ជា និង ខៀវ សំផន បានថ្លែង។ នួន ជា បានចូលរួមនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលក្នុងអំឡុងពេល

នោះមានការពិភាក្សាទៅលើយុទ្ធវិធីអំពីអ្វីដែលត្រូវលាតត្រដាង និងអ្វីដែលត្រូវរក្សាការសម្ងាត់ ហើយការរក្សាការសម្ងាត់គឺជាសមាសធាតុសំខាន់នៃការឃោសនាដ៏មានប្រសិទ្ធភាពមួយ។ នួន ជា ទទួលខុសត្រូវជាចម្បងទៅលើបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងការឃោសនា និងការអប់រំកសិករ កម្មាភិបាល និងសមាជិកបក្សផ្សេងទៀត ដោយផ្តោតជាពិសេសទៅលើគោលការណ៍សំខាន់ៗ និង គោលនយោបាយសេដ្ឋកិច្ចរបស់បក្ស។ ការទទួលខុសត្រូវជាផ្លូវការរបស់ នួន ជា ខាងផ្នែក ឃោសនាការ និងបញ្ហាពាក់ព័ន្ធនឹងការអប់រំ រួមទាំងកិច្ចការវិន័យសីលធម៌របស់កម្មាភិបាល និង បញ្ហាសន្តិសុខផ្ទៃក្នុងផ្សេងៗទៀត ព្រមទាំងសភាពការណ៍ខ្លាំងជាទូទៅផងដែរ ដោយគាត់បាន ជំរុញឲ្យវែកមុខ និងកម្ចាត់ខ្មាំង។ ដូច្នេះអង្គជំនុំជម្រះជឿជាក់ថា តាមរយៈតួនាទីរបស់គាត់នៅក្នុង យុទ្ធនាការឃោសនា និងយុទ្ធវិធីផ្សេងៗ ក៏ដូចជាការបណ្តុះបណ្តាលកម្មាភិបាលទាំងមុន និង ក្រោយខែមេសា ឆ្នាំ១៩៧៥ នួន ជា បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្ត និងផ្សព្វផ្សាយគោល បំណងរួមនេះ។

៤៧. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះយល់ឃើញថា ការចូលរួមចំណែករបស់ នួន ជា នៅក្នុងការ ប្រព្រឹត្តឧក្រិដ្ឋកម្ម មានលើសពីការបង្កើតគោលនយោបាយ ការអនុវត្ត និងការផ្សព្វផ្សាយគោល បំណងរួមតាមរយៈការឃោសនា និងការអប់រំ។ នួន ជា បានអនុវត្តគោលបំណងរួមដោយផ្ទាល់ និងបានចូលរួមយ៉ាងសកម្មក្នុងការបោសសម្អាតកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា។ គាត់មិនត្រឹម តែជួយរៀបចំធ្វើការបោសសម្អាតភូមិភាគពាយព្យ ភូមិភាគកណ្តាល (ឧត្តរចាស់) និងភូមិភាគ បូព៌ាប៉ុណ្ណោះទេ គាត់ថែមទាំងបានចូលរួមដោយផ្ទាល់នៅក្នុងការត្រួតពិនិត្យទៅលើមន្ទីរសន្តិសុខ ស-២១ និងការបោសសម្អាតសមាជិកសំខាន់ៗរបស់បក្ស ដូចជា រស់ ញឹម ដែលជាលេខាភូមិភាគ ពាយព្យ ជាដើម។

៤៨. ទាក់ទងនឹងមន្ទីរសន្តិសុខ ស-២១ ឯកសារនាសម័យនោះ ជាពិសេស ចម្លើយសារភាព របស់អ្នកជាប់ឃុំ បង្ហាញថា ចាប់តាំងពីពេលមន្ទីរសន្តិសុខ ស-២១ ដំណើរការដំបូង នួន ជា បាន ដឹង និងចូលរួមនៅក្នុងការចាប់ខ្លួន ការឃុំខ្លួន ការធ្វើទារុណកម្ម និងការសម្លាប់កម្មាភិបាលដែល ត្រូវបានកំណត់ជាគោលដៅសម្រាប់ការបោសសម្អាត។ អង្គជំនុំជម្រះយល់ឃើញទៀតថា នួន ជា បានបំពេញតួនាទីជាអ្នកគ្រប់គ្រងផ្ទាល់លើ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ចាប់ពីថ្ងៃទី១៥ ខែសីហា ឆ្នាំ

១៩៧៧ បន្ទាប់ពី សុន សេន បានចាកចេញទៅសមរភូមិ នៅភូមិភាគបូព៌ា រហូតដល់ពេលដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅដើមខែមករា ឆ្នាំ១៩៧៩។ នៅក្នុងមុខនាទីនេះ នួន ជា បានជួបប្រជុំជាទៀងទាត់ជាមួយ ឌុច និងផ្តល់ការណែនាំនានា រួមទាំងការណែនាំទាក់ទងនឹងអ្នកជាប់ឃុំសំខាន់ៗមួយចំនួន។ នួន ជា បានទទួល និងអានចម្លើយសារភាពពីមន្ទីរសន្តិសុខ ស-២១ ហើយនៅពេលគាត់យល់ឃើញថាចាំបាច់ គាត់បញ្ជាឲ្យកែតម្រូវ។ លើសពីនេះទៀត អង្គជំនុំជម្រះយល់ឃើញថា នួន ជា ស្ថិតនៅក្នុងចំណោមអ្នកដែលធ្វើសេចក្តីសម្រេចចិត្តថាត្រូវចាប់ខ្លួននរណាខ្លះដើម្បីបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១។ នួន ជា បានបញ្ជាឱ្យសម្លាប់មនុស្សមួយក្រុមៗជាច្រើននាក់ ដូចជា អ្នកទាំងឡាយដែលបានមកដល់មន្ទីរសន្តិសុខ ស-២១ ដោយសារតែការបោសសម្អាតភូមិភាគបូព៌ា ក្នុងឆ្នាំ១៩៧៨ និងអ្នកដែលត្រូវបានឃុំខ្លួនដោយផ្ទាល់នៅមន្ទីរសន្តិសុខ ស-២១ មុនពេលបោះបង់មន្ទីរនេះចោល ព្រមទាំងបុគ្គលជាក់លាក់មួយចំនួនទៀត។ ដោយសារតែកងទ័ពវៀតណាមបានសម្រុកចូលក្រុងភ្នំពេញភ្លាមៗ និងការបោះបង់ចោលមន្ទីរសន្តិសុខ ស-២១ ទាំងតក់ក្រហល់ នៅក្នុងខែមករា ឆ្នាំ១៩៧៩ មិនមានការប៉ះពាល់អ្វីទេទៅលើឯកសារផ្ទៃក្នុងរបស់មន្ទីរនេះដែលរៀបរាប់លម្អិតអំពីដំណើរការមន្ទីរសន្តិសុខ ដោយឯកសារទាំងនោះស្ថិតនៅទីកន្លែងដដែល។ ក្រោយមក នួន ជា បានស្តីបន្ទោស ឌុច ដោយសារតែមិនបានបំផ្លាញឯកសារទាំងនោះចោល។

៤៩. សរុបមកវិញ អង្គជំនុំជម្រះយល់ឃើញថា នួន ជា បានចូលរួមក្នុងគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម។ នួន ជា បានចូលរួមរៀបចំបង្កើត អនុវត្ត និងផ្សព្វផ្សាយគោលបំណងរួមនេះ តាមរយៈការពន្យល់ជាសាធារណៈ ការឯកភាព និងជំរុញគោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា។ គាត់បានធ្វើដូច្នេះតាមរយៈតួនាទីដឹកនាំក្នុងនាមជាដៃស្តាំរបស់ ប៉ុល ពត ជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា និងជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស និងតាមរយៈការចូលរួមយ៉ាងសកម្មរបស់គាត់ក្នុងការឃោសនា និងការអប់រំ។ លើសពីនេះទៀត តាមរយៈការចូលរួមដោយផ្ទាល់ និងយ៉ាងទូលំទូលាយរបស់គាត់ក្នុងការបោសសម្អាត និងដំណើរការរបស់មន្ទីរសន្តិសុខ ស-២១ នួន ជា បានអនុវត្តគោលបំណងរួមនេះដោយប្រើអន្តរការី ដូចជា ឌុច និងចារីផ្ទាល់ផ្សេងៗទៀត ដូចជា បុគ្គលិកមន្ទីរសន្តិសុខ ស-២១ ជាឧបករណ៍នៃសហឧក្រិដ្ឋកម្មរួម។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា នួន ជា បាន

ចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២។

៥០. ម្យ៉ាងវិញទៀត ដូចបានរៀបរាប់ខាងលើមកហើយ អង្គជំនុំជម្រះយល់ឃើញថា នួន ជា មានចេតនាដែលជាចេតនារួមរបស់សមាជិកសហឧក្រិដ្ឋកម្មរួមផ្សេងៗទៀត រួមទាំង ចេតនាជាក់លាក់ និងចេតនារើសអើង ដែលជាលក្ខខណ្ឌកំណត់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មផ្សេងៗ ដែលស្ថិតនៅក្នុងគោលបំណងរួម លើកលែងតែឧក្រិដ្ឋកម្មមួយប៉ុណ្ណោះ។ អង្គជំនុំជម្រះមិនអាចកំណត់ ឬសន្និដ្ឋានពីចេតនាប្រល័យពូជសាសន៍របស់ នួន ជា ទាក់ទងនឹងជនជាតិចាមនោះទេ ហើយក៏មិនអាចសន្និដ្ឋានឲ្យហួសពីវិមតិសង្ស័យថា នួន ជា បានដឹងថា អំពើប្រល័យពូជសាសន៍ត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងជនជាតិចាមដែរ។ យ៉ាងណាក៏ដោយ អង្គជំនុំជម្រះជឿជាក់ថា នួន ជា យ៉ាងហោចណាស់ ក៏មានហេតុផលដឹងថា អំពើប្រល័យពូជសាសន៍ត្រូវបានប្រព្រឹត្ត ឬគ្រោងនឹងប្រព្រឹត្តលើជនជាតិចាម។

៥១. អង្គជំនុំជម្រះយល់ឃើញថា នួន ជា បានប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម (ក) ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការបាត់ខ្លួនដោយបង្ខំ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការជម្លៀសដោយបង្ខំ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ (ខ) ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាមរយៈការធ្វើមនុស្សឃាតលើសមាជិកនៃក្រុមជាតិជាតិពន្ធុ ពូជសាសន៍វៀតណាម និង (គ) ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ តាមរយៈការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខ

ភាព ការដកហូតដោយចេតនានូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការឃុំខ្លួនដោយខុសច្បាប់នៅមន្ទីរសន្តិសុខ ស-២១ ប្រឆាំងនឹងបុគ្គលទាំងឡាយដែលត្រូវទទួលបានការការពារស្របតាមអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសម្រេចផ្តន្ទាទោសចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មតាមរយៈសហឧក្រិដ្ឋរួម ត្រង់ចំណុចដែល នួន ជា មានចេតនាដោយផ្ទាល់ ចេតនារើសអើង និងចេតនាជាក់លាក់ ដូចចេតនារបស់សមាជិកសហឧក្រិដ្ឋកម្មរួមផ្សេងទៀតដែរ។

៩២. លើសពីនេះទៀត ពាក់ព័ន្ធនឹងការស្លាប់នៅសហករណ៍ ការដ្ឋានការងារ និងមន្ទីរសន្តិសុខ ដោយសារតែ*ចេតនាដោយប្រយោល* (ដែលមិនស្ថិតក្នុងគោលបំណងរួម) អង្គជំនុំជម្រះយល់ឃើញថា នួន ជា បានជួយ និងជំរុញឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាតដែលត្រូវបានអនុវត្តដោយ*ចេតនាដោយប្រយោល* នៅសហករណ៍ត្រាំកក់ ការដ្ឋានការងារទំនប់ ១ មករា ការដ្ឋានការងារទំនប់ត្រពាំងថ្ម ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោល។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ការប្រព្រឹត្តរបស់ នួន ជា ត្រូវបានចាត់ទុកថា ជាទម្រង់នៃការជួយ និងជំរុញ។ គាត់បានផ្តល់ការលើកទឹកចិត្ត និងការគាំទ្រផ្លូវចិត្ត ដោយលើកទឹកចិត្តឲ្យកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា អនុវត្តគោលនយោបាយរបស់មជ្ឈិមបក្សយ៉ាងត្មៀវក្លា តាមរយៈតួនាទីដ៏សំខាន់របស់គាត់ក្នុងការឃោសនា ព្រមទាំងការបង្ហាញខ្លួនជាច្រើនលើកនៅក្នុងកិច្ចប្រជុំ និងថ្លែងសុន្ទរកថានៅក្នុងវគ្គអប់រំនៅទូទាំងប្រទេស។ អង្គជំនុំជម្រះយល់ឃើញថា ទង្វើនេះមានឥទ្ធិពលយ៉ាងខ្លាំងលើការប្រព្រឹត្តឧក្រិដ្ឋកម្ម ហើយ នួន ជា បានដឹងអំពីរឿងនេះ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសម្រេចផ្តន្ទាទោសចំពោះការជួយ និងជំរុញឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាតដោយ*ចេតនាដោយប្រយោល* នៅទីតាំងដែលកើតមានឧក្រិដ្ឋកម្មខាងលើទាំងនេះ។

៩៣. ជាចុងក្រោយ អង្គជំនុំជម្រះយល់ឃើញថា នួន ជា បានប្រើអំណាចសម្រេចចិត្តចុងក្រោយជាមួយនឹង ប៉ុល ពត ហើយមានសិទ្ធិអំណាចក្នុងការដាក់វិន័យសមាជិកថ្នាក់ក្រោមនៅក្នុងបក្ស និងនៅក្នុងជួរយោធា។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា នួន ជា ត្រូវទទួលខុសត្រូវ

ក្នុងនាមជាថ្នាក់លើចំពោះឧក្រិដ្ឋកម្មទាំងអស់ ដែលបានប្រព្រឹត្តឡើងតាមគោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២។ ឧក្រិដ្ឋកម្មទាំងនេះ រួមបញ្ចូលទាំងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាមរយៈការធ្វើមនុស្សឃាតលើសមាជិកនៃក្រុមជាតិពន្ធុចាម និងសាសនា។ យ៉ាងណាក៏ដោយ ដោយយល់ឃើញថា ទីមួយ នួន ជា ត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះបទល្មើសទាំងនេះ តាមរយៈការចូលរួមរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួម លើកលែងតែឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើជនជាតិចាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាតដែលបានប្រព្រឹត្តដោយ *ចេតនាដោយប្រយោល* ដូចបានបញ្ជាក់ច្បាស់ខាងលើ ហើយទីពីរ នួន ជា ត្រូវទទួលខុសត្រូវចំពោះការជួយ និងជំរុញឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាតដែលបានប្រព្រឹត្តដោយ *ចេតនាដោយប្រយោល* អង្គជំនុំជម្រះសម្រេចផ្តន្ទាទោសក្រោមទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាមរយៈការធ្វើមនុស្សឃាតលើសមាជិកនៃក្រុមជាតិពន្ធុចាម និងសាសនា។ ចំពោះចំណុចផ្សេងៗទៀត អង្គជំនុំជម្រះបានពិចារណាលើតួនាទីរបស់ នួន ជា នៅក្នុងការកំណត់ទោស។

### ១.៤.២. ការទទួលខុសត្រូវរបស់ ខៀវ សំផន

៥៤. នៅឆ្នាំ១៩៧១ ខៀវ សំផន បានក្លាយជាសមាជិកត្រៀមនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ហើយនៅឆ្នាំ១៩៧៦ គាត់បានក្លាយជាសមាជិកពេញសិទ្ធិ។ នៅឆ្នាំ១៩៧០ ខៀវ សំផន ត្រូវបានតែងតាំងជាអនុប្រធានរណសិរ្សរួបរួមជាតិកម្ពុជា និងជាអគ្គមេបញ្ជាការកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា។ ជាក់ស្តែង ខៀវ សំផន ពុំមានអំណាចផ្នែកយោធាដោយផ្ទាល់នោះឡើយ ហើយ ប៉ុល ពត ឯណោះទេដែលទទួលបន្ទុកលើកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជានោះ។ ខៀវ សំផន ក៏បានកាន់តំណែងជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារជាតិនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាផងដែរ។ ក្រោយពេលដួលរលំទីក្រុងភ្នំពេញ ក្នុងខែមេសា ឆ្នាំ១៩៧៥ ខៀវ សំផន បានរក្សាតួនាទីរបស់ខ្លួនជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិ និងជាអគ្គមេបញ្ជាការកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា។ ដូច្នេះហើយ គាត់បានបន្ត

បំពេញមុខងារការទូតមួយចំនួន ដូចជាការជួបជាមួយគណៈប្រតិភូបរទេសដែលមកធ្វើទស្សនកិច្ចនៅកម្ពុជា និងការដឹកនាំគណៈប្រតិភូកម្ពុជាទៅធ្វើទស្សនកិច្ចនៅឯបរទេស។

៩៥. នៅក្នុងខែតុលា ឆ្នាំ១៩៧៥ គណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជាបានតែងតាំង ខៀវ សំផន ឱ្យទទួលខុសត្រូវផ្នែក "រណសិរ្ស និងរាជរដ្ឋាភិបាល និងពាណិជ្ជកម្ម ខាងបញ្ជីនិងតម្លៃ"។ ក្នុងអំឡុងខែតុលា ឆ្នាំ១៩៧៥ ខៀវ សំផន បានក្លាយជាសមាជិកមួយរូបក្នុងចំណោមសមាជិកពីររូបនៃមន្ទីរ ៨៧០ ដែលត្រួតពិនិត្យលើការអនុវត្តរាល់សេចក្តីសម្រេចរបស់គណៈកម្មា- ធិការអចិន្ត្រៃយ៍។ ទោះបីជាយ៉ាងណា អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន មិនធ្លាប់បានធ្វើជាប្រធានមន្ទីរ ៨៧០ ដូចដែលគាត់ត្រូវបានចោទប្រកាន់នោះឡើយ។ នៅក្នុងខែមេសា ឆ្នាំ១៩៧៦ ខៀវ សំផន ត្រូវបានតែងតាំងជាប្រធានគណៈប្រធានរដ្ឋ ដែលគ្រាន់តែជាតួនាទីនិមិត្តរូបតែប៉ុណ្ណោះ ដោយគាត់ពុំមានអំណាចផ្នែកប្រតិបត្តិនោះឡើយ។ ក្នុងនាមជាប្រធានគណៈប្រធានរដ្ឋ ខៀវ សំផន បានបន្តបំពេញមុខងារផ្នែកការទូត និងក្នុងពិធីការផ្សេងៗ។

៩៦. ខៀវ សំផន មិនធ្លាប់ជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជាជាផ្លូវការម្តងណាទេ ប៉ុន្តែគាត់មានវត្តមាន និងបានចូលរួមយ៉ាងទៀងទាត់នៅក្នុងកិច្ចប្រជុំផ្សេងៗរបស់គណៈកម្មាធិការអចិន្ត្រៃយ៍បក្ស ដែលមានការពិភាក្សាទៅលើបញ្ហាសំខាន់ៗទាក់ទងនឹងគោលបំណងរួមនេះ។ ក្នុងនាមជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស ខៀវ សំផន បានចូលរួមនៅក្នុងសន្និបាតបក្សលើកទីបី លើកទីបួន និងលើកទីប្រាំ ដែលបានអនុម័តទៅលើគោលនយោបាយរបស់គណៈកម្មាធិការអចិន្ត្រៃយ៍បក្ស ទាក់ទងនឹងមាគ៌ានយោបាយរួម ស្របទៅនឹងគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ។ ខៀវ សំផន គឺជាសមាជិកពេញសិទ្ធិនៅពេលដែលគណៈកម្មាធិការមជ្ឈិមបក្សយល់ព្រមប្រគល់ "សិទ្ធិកម្ទេច" ឱ្យទៅបក្សកុម្មុយនីស្តកម្ពុជានៅថ្នាក់ក្រោមៗ។ ក្នុងនាមជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិមបក្សដែលមានសិទ្ធិបោះឆ្នោត ខៀវ សំផន បានចូលរួមចំណែកក្នុងការអនុម័តអនុស្សរណៈរបស់គណៈកម្មាធិការមជ្ឈិមបក្សនៅពាក់កណ្តាលឆ្នាំ១៩៧៨ ដែលធ្វើការអំពាវនាវឱ្យមានការអាណិតអាសូរចំពោះ "ជនដែលត្រូវគេបោកបញ្ឆោត" ឱ្យធ្វើជាគិញ្ឃុន ដែលនេះជាគោលនយោបាយមួយ ដែលអង្គជំនុំជម្រះយល់ឃើញថាគ្មានឥទ្ធិពលជាក់ស្តែងនោះទេ។ អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន មិនត្រឹមតែបានចូលរួមគាំទ្រជាមួយអ្នកផ្សេងទៅនឹងគោលបំណង

រួមប៉ុណ្ណោះទេ ប៉ុន្តែគាត់ថែមទាំងបានគាំទ្រទៅលើគោលបំណងរួមនេះជាសាធារណៈ នៅគ្រប់ពេលនៃរបបកម្ពុជាប្រជាធិបតេយ្យទៀតផង។

៥៧. លើសពីនេះទៀត អង្គជំនុំជម្រះយល់ឃើញថា នៅក្នុងទម្រង់មួយដែលបានបន្តគ្រប់ពេលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន បានផ្សព្វផ្សាយ អះអាង និងយល់ស្របជាសាធារណៈទៅលើគោលបំណងរួមនេះ។ គាត់ជាប្រធានសន្និបាតជាតិវិសាមញ្ញមួយដែលបានធ្វើឡើងនៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយបានចូលរួមប្រជុំផ្សេងៗ នៅខែឧសភា ឆ្នាំ១៩៧៥ នៅវិហារព្រះកែវមរកត ក្នុងក្រុងភ្នំពេញ។ លើសពីនេះទៀត ខៀវ សំផន បានរក្សាមាគ៌ាបក្សដោយបានដឹកនាំវគ្គបំពាក់បំប៉ននៅក្នុងអង្គមីទ្ទីង និងវគ្គរៀនសូត្រ សម្រាប់អ្នកផ្សេងៗ រួមទាំងអ្នកដែលវិលត្រឡប់មកពីបរទេស និងកម្មាភិបាលក្រសួងពាណិជ្ជកម្ម ក្នុងគោលបំណងពង្រឹងស្មារតីសង្គមនិយម បង្កើតអត្តសញ្ញាណកម្មករ-កសិករ និងធ្វើឲ្យមានការគាំទ្រគោលនយោបាយបក្សកុម្មុយ-នីស្តកម្ពុជា។ នៅខួបអនុស្សាវរីយ៍ថ្ងៃទី១៧ ខែមេសា និងនៅព្រឹត្តិការណ៍ផ្សេងៗទៀត ខៀវ សំផន បានកោតសរសើរជាសាធារណៈចំពោះភាពជោគជ័យរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយបានលើកទឹកចិត្តឲ្យប្រជាជនគាំទ្រកម្មវិធីរបស់*អង្គការ* ក្នុងការកសាង និងការពាររបបកម្ពុជាប្រជាធិបតេយ្យ។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន មិនត្រឹមតែមានការគាំទ្ររួមជាមួយអ្នកផ្សេងលើគោលបំណងរួមនេះប៉ុណ្ណោះនោះទេ ប៉ុន្តែក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ គាត់បានលើកទឹកចិត្តយ៉ាងសកម្ម យ៉ាងខ្លាំងក្លា និងជាសាធារណៈ អះអាងបញ្ជាក់ និងគាំទ្រគោលបំណងរួមនេះ នៅក្នុងប្រទេស និងនៅលើឆាកអន្តរជាតិ។ លើសពីនេះទៀត តាមរយៈសុន្ទរកថា និងសេចក្តីថ្លែងការណ៍ជាសាធារណៈជាច្រើនរបស់គាត់ក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន បានលើកទឹកចិត្ត និងញុះញង់ឱ្យមានការអនុវត្តគោលនយោបាយផ្សេងៗរបស់បក្សកុម្មុយនីស្តកម្ពុជា។

៥៨. សរុបមក អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន បានចូលរួមនៅក្នុងគោលបំណងរួម។ ក្នុងនាមជាអ្នកតំណាងឲ្យកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន បានគាំទ្រ និងជំរុញគោលបំណងរួមនេះ ហើយបានលើកទឹកចិត្ត ញុះញង់ និងផ្តល់ភាពស្របច្បាប់ដល់ការអនុវត្តគោលបំណងរួមតាមរយៈគោលនយោបាយឧក្រិដ្ឋ។ គាត់ក៏បានណែនាំឲ្យកម្មាភិបាលអនុវត្តគោលនយោបាយទាំងនោះ ហើយនៅពេលជាមួយគ្នានោះ គាត់បានផ្តល់លទ្ធភាព និងគ្រប់គ្រងទៅលើគោលនយោបាយ

ទាំងនោះផងដែរ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន បានចូលរួមចំណែកយ៉ាងសំខាន់លើការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាបានប្រព្រឹត្តឡើង ហើយស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២។

៥៩. ម្យ៉ាងវិញទៀត ដូចបានរៀបរាប់ខាងលើរួចមកហើយ អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន មានចេតនារួមជាមួយនឹងសមាជិកសហឧក្រិដ្ឋកម្មផ្សេងៗទៀត រួមទាំង មានចេតនាជាក់លាក់ និងចេតនារើសអើង ដែលជាលក្ខខណ្ឌកំណត់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលស្ថិតក្នុងគោលបំណងរួម លើកលែងតែឧក្រិដ្ឋកម្មមួយប៉ុណ្ណោះ។ អង្គជំនុំជម្រះមិនអាចកំណត់ ឬ សន្និដ្ឋានពីចេតនាប្រល័យពូជសាសន៍របស់ ខៀវ សំផន ទាក់ទងនឹងជនជាតិចាមបានឡើយ។

៦០. ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន បានប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម (ក) ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការបាត់ខ្លួនដោយបង្ខំ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការជម្លៀសដោយបង្ខំ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ (ខ) ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាមរយៈការធ្វើមនុស្សឃាតលើសមាជិកនៃក្រុមជាតិ ជាតិពន្ធុ និងពូជសាសន៍វៀតណាម និង (គ) ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ តាមរយៈការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនានូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការឃុំខ្លួនដោយខុសច្បាប់នៅមន្ទីរសន្តិសុខ ស-២១ ប្រឆាំងនឹងបុគ្គលទាំងឡាយដែលត្រូវទទួលបានការការពារដោយអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩។ អាស្រ័យ ហេតុ

នេះ អង្គជំនុំជម្រះសម្រេចផ្តន្ទាទោសចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្ម តាមរយៈសហឧក្រិដ្ឋកម្មរួម ដែល ខៀវ សំផន មានចេតនាដោយផ្ទាល់ ចេតនារើសអើង និងចេតនាជាក់លាក់ ដូចសមាជិកសហឧក្រិដ្ឋកម្មរួមដទៃទៀតដែរ។

៦១. លើសពីនេះទៀត ពាក់ព័ន្ធនឹងការស្លាប់អ្នកធ្វើការ និងកសិករនៅសហករណ៍ នៅការដ្ឋានការងារ និងនៅមន្ទីរសន្តិសុខ ដោយសារតែ*ចេតនាដោយប្រយោល* (ដែលមិនស្ថិតនៅក្នុងគោលបំណងរួម) អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន បានជួយ និងជំរុញឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាតនៅសហករណ៍ត្រាំកក់ នៅការដ្ឋានការងារទំនប់ ១ មករា ការដ្ឋានការងារទំនប់ត្រពាំងថ្ម ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោល។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ការប្រព្រឹត្តរបស់ ខៀវ សំផន គួរតែត្រូវចាត់ទុកថាជាទម្រង់នៃការជួយ និងជំរុញ។ គាត់បានផ្តល់ការលើកទឹកចិត្ត និងការគាំទ្រផ្នែកស្មារតី ដោយបានចូលរួមនៅក្នុងកិច្ចប្រជុំ និងមានវត្តមាន ព្រមទាំងថ្លែងសុន្ទរកថានៅក្នុងវគ្គរៀនសូត្រនៅទូទាំងប្រទេស ដោយបានលើកទឹកចិត្តយ៉ាងចំហ និងសកម្ម ហើយផ្តល់ការគាំទ្រផ្នែកស្មារតីដល់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាក្នុងការអនុវត្តគោលនយោបាយរបស់គណៈកម្មាធិការមជ្ឈិមបក្ស។ អង្គជំនុំជម្រះយល់ឃើញថា ទង្វើទាំងនេះមានឥទ្ធិពលយ៉ាងខ្លាំងលើការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ ហើយ ខៀវ សំផន បានដឹងអំពីរឿងនេះ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចផ្តន្ទាទោសចំពោះការជួយ និងជំរុញឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាតដោយ *ចេតនាដោយប្រយោល* នៅតាមទីតាំងដែលកើតមានឧក្រិដ្ឋកម្មខាងលើទាំងនេះ។

៦២. ជាចុងក្រោយ ភ័ស្តុតាងពុំបានបង្ហាញដល់កម្រិតមួយដែលថា ខៀវ សំផន បានជួយ និងសម្របសម្រួលយ៉ាងសកម្ម លើការអនុវត្តគោលនយោបាយប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម ឡើយ។ អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន មិនមែនជាថ្នាក់លើក្នុងន័យថា គាត់មានលទ្ធភាពទប់ស្កាត់ ឬ ដាក់ទណ្ឌកម្មលើការប្រព្រឹត្តឧក្រិដ្ឋកម្មនោះទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន មិនត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាមរយៈការធ្វើមនុស្ស

ឃាតលើសមាជិកនៃក្រុមជាតិពន្ធុចាម និងសាសនា នោះទេ ហើយគាត់ក៏មិនមែនជាអ្នកជួយ និងជំរុញ និងជាថ្នាក់លើដែរ។

## ១.៥. សំណាងចំពោះដើមបណ្តឹងរដ្ឋប្បវេណី

៦៣. ដើមបណ្តឹងរដ្ឋប្បវេណីសរុបចំនួន ៣.៨៦៥នាក់ ត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះ និងត្រូវបានបញ្ចូលទៅក្នុងក្រុមដើមបណ្តឹងរដ្ឋប្បវេណីតែមួយក្នុងពេលជំនុំជម្រះ ដែលតំណាងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

៦៤. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ជនជាប់ចោទទាំងពីរនាក់ក្នុងសំណុំរឿង ០០២ ត្រូវបានកំណត់ថាជាជនក្រីក្រគ្មានលទ្ធភាព។ អនុលោមតាមវិធានផ្ទៃក្នុង អ.វ.ត.ក. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អាចស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់នូវវិធានការសំណងជាក់លាក់នោះ។ វិធានការទាំងនោះត្រូវបានបង្កើត ឬកំណត់ឡើង ដោយមានការសម្របសម្រួលគ្នាជាមួយនឹងអង្គភាពគាំពារជនរងគ្រោះ ក្នុងគោលបំណងធ្វើឱ្យមានការទទួលស្គាល់យ៉ាងត្រឹមត្រូវចំពោះព្យសនកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង ដោយសារតែការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយដែលកំពុងត្រូវបានជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២ និងធ្វើឱ្យមានការផ្តល់ជាអត្ថប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីជាការដោះស្រាយចំពោះព្យសនកម្មនេះ។ នៅក្នុងសំណុំរឿង ០០២/០២ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឱ្យមានការទទួលស្គាល់តាមផ្លូវតុលាការចំពោះគម្រោងចំនួន ១៤ ថាជាសំណងសមស្របក្នុងចំណោមគម្រោងចំនួន១៨ ដែលបានស្នើសុំពីដំបូង។

៦៥. អង្គជំនុំជម្រះយល់ឃើញថា ឧក្រិដ្ឋកម្មទាំងឡាយដែលជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធ បានធ្វើឱ្យដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះជាច្រើនផ្សេងទៀត ទទួលរងព្យសនកម្មយ៉ាងខ្លាំងដែលមិនអាចវាស់បាន ដែលរួមមាន ការឈឺចាប់ផ្នែករាងកាយ ការខាតបង់ផ្នែកសេដ្ឋកិច្ច ការបាត់បង់សេចក្តីថ្លៃថ្នូរ ការបាក់ស្បាតផ្លូវចិត្ត និងសេចក្តីទុក្ខព្រួយដោយសារតែការព្រាត់ប្រាសនិរាសសមាជិកគ្រួសារ ឬសាច់ញាតិលោហិត។

៦៦. អង្គជំនុំជម្រះយល់ឃើញថា គម្រោងខាងក្រោមនេះស្របតាមលក្ខខណ្ឌតម្រូវនៃវិធាន២៣ *ស្ទួនបួន* នៃវិធានផ្ទៃក្នុង អ.វ.ត.ក. ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចទទួលយកគម្រោងទាំងនេះ។ គម្រោងទី១ គម្រោងទី២ និងគម្រោងទី៣ ពាក់ព័ន្ធនឹងទម្រង់នៃការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងបទពិសោធន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមានគោលបំណងមិនឲ្យរបបបែបនេះកើតឡើងសាជាថ្មី។ គម្រោងទី៤ គម្រោងទី៥ គម្រោងទី៦ និងគម្រោងទី១២ គឺការចងក្រងឯកសារស្តីពីបទពិសោធន៍របស់ក្រុមដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងជនរងគ្រោះដែលទទួលរងការប៉ះពាល់ដោយការប្រព្រឹត្តលើជនជាតិចាម ការប្រព្រឹត្តលើជនជាតិវៀតណាម និងការចេញបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍ ដើម្បីទប់ស្កាត់ការកើតឡើងវិញនៃឧក្រិដ្ឋកម្មដែលកំណត់គោលដៅទៅលើក្រុមទាំងនេះ។ គម្រោងទី៧ គម្រោងទី៨ គម្រោងទី៩ និងគម្រោងទី១០ រម្លឹកពីការចងចាំអំពីការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលអាចឲ្យសង្គមទូទៅដឹងរឿងរ៉ាវទាំងនេះ ដែលផ្តល់ជាមធ្យោបាយធ្វើឲ្យពួកគាត់អាចមានការស្ងប់អារម្មណ៍។ គម្រោងទី១១ និងផ្នែកស្តីពីការថែទាំសុខភាពនៃគម្រោងទី១៣ ផ្តល់ការថែទាំសុខភាពផ្លូវចិត្តនិងផ្លូវកាយទៅដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្តោតលើការស្តារនីតិសម្បទា។

៦៧. អង្គជំនុំជម្រះយល់ឃើញថា ផ្នែកជាក់លាក់មួយនៃគម្រោងទី១៣ ដែលទាក់ទងនឹងការគាំទ្រផ្នែកជីវភាព មានបំណងផ្តល់អត្ថប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងទម្រង់សំណងជាថវិកាផ្ទាល់ទៅបុគ្គលម្នាក់ៗ។ ដោយសារតែការផ្តួចផ្តើមទាំងនេះស្ថិតនៅក្រៅវិសាលភាពនៃវិធាន ២៣ *ស្ទួនបួន* (១) នៃវិធានផ្ទៃក្នុង អ.វ.ត.ក. ដែលចែងថា អង្គជំនុំជម្រះអាចផ្តល់ត្រឹមតែសំណងផ្លូវចិត្តនិងជាសមូហភាពតែប៉ុណ្ណោះ ហើយមិនមានសំណងជាថវិកាសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ហេតុដូច្នេះហើយ អង្គជំនុំជម្រះមិនអាចអនុម័តទៅលើគម្រោងទាំងនេះ ថាជាវិធានការសំណងបានឡើយ។ លើសពីនេះទៅទៀត អង្គជំនុំជម្រះមិនអាចអនុម័តទៅលើគម្រោងទី១៥ ដែលចង់ឲ្យមានការទទួលស្គាល់លើការឈឺចាប់ដែលជនជាតិដើមភាគតិចនៅខេត្តរតនគិរី និងខេត្តមណ្ឌលគិរី បានទទួលរង ដោយសារតែការមាក់ងាយ ការរើសអើង និងការធ្វើទុក្ខបុកម្នេញបានឡើយ។ អង្គជំនុំជម្រះរម្លឹកថា សំណុំរឿង ០០២/០២ មិនមានការចោទប្រកាន់ទាក់ទងនឹងការកំណត់គោលដៅ ការរើសអើង ឬការធ្វើទុក្ខបុកម្នេញលើជនជាតិភាគតិច ដែលរស់នៅក្នុងខេត្តរតនគិរី និងខេត្តមណ្ឌលគិរីឡើយ។ ទោះបីជាបានទទួលស្គាល់អំពីគុណតម្លៃនៃគម្រោងនេះក៏ដោយ

ក៏អង្គជំនុំជម្រះយល់ឃើញថា គម្រោងនេះមិនបំពេញតាមលក្ខខណ្ឌនៃវិធាន ២៣ *ស្ទួនបួន* (១) នៃវិធានផ្ទៃក្នុង អ.វ.ត.ក. នោះទេ គឺថាវិធានការសំណងត្រូវទទួលស្គាល់ថា វាជាព្យសនកម្មដែលកើតមានឡើងដោយសារតែការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលជនជាប់ចោទត្រូវបានផ្តន្ទាទោសប៉ុណ្ណោះ។ ហេតុដូច្នេះ អង្គជំនុំជម្រះបដិសេធការអនុម័តលើគម្រោងនេះ។

៦៨. សេចក្តីសង្ខេបនៃសំអាងហេតុរបស់អង្គជំនុំជម្រះចប់ត្រឹមនេះ ហើយជាបន្ត យើងនឹងអានផ្នែកសេចក្តីសម្រេច។

## ១.៦. ផ្នែកសេចក្តីសម្រេច និងការផ្តន្ទាទោស

៦៩. អង្គជំនុំជម្រះបដិសេធសំណើរបស់ក្រុមមេធាវីការពារក្តី **ខៀវ សំផន** ដែលសុំឲ្យកម្រិតវិសាលភាពនៃសំណុំរឿង ០០២/០២។

៧០. អង្គជំនុំជម្រះសម្រេចផ្លាស់ប្តូរការកំណត់បទចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្ស-ជាតិ តាមរយៈការសម្លាប់រង្គាលទៅជាការធ្វើមនុស្សឃាត ដោយរួមបញ្ចូល*ចេតនាដោយប្រយោល* ពាក់ព័ន្ធនឹងការស្លាប់ដែលបានកើតឡើងក្រោមលក្ខខណ្ឌ និងកាលៈទេសៈនានា ដែលត្រូវបានប្រព្រឹត្តទៅលើជនរងគ្រោះនៅតាមទីតាំងឧក្រិដ្ឋកម្មដូចតទៅនេះ៖ សហករណ៍ត្រាំកក់ ការដ្ឋានការងារទំនប់ ១ មករា ការដ្ឋានការងារទំនប់ត្រពាំងថ្ម ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោល។

៧១. អង្គជំនុំជម្រះសាលាដំបូងរកឃើញថា ជនជាប់ចោទ **នួន ជា** មានពិរុទ្ធ ដែលបានប្រព្រឹត្តនៅលើទឹកដីនៃប្រទេសកម្ពុជា ចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ដូចបានរៀបរាប់ដោយសង្ខេបខាងលើ និងដោយលម្អិតនៅក្នុងសាលក្រមជាលាយលក្ខណ៍អក្សរ តាមរយៈអំពើសកម្ម និងអកម្ម ចំពោះឧក្រិដ្ឋកម្មទាំងឡាយដូចខាងក្រោម ៖

- **ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ** តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោម

ទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការបាត់ខ្លួនដោយបង្ខំ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការជម្លៀសដោយបង្ខំ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អនុលោមតាមបទប្បញ្ញត្តិមាត្រា ៥ និង មាត្រា ២៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

- **ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ** តាមរយៈការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិល នូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ អនុលោមតាមមាត្រា ៦ និងមាត្រា ២៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

- **ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍** តាមរយៈការធ្វើមនុស្សឃាតលើសមាជិកនៃក្រុមជនជាតិវៀតណាម និងជនជាតិចាម អនុលោមតាមមាត្រា ៤ និងមាត្រា ២៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

៧២. អង្គជំនុំជម្រះសាលាដំបូងរកឃើញថា ជនជាប់ចោទ **ខៀវ សំផន** មានពិរុទ្ធ ដែលបានប្រព្រឹត្តនៅលើទឹកដីនៃប្រទេសកម្ពុជា ចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ដូចបានរៀបរាប់ដោយសង្ខេបខាងលើ និងដោយលម្អិតនៅក្នុងសាលក្រមជាលាយលក្ខណ៍អក្សរ តាមរយៈអំពើសកម្ម និងអកម្ម ចំពោះឧក្រិដ្ឋកម្មទាំងឡាយ ដូចខាងក្រោម៖

- **ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ** តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា និង

ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការបាត់ខ្លួនដោយបង្ខំ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការជម្លៀសដោយបង្ខំ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អនុលោមតាមបទប្បញ្ញត្តិមាត្រា ៥ និងមាត្រា ២៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

- **ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ** តាមរយៈការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិល នូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ អនុលោមតាមមាត្រា ៦ និងមាត្រា ២៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

- **ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍** តាមរយៈការធ្វើមនុស្សឃាតលើសមាជិកនៃក្រុមជនជាតិវៀតណាម អនុលោមតាមមាត្រា ៤ និងមាត្រា ២៩ (ថ្មី) នៃច្បាប់ស្តីពីការ បង្កើត អ.វ.ត.ក.។

៧៣. អង្គជំនុំជម្រះរកឃើញថា ជនជាប់ចោទ **នួន ជា** និង **ខៀវ សំផន** មិនមានពិរុទ្ធចំពោះបទចោទផ្សេងទៀតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចឲ្យជនជាប់ចោទទាំងពីរនាក់រួចផុតពីបទចោទប្រកាន់ទាំងនេះ។

៧៤. អង្គជំនុំជម្រះបានពិចារណាទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម រួមទាំងទំហំ និងភាពសាហាវព្រៃផ្សៃ ក៏ដូចជាចំនួន និងភាពទន់ខ្សោយរបស់ជនរងគ្រោះ ដែលជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធ រួមទាំងស្ថានទម្ងន់ទោស និងស្ថានសម្រាលទោសនានាដែលពាក់ព័ន្ធ។

៧៥. អនុលោមតាមមាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. អង្គជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទ **នួន ជា** ដាក់ពន្ធនាគារ**អស់មួយជីវិត**។ ដោយពិចារណាទៅលើការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតចំពោះគាត់ នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះរួមបញ្ចូលគ្នានូវការផ្តន្ទាទោសទាំងពីរ ទៅជាការផ្តន្ទាទោស**ដាក់ពន្ធនាគារអស់មួយជីវិត តែមួយ** ។

៧៦. អនុលោមតាមមាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. អង្គជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទ **ខៀវ សំផន** ដាក់ពន្ធនាគារ**អស់មួយជីវិត**។ ដោយពិចារណាទៅលើការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតចំពោះគាត់ នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះរួមបញ្ចូលគ្នានូវការផ្តន្ទាទោសទាំងពីរ ទៅជាការផ្តន្ទាទោស**ដាក់ពន្ធនាគារអស់មួយជីវិត តែមួយ** ។

៧៧. ប្រកាសថា ដើមបណ្តឹងរដ្ឋប្បវេណីដែលរួមបញ្ចូលជាក្រុមដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីដែលជាឧបសម្ព័ន្ធ២ ពិតជាបានទទួលរងព្យសនកម្មដែលជាផល-វិបាកដោយផ្ទាល់ដែលកើតចេញពីឧក្រិដ្ឋកម្មដែល **នួន ជា** និង **ខៀវ សំផន** ត្រូវបានរកឃើញថាមានពិរុទ្ធ និងដោយអនុលោមតាមវិធាន ២៣ ស្ទួនបួន (ខ)(៣) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. អង្គជំនុំជម្រះសម្រេចទទួលយកផ្នែកខ្លះនៃសំណើសុំសំណងផ្លូវចិត្ត និងជាសមូហភាព ដូចមានចែងលម្អិតនៅក្នុងផ្នែកទី២១ នៃសាលក្រមជាលាយលក្ខណ៍អក្សរ អង្គជំនុំជម្រះសម្រេចទទួលយកនូវគម្រោងសំណងដែលមានលក្ខណៈសមស្រប និងដែលអាចអនុវត្តបានចំនួន ១៣គម្រោង ដែលទាក់ទងនឹងទិវានៃការចងចាំចំពោះជនរងគ្រោះ និងពិធីរម្លឹកផ្សេងៗចំពោះការឈឺចាប់ដែលពួកគាត់បានទទួលរង វិធីព្យាបាលតាមរយៈការចងក្រងនូវសក្ខីកម្ម និងការព្យាបាលជំងឺផ្លូវចិត្តដល់ជនរងគ្រោះ និងការតាំងពិព័រណ៍ឯកសារ និងគម្រោងអប់រំ។ អង្គជំនុំជម្រះសម្រេចបដិសេធគម្រោងសំណងដែលបានស្នើសុំចំនួន២ (មួយបដិសេធទាំងស្រុង និងមួយទៀតបដិសេធផ្នែកខ្លះ) ដែលមិនស្របតាមលក្ខខណ្ឌតម្រូវនៃវិធាន ២៣ ស្ទួនបួន(ខ)(៣) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. ដូចមានចែងលម្អិតនៅក្នុងផ្នែកទី២១ នៃសាលក្រមជាលាយលក្ខណ៍អក្សរ។

៧៨. សាលក្រមនេះប្រកាសជាសាធារណៈនៅក្នុងសាលសវនាការធំនៃ អ.វ.ត.ក. ក្នុងរាជធានីភ្នំពេញ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។

៧៩. សាលក្រមនេះបើកផ្លូវឲ្យភាគីប្ដឹងសាទុក្ខអនុលោមតាមវិធានផ្ទៃក្នុង។ ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងសូមបញ្ជាក់ថា អនុលោមតាមវិធាន១០៧(៤) នៃវិធានផ្ទៃក្នុង និងមាត្រា ៨.៥ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក. រយៈពេលកំណត់សម្រាប់ការដាក់សេចក្ដីជូនដំណឹងពីបណ្ដឹងសាទុក្ខ ប្រសិនបើមាន នឹងត្រូវចាប់ផ្ដើមរាប់មួយថ្ងៃបន្ទាប់នៃថ្ងៃប្រក្រតីទិន ក្រោយពីការបញ្ជូននូវការជូនដំណឹងពីសាលក្រមជាលាយលក្ខណ៍អក្សរដែលមានសំអាងហេតុពេញលេញជាភាសាខ្មែរ និងភាសាផ្លូវការណាមួយផ្សេងទៀតរបស់ អ.វ.ត.ក. ដែលភាគីនីមួយៗបានជ្រើសរើស ដោយអនុលោមទៅតាមមាត្រា ២.២ នៃសេចក្ដីណែនាំអនុវត្ត។

៨០. លោកចៅក្រម **យូរ ឧត្ដារា** មានមតិដោយឡែកពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលមានភ្ជាប់ជាមួយនឹងសាលក្រម។

៨១. អង្គជំនុំជម្រះប្រកាសបិទបញ្ចប់សវនាការលើសំណុំរឿង ០០២/០២ ។

# ឧបសម្ព័ន្ធ ៤

01070797

លេខ: D128

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 03 / 03 / 2015
ម៉ោង (Time/Heure): 15:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥**

ភាសា ៖ **ខ្មែរ/អង់គ្លេស [អង់គ្លេស ភាសាដើម]**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់** **ប្តូរទៅជាសាធារណៈ**

## ដីកាសម្រេចដាក់ មាស មុត ឲ្យស្ថិតក្រោមការពិនិត្យ*ដោយតំណាងមុខ*

**ផ្ញើជូន ៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីរបស់ មាស មុត**
Michael KARNAVAS
អាង ឧត្តម

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖**
ហុង គឹមសួន
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
សំ សុគង់
ទី ស្រីនណា
វ៉ែន ពៅ
Philippe CANONNE
Laure DESFORGES
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES

**បានឃើញ** ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក")។

**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ របស់សហព្រះរាជអាជ្ញា ដាក់នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ")[1]។

**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣ ដាក់នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម")[2]។

**បានឃើញ** កិច្ចស៊ើបសួរដែលបានបើកធ្វើទាក់ទងនឹងការចោទប្រកាន់អំពីការរំលោភបំពាន**ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ អនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩** និង**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** ជាបទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៣(ថ្មី), ៥, ៦, ២៩ និង៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា៥០០, ៥០១, ៥០៣, ៥០៤, ៥០៥, ៥០៦, ៥០៧ និង៥០៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

**បានឃើញ** មាត្រា ២៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា ២៥ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង អ.វ.ត.ក")។

**បានឃើញ**វិធាន ២, ១៥, ២១, ៤៥, ៥៥, ៦២, ៧២ និង៨១ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ("វិធានផ្ទៃក្នុង")។

**បានឃើញ**ករណីខ្វែងយោបល់គ្នា ចុះបញ្ជីនៅថ្ងៃទី ៧ និងថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣។

---

[1]សំណុំរឿង ០០៣ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២របស់សហព្រះរាជអាជ្ញា ទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជា* ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨។ សំណុំរឿង ០០៣ ឯកសារ D1/1 *ការជូនដំណឹងអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ២ របស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី* ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ។

[2]សំណុំរឿង ០០៣ ឯកសារ D120 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣* ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤។

## ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដែលក្នុងនោះ គាត់បានចោទថា មាស មុត ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក។ ការចោទប្រកាន់បន្ថែមទៀតក៏បានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដាក់នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤។

២. នៅថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស. អន្តរជាតិ") Marcel Lemonde បានចេញដីកាចាត់ឲ្យស៊ើបសួរជំនួសដើម្បីស៊ើបអង្កេតទីតាំងឧក្រិដ្ឋកម្មនានាដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[3]។ នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") បានចេញសេចក្តីជូនដំណឹងស្តីពីការបិទកិច្ចស៊ើបសួរ ដោយជូនដំណឹងសហព្រះរាជអាជ្ញាថា ស.ច.ស បានចាត់ទុកថាកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ ត្រូវបានបញ្ចប់សព្វគ្រប់ហើយ អនុលោមតាមវិធានផ្ទៃក្នុង ៦៦[4]។

៣. នៅថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Laurent Kasper-Ansermet ("ស.ច.ស.អ.ប") បានចេញដីកាសម្រេចឲ្យបើកកិច្ចស៊ើបសួរឡើងវិញ[5] ដោយដីកាសម្រេចរបស់គាត់ ផ្អែកលើមូលដ្ឋាន ដូចជា ដើម្បីជាប្រយោជន៍យុត្តិធម៌ យុត្តិធម៌សម្រាប់ភាគីនានានៅក្នុងកិច្ចដំណើរការនីតិវិធី និងជាប្រយោជន៍ដល់សាធារណជនទូទៅនៅក្នុងសំណុំរឿង[6]។

៤. នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ ស.ច.ស.អ.ប បានជូនដំណឹង ជនសង្ស័យថា គាត់ "*ត្រូវបានជាប់ឈ្មោះថាជាជនសង្ស័យម្នាក់នៅក្នុងកិច្ចស៊ើបសួរកំពុងបន្តដំណើរការ ដោយយោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២០ ខែ*

---

[3]សំណុំរឿង ០០៣ ឯកសារ D2 *ដីកាចាត់ឲ្យស៊ើបសួរជំនួស* ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១០។

[4]សំណុំរឿង ០០៣ ឯកសារ D13 *សេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួរ* ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១។

[5]សំណុំរឿង ០០៣ ឯកសារ D28 *ដីកាសម្រេចស្តីអំពីការបើកកាស៊ើបអង្កេតបឋមឡើងវិញ* ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១១។

[6]*ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៨ និង ១១។

*វិច្ឆិកា ឆ្នាំ ២០០៨"* ហើយក៏បានជូនដំណឹងគាត់អំពីការចោទប្រកាន់ប្រឆាំងគាត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[7]។

៥. នៅថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១២ ស.ច.ស.អ.ប បានចេញដីកាសម្រេចមានការកោសលុប ដោយសម្រេចថា ជនសង្ស័យ *"ត្រូវបានចាត់ទុកថាជាជនម្នាក់ក្នុងចំណោមជនដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរយៈពេលរវាងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩"*[8]។

៦. នៅថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ ស.ច.ស បានចុះបញ្ជីករណីខ្វែងយោបល់គ្នា ទាក់ទងនឹងសំណុំរឿង ០០៣[9]។

៧. ចាប់តាំងពីថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៣ និងរហូតដល់ពេលចេញដីកាសម្រេចនេះ មាស មុត តាមរយៈសហមេធាវីរបស់គាត់ បានដាក់សំណើ ញត្តិ និងបណ្តឹងតវ៉ាផ្សេងៗជូនទៅ ស.ច.ស.អន្តរជាតិ និងអង្គបុរេជំនុំជម្រះ ("អ.ប.ជ") ទាក់ទងនឹងការចូលពិនិត្យមើលសំណុំរឿង និងការចូលរួមកិច្ចស៊ើបសួរ[10]។

---

[7] សំណុំរឿង ០០៣ ឯកសារ D30 *ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ[វិធាន ២១(១((ឃ)]* ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១។

[8] សំណុំរឿង ០០៣ ឯកសារ D48 *ដីកាសម្រេចលើយុត្តាធិការបុគ្គល និងគោលនយោបាយស៊ើបអង្កេតទាក់ទងនឹងជនសង្ស័យមាស មុត* ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១២។

[9] កំណត់ហេតុនៃករណីខ្វែងយោបល់គ្នា ចុះថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[10] សំណុំរឿង ០០៣ ឯកសារ D82 *សំណើរបស់មាស មុត ស្នើសុំការអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿង និង ចូលរួមក្នុងការស៊ើបអង្កេតតាមផ្លូវតុលាការ* ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៣ ។ សំណុំរឿង ០០៣ ឯកសារ D82/2 *សំណើសុំទទួលបានឯកសារទាំងមូលនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងសម្ភារៈគាំទ្រ* ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣។ សំណុំរឿង ០០៣ ឯកសារ D82/3/1 *សំណើសុំព័ត៌មានទាក់ទងនឹងការខ្វែងគំនិតគ្នាចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ និងថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣* ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤។ សំណុំរឿង០០៣ ឯកសារD82/3/5 *សំណើសុំការពិចារណារបស់ មាស មុត ស្តីពីការពិចារណាសាជាថ្មីទៅលើដីកាសម្រេចរបស់ ស.ច.ស.អ.ប លើយុត្តាធិការបុគ្គល និងសេចក្តីសម្រេចអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿងនៅក្នុងសេចក្តីជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ* ថ្ងៃទី៣០ ខែ កក្កដា ឆ្នាំ២០១៤។ សំណុំរឿង ០០៣ ឯកសារ D82/3/3/3/1 *ញត្តិរបស់លោកមាស មុត សុំលុបចោលចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិតបទៅនឹងការជូនដំណឹងទាក់ទងនឹងសំណើរបស់ជនសង្ស័យសុំចូលពិនិត្យមើលសំណុំរឿង ចូលរួមក្នុងការស៊ើប អង្កេតតាមផ្លូវតុលាការ និងសុំឯកសារទាំងមូលនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ* ថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០១៤។ សំណុំរឿង ០០៣ ឯកសារ D82/4/1 *សេចក្តីជូនដំណឹងរបស់មាស មុតអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង*

៨. នៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤ ស.ច.ស បានចុះបញ្ជីករណីខ្វែងយោបល់គ្នា ទាក់ទងនឹងសំណុំរឿង ០០៣[11]។

៩. នៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤ មាស មុត បានដាក់សំណើជាមុនដោយចោទសួរសំណួរសម្មតិកម្មអំពីសុពលភាពដីកាកោះដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ដើម្បីចោទប្រកាន់ជនសង្ស័យ[12]។

១០. នៅថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៤ ស.ច.ស.អន្តរជាតិ បានបញ្ជាក់ថា ដីកាកោះដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ គឺមានសុពលភាព ដោយអនុលោមតាមមាត្រា ៥ និង៧ នៃកិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ២៣*ថ្មី* នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង ៧២[13]។ ស.ច.ស.អន្តរជាតិ ក៏បានណែនាំឲ្យសហមេធាវីរបស់ជនសង្ស័យទៅពិនិត្យមើលសេចក្តីសម្រេចរបស់ អ.ជ.ប នៅក្នុងសំណុំរឿងមួយទៀត ដែលសម្រេចថា *"អំណាច [របស់ ស.ច.ស] ក្នុងការចេញដីកាកោះហៅជនសង្ស័យណាម្នាក់ដែលមានសុពលភាពតែម្នាក់ឯង មានចែងយ៉ាងច្បាស់នៅក្នុងបទប្បញ្ញត្តិនៃក្រមច្បាប់ អ.វ.ត.ក និង*

---

*ការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេត ចំពោះញត្តិសុំលុបចោល និងសំណើសុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងការស៊ើបអង្កេតតាមផ្លូវតុលាការ* ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤។ សំណុំរឿង ០០៣ ឯកសារ D122/1/1 *បណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការបដិសេធរបស់សហចៅក្រមស៊ើបអង្កេត HARMON ទៅនឹងសំណើរបស់គាត់សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ* ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៤។

[11] កំណត់ហេតុនៃករណីខ្វែងយោបល់គ្នា ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤។

[12] សំណុំរឿង ០០៣ ឯកសារ D117 *សំណើរបស់មាស មុតសុំព័ត៌មានទាក់ទងនឹងសុពលភាពនៃដីកាកោះដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់* ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤។

[13] សំណុំរឿង ០០៣ ឯកសារ D117/1 *ដីកាសម្រេចលើសំណើរបស់ជនសង្ស័យទាក់ទងនឹងដីកាកោះដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់* ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៤ កថាខណ្ឌ ៣។

01070802



*យុត្តិសាស្ត្ររបស់ អ.ប.ជ*"[14]។ សហមេធាវីជនសង្ស័យ បានប្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចនេះ នៅថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០១៤[15]។

១១. រវាងថ្ងៃទី ១៥ ខែ កញ្ញា និងថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ ស.ច.ស.អន្តរជាតិ បានជួបជាមួយតំណាងម្នាក់របស់នគរបាលយុត្តិធម៌ ដើម្បីពិភាក្សាអំពីការអនុវត្តដីកានាំខ្លួនជនសង្ស័យម្នាក់នៅក្នុងសំណុំរឿងមួយទៀត។ តំណាងនគរបាលយុត្តិធម៌រូបនោះបានផ្តល់យោបល់ថា គួររៀបចំធ្វើសកម្មភាពផ្សព្វផ្សាយនៅតំបន់គោលដៅនានា ដើម្បីធ្វើឱ្យប្រជាជនមូលដ្ឋាននៅទីនោះជឿជាក់ថា ការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") មិនមានបំណងធ្វើការចាប់ខ្លួនមនុស្សជាច្រើននាក់នៅតំបន់នោះទេ។

១២. កម្មវិធីផ្សព្វផ្សាយដាច់ដោយឡែកចំនួនប្រាំបួន ត្រូវបានរៀបចំធ្វើឡើងដោយបុគ្គលិករបស់ ក.ស.ច.ស និង ស.ច.ស.អន្តរជាតិ រវាងថ្ងៃទី ១១ និងថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៤ នៅក្នុងខេត្តឧត្តរមានជ័យ បាត់ដំបង និងប៉ៃលិន រួមបញ្ចូលទាំង សំឡូត ផងដែរ ដែល មាស មុត មានទីលំនៅនៅទីនោះ[16]។

១៣. នៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ស.ច.ស.អន្តរជាតិ បានកោះហៅ មាស មុត ឱ្យចូលបង្ហាញខ្លួនលើកដំបូងនៅ អ.វ.ត.ក នៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៤ អនុលោមតាមវិធានផ្ទៃក្នុង ៥៧[17]។

១៤. នៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ អ្នកស៊ើបអង្កេតម្នាក់របស់ ក.ស.ច.ស បានប្រគល់ដីកាកោះជូន មាស មុត ដោយផ្ទាល់នៅលំនៅដ្ឋានរបស់គាត់[18]។ បន្ទាប់ពីត្រូវបានជូនដំណឹង

---

[14] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៤ ដោយដកស្រង់សំណុំរឿង ០០៤ ឯកសារ A122/6.1/3 *សេចក្តីសម្រេចលើសំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម សុំព្យួរការអនុវត្តដីកាកោះហៅអ្នកស្រីឱ្យមកបង្ហាញខ្លួនជាលើកដំបូង* ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១៤។

[15] សំណុំរឿង ០០៣ ឯកសារ D117/1/1/1 *បណ្តឹងឧទ្ធរណ៍របស់មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ជនសង្ស័យទាក់ទងនឹងដីកាកោះដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់* ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៤។

[16] *សូមមើល* របាយការណ៍តុលាការរបស់ អ.វ.ត.ក ខែ ធ្នូ ឆ្នាំ ២០១៤ ទំព័រ ៣៖

http://www.eccc.gov.kh/en/publication/court-report-december-2014។

[17] សំណុំរឿង ០០៣ ឯកសារ A66 *ដីកាកោះហៅមាស មុត ឱ្យបង្ហាញខ្លួនលើកដំបូង* ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៤។

អំពីខ្លឹមសារនៃដីកាកោះរួចហើយ មាស មុត បានប្រកាសថា គាត់នឹងមិនបង្ហាញខ្លួននៅ អ.វ.ត.ក ទេ ហើយបានបដិសេធមិនព្រមចុះហត្ថលេខាលើលិខិតទទួលស្គាល់ការប្រគល់ដីកាកោះ[19]។

១៥. នៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ សហមេធាវីរបស់ មាស មុត ត្រូវបានកោះហៅឱ្យចូលរួមការបង្ហាញខ្លួនលើកដំបូងរបស់គាត់[20]។ សហមេធាវីក៏ត្រូវបានជូនដំណឹងដោយឡែកពីគ្នាថា ប្រសិនបើត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យ នៅពេលបញ្ចប់ការបង្ហាញខ្លួនលើកដំបូងនេះ មាស មុត នឹងទទួលបានសិទ្ធិ និងផលប្រយោជន៍ដែលជនត្រូវចោទទទួលបាន តាមវិធានផ្ទៃក្នុង[21]។

១៦. នៅថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៤ មាស មុត បានជូនដំណឹង ស.ច.ស.អន្តរជាតិ ជាលាយលក្ខណ៍អក្សរថា គាត់មិនទទួលស្គាល់ថា ដីកាកោះដែលមិនបានចុះហត្ថលេខាដោយ ស.ច.ស.ជាតិ មានសុពលភាពទេ[22]។ គាត់ក៏បានទទូចថា មេធាវីរបស់គាត់ គួរទទួលបានការអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត ហើយបានបញ្ជាក់ថា គាត់មានបំណងប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប[23]។

---

[18]សំណុំរឿង ០០៣ ឯកសារ A66/1 *កំណត់ហេតុនៃការប្រគល់ដីកាកោះ* ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៤។

[19]*ដូចដើងទំព័រខាងលើ* ទំព័រ ៣។

[20]សំណុំរឿង០០៣ ឯកសារ A67 *ដីកាកោះហៅសហមេធាវី* ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤។

[21]សំណុំរឿង០០៣ ឯកសារ D82/5 *ការជូនដំណឹងស្តីពីសំណើរបស់ជនសង្ស័យសុំចូលពិនិត្យមើលសំណុំរឿងចូលរួមការស៊ើបអង្កេត និងសុំលុបចោលចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ កថាខណ្ឌ ១៥-១៧។

[22]សំណុំរឿង០០៣ ឯកសារ A67/1.1 *សេចក្តីជូនដំណឹងស្តីពីការមិនទទួលស្គាល់ដីកាកោះ* ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៤ (“សេចក្តីជូនដំណឹងរបស់មាស មុត”)។

[23] សេចក្តីជូនដំណឹងរបស់មាស មុត ទំព័រ ១-២។

១៧. នៅថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១៤ អ.ប.ជ បានច្រានចោលបណ្តឹងឧទ្ធរណ៍របស់ មាស មុត ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៤ ហើយបានបញ្ជាក់ថា ដីកាកោះដែលចេញដោយ ស.ច.ស តែម្នាក់ គឺស្ថិតនៅក្នុងដែនកំណត់នៃសិទ្ធិអំណាចរបស់ ស.ច.ស[24]។

១៨. នៅថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៤ ស.ច.ស.អន្តរជាតិ បានឆ្លើយតបទៅនឹងសេចក្តីជូនដំណឹងរបស់ មាស មុត ចុះថ្ងៃទី ២ ខែ ធ្នូ ដោយបានបញ្ជាក់ឡើងវិញអំពីសេចក្តីសម្រេចរបស់ អ.ប.ជ ដែលបានដាក់នៅថ្ងៃទី ៣ ខែ ធ្នូ[25]។ ទាក់ទងនឹង មាស មុត ដែលបានបង្ហាញពីចេតនាមិនចូលបង្ហាញខ្លួននៅ អ.វ.ត.ក នោះ ស.ច.ស.អន្តរជាតិ បានជូនដំណឹង មាស មុត ថា ការខកខានរបស់គាត់មិនចូលបង្ហាញខ្លួន *"នឹងរំលោភបំពានដោយផ្ទាល់ទៅលើដីកាដែលជាប់កាតព្វកិច្ចផ្លូវច្បាប់"* ហើយ ស.ច.ស.អន្តរជាតិ នឹង*"ពិចារណាវិធានការបន្ថែមទៀតដែលអាចមានតាមច្បាប់ជាធរមាននៅ អ.វ.ត.ក ដើម្បីធានាថា គាត់បានចូលបង្ហាញខ្លួន"*[26]។

១៩. នៅថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៤ សហមេធាវី របស់ មាស មុត បានជូនដំណឹង ស.ច.ស.អន្តរជាតិថា *"ទោះបីជាកូនក្តី[របស់ពួកគាត់] មានចេតនាមិនគោរពតាមដីកាកោះក៏ដោយ"* ក៏"[ពួកគាត់]មិនដែលមានចេតនាមិនគោរពតាមដីកាកោះ"ឲ្យបង្ហាញខ្លួននៅចំពោះមុខ ស.ច.ស.អន្តរជាតិនោះទេ[27]។

---

[24]សំណុំរឿង០០៣ ឯកសារ D117/1/1/2 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ជនសង្ស័យទាក់ទងនឹងដីកាកោះដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់* ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១៤ ("សាលដីការបស់ អ.ប.ជ") កថាខណ្ឌ ១៦។

[25]សំណុំរឿង០០៣ ឯកសារ A67/1/1 *ការឆ្លើយតបទៅនឹងសេចក្តីជូនដំណឹងទាក់ទងនឹងសេចក្តីសម្រេចចិត្តរបស់លោក មាស មុត មិនទទួលស្គាល់ដីកាកោះ ចុះថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១៤* ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៤ ("ការឆ្លើយតបទៅនឹងសេចក្តីជូនដំណឹងរបស់មាស មុត") កថាខណ្ឌ ៤ ដោយដកស្រង់សេចក្តីសម្រេចរបស់ អ.ប.ជ។

[26]ការឆ្លើយតបទៅនឹងសេចក្តីជូនដំណឹងរបស់មាស មុត កថាខណ្ឌ ៥។

[27]សំណុំរឿង០០៣ ឯកសារA67/2 *សេចក្តីជូនដំណឹងទាក់ទងនឹងការចូលរួមការបង្ហាញខ្លួនលើកដំបូង ដែលគ្រោងធ្វើឡើងនៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៤* ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៤ ។ *សូមមើលផងដែរ* សំណុំរឿង០០៣ ឯកសារA67/2 /1 *សេចក្តីជូនដំណឹងទាក់ទងនឹងការចូលរួមការបង្ហាញខ្លួនលើកដំបូង ដែលគ្រោងធ្វើឡើង នៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៤ ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៤* ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៤។

២០. នៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៤ មាស មុត មានចេតនាមិនបានចូលបង្ហាញខ្លួនក្នុងការបង្ហាញខ្លួនលើកដំបូងដែលបានគ្រោងទុកនៅចំពោះមុខ ស.ច.ស.អន្តរជាតិទេ[28]។ នៅអំឡុងពេលសវនាការបង្ហាញខ្លួនលើកដំបូងនេះ សហមេធាវីជាតិរបស់ មាស មុត បានប្រកាសថា មាស មុត បានបដិសេធមិនចូលបង្ហាញខ្លួនដោយផ្អែកលើមូលដ្ឋានថា គាត់មិនទទួលស្គាល់ថា ដីកាកោះដែលចេញដោយ ស.ច.ស តែម្នាក់ មានសុពលភាពទេ ទោះបីជាមានការជូនដំណឹងចុះថ្ងៃទី ៤ ខែ ធ្នូ ក៏ដោយ[29]។ សហមេធាវីជាតិ ក៏បានស្នើសុំចូលពិនិត្យមើលសំណុំរឿង ០០៣ ហើយសំណើនេះត្រូវបានបដិសេធដោយ ស.ច.ស.អន្តរជាតិ។ ដោយសារអវត្តមានរបស់ មាស មុត ស.ច.ស.អន្តរជាតិ បានបញ្ចប់សវនាការបង្ហាញខ្លួនលើកដំបូង[30]។

២១. នៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤ ស.ច.ស.អន្តរជាតិ បានចេញដីកាបង្គាប់ឱ្យនាំខ្លួន ("ដីកានាំខ្លួន") មាស មុត ដោយអនុលោមតាមវិធាន ៤២ នៃវិធានផ្ទៃក្នុង និងបានបង្គាប់ឱ្យ *"នគរបាលយុត្តិធម៌ត្រូវនាំ មាស មុត មកបង្ហាញខ្លួននៅចំពោះមុខ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រាប់ការបង្ហាញខ្លួនលើកដំបូង"* អនុលោមតាមវិធាន ១៥(២)[31] នៃវិធានផ្ទៃក្នុង។ ដីកានាំខ្លួននេះបានប្រគល់ជូននគរបាលយុត្តិធម៌ នៅថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៤[32]។

២២. នៅថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤ សហមេធាវីរបស់ មាស មុត បានដាក់ពាក្យសុំប្ដឹងអង្គបុរេជំនុំជម្រះ ឱ្យទទួលពិនិត្យ និងចាត់ការលើសំណើសុំមោឃភាពដីកាកោះហៅ មាស មុត ដោយផ្ដល់ទឡ្ហីករណ៍ ដូចជាថា ដីកានាំខ្លួនគួរតែបានចេញរួមគ្នាដោយ ស.ច.ស[33]។

២៣. នៅថ្ងៃ ១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ស.ច.ស.អន្តរជាតិ បានបដិសេធពាក្យសុំរបស់ មាស មុត ដោយផ្អែកលើមូលដ្ឋានថា គាត់មិនមានសិទ្ធិ[34]។ ស.ច.ស.អន្តរជាតិ បានរំឭកថា ស្របតាម

---

[28]សំណុំរឿង ០០៣ ឯកសារ D122 *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង* ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៤ ដាក់ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៤។

[29]*ដូចជើងទំព័រខាងលើ*។

[30]*ដូចជើងទំព័រខាងលើ* ទំព័រ ៣។

[31]សំណុំរឿង ០០៣ ឯកសារ C1 *ដីកាបង្គាប់ឱ្យនាំខ្លួន* ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤ ដាក់ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៤។

[32]សំណុំរឿង ០០៣ ឯកសារ C1.2 *កំណត់ហេតុនៃការប្រគល់ដីកាបង្គាប់ឱ្យនាំខ្លួនទៅនគរបាលយុត្តិធម៌* ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៤។

[33]សំណុំរឿង ០០៣ ឯកសារ A77 *ពាក្យសុំរបស់មាស មុត សុំប្ដឹងអង្គបុរេជំនុំជម្រះឱ្យទទួលពិនិត្យ និងចាត់ការលើសំណើសុំមោឃភាពដីកាកោះឱ្យបង្ហាញខ្លួនលើកដំបូង* ថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០១៤។

ច្បាប់កម្ពុជា វិធាន ៤៨ នៃវិធានផ្ទៃក្នុង អនុញ្ញាតឲ្យ "ភាគី" នៅក្នុងកិច្ចដំណើរការនីតិវិធី ដាក់សំណើសុំមោឃភាពកិច្ចស៊ើបសួរ ដោយបានបញ្ជាក់សាឡើងវិញថា ជនសង្ស័យ មិនស្ថិតនៅក្នុងដែនកំណត់នៃការអនុញ្ញាតនេះទេ[35]។

២៤. នៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៤ បុគ្គលិកពីររូបរបស់ ក.ស.ច.ស បានជួបប្រជុំជាមួយតំណាងម្នាក់របស់នគរបាលយុត្តិធម៌ ដើម្បីពិភាក្សាអំពីវឌ្ឍនភាពនៅក្នុងការអនុវត្តដីកានាំខ្លួន។ បុគ្គលិកទាំងនោះត្រូវបានជូនដំណឹងថា នគរបាលយុត្តិធម៌ មិនទាន់បានធ្វើការស្ទង់មតិក្រោយសកម្មភាពផ្សព្វផ្សាយទេ។ តំណាងនរគបាលយុត្តិធម៌រូបនោះ មិនស្ថិតនៅក្នុងតួនាទីដែលអាចបញ្ជាក់ថាតើនៅពេលណាដែលដីកានាំខ្លួនអាចអនុវត្តបានឡើយ។ តំណាងនគរបាលយុត្តិធម៌រូបនោះ បានបញ្ជាក់ថា សេចក្ដីសម្រេចចុងក្រោយចំពោះរឿងនេះ គឺស្ថិតនៅលើគណៈកម្មការសន្តិសុខប្រចាំ អ.វ.ត.ក។

២៥. នៅថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥ ស.ច.ស.អន្តរជាតិ បានសរសេរលិខិតមួយច្បាប់ជូនប្រធានគណៈកម្មការសន្តិសុខប្រចាំ អ.វ.ត.ក ហើយលិខិតនោះបានប្រគល់ជូន នៅថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៥។ នៅក្នុងលិខិតនោះ ស.ច.ស.អន្តរជាតិ បានកត់សម្គាល់ *ក្នុងចំណោមនោះ* ថា កិច្ចខិតខំប្រឹងប្រែងដើម្បីធានាឲ្យ មាស មុត និងជនសង្ស័យម្នាក់ទៀត ចូលបង្ហាញខ្លួនលើកដំបូងនៅ អ.វ.ត.ក គឺមិនបានទទួលជោគជ័យទេ។ ស.ច.ស.អន្តរជាតិ បានកត់សម្គាល់ទាំងក្ដីបារម្ភថា មិនច្បាស់ថាតើដីកានាំខ្លួននឹងត្រូវអនុវត្តនៅពេលណានោះទេ។ គាត់បានបន្ថែមទៀតថា ការពន្យារពេលបន្ថែមទៀតប៉ះពាល់ដល់ប្រយោជន៍យុត្តិធម៌ និងសិទ្ធិរបស់ មាស មុត តាមច្បាប់អន្តរជាតិ ក្នុងនោះរួមទាំងសិទ្ធិចូលរួមការស៊ើបអង្កេត និងសិទ្ធិទទួលបានការជំនុំជម្រះដោយឥតពន្យារពេលយូរហួស។ ស.ច.ស.អន្តរជាតិ ក៏បានកត់សម្គាល់ទៀតថា

---

[34]សំណុំរឿង ០០៣ ឯកសារ A77/1 *ដីកាសម្រេចលើពាក្យសុំរបស់មាស មុត សុំប្ដឹងអង្គបុរេជំនុំជម្រះឲ្យទទួលពិនិត្យ និងចាត់ការលើសំណើសុំមោឃភាពដីកាកោះឲ្យបង្ហាញខ្លួនលើកដំបូង* ថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០១៤ ដាក់នៅថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ២០១៤។

[35]*ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១៣។ នៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៥ សហមេធាវីរបស់មាស មុត បានជំទាស់ដីកាសម្រេចរបស់ ស.ច.ស.អន្តរជាតិ នៅចំពោះមុខ អ.ប.ជ។ សូមមើលសំណុំរឿង ០០៣ ឯកសារ A77/1/1 *បណ្ដឹងឧទ្ធរណ៍របស់មាស មុត ប្រឆាំងនឹងការបដិសេធរបស់សហចៅក្រមស៊ើបអង្កេត HARMON នូវ ពាក្យសុំរបស់មាស មុត សុំប្ដឹងអង្គបុរេជំនុំជម្រះឲ្យទទួលពិនិត្យ និងចាត់ការលើសំណើសុំមោឃភាពដីកាកោះឲ្យបង្ហាញខ្លួនលើកដំបូង* ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៥។ នៅពេលដាក់ដីកាសម្រេចនេះ អ.ប.ជ មិនទាន់សម្រេចលើបណ្ដឹងឧទ្ធរណ៍នេះទេ។

ការពន្យារពេលបន្ថែមទៀតក៏នឹងប៉ះពាល់យ៉ាងធ្ងន់ធ្ងរផងដែរដល់ដល់សិទ្ធិរបស់ជនរងគ្រោះ និងប្រជាជនកម្ពុជាដើម្បីទទួលបានយុត្តិធម៌ចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ស.ច.ស.អន្តរជាតិ បានបញ្ជាក់ថា គាត់នឹងបន្តកិច្ចដំណើរការនីតិវិធីក្នុងការដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ដោយសារថា ការពន្យារពេលថែមទៀតអាចបង្កើតឱ្យមានហានិភ័យមិនអាចទទួលយកបាន ប្រសិនបើ មាស មុត មិនបានបង្ហាញខ្លួននៅ អ.វ.ត.ក នៅត្រឹមថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឬក៏មិនត្រូវបាននាំខ្លួននៅត្រឹមកាលបរិច្ឆេទនោះទេ។ ស.ច.ស.អន្តរជាតិ បានជូនដំណឹងដល់ប្រធានគណៈកម្មការសន្តិសុខ ថា គាត់យល់ឃើញថា នេះគឺជាដំណើរការនៃវិធានការដែលអាចកាត់បន្ថយហានិភ័យតែមួយគាត់ ដោយសារគ្មានចំណាត់ការពីនគរបាលយុត្តិធម៌[36]។

២៦. កាលបរិច្ឆេទថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ ដែលបានលើកឡើងខាងលើ បានកន្លងផុតហើយ ដោយ មាស មុត មិនបានចូលបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក ទេ ហើយដីកានាំខ្លួនក៏មិនបានអនុវត្តដែរ។

**ច្បាប់ជាធរមាន**

**វិធានស្តីពីនីតិវិធីដែលអាចអនុវត្តទៅលើការស៊ើបអង្កេតរបស់តុលាការនៅ អ.វ.ត.ក**

២៧. មាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងអំពីផ្នែកពាក់ព័ន្ធថា៖

> "រាល់ការស៊ើបអង្កេត គឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមពីរនាក់ ម្នាក់ជាកម្ពុជា និងម្នាក់ទៀតជាបរទេស ដែលហៅថា "សហចៅក្រមស៊ើបអង្កេត" ដោយអនុវត្តតាមនីតិវិធីដែលនៅជាធរមាន។ ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ឬ ប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ"។

---

[36]សំណុំរឿង ០០៣ ឯកសារ D127 *លិខិតផ្ញើជូនប្រធានគណៈកម្មការសន្តិសុខប្រចាំ អ.វ.ត.ក* ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥។

**កាតព្វកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការផ្តល់ជំនួយដល់ ស.ច.ស**

២៨. មាត្រា ២៥ នៃកិច្ចព្រមព្រៀង អ.វ.ត.ក ចែងថា៖

> “រាជរដ្ឋាភិបាលនឹងអនុវត្តដោយគ្មានការពន្យារពេលតាមការស្នើសុំជំនួយរបស់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា ឬអង្គជំនុំជម្រះវិសាមញ្ញ ឬក៏បញ្ជារបស់ពួកគេរួមមាន ប៉ុន្តែមិនមែនត្រឹមតែ៖
>
> ក-រកអត្តសញ្ញាណ និងទីកន្លែងរបស់បុគ្គលណាមួយ។
>
> ខ-ផ្តល់ឯកសារ។
>
> គ-ចាប់ខ្លួន ឬឃុំខ្លួនបុគ្គលណាមួយ។
>
> ឃ-បញ្ជូនជនជាប់ចោទ មកកាន់អង្គជំនុំជម្រះវិសាមញ្ញ”។

២៩. មាត្រា ២៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងអំពីផ្នែកពាក់ព័ន្ធថា៖

> “ក្នុងការអនុវត្តភារកិច្ចនេះ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការជួយឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជាបាន ប្រសិនបើយល់ឃើញថាសមស្រប និងមានប្រយោជន៍ដល់ការស៊ើបអង្កេត ហើយការជួយឧបត្ថម្ភនេះត្រូវតែបានផ្តល់ជូន”។

**កាតព្វកិច្ចរបស់នគរបាលយុត្តិធម៌ក្នុងការផ្តល់ជំនួយដល់ ស.ច.ស**

៣០. វិធានផ្ទៃក្នុង ១៥ ចែងអំពីផ្នែកពាក់ព័ន្ធថា៖

> “នគរបាលយុត្តិធម៌ គឺជាមន្ត្រីជំនួយរបស់អង្គជំនុំជម្រះវិសាមញ្ញ។ មន្ត្រីទាំងនេះអនុវត្តការស៊ើបអង្កេតនៅទូទាំងប្រទេសកម្ពុជា ក្រោមការណែនាំតែពីសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះ តាមករណីសមស្រប ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុងនេះ។ នៅក្នុងការបំពេញមុខងាររបស់ខ្លួននគរបាលយុត្តិធម៌មិនត្រូវស្វែងរក ឬ ទទួលបញ្ជាពីជនណាផ្សេងទៀតឡើយ”។

សហព្រះរាជអាជ្ញាត្រូវដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់នគរបាលយុត្តិធម៌ រហូតដល់ការស៊ើបសួរ ត្រូវបានចាប់ផ្តើមដំណើរការ។ នៅពេលការស៊ើបសួរចាប់ផ្តើមដំណើរការ នគរបាលយុត្តិធម៌ត្រូវបំពេញភារកិច្ចរបស់ខ្លួនតាមការណែនាំរបស់សហចៅក្រមស៊ើបអង្កេត។

៣១. វិធានផ្ទៃក្នុង ៤៥ ចែងអំពីផ្នែកពាក់ព័ន្ធថា៖

រាល់ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យឃុំខ្លួន និងដីកាបង្គាប់ឱ្យចាប់ខ្លួនទាំងអស់ ត្រូវអនុវត្តដោយនគរបាលយុត្តិធម៌។ ដីកាដើមត្រូវប្រគល់ឱ្យភ្ជាមដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលមានភារកិច្ចត្រូវទទួលអនុវត្តដីកានេះ។ ក្នុងករណីបន្ទាន់ ត្រូវជូនដំណឹងអំពីដីកានេះទៅដល់មន្ត្រីនគរបាលយុត្តិធម៌ ដោយប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ ហើយដីកាដើមត្រូវប្រគល់ឱ្យនគរបាលយុត្តិធម៌ ក្នុងរយៈពេល ៤៨ (សែសិបប្រាំបី) ម៉ោង។

៣២. វិធានផ្ទៃក្នុង ៦២ ចែងអំពីផ្នែកពាក់ព័ន្ធថា៖

“សហចៅក្រមស៊ើបអង្កេត អាចចេញដីកាចាត់ឱ្យស៊ើបសួរជំនួសទៅឱ្យអ្នកស៊ើបអង្កេតនៃការិយាល័យរបស់ខ្លួន ឬនគរបាលយុត្តិធម៌ដើម្បីបំពេញកិច្ចស៊ើបសួរ។ ប៉ុន្តែមានតែនគរបាលយុត្តិធម៌ទេ ដែលមានអំណាចក្នុងការអនុវត្តន៍វិធានការចាប់បង្ខំ”។

**ការដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យនៅក្នុងការស៊ើបអង្កេតរបស់តុលាការនៅ អ.វ.ត.ក**

៣៣. វិធានផ្ទៃក្នុង ២១(១)(ឃ) ចែងថា៖

“ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោសដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ។ ជនទាំងនេះមានសិទ្ធិទទួលដំណឹងអំពីបទល្មើស ដែលចោទប្រកាន់ចំពោះខ្លួន និងមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន ហើយនិងនៅក្នុងគ្រប់ដំណាក់កាល ទាំងអស់នៃកិច្ចដំណើរការនីតិវិធីត្រូវផ្តល់ព័ត៌មានដល់គេ អំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប”។

៣៤. វិធានផ្ទៃក្នុង ៥៥(៤)ចែងថា៖

"សហចៅក្រមស៊ើបអង្កេត មានអំណាចបើកការស៊ើបសួរប្រឆាំងនឹងជនទាំងឡាយណា ដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេតអាចបើកកិច្ចស៊ើបសួរផងដែរ ចំពោះបុគ្គលគ្រប់រូបដែលមានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា បុគ្គលនោះអាចជាអ្នកទទួលខុសត្រូវក្នុងការប្រព្រឹត្តបទឧក្រិដ្ឋដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទោះបីជាបុគ្គលទាំងនោះមិនមានឈ្មោះក្នុងដីកាក៏ដោយ។ ក្នុងករណីចុងក្រោយនេះ សហចៅក្រមស៊ើបអង្កេតត្រូវសួរយោបល់សហព្រះរាជអាជ្ញាមុនពេលដាក់បុគ្គលនោះឱ្យស្ថិតនៅក្រោមការពិនិត្យ"។

## ការដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*

<u>វិធានផ្ទៃក្នុង</u>

៣៥. វិធានផ្ទៃក្នុង ៨១(១) ចែងពីគោលការណ៍ដែលថា *"ការជំនុំជម្រះត្រូវតែធ្វើឡើងដោយមានវត្តមានរបស់ជនជាប់ចោទ"* លើកលែងតែកាលៈទេសៈពិសេសដែលចែងខុសពីវិធានផ្ទៃក្នុង ៨១។ នេះគឺជាការដាក់កំហិតយ៉ាងច្បាស់ទៅលើការទទួលយកជាទូទៅនូវការជំនុំជម្រះ*ដោយកំបាំងមុខ*តាមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[37]។ ទោះយ៉ាងណា ការដាក់កំហិតនេះមានលក្ខណៈកម្រិត ពីព្រោះថា ការដាក់កំហិតនេះអនុវត្តតែទៅលើ*ជនជាប់ចោទ* នៅក្នុងដំណាក់កាលជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីតែប៉ុណ្ណោះ (ជនជាប់ចោទ គឺជាបុគ្គលដែលត្រូវចោទប្រកាន់ដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ)[38]។ វិធានផ្ទៃក្នុង ៨១ គ្រាន់តែតម្រូវឱ្យមានវត្តមានរបស់ជនជាប់ចោទ នៅក្នុងសវនាការបឋមនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងតែប៉ុណ្ណោះ ដូចបានបញ្ជាក់នៅក្នុងវិធាន ៨១(៤)។ វិធានផ្ទៃក្នុង ៨១(៣) បញ្ជាក់យ៉ាងច្បាស់ថា វត្តមានរបស់ជនជាប់ចោទនៅក្នុងសវនាការបឋមនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង គឺជាលក្ខខណ្ឌតម្រូវមួយដែលចាំបាច់ដើម្បីបន្តសវនាការជាបន្តបន្ទាប់។

៣៦. វិធានផ្ទៃក្នុង មិនមានចែងពីការដាក់កំហិតដូចគ្នានេះទេទាក់ទងនឹងដំណាក់កាលស៊ើបអង្កេតនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌនៅចំពោះមុខ អ.វ.ត.ក។ វិធានផ្ទៃក្នុង ៥៧ មិនដាក់បុរេ

---

[37] *សូមមើល* មាត្រា ៣៣៣, ៣៥៣, ៣៦១ និង ៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[38] *សូមមើល* សន្ទានុក្រមក្នុងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។

លក្ខខណ្ឌចាំបាច់ថា [ជនសង្ស័យ]ត្រូវតែវត្តមានជាក់ស្តែងដើម្បីឱ្យ ស.ច.ស. បន្តកិច្ចដំណើរការនីតិវិធីដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យទេ។ ទោះជាយ៉ាងណាក្តី វិធានផ្ទៃក្នុងមិនមានបទប្បញ្ញត្តិណាដែលចែងពីការដាក់ឱ្យស្ថិតក្រោមការពិនិត្យទៅលើជនសង្ស័យណាដែលបានបដិសេធមិនចូលបង្ហាញខ្លួនលើកដំបូងអនុលោមតាមវិធានផ្ទៃក្នុង ៥៧ ហើយក៏មិនអាចឱ្យចូលបង្ហាញខ្លួនតាមមធ្យោបាយបង្ខំដែរ។

៣៧. វិធានផ្ទៃក្នុងគឺជាប្រភពឯកសារចម្បងស្តីពីនីតិវិធីនៅ អ.វ.ត.ក ប៉ុន្តែនៅពេលដែលបញ្ហាណាមួយមិនមានចែងនៅក្នុងវិធានផ្ទៃក្នុង *នោះ* ស.ច.ស ត្រូវតែសម្រេចថាតើ បញ្ហានោះមានចែងនៅក្នុងច្បាប់កម្ពុជាដែរឬអត់[39]។ ស.ច.ស អាចស្វែងរកការណែនាំផ្នែកវិធានស្តីពីនីតិវិធីដែលបានបង្កើតឡើងនៅថ្នាក់អន្តរជាតិក្នុងករណីដែលក្នុងអំឡុងពេលស៊ើបអង្កេត មានបញ្ហាណាមួយកើតឡើង ហើយមិនមានចែងនៅក្នុងវិធានផ្ទៃក្នុង ឬក្នុងច្បាប់កម្ពុជា ក្នុងករណីដែលមានភាពមិនច្បាស់លាស់ទាក់ទងនឹងការបកស្រាយ ឬការអនុវត្ត ឬក៏ទាក់ទងនឹងសង្គតិភាពជាមួយបទដ្ឋានអន្តរជាតិ[40]។

៣៨. ដូច្នេះ នៅពេលដែលពិចារណាដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ស.ច.ស.អន្តរជាតិ នឹងពិនិត្យថាតើនីតិវិធីនេះមានចែងនៅក្នុងច្បាប់កម្ពុជាដែរឬអត់។ បន្ទាប់មក ប្រសិនបើចាំបាច់ ការណែនាំបន្ថែមទៀតនឹងត្រូវស្វែងរកទាក់ទងនឹងវិធានស្តីពីនីតិវិធីដែលបានបង្កើតឡើងនៅថ្នាក់អន្តរជាតិ។

## <u>ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា</u>

៣៩. ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនមានបទប្បញ្ញត្តិដែលចែងច្បាស់លាស់អំពីការដាក់ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*ទេ។ ទោះជាយ៉ាងណាក្តី ក្រមនេះអនុញ្ញាត ហើយក៏មានបទប្បញ្ញត្តិច្បាស់លាស់ដែលចែងអំពីការជំនុំជម្រះ និងការប្រកាសសាលក្រម*ដោយកំបាំងមុខ*

---

[39]សំណុំរឿង ០០២ ឯកសារ D55/I/8 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោកខ្លួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព* ថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០០៨ កថាខណ្ឌ ១៤-១៥។

[40]កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិជាមួយរាជរដ្ឋាភិបាលកម្ពុជា ("កិច្ចព្រមព្រៀង អ.វ.ត.ក") មាត្រា ១២(១)។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២៣ ថ្មី។ វិធាន ២ នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* សំណុំរឿង ០០១ ឯកសារ E188 សាលក្រម ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៥។

ដែរ[41]។ ក្នុងចំណោមបទប្បញ្ញត្តិទាំងនេះ មាត្រា ៣៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចំណងជើង *"ការស្វែងរកពិតក្នុងករណីអវត្តមានរបស់ជនជាប់ចោទ"* ចែងថា *"ទោះបីជាជនជាប់ចោទ អវត្តមានក៏ដោយ តុលាការត្រូវតែស្វែងរកឱ្យឃើញការពិត ស្តាប់ចម្លើយភាគីដទៃទៀត សាក្សី និងពិនិត្យវត្ថុតាង"*។ ការស្វែងរកការពិតក៏ជាភារកិច្ចចម្បងដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ ស.ច.ស នៅអំឡុងពេលស៊ើបអង្កេតនៅ អ.វ.ត.ក[42]។

៤០. ស.ច.ស.អន្តរជាតិ មិនអាចចូលពិនិត្យមើលឯកសារកំណត់ហេតុនៃកិច្ចដំណើរការនីតិវិធី *ដោយកំបាំងមុខ* នៅក្នុងតុលាការនៃព្រះរាជាណាចក្រកម្ពុជាទេ។ ទោះជាយ៉ាងណាក្តី ការត្រួតពិនិត្យមើលអត្ថបទសារព័ត៌មានដែលបានចេញផ្សាយរវាងឆ្នាំ ២០១០ ដល់ឆ្នាំ ២០១៤ បង្ហាញឱ្យឃើញថា តាមពិត កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ*ដោយកំបាំងមុខ* ត្រូវបានអនុវត្តនៅក្នុងតុលាការជាតិ[43]។ ស.ច.ស.អន្តរជាតិ ពឹងផ្អែកលើអត្ថបទសារព័ត៌មានទាំងនេះក្នុងគោលបំណងតែមួយគត់ដើម្បីបញ្ជាក់ថា កិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ* បានអនុវត្តនៅក្នុងប្រទេសកម្ពុជា។

៤១. ដោយផ្អែកលើក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងការអនុវត្តរបស់តុលាការ ស.ច.ស.អន្តរជាតិ ជឿជាក់ថា កិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ* ត្រូវបានអនុញ្ញាតតាមច្បាប់កម្ពុជា[44]។

---

[41] *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៣៣៣, ៣៥១, ៣៦១ និង ៣៦២។

[42] *សូមមើល* មាត្រា ២៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង ៥៥(៥)។

[43] ឌី ខែមបូឌា ដេលី *តុលាការកាត់ទោសមនុស្សប្រាំមួយនាក់ ប្រាំនាក់ដោយកំបាំងមុខ ចំពោះការធ្វើឃាតអ្នកសារព័ត៌មាន* ថ្ងៃទី១២ ខែ វិច្ឆិកា ឆ្នាំ ២០១៤៖ https://www.cambodiadaily.com/news/court-sentences-six-five-in-absentia-for-journalists-murder-72121/។ វិទ្យុអាស៊ីសេរី *តុលាការកម្ពុជា តម្កល់ទោសអតីតអភិបាលដែលរត់គេចខ្លួន* ថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១៣៖ http://www.rfa.org/english/news/cambodia/appeal-11042013143446.html។ សារព័ត៌មាន The New York Times *ប្រទេសកម្ពុជា៖ មេដឹកនាំគណបក្សប្រឆាំង ត្រូវបានផ្តន្ទាទោសដោយកំបាំងមុខ* ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១០៖ http://www.nytimes.com/2010/09/24/world/asia/24briefs-Cambodia.html?_r=0។ សារព័ត៌មាន South China Morning Post *អតីតអភិបាលនៅកម្ពុជាត្រូវបានដាក់ពន្ធនាគារដោយកំបាំងមុខដោយសារបាញ់កម្មកររោងចក្របីនាក់* ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៣៖

http://www.scmp.com/news/asia/article/1268733/ex-cambodian-official-convicted-absentia។

[44] សេចក្តីសន្និដ្ឋាននេះគឺស្របគ្នាជាមួយច្បាប់បារាំង ដែលទោះបីជាមិនអាចអនុវត្តបាននៅក្នុងកម្ពុជាក៏ដោយ ក៏អាចផ្តល់ជាការណែនាំដោយមានសារៈប្រយោជន៍ក្នុងការបកស្រាយក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមាន

01070813



៤២. ទោះបីជាការជំនុំជម្រះ*ដោយកំបាំងមុខ* អាចអនុវត្តបានតាមច្បាប់កម្ពុជាក៏ដោយ ក៏វិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនមានបទប្បញ្ញត្តិដែលចែងឱ្យបានច្បាស់អំពីការដាក់ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*នោះទេ។ អាស្រ័យហេតុនេះ ស.ច.ស.អន្តរជាតិនឹងស្វែងរកការណែនាំផ្នែកវិធានស្តីពីនីតិវិធីដែលបានបង្កើតឡើងនៅថ្នាក់អន្តរជាតិ។

<u>ភាពអាចទទួលយកកិច្ចដំណើរនីតិវិធី*ដោយកំបាំងមុខ*តាមច្បាប់សិទ្ធិមនុស្ស</u>

៤៣. យោងតាមមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ ១៩៦៦ ("ICCPR")[45] ជនជាប់ចោទមានសិទ្ធិមានវត្តមាននៅក្នុងការជំនុំជម្រះ ហើយមានសិទ្ធិការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់តាមការជ្រើសរើសរបស់ខ្លួន។ ទោះយ៉ាងណា នៅក្នុងកាលៈទេសៈពិសេស កិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ* អាចអនុវត្តបាន។ គណៈកម្មាធិការសិទ្ធិមនុស្ស បានសម្រេចថា សិទ្ធិមានវត្តមាននៅក្នុងការជំនុំជម្រះ៖

> "មិនអាចបកស្រាយក្នុងន័យ ដែលត្រូវតែធ្វើឱ្យកិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ* មិនអាចទទួលយកដោយមិនគិតដល់សំអាងហេតុដែលជនជាប់ចោទអវត្តមានឡើយ។ តាមពិត នៅក្នុងកាលៈទេសៈខ្លះ (ឧទាហរណ៍ នៅពេលដែលជនជាប់ចោទ ទោះបីជាត្រូវបានជូនដំណឹងជាមុនបានគ្រប់គ្រាន់អំពីកិច្ចដំណើរការនីតិវិធីយ៉ាងណា ក៏ដោយ

---

មូលដ្ឋានភាគច្រើនផ្អែកលើក្រមនីតិវិធីព្រហ្មទណ្ឌបារាំង)។ នៅប្រទេសបារាំង បន្ទាប់ពីការស្វែងរកត្រូវបានរាយការណ៍ថាគ្មានលទ្ធផលនោះ ជនសង្ស័យអាចត្រូវដាក់ឱ្យស្ថិតក្រោមការពិនិត្យដោយគ្មានវត្តមានគាត់។ *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ១៣៤៖ *"Si la personne ne peut être saisie, un procès-verbal de perquisition et de recherches infructueuses est adressé au magistrat qui a délivré le mandat. La personne est alors considérée comme mise en examen pour l'application de l'article 176".* *សូមមើល* មាត្រា ១៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង៖ *"Le juge d'instruction examine s'il existe contre la personne mise en examen des charges constitutives d'infraction, dont il détermine la qualification juridique".*

[45] មាត្រា ១៤ និង ១៥ នៃកតិកាសញ្ញា ICCPR អាចអនុវត្តដោយផ្ទាល់នៅ អ.វ.ត.ក អនុលោមតាមមាត្រា ១២(២)នៃកិច្ចព្រមព្រៀង អ.វ.ត.ក។ ព្រះរាជាណាចក្រកម្ពុជា ក៏ជាភាគីនៅក្នុងកតិកាសញ្ញា ICCPR ដែរ ដែលកម្ពុជាបានផ្តល់សច្ចាប័ននៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩២។

ប៉ុន្តែនៅតែបដិសេធមិនប្រើប្រាស់សិទ្ធិមានវត្តមាន) កិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ*អាចអនុវត្តបានដើម្បីជាប្រយោជន៍ដល់កិច្ចការរដ្ឋបាលតុលាការឲ្យបានត្រឹមត្រូវ"[46]។

៤៤. គណៈកម្មាធិការសិទ្ធិមនុស្ស ក៏បានបញ្ជាក់ថា "*នៅពេលដែលការជំនុំជម្រះដោយកំបាំងមុខត្រូវបានធ្វើឡើងក្នុងករណីពិសេស ដោយសារមានសំអាងហេតុប្រកបដោយយុត្តិកម្មនោះ អ្វីទាំងអស់ដែលចាំបាច់ជាងនេះគឺត្រូវគោរពដាច់ខាតនូវសិទ្ធិការពារក្តី*"[47]។

៤៥. កិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ*ស្របគ្នាជាមួយច្បាប់សិទ្ធិមនុស្ស ក៏ត្រូវបានបញ្ជាក់ផងដែរដោយតុលាការសិទ្ធិមនុស្សអឺរ៉ុប[48] ដែលបានសង្កត់ធ្ងន់ថា នៅពេលដែលជនណាម្នាក់ត្រូវបានជំនុំជម្រះ*ដោយកំបាំងមុខ* គាត់គួរតែមានតំណាងមេធាវីគ្រប់គ្រាន់ និងទទួលបានការការពារប្រកបដោយប្រសិទ្ធភាព[49]។

<u>វិធានស្តីពីនីតិវិធីដែលបានង្កើតនៅថ្នាក់អន្តរជាតិ</u>

*ក. តុលាការពិសេសសម្រាប់លីបង់*

៤៦. មាត្រា ១៦ នៃលក្ខន្តិកៈរបស់តុលាការពិសេសសម្រាប់លីបង់("STL")ចែងថា ជនជាប់ចោទមានសិទ្ធិ "*ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន និងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់តាមការជ្រើសរើសរបស់ខ្លួន[...]*"[50]។ លក្ខន្តិកៈរបស់តុលាការ STL

---

[46] គណៈកម្មាធិការសិទ្ធិមនុស្ស រឿងក្តី *Daniel Monguya តទល់នឹង Zaire* អង្គការសហប្រជាជាតិ ឯកសារ CCPR/C/18/D/16/1977 ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៨៣ កថាខណ្ឌ ១៤.១។

[47] គណៈកម្មាធិការសិទ្ធិមនុស្ស មតិយោបល់រួម ១៣ មាត្រា ១៤ (សម័យប្រជុំលើកទី ២១ ឆ្នាំ ១៩៨៤) កថាខណ្ឌ ១១។

[48] *សូមមើល* តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Sejdovic តទល់នឹងអ៊ីតាលី* ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០០៦ កថាខណ្ឌ ៨៦។

[49] *សូមមើល* តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Lala តទល់នឹងហូឡង់* ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៤ កថាខណ្ឌ ៣៣។ *សូមមើលផងដែរ* តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Krombach តទល់នឹងបារាំង* ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០១ កថាខណ្ឌ ៨៤។ តុលាការសិទ្ធិមនុស្សអឺរ៉ុប បានបន្ថែមថា *"សារៈសំខាន់'ជាចាំបាច់'នៃការការពារជនជាប់ចោទ គួរតែសំខាន់ជាងសារៈសំខាន់ 'ជាគោលការណ៍'នៃការបង្ហាញខ្លួនរបស់ជនជាប់ចោទនៅក្នុងជំនុំជម្រះ"*។ *សូមមើល* តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Sejdovic តទល់នឹងអ៊ីតាលី* ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០០៦ កថាខណ្ឌ ៦៩។

[50] លក្ខន្តិកៈរបស់តុលាការ STL មាត្រា ១៦។

ក៏អនុញ្ញាតឱ្យមានលទ្ធភាពនៃការរៀបចំការជំនុំជម្រះ*ដោយកំបាំងមុខ* តាមលក្ខខណ្ឌមួយចំនួនផងដែរ[51]។

៤៧. មាត្រា២២(១)នៃលក្ខន្តិកៈរបស់តុលាការ STL ចែងថា កិច្ចដំណើរការនីតិវិធីជំនុំជម្រះដោយគ្មានវត្តមានរបស់ជនជាប់ចោទ អាចអនុវត្តបាននៅពេលដែលលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌខាងក្រោមត្រូវបានបំពេញ៖

"ក) ជនជាប់ចោទ បានបង្ហាញយ៉ាងច្បាស់ និងមានជាលាយលក្ខណ៍អក្សរថា គាត់បានលះបង់សិទ្ធិមានវត្តមានរបស់គាត់។

ខ) ជនជាប់ចោទមិនទាន់ត្រូវបានប្រគល់ជូនតុលាការ ពីអាជ្ញាធរពាក់ព័ន្ធរបស់រដ្ឋ ឬ

គ) ជនជាប់ចោទ បានរត់គេច ឬមិនអាចរកឃើញ ហើយវិធានការសមហេតុផលទាំងអស់ត្រូវបានអនុវត្តរួចហើយដើម្បីធានាថា គាត់បានចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ និងដើម្បីជូនដំណឹងគាត់ អំពីបទចោទប្រកាន់ដែលបានបញ្ជាក់ដោយចៅក្រមបុរេជំនុំជម្រះ"[52]។

៤៨. យោងតាមមាត្រា ២២(២)នៃលក្ខន្តិកៈរបស់តុលាការ STL នៅពេលដែលសវនាការត្រូវបានធ្វើឡើងដោយគ្មានវត្តមានរបស់ជនជាប់ចោទ តុលាការ STL ត្រូវតែធានាថា៖

"ក) ជនជាប់ចោទ ត្រូវបានជូនដំណឹង ឬត្រូវបានប្រគល់ជូននូវដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬការជូនដំណឹងអំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានចេញផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ឬតាមរយៈការផ្សព្វផ្សាយទៅរដ្ឋដែលជនជាប់ចោទស្នាក់នៅ ឬមានសញ្ជាតិ។

[51] លក្ខន្តិកៈរបស់តុលាការ STL មាត្រា ២២។ វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ STL វិធាន ១០៥*ស្ទួន*។

[52] លក្ខន្តិកៈរបស់តុលាការ STL មាត្រា ២២។ វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ STL វិធាន ១០៦។

ខ) ជនជាប់ចោទ បានតែងតាំងមេធាវីការពារក្តីតាមការជ្រើសរើសរបស់ខ្លួន ដែលការចំណាយត្រូវរ៉ាប់រងដោយជនជាប់ចោទ ឬដោយតុលាការ ប្រសិនបើជនជាប់ចោទត្រូវបានបញ្ជាក់ថាជាជនក្រីក្រ។

គ) នៅពេលណាដែលជនជាប់ចោទ បដិសេធមិនតែងតាំង ឬខកខានមិនបានតែងតាំងមេធាវីការពារក្តី មេធាវីការពារក្តីបែបនោះត្រូវបានចាត់តាំងដោយការិយាល័យការពារក្តីរបស់តុលាការ ដើម្បីធានាថា ប្រយោជន៍ និងសិទ្ធិរបស់ជនជាប់ចោទមានតំណាងពេញលេញ"។

៤៩. វិធាន ១០៦(ក)នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ STL គឺដូចគ្នានឹងមាត្រា ២២(១) នៃលក្ខន្តិកៈរបស់តុលាការ STL។ វិធាន ១០៦(ខ) ចែងថា ក្នុងករណីដែលជនជាប់ចោទអវត្តមានដោយសារការខកខាន ឬការបដិសេធរបស់រដ្ឋមិនប្រគល់ជនជាប់ចោទនោះ មុនពេលសម្រេចអនុវត្តកិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ* អង្គជំនុំជម្រះសាលាដំបូងត្រូវតែ៖

ក) ប្រឹក្សាជាមួយប្រធាន និងធានាថា វិធានការចាំបាច់ទាំងអស់ត្រូវបានអនុវត្តរួចហើយដើម្បីធានាថា ជនជាប់ចោទអាចចូលរួមកិច្ចដំណើរការនីតិវិធីនេះក្នុងរបៀបដែលសមស្របបំផុត ហើយ

ខ) ធានាថា លក្ខខណ្ឌតម្រូវនៃមាត្រា ២២(២)នៃលក្ខន្តិកៈត្រូវបានបំពេញ។

៥០. នៅក្នុងការអនុវត្តតាមលក្ខខណ្ឌទាំងនេះ អង្គជំនុំជម្រះសាលាដំបូងនៃ តុលាការ STL បានចេញសេចក្តីសម្រេចចំនួនពីរដើម្បីរៀបចំសវនាការ*ដោយកំបាំងមុខ*។ អង្គជំនុះជម្រះសាលាដំបូង បានជឿជាក់ថា ជនជាប់ចោទ "*បានរត់គេច ឬមិនអាចរកឃើញ ហើយវិធានការសមហេតុផលទាំងអស់ត្រូវបានអនុវត្តរួចហើយដើម្បីធានាថា [ពួកគាត់]បានចូលបង្ហាញខ្លួន[...] និងដើម្បីជូនដំណឹង[ពួកគាត់]អំពីបទចោទប្រកាន់[...]*"[53]។ ដូច្នេះ នៅក្នុងរឿងក្តី *រដ្ឋអាជ្ញា*

[53] *សូមមើល* រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Ayyash និងអ្នកផ្សេងទៀត* សំណុំរឿងលេខ STL-11-01/I/TC សេចក្តីសម្រេចរៀបចំសវនាការ*ដោយកំបាំងមុខ* ថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១០៧-១១០។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Merhi* សំណុំរឿងលេខ STL-13-04/I/TC *សេចក្តីសម្រេចរៀបចំសវនាការដោយកំបាំងមុខ* ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៣ កថាខណ្ឌ ៤ និង ១១១។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Ayyash និងអ្នកផ្សេងទៀត* សំណុំរឿងលេខ STL-11-O1/PT/AC/ARI26.1 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្តីប្រឆាំងនឹង*

*តទល់នឹង Ayyash និងអ្នកផ្សេងទៀត* អង្គជំនុំជម្រះបានសម្រេចថា ជនជាប់ចោទទាំងបួននាក់ *"មិនមានបំណងចូលរួមសវនាការទេ"*[54] ហើយនៅក្នុងរឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Merhi* អង្គជំនុំជម្រះបានយល់ឃើញថា ជនជាប់ចោទ *"ប្រាកដជាបានជ្រើសរើសសម្រេចមិនចូលរួមសវនាការទេ ដូច្នេះគាត់បានលះបង់សិទ្ធិមានវត្តមានរបស់គាត់"*[55]។

*ខ. តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ("ICTY") និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដា ("ICTR")*

៥១. វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY និង ICTR អនុញ្ញាតឱ្យមានកិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ* ក្នុងករណីដែលមានការខកខានមិនបានអនុវត្តដីកានាំខ្លួន[56]។ វិធានការបែបនេះត្រូវយកមកប្រើប្រាស់ប្រសិនបើ *"វិធានការសមហេតុផលទាំងអស់"*ត្រូវបានអនុវត្តរួចហើយដើម្បីធានាថា ជនជាប់ចោទត្រូវបាននាំខ្លួន និងដើម្បីស្វែងរកកន្លែងលាក់ខ្លួនរបស់គាត់[57]។ អង្គជំនុំជម្រះសាលាដំបូងនៅតុលាការ ICTY បានបង្ហាញពីសារៈសំខាន់នៃយន្តការបែបនេះ ដោយសង្កត់ធ្ងន់ថា *"យុត្តិធម៌ឧក្រិដ្ឋកម្មអន្តរជាតិ ដែលមិនអាចសម្របតាមការខកខានរបស់បុគ្គល ឬរដ្ឋនានានោះទេ គឺត្រូវតែបន្តបេសកកម្មរបស់ខ្លួនក្នុងការលាតត្រដាង*

---

*សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការពិចារណាឡើងវិញលើសវនាការដោយកំបាំងមុខ* ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១២ កថាខណ្ឌ ៤៦, ៥១។

[54] រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Ayyash និងអ្នកផ្សេងទៀត* សំណុំរឿងលេខ STL-11-01/I/TC *សេចក្តីសម្រេចរៀបចំសវនាការដោយកំបាំងមុខ* ថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១១១។

[55] រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Merhi* សំណុំរឿងលេខ STL-13-04/I/TC *សេចក្តីសម្រេចរៀបចំសវនាការដោយកំបាំងមុខ* ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៣ កថាខណ្ឌ ១០៣-១០៩។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Ayyash និងអ្នកផ្សេងទៀត* សំណុំរឿងលេខ STL-11-O1/PT/AC/ARI26.1 *ខាងលើ* កថាខណ្ឌ ៣១។

[56]នេះរួមបញ្ចូលទាំងការបញ្ជាក់ឡើងវិញអំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងលទ្ធភាពដែលរដ្ឋអាជ្ញាអាចផ្តល់ភស្តុតាងគាំទ្រ ឬភស្តុតាងបន្ថែម។ សវនាការបែបនេះមានបំណងសម្រេចលើភាពគ្រប់គ្រាន់នៃភស្តុតាងបឋមដែលដាក់ដោយរដ្ឋអាជ្ញា និងដើម្បីសម្រេចថាតើមានមូលដ្ឋានសមហេតុផលដែលជឿថា ជនជាប់ចោទ បានប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយ ឬឧក្រិដ្ឋកម្មទាំងអស់ដែលបានចោទ។ *សូមមើល* A/51/292។ S/1996/665 របាយការណ៍មហាសន្និបាត លើកទី ២១ របស់តុលាការ ICTY ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ១៩៩៦ កថាខណ្ឌ ៥០-៦១។

[57] វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តលាការ ICTY និង ICTR វិធាន ៦១។

*ការពិតអំពីអំពើដែលបានប្រព្រឹត្ត និងទុក្ខលំបាកដែលបានទទួលរង ព្រមទាំងរកអត្តសញ្ញាណ និងនាំខ្លួនជនដែលត្រូវបានចោទថាជាអ្នកទទួលខុសត្រូវ*”[58]។

*គ. តុលាការព្រហ្មទណ្ឌអន្តរជាតិ(“ICC”)*

៥២. មាត្រា ៦១(២)នៃលក្ខន្តិកៈក្រុងរ៉ូមរបស់តុលាការ ICC វិធាន ១២៥ នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICC អនុញ្ញាតឱ្យមានការបញ្ជាក់អំពីសវនាការស្តីពីបទចោទប្រកាន់ *ដោយកំបាំងមុខ* ប្រសិនបើជនជាប់ចោទ“*បានលះបង់សិទ្ធិមានវត្តមានរបស់គាត់*”ជាលាយលក្ខណ៍អក្សរ ឬ“*បានគេចខ្លួន ឬមិនអាចរកឃើញ ហើយវិធានការសមហេតុផលទាំងអស់ត្រូវបានអនុវត្តរួចហើយដើម្បីធានាថាគាត់បានចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ និងដើម្បីជូនដំណឹងគាត់អំពីបទចោទប្រកាន់ ហើយសវនាការដើម្បីបញ្ជាក់អំពីការចោទប្រកាន់ទាំងនោះនឹងត្រូវរៀបចំធ្វើឡើង*”[59]។

<u>សេចក្តីសន្និដ្ឋាន</u>

៥៣. ដោយផ្អែកលើការពិនិត្យមើលច្បាប់កម្ពុជា និងវិធានស្តីពីនីតិវិធី និងភស្តុតាងដែលបានបង្កើតឡើងនៅថ្នាក់អន្តរជាតិ និងដោយបានពិចារណាលើភាពខុសគ្នានៅក្នុងនីតិវិធីដែលអាចអនុវត្តបាននៅ អ.វ.ត.ក និងនៅតុលាការអន្តរជាតិក្នុងករណីដែលវិធានស្តីពីនីតិវិធីទាំងនេះបានបង្កើតឡើងនោះ ស.ច.ស.អន្តរជាតិ សន្និដ្ឋានថា៖

ក) វិធានផ្ទៃក្នុង ខណៈដែលចែងអំពីដំណើរការដាក់ឱ្យស្ថិតក្រោមការពិនិត្យដោយមានវត្តមានរបស់ជនសង្ស័យយ៉ាងណាក៏ដោយ ក៏មិនតម្រូវថា វត្តមានរបស់ជនសង្ស័យនៅក្នុងការបង្ហាញខ្លួនលើកដំបូង គឺជាបុរេលក្ខខណ្ឌមួយ

---

[58] រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង* *Radovan Karadžić* *និង* *Ratko Mladić* សំណុំរឿងលេខ IT-95-5-R61 និងសំណុំរឿងលេខ IT-95-18-R61 ការពិនិត្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ អនុលោមតាមវិធាន ៦១ នៃវិធានស្តីពីនីតិវិធី និងភស្តុតាង ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៩៦ កថាខណ្ឌ ៣។

[59] លក្ខន្តិកៈក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា ៦១(២)។ វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុការ ICC វិធាន ១២៤(១)។ *សូមមើល* រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Abdallah Banda Abaer Nourain* *និង* *Saleh Mohammed Jerbo Jamus* សំណុំរឿងលេខ ICC-02/05-03/09 សេចក្តីសម្រេចលើបញ្ហាទាក់ទងនឹងសវនាការស្តីពីការបញ្ជាក់អំពីបទចោទប្រកាន់ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១០។

ដែលចាំបាច់ដើម្បីបន្តកិច្ចដំណើរការនីតិវិធីដាក់ឱ្យស្ថិតក្រោមការពិនិត្យទេ។ វិធានផ្ទៃក្នុង មិនមានចែងអំពីនីតិវិធីដែលត្រូវអនុវត្តនៅពេលដែលដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យ ដែលជនសង្ស័យនោះខកខានមិនបានចូលរួមក្នុងការបង្ហាញខ្លួនលើកដំបូង។

ខ) កិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ* ត្រូវបានអនុញ្ញាតតាមច្បាប់កម្ពុជា។

គ) កិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ* អាចទទួលយកតាមច្បាប់សិទ្ធិមនុស្សនៅក្នុងកាលៈទេសៈមួយចំនួន ដូចជា ជនដែលអាចស្ថិតនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌបានបដិសេធមិនចូលបង្ហាញខ្លួន នៅចំពោះមុខតុលាការមានសមត្ថកិច្ច។

ឃ) វិធានស្តីពីនីតិវិធីដែលបានបង្កើតឡើងនៅថ្នាក់អន្តរជាតិ អនុញ្ញាតឱ្យមានកិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ*នៅពេលដែលជនណាម្នាក់ បានបង្ហាញយ៉ាងច្បាស់ និងមានជាលាយលក្ខណ៍អក្សរថាបានលះបង់សិទ្ធិមានវត្តមានរបស់គាត់ ឬនៅពេលដែលវិធានការសមហេតុផលទាំងអស់ត្រូវបានអនុវត្តរួចហើយដើម្បីធានាថា គាត់បានចូលបង្ហាញខ្លួននៅចំពោះមុខតុលាការមានសមត្ថកិច្ច និងដើម្បីជូនដំណឹងគាត់ អំពីបទចោទប្រកាន់ ប៉ុន្តែ កិច្ចខិតខំប្រឹងប្រែងទាំងនោះមិនបានទទួលជោគជ័យ។

ង) នៅពេលដែលរៀបចំកិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ* តុលាការចាំបាច់ត្រូវតែធានាថា ជនជាប់ចោទ ឬជនត្រូវចោទដែលអវត្តមាន មានតំណាងគ្រប់គ្រាន់ និងប្រកបដោយប្រសិទ្ធភាព។

៥៤. អាស្រ័យហេតុ ស.ច.ស.អន្តរជាតិ ជឿជាក់ថា ច្បាប់ដែលអាចអនុវត្តបាននៅ អ.វ.ត.ក អនុញ្ញាតឱ្យដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*នៅពេលដែលជនសង្ស័យបានបដិសេធមិនចូលបង្ហាញខ្លួនលើកដំបូងអនុលោមវិធានផ្ទៃក្នុង ៥៧ និងនៅពេលដែលកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់មកទៀតដើម្បីធានាថាជនសង្ស័យមានវត្តមាន មិនបានទទួលលទ្ធផល។

**ការពិភាក្សា**

**ការបំពេញតាមលក្ខខណ្ឌតម្រូវផ្លូវច្បាប់ដើម្បីដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ***

<u>មាស មុត បានដឹងឮពីកាលបរិច្ឆេទ និងពេលវេលានៃការបង្ហាញខ្លួនលើកដំបូងរបស់គាត់</u>

៥៥. ស.ច.ស.អន្តរជាតិ បានសម្រេចថា មានភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា មាស មុត អាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មមួយចំនួន ដែលបានចោទនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[60]។ ហេតុនេះ នៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ស.ច.ស.អន្តរជាតិ បានចេញដីកាកោះដែលបានប្រគល់ជូន មាស មុត ដោយផ្ទាល់ នៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤។ សហមេធាវីរបស់ មាស មុត ក៏ត្រូវបានជូនដំណឹង និងកោះហៅឱ្យចូលរួមការបង្ហាញខ្លួនលើកដំបូងដែលបានគ្រោងទុកនេះដែរ។

៥៦. នៅថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៤ ជនសង្ស័យ បានជូនដំណឹង ស.ច.ស.អន្តរជាតិ ជាលាយលក្ខណ៍អក្សរថា គាត់មិនទទួលស្គាល់ថា ដីកាកោះដែលបានចុះហត្ថលេខាដោយ ស.ច.ស ម្នាក់ មានសុពលភាពទេ ហើយក៏បានលើកឡើងម្តងទៀតនូវសំណើសុំចូលពិនិត្យមើលសំណុំរឿងតាមរយៈសហមេធាវីចាត់តាំងរបស់គាត់។

៥៧. តាមរយៈការជូនដំណឹងរបស់សហមេធាវី ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៤ គឺបង្ហាញច្បាស់ថា សហមេធាវី បានទាក់ទង មាស មុត និងបានទទួលការណែនាំពីគាត់ទាក់ទងនឹងការបង្ហាញខ្លួនលើកដំបូងដែលបានគ្រោងទុកនេះ។ ជាការកត់សម្គាល់ សហមេធាវីបានជូនដំណឹង ស.ច.ស.អន្តរជាតិ ថា មាស មុត មិនមានបំណងគោរពតាមដីកាកោះទេ ប៉ុន្តែថា សហមេធាវីនឹងចូលរួមសវនាការបង្ហាញខ្លួនលើកដំបូងដែលគ្រោងធ្វើឡើងនៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៤។

៥៨. ទោះបីជា ទាំង ស.ច.ស.អន្តរជាតិ ទាំង អ.ប.ជ បានបញ្ជាក់អំពីសុពលភាពនៃដីកាកោះដែលចេញដោយ ស.ច.ស តែម្នាក់ក៏ដោយ ក៏ មាស មុត នៅតែបន្តធ្វើតាមការបកស្រាយរបស់ខ្លួនទៅលើវិធានស្តីពីនីតិវិធីទាំងមានការភ័ន្តច្រឡំ និងដើម្បីជាប្រយោជន៍ខ្លួនឯង ដើម្បីជាលេស

---

[60] *សូមមើល* ការជូនដំណឹងអំពីបទចោទប្រកាន់ ភ្ជាប់ជាមួយដីកាសម្រេចនេះ។

មិនចូលបង្ហាញខ្លួនលើកដំបូង។ សវនាការបង្ហាញខ្លួនលើកដំបូងបានធ្វើឡើងនៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៤ ហើយបានចូលរួមដោយសហមេធាវីជាតិ និងអ្នកប្រឹក្សាច្បាប់ជាន់ខ្ពស់របស់ មាស មុត។

៥៩. ស.ច.ស.អន្តរជាតិ ជឿជាក់ថា កាលទេសៈទាំងនេះបង្ហាញយ៉ាងច្បាស់ថា មាស មុត ត្រូវបានជូនដំណឹងអំពីការបង្ហាញខ្លួនលើកដំបូងដែលគ្រោងធ្វើឡើងនៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៤ ប៉ុន្តែមានចេតនា និងមានបំណងមិនចូលបង្ហាញខ្លួន ដូច្នេះបានលះបង់សិទ្ធិមានវត្តមានរបស់ខ្លួន។ ស.ច.ស.អន្តរជាតិ ក៏ជឿជាក់ថា មាស មុត បានបង្ហាញយ៉ាងច្បាស់ថា គាត់មិនមានចេតនាចូលបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក នៅថ្ងៃណាមួយនោះទេ។

**វិធានការដើម្បីធានាថា មាស មុត បានចូលបង្ហាញខ្លួន មិនបានទទួលជោគជ័យ**

៦០. នៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤ ដោយអនុលោមតាមមាត្រា ២៥(គ)នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងវិធាន ១៥ នៃវិធានផ្ទៃក្នុង និងបន្ទាប់ពី មាស មុត មានចេតនាមិនបានចូលបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក នោះ ស.ច.ស អន្តរជាតិ បានចេញដីកានាំខ្លួន ដែលក្នុងនោះគាត់បានបង្គាប់ឱ្យនគរបាលយុត្តិធម៌ នាំខ្លួន មាស មុត មកបង្ហាញខ្លួននៅចំពោះមុខគាត់សម្រាប់ការបង្ហាញខ្លួនលើកដំបូង។

៦១. រវាងថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៤ និងកាលបរិច្ឆេទនៃដីកាសម្រេចនេះ ស.ច.ស.អន្តរជាតិ បានទាក់ទងនគរបាលយុត្តិធម៌ ដោយស្នើសុំបច្ចុប្បន្នភាពអំពីការអនុវត្តដីកានាំខ្លួនជនសង្ស័យម្នាក់ទៀត។

៦២. រវាងថ្ងៃទី ១១ និងថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៤ បុគ្គលិករបស់ ក.ស.ច.ស រួមទាំង ស.ច.ស.អន្តរជាតិ បានអនុវត្តកម្មវិធីផ្សព្វផ្សាយចំនួនប្រាំបួនដាក់ដោយឡែកគ្នានៅក្នុងតំបន់នានាតាមការណែនាំពីអាជ្ញាធរកម្ពុជា រាប់បញ្ចូលទាំងស្រុកដែល មាស មុត រស់នៅផងដែរ។

៦៣. នៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៤ តំណាងម្នាក់របស់នគរបាលយុត្តិធម៌ បានជូនដំណឹង បុគ្គលិករបស់ ក.ស.ច.ស ថា គាត់មិនអាចផ្តល់ការប៉ាន់ស្មានគួរឱ្យទុកចិត្តបានថាតើដីកានាំខ្លួននឹងត្រូវអនុវត្តនៅពេលណានោះទេ។ គាត់បានបញ្ជាក់ទៀតថា សេចក្តីសម្រេចចុងក្រោយថាតើដីកានាំខ្លួននឹងត្រូវអនុវត្តនៅពេលណានោះគឺស្ថិតនៅលើគណៈកម្មការសន្តិសុខប្រចាំ អ.វ.ត.ក។

៦៤. នៅថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥ ស.ច.ស.អន្តរជាតិ បានផ្ញើលិខិតមួយច្បាប់ជូនទៅប្រធានគណៈកម្មការសន្តិសុខប្រចាំ អ.វ.ត.ក ដោយជូនដំណឹងគាត់ថា ប្រសិនបើ មាស មុត មិនចូលបង្ហាញខ្លួន ឬមិនត្រូវបាននាំមកបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក នៅត្រឹមថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥នោះទេ ស.ច.ស.អន្តរជាតិ នឹងបន្តកិច្ចដំណើរការនីតិវិធីដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*[61]។

៦៥. ស.ច.ស.អន្តរជាតិ មិនបានទទួលការឆ្លើយតបទៅនឹងលិខិតដែលបានផ្ញើជូនប្រធានគណៈកម្មការសន្តិសុខប្រចាំ អ.វ.ត.ក ទេ។ កាលបរិច្ឆេទថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ ដែលបានកំណត់នៅក្នុងលិខិតខាងលើនោះ បានកន្លងផុតហើយ ដោយមាស មុត មិនបានចូលបង្ហាញខ្លួននៅ អ.វ.ត.ក ហើយ នគរបាលយុត្តិធម៌ ក៏មិនបានអនុវត្តដីកានាំខ្លួនដែរ។ ស.ច.ស.អន្តរជាតិ កត់សម្គាល់ថា ដីកានាំខ្លួននៅតែមានជាធរមាន។

៦៦. ស.ច.ស.អន្តរជាតិ ជឿជាក់ថា មាស មុត មិនលាក់ខ្លួនទេ នគរបាលយុត្តិធម៌ដឹងពីទីកន្លែងដែល មាស មុត ស្នាក់នៅ នគរបាលយុត្តិធម៌ មានមធ្យោបាយជាក់ស្តែងដើម្បីអនុវត្តដីកានាំខ្លួន ហើយ នគរបាលយុត្តិធម៌ មិនបានបំពេញការទទួលខុសត្រូវដែលបានកំណត់ដោយកិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង។ ដូច្នេះ ស.ច.ស.អន្តរជាតិ ជឿជាក់ថា វិធានការសមហេតុផលទាំងអស់ត្រូវបានអនុវត្តរួចហើយដើម្បីធានាថា មាស មុត បានចូលបង្ហាញខ្លួននៅ អ.វ.ត.ក សម្រាប់ការបង្ហាញខ្លួនលើកដំបូងដោយអនុលោមតាមវិធាន ៥៧ នៃវិធានផ្ទៃក្នុង។

៦៧. ដូច្នេះ ស.ច.ស.អន្តរជាតិ យល់ឃើញថា លក្ខខណ្ឌតម្រូវផ្នែកច្បាប់ទាំងអស់ដើម្បីដាក់ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ត្រូវបានបំពេញរួចហើយ។

---

[61] ការប្រាស្រ័យទាក់ទងទាំងនេះត្រូវបានសង្ខេបនៅក្នុងផ្នែកប្រវត្តិនីតិវិធីនៃដីកាសម្រេចនេះ។

**ការពិចារណាផ្សេងទៀតដែលតម្រូវថា មាស មុត ត្រូវដាក់ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ***

៦៨. ជនសង្ស័យ មិនមែនជាភាគីនៅក្នុងកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០៣ ទេ។ ដូច្នេះ ជនសង្ស័យ មិនមានសិទ្ធិចូលពិនិត្យមើលសំណុំរឿង ចូលរួមការស៊ើបអង្កេតរបស់តុលាការ[62] តទល់ជាមួយសាក្សី[63] ឬក៏ស្នើឱ្យ ស.ច.ស ដាក់ពាក្យសុំមោឃភាពកិច្ចស៊ើបសួរទៅ អ.ប.ជ ទេ[64]។ ជនសង្ស័យ អាចប្រើប្រាស់សិទ្ធិទាំងនេះបាន លុះត្រាតែជនសង្ស័យត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យ។ ស.ច.ស.អន្តរជាតិ អាចចេញការជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរបានតែពេលណា ភាគីទាំងអស់ រួមបញ្ចូលទាំងជនត្រូវចោទ មានឱកាសចូលរួមដំណើរការស៊ើបអង្កេត និងនៅពេលណាដែល ស.ច.ស ពិចារណាថា កិច្ចស៊ើបសួរបានបញ្ចប់[65]។ ការជូនដំណឹងបែបនេះនាំឱ្យមានវិធានការនីតិវិធីបន្ថែមទៀត ដែលចុងក្រោយបំផុតនឹងនាំឱ្យមានការចេញដីកាដំណោះស្រាយដែលអាចជាដីកាលើកលែងការចោទប្រកាន់ ឬក៏ជាដីកាចោទប្រកាន់ ហើយបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ[66]។

៦៩. ការខកខានដោយចេតនារបស់ មាស មុត ដែលមិនបានចូលបង្ហាញខ្លួនលើកដំបូង ឬក៏ការខកខានរបស់នគរបាលយុត្តិធម៌ ដែលមិនបានអនុវត្តដីកានាំខ្លួនឱ្យបានឆាប់រហ័សដោយឥតពន្យារពេលយូរហួសដើម្បីនាំគាត់មកបង្ហាញខ្លួននៅចំពោះមុខតុលាការនោះ មិនអាចបណ្ដោយឱ្យដំណើរការស៊ើបអង្កេតរបស់តុលាការជាប់គាំងទេ បើមិនអញ្ចឹងទេ វានឹងរារាំង ស.ច.ស មិនឱ្យអនុវត្តការទទួលខុសត្រូវរបស់ខ្លួនក្នុងការបំពេញកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៣ ឱ្យបានចប់។ ទង្វើបែបនេះនឹងធ្វើឱ្យ មាស មុត និងនគរបាលយុត្តិធម៌ មានសមត្ថភាពអាច

---

[62] *សូមមើល* វិធានផ្ទៃក្នុង ៥៥(៦) និង ៥៥(១០) និងសន្ទានុក្រមនៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* សំណុំរឿង ០០៤ ឯកសារ D121/4 *សេចក្ដីសម្រេចលើណើរបស់ក្រុមមេធាវីការពារក្ដី[កោសលុប]សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត* ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៦-៣៨។

[63] *សូមមើល* វិធានផ្ទៃក្នុង ៦០(២)។

[64] *សូមមើល* វិធានផ្ទៃក្នុង ៧៦(២)។ *សូមមើលផងដែរ* សំណុំរឿង ០០៤ ឯកសារ D207/1 *ដីកាសម្រេចលើសំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម ស្នើសុំឱ្យបញ្ជូនសំណើសុំមោឃភាពដីកាកោះហៅអ្នកស្រី និងសហមេធាវីការពារក្ដីគាត់ទៅអង្គបុរេជំនុំជម្រះ* ថ្ងៃទី១៨ ខែសីហា ឆ្នាំ ២០១៤។ សំណុំរឿង ០០៤ ឯកសារ *ដីកាសម្រេចលើញត្តិ[កោសលុប] សុំមោឃភាពកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៧៦នៃវិធានផ្ទៃក្នុង* ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤ កថាខណ្ឌ ៣៣។

[65] *សូមមើល* វិធានផ្ទៃក្នុង ៦៦។

[66] *សូមមើល* វិធានផ្ទៃក្នុង ៦៧។

កំណត់ថាតើ កិច្ចស៊ើបសួររបស់តុលាការនៅ អ.វ.ត.ក អាចដំណើរការបាន ឬអត់ ហើយទង្វើបែបនេះនឹងរារាំងគោលបំណងនៃច្បាប់ ដែលត្រូវវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តរវាងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩។

៧០. ការពន្យារពេលបន្ថែមទៀតក៏នឹងធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ មាស មុត ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ក្នុងនោះរួមទាំងសិទ្ធិមានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់ក្នុងការចូលរួមកិច្ចស៊ើបសួរ និងរៀបចំការការពារខ្លួន សិទ្ធិស្នើសុំឲ្យមានការចូលរួមពីសាក្សីតាមរយៈការដាក់សំណើសុំបំពេញកិច្ចស៊ើបសួរទៅ ស.ច.ស និងសិទ្ធិទទួលបានថិរវេលាសមហេតុផលសម្រាប់កិច្ចដំណើរការនីតិវិធីប្រឆាំងគាត់[67]។

៧១. បន្ថែមពីលើនេះទៀត ការពន្យារពេលបន្ថែមទៀតរបស់នគរបាលយុត្តិធម៌ក្នុងការនាំខ្លួន មាស មុត មកបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក ឬក៏ការខកខានមិននាំខ្លួនគាត់ នឹងធ្វើឲ្យប៉ះពាល់ដល់សិទ្ធិជនរងគ្រោះ និងប្រជាជនកម្ពុជា ហើយអាចនាំឲ្យមិនមានការគោរពដល់ អ.វ.ត.ក ដែលជាផ្នែកមួយដ៏ពិសេស និងសំខាន់នៅក្នុងប្រព័ន្ធតុលាការកម្ពុជា។

## សេចក្តីសន្និដ្ឋាន

៧២. ដោយពិចារណាថា មានភាពមិនច្បាស់លាស់ទាល់តែសោះថាតើដីកានាំខ្លួននឹងត្រូវអនុវត្តនៅពេលណា ហើយត្រូវអនុវត្តឬអត់នោះ ស.ច.ស.អន្តរជាតិ យល់ឃើញថា ការដាក់ មាស មុត ឲ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* គឺជាវិធីតែមួយគត់ដើម្បីធានាថា កិច្ចដំណើរការនីតិវិធីអនុវត្តបានដោយយុត្តិធម៌ និងបានឆាប់រហ័ស។ ដោយបានចេញដីកាសម្រេចនេះ ឋានៈរបស់ មាស មុត ត្រូវតែផ្លាស់ប្តូរពី "ជនសង្ស័យ" ទៅជា "ជនត្រូវចោទ" ដូច្នេះ មាស មុត នឹងអាចប្រើប្រាស់សិទ្ធិទាំងអស់ ដែលជនត្រូវចោទមានសិទ្ធិទទួលបានតាមវិធានផ្ទៃក្នុង។

---

[67]អនុលោមតាមវិធានផ្ទៃក្នុង ៥៥ មានតែជនត្រូវចោទ និងភាគីផ្សេងទៀតដែលអាចចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេតរបស់តុលាការ។ ជនសង្ស័យ ក្នុងឋានៈមិនមែនជាភាគី មិនមានសិទ្ធិទាំងនេះ។ *សូមមើលផងដែរ* សំណុំរឿង០០៤ ឯកសារ D121/4 *សេចក្តីសម្រេចលើសំណើរបស់ក្រុមមេធាវីការពារក្តី[កោសល្យប] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត* ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៦-៣៨ និងកថាខណ្ឌ ៦២។

៧៣. ស.ច.ស.អន្តរជាតិ កត់សម្គាល់ថា មាស មុត មានសហមេធាវីតាមការជ្រើសរើសរបស់ខ្លួនជាតំណាងរួចហើយ[68]។

៧៤. ដើមហេតុ និងលក្ខណៈនៃបទចោទប្រកាន់ប្រឆាំង មាស មុត ព្រមទាំងព័ត៌មានលម្អិតផ្ទាល់ខ្លួនរបស់គាត់ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត គឺមានបញ្ជាក់នៅក្នុងការជូនដំណឹងអំពីបទចោទប្រកាន់ដែលភ្ជាប់មកជាមួយដីកាសម្រេចនេះ។

**តាមសំអាងហេតុខាងលើ ខ្ញុំ MARK B. HARMON ៖**

៧៥. **សម្រេចដាក់** មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ដូចបានបញ្ជាក់នៅក្នុងការជូនដំណឹងអំពីបទចោទប្រកាន់ដែលភ្ជាប់ជាមួយដីកាសម្រេចនេះ, និង

៧៦. **បង្គាប់ឱ្យក្រឡាបញ្ជី** ចាត់វិធានការចាំបាច់ដើម្បីធានាថា សហមេធាវីរបស់ មាស មុត ទទួលបានការអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿង ០០៣ ឱ្យបានឆាប់តាមការជាក់ស្តែង។

ភ្នំពេញ ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥

**ចៅក្រម Mark B. Harmon**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**

---

[68] សំណុំរឿង០០៣ ឯកសារD56/19/38 *សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលបដិសេធការតែងតាំងលោកអាង ឧត្តម និងលោក Michael KARNAVAS មិនឱ្យធ្វើជាសហមេធាវីរបស់គាត់* ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤។

# ឧបសម្ព័ន្ធ ៥

01108455

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

**ឯកសារលេខ៖ D122/1/2**

*តាមនាមព្រះរាជាណាចក្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៣/០៧-០៩-២០០៩-អវតក/កសចស (**អបជ១៦**)

ចំពោះមុខ: **ចៅក្រម ប្រាក់ គឹមសាន ប្រធាន**
**ចៅក្រម Olivier BEAUVALLET**
**ចៅក្រម ន័យ ថុល**
**ចៅក្រម Steven J. BWANA**
**ចៅក្រម ហួត វុទ្ធី**

កាលបរិច្ឆេទ: ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 17 / 06 / 2015
ម៉ោង (Time/Heure): 15:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**សាធារណៈ**

**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបដិសេធសិទ្ធិចូលពិនិត្យមើលសំណុំរឿង**

**សហព្រះរាជអាជ្ញា:**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តីម្ចាស់បណ្តឹងឧទ្ធរណ៍:**
អាង ឧត្តម

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី:**
ហុង គឹមសួន
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
សំ សុគង់
ទី ស្រីនណា
Laure DESFORGES
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN

Michael G. KARNAVAS

វ៉ែន ពៅ
Philippe CANONNE

Nushin SARKARATI
Fabienne TRUSSES

01108457



**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានទទួល "បណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការបដិសេធរបស់សហចៅក្រមស៊ើបអង្កេត Harmon ទៅនឹងសំណើរបស់គាត់សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ" ("ម្ចាស់បណ្ដឹងឧទ្ធរណ៍" និង "បណ្ដឹងឧទ្ធរណ៍" ដែលបានដាក់ជាភាសាអង់គ្លេសនៅថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៤ និងជាភាសាខ្មែរនៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៥[1]។

1. នៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៣ ម្ចាស់បណ្ដឹងឧទ្ធរណ៍ ដែលត្រូវបានដាក់ឈ្មោះជាជនសង្ស័យនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជា ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ")[2] បានស្នើសុំសិទ្ធិចូលពិនិត្យមើលសំណុំរឿង ០០៣ និងបានស្នើសុំអនុញ្ញាតឱ្យគាត់មានសិទ្ធិចូលរួមនៅក្នុងកិច្ចស៊ើបសួរ[3]។ នៅថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ គាត់បានស្នើបន្ថែមទៀតសុំសិទ្ធិចូលពិនិត្យមើលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទាំងមូល និងសម្ភារៈគាំទ្រ[4] (ហៅជារួមថា "សំណើសុំ")។

2. សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានលើកពេលពិចារណាលើសំណើសុំទាំងនេះរហូតដល់ពេលមានការដោះស្រាយបញ្ហាបឋមទាក់ទងនឹងការតំណាងតាមផ្លូវច្បាប់របស់ម្ចាស់បណ្ដឹងឧទ្ធរណ៍បានចប់សព្វគ្រប់ជាមុនសិន[5] ដែលបញ្ហាបឋមនេះបានកើតឡើងនៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ

---

[1] ឯកសារ D122/1/1។

[2] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ របស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងកងទ័ពបដិវត្តកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1។ សូមមើលផងដែរ សេចក្ដីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្ដីទីអំពីការដាក់ឯកសារស្ដីពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី២ ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ D1/1។

[3] សំណើរបស់ មាស មុត ស្នើសុំការអនុញ្ញាតឱ្យចូលមើលសំណុំរឿង និងចូលរួមក្នុងការស៊ើបអង្កេតតាមផ្លូវតុលាការ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ D82។

[4] សំណើសុំឱ្យផ្ដល់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទាំងមូល និងសម្ភារៈគាំទ្រ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ ឯកសារ D82/2។

[5] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបដិសេធចោលការតែងតាំងសហមេធាវីដែលត្រូវបានចាត់តាំងដោយផ្អែកលើមូលដ្ឋាននៃទំនាស់ផលប្រយោជន៍ដែលពុំអាចផ្សះផ្សាបាន ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារ D56/1។ លិខិតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទាក់ទងនឹងសារណារបស់សហមេធាវីដែលបានចាត់តាំងក្នុងសំណុំរឿង ០០៣ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D87។ ដំណោះស្រាយនេះត្រូវបានគាំទ្រដោយអង្គបុរេជំនុំជម្រះ។ *សូមមើល* សេចក្ដីសម្រេចលើបណ្ដឹង *សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបដិសេធសិទ្ធិចូលពិនិត្យមើលសំណុំរឿង*

២០១៤[6]។ ក្រោយពេលអង្គបុរេជំនុំជម្រះបានទទួលស្គាល់សហមេធាវីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានធ្វើការពិចារណាសាជាថ្មីលើសេចក្តីសម្រេចចំនួនពីរដែលបានធ្វើឡើងនាពេលមុនដោយអតីតសហចៅក្រមអន្តរជាតិបម្រុងពាក់ព័ន្ធនឹងសិទ្ធិរបស់ជនសង្ស័យ និងយុត្តិធិការបុគ្គលរបស់ អ.វ.ត.ក ក្នុងការចោទប្រកាន់ម្ចាស់បណ្តឹងឧទ្ធរណ៍[7] ក្នុងគោលបំណងធ្វើការវិនិច្ឆ័យលើសំណើសុំទាំងនេះ[8]។ នៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ សហចៅក្រមអន្តរជាតិបានកោះហៅម្ចាស់បណ្តឹងឧទ្ធរណ៍ និងសហមេធាវីរបស់គាត់ឱ្យបង្ហាញខ្លួននៅចំពោះមុខខ្លួននៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៤ ដើម្បីជាការបង្ហាញខ្លួនលើកដំបូងអនុលោមតាមវិធាន ៥៧ នៃវិធានផ្ទៃក្នុង (“ដីកាកោះ”)[9]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានជូនដំណឹងដល់ម្ចាស់បណ្តឹងឧទ្ធរណ៍ថា ក្នុងករណីមានការចោទប្រកាន់នៅក្នុងពេលបង្ហាញខ្លួនលើកដំបូងនេះ គាត់នឹងទទួលបានសិទ្ធិចូលពិនិត្យមើលសំណុំរឿង និងត្រូវបានអនុញ្ញាតឱ្យចូលរួមនៅក្នុងកិច្ចស៊ើបសួរ[10]។ នៅក្នុងកាលៈទេសៈទាំងនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិចារណាឃើញថា វានឹងពុំមាន “ប្រសិទ្ធភាពតាមផ្លូវតុលាការ” នោះទេ ប្រសិនបើសម្រេចលើសំណើសុំទាំងនេះនៅមុនថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ២០១៤

---

ឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេតទៅលើសារណារបស់ មាស មុត ចំនួនដប់បួនច្បាប់ដែលបានដាក់ទៅ [ការិយាល័យសហចៅក្រមស៊ើបអង្កេត] ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D87/2/2 កថាខណ្ឌ ១៣។

[6] ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ច្រានចោលការតែងតាំង អាង ឧត្តម និង Michael KARNAVAS ជាសហមេធាវី ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D56/19/36 (សេចក្តីសម្រេច) និងចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ D46/19/38 (សំអាងហេតុ)។

[7] *សូមមើល* ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង] ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ D30 *និង* សេចក្តីសម្រេចលើយុត្តាធិការបុគ្គល និងគោលនយោបាយស៊ើបសួរទាក់ទងនឹងជនសង្ស័យ ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១២ ឯកសារ D48។

[8] ការជូនដំណឹងទាក់ទងនឹងសំណើរបស់ជនសង្ស័យសុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត (D82) និងសុំឯកសារទាំងមូលនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងសម្ភារៈគាំទ្រ (D82/2) ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ D82/3 កថាខណ្ឌ ១៦។

[9] ដីកាកោះឱ្យបង្ហាញខ្លួនលើកដំបូង ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ A66។ កំណត់ហេតុនៃការប្រគល់ដីកាកោះ ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ A66/1។ ដីកាកោះមេធាវី ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ A67។

[10] ការជូនដំណឹងស្តីពីសំណើរបស់ជនសង្ស័យសុំចូលពិនិត្យមើលសំណើរឿង ចូលរួមការស៊ើបអង្កេត និងសុំលុបចោលចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ D82/5 កថាខណ្ឌ ១៦-១៧។

ឬ ប្រសិនបើធ្វើការពិចារណាសាជាថ្មីលើសេចក្តីសម្រេចមុនៗដែលបានធ្វើឡើងដោយអតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងនៅក្នុងដំណាក់កាលនេះ[11]។

3. នៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៤ ម្ចាស់បណ្តឹងឧទ្ធរណ៍ពុំបានបង្ហាញខ្លួននៅចំពោះមុខសហចៅក្រមស៊ើបអង្កេតអន្តរជាតិនោះទេ ប៉ុន្តែសហមេធាវីបានបង្ហាញខ្លួន។ នៅក្នុងពេលបង្ហាញខ្លួន សហមេធាវីជាតិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍បានដាក់សំណើផ្ទាល់មាត់សុំសិទ្ធិចូលពិនិត្យមើលសំណុំរឿង[12]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានច្រានចោលសំណើសុំនេះដោយផ្ទាល់មាត់ដោយពុំបានផ្តល់សំអាងហេតុអ្វីទាល់តែសោះ ("សេចក្តីសម្រេចដែលត្រូវបានជំទាស់")[13]។ ម្ចាស់បណ្តឹងឧទ្ធរណ៍បានជូនដំណឹងអំពីបំណងរបស់គាត់ក្នុងការបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចដែលត្រូវបានជំទាស់នេះនៅថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤[14] ហើយបានដាក់សារណាបណ្តឹងឧទ្ធរណ៍ជាភាសាអង់គ្លេសនៅថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៤ និងជាភាសាខ្មែរនៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៥។

4. នៅថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដាក់ម្ចាស់បណ្តឹងឧទ្ធរណ៍ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ *ដោយកំបាំងមុខ* ពីបទឧក្រិដ្ឋកម្មជាច្រើនដូចបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[15]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា "ដោយបានចេញដីកាសម្រេចនេះ ឋានៈរបស់ មាស មុត ត្រូវតែផ្លាស់ប្តូរពី "ជនសង្ស័យ" ទៅជា "ជនត្រូវចោទ" ដូច្នេះ មាស មុត អាចនឹងប្រើប្រាស់សិទ្ធិទាំងអស់ដែលជនត្រូវចោទមានសិទ្ធិទទួលបានតាមវិធានផ្ទៃក្នុង" ក្នុងនោះរួមមាន "សិទ្ធិចូលពិនិត្យមើលសំណុំរឿង សិទ្ធិចូលរួមក្នុងកិច្ចស៊ើបសួរ សិទ្ធិតទល់ជាមួយនឹងសាក្សី ឬ សិទ្ធិស្នើសុំឲ្យ [សហចៅក្រមស៊ើប អង្កេត] ដាក់សំណើទៅ

[11] *ដូចខាងលើ*។

[12] កំណត់ហេតុនៃការចូលខ្លួនដំបូង ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ D122។

[13] *ដូចខាងលើ*។

[14] ឯកសារ D122/1។

[15] ដីកាសម្រេចដាក់ មាស មុត ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ*ដោយកំបាំងមុខ* ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ D128 *និង*ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង មាស មុត ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ D128.1។

[អង្គបុរេជំនុំជម្រះ] សុំឱ្យមោឃភាពកិច្ចស៊ើបសួរជាដើម"[16]។ ដោយសារមូលហេតុនេះ ម្ចាស់បណ្តឹងឧទ្ធរណ៍ទទួលបានដំណោះស្រាយដែលគាត់បានស្នើសុំមកអង្គបុរេជំនុំជម្រះយ៉ាងមានប្រសិទ្ធភាព ដែលត្រូវ "បង្គាប់ឱ្យសហចៅក្រមស៊ើបអង្កេតអនុញ្ញាតឱ្យមេធាវីការពារក្តីបានចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ"[17]។ ហេតុដូច្នេះ បណ្តឹងឧទ្ធរណ៍នេះត្រូវចាត់ទុកជាមោឃៈ និងគួរត្រូវច្រានចោលដោយសារមូលហេតុនេះដោយពុំចាំបាច់សម្រេចលើភាពអាចទទួលយកបាន ឬ អង្គសេចក្តីនោះឡើយ[18]។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទ:**

**បដិសេធ** បណ្តឹងឧទ្ធរណ៍ដោយចាត់ទុកជាមោឃៈ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **ន៉ី ថុល** **Steven J. BWANA** **ហួត វុទ្ធី**

---

[16] *ដូចខាងលើ* កថាខណ្ឌ ៧២។

[17] បណ្តឹងឧទ្ធរណ៍ ដំណោះស្រាយដែលស្នើសុំ កថាខណ្ឌ ខ។

[18] *សូមមើល ឧ.* សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ជ/អ.ជ.ត.ក (២៥) សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចស្តាប់សក្ខីកម្មសាក្សីជំនាញ មុនពេលចេញសេចក្តីសម្រេចថ្មីស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ E264/1/2/2 កថាខណ្ឌ ១០។

*សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបដិសេធសិទ្ធិចូលពិនិត្យមើលសំណុំរឿង*